សៀវភៅណែនាំការស្រាវជ្រាវប្រតិបត្តិ សម្រាប់គ្រូឧទ្ទេស

កសាងសន្តិភាព និងលើកកម្ពស់ការគ្រាស្រ័យទាក់ទងបែបអហិង្សា ក្នុងថ្នាក់រៀន



ការបោះពុម្ពលើកទី១

សហការចងក្រងដោយ៖

បោះពុម្ពលើកទី១

២០២៥

បោះពុម្ពផ្សាយដោយ

វិទ្យាស្ថានគរុកោសល្យបាត់ដំបង (វគប) និង

Forum Ziviler Friedensdienst (forumZFD)

ខេត្តបាត់ដំបង ប្រទេសកម្ពុជា

គាំទ្រហិរញ្ញវត្ថុដោយក្រសួងសហព័ន្ធអាល្លឺម៉ង់ស្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (BMZ)

ជាមួយនឹងការគោរពដ៏ជ្រាលជ្រៅ និងពោរពេញដោយការសោកស្តាយ យើងខ្ញុំសូមឧទ្ទិសសេចក្តីល្អរបស់ស្បៃរភៅនេះជូនចំពោះវីរៈកងទ័ព និងប្រជាពលរដ្ឋទាំងអស់ដែលបានពលី និងបាត់បង់ជីវិត ក្នុងព្រឹត្តិការណ៍ជម្លោះតាមព្រំដែន។ សូមឱ្យការលះបង់ដ៏ខត្តុង្គខត្តម និងការបាត់បង់ជីវិតរបស់ពួកគាត់ ក្លាយជាការរំឭកដ៏មានន័យ និងជាការជំរុញឱ្យយើងទាំងអស់គ្នា ប្តេជ្ញាចិត្តលើការអប់រំលើកស្ទួយសន្តិភាព អហិង្សា និងការយោគយល់គ្នាទៅវិញទៅមក ក្នុងសង្គមជាតិ និងមនុស្សជាតិទាំងមូល។

គណៈកម្មការរៀបរៀង

ការរៀបចំ **សៀវភៅណែនាំការស្រាវជ្រាវប្រតិបត្តិសម្រាប់គ្រូឧទ្ទេស** ការកសាងសន្តិភាព និងលើកកម្ពស់ការប្រាស្រ័យទាក់ទងបែបអហិង្សាក្នុងថ្នាក់រៀននេះ បានសម្រេចទៅដោយជោគជ័យ ដោយមានការណែនាំប្រឹក្សា ត្រួតពិនិត្យ ការសហការយ៉ាងជិតស្និទ្ធ និងការគាំទ្រពីសមាជិកគណៈកម្មការ និងមន្ត្រីអប់រំ នៃវិទ្យាស្ថានគរុកោសល្យបាត់ដំបង ដូចបានរាយនាមខាងក្រោម៖

គណៈកម្មការប្រឹក្សា

- ឯកឧត្តមបណ្ឌិត **ជា រដ្ឋា** នាយកវិទ្យាស្ថានគរុកោសល្យបាត់ដំបង (វគប)
- លោក Manoj PANDEY ប្រធានគម្រោង អង្គការ forumZFD Cambodia

អ្នកគាំទ្របច្ចេកទេស

- លោក **រឿន សត្យា** មន្ត្រីគម្រោងអង្គការ forumZFD Cambodia

គណៈកម្មការសរសេរ និងរៀបចំសៀវភៅ

- លោក **សឿង សុផា** អ្នករៀបចំចងក្រង និងអ្នកប្រឹក្សាបច្ចេកទេស
- លោក **សុន សុគន្ធ** ព្រឹទ្ធបុរសមហាវិទ្យាល័យស្រាវជ្រាវគរុកោសល្យ នៃ វគប

គណៈកម្មការពិនិត្យ គាំទ្រកែសម្រួល និងវិចារណាអត្ថបទ

- លោកស្រីបណ្ឌិត **ទេព ឥណ្ឌី** នាយិការង វគប
- លោកស្រី **អ៊ុត ចាន់ធឿន** ព្រឹទ្ធបុរសរងមហាវិទ្យាល័យស្រាវជ្រាវគរុកោសល្យ វគប
- លោកស្រី **លាង សុខម៉ែង** ជំនួយការគម្រោងអង្គការ forumZFD Cambodia

គណៈកម្មការសម្របសម្រួល

- លោកស្រី **លិម ជាលីន** ប្រធានដេប៉ាតឺម៉ង់ស្រាវជ្រាវ និងបណ្ណាល័យនៃ វគប
- លោក **រឿន សត្យា** មន្ត្រីគម្រោងអង្គការ forumZFD Cambodia

គណៈកម្មការរៀបចំសៀវភៅ សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ និងដោយសេចក្តីគោរពខ្ពង់ខ្ពស់ ចំពោះបុគ្គល និងស្ថាប័នទាំងអស់ ដែលបានចូលរួមចែករំលែកជំនាញ បទពិសោធន៍ មតិយោបល់ និងការលើកទឹកចិត្តយ៉ាងស្មោះស្ម័គ្រ នៅគ្រប់ដំណាក់កាលនៃការអភិវឌ្ឍសៀវភៅណែនាំនេះ។

អ្នកចូលរួម និងផ្តល់ឆាតុចូល

- លោក **គង់ ស៊ីថា** ព្រឹទ្ធបុរសរងមហាវិទ្យាល័យស្រាវជ្រាវគរុកោសល្យ
- លោក **លឹម សុផាន់ដារ៉ា** អនុប្រធានដេប៉ាតឺម៉ង់ស្រាវជ្រាវ និងបណ្ណាល័យ
- លោកស្រី **ផន សុតា** អនុប្រធានដេប៉ាតឺម៉ង់ស្រាវជ្រាវ និងបណ្ណាល័យ
- លោក **យស ជាតុធ** អនុប្រធានការិយាល័យសិក្សា និងវិក្រឹតការ
- លោក **ឃុន មុនី** អនុប្រធានដេប៉ាតឺម៉ង់វិទ្យាសាស្ត្រសង្គម
- លោក **ភូ សុផល** អនុប្រធានដេប៉ាតឺម៉ង់វិទ្យាសាស្ត្រសង្គម
- លោក **អ៊ុំ ឈាន់** អនុប្រធានដេប៉ាតឺម៉ង់គរុកោសល្យ
- លោក **ម៉ៅ ឌាសនា** អនុប្រធានដេប៉ាតឺម៉ង់គរុកោសល្យ
- លោក **ធី សុផាត** នាយករងសាលាបឋមសិក្សាអនុវត្តន៍
- លោក **អ៊ន់ ឥន្ធ** គ្រូឧទ្ទេស វគ្គ
- លោក **ប៉ោ សុវត្ថា** គ្រូឧទ្ទេស វគ្គ
- លោក **លី ឌ៉ានី** គ្រូឧទ្ទេស វគ្គ
- លោកស្រី **ឡេង រចនា** គ្រូឧទ្ទេស វគ្គ
- លោកស្រី **ស៊ាង ម៉ីលី** គ្រូឧទ្ទេស វគ្គ
- លោកស្រី **សែន សៅយ៉ា** គ្រូឧទ្ទេស វគ្គ
- លោក **ឡាង ប៊ុនឡុង** គ្រូឧទ្ទេស វគ្គ
- លោកស្រី **ផា ឥន្ធាតិ** បណ្ណារក្ស វគ្គ
- លោកស្រី **មុំ ចន្ថា** គ្រូបង្រៀន អនុវិទ្យាល័យអនុវត្តន៍
- លោកស្រី **គឹមលី ចិន្តា** គ្រូបង្រៀន អនុវិទ្យាល័យអនុវត្តន៍
- លោកស្រី **ភាវ សុខសំណាង** លេខាធិការមហាវិទ្យាល័យស្រាវជ្រាវគរុកោសល្យ

សហការចងក្រងដោយ៖

អារម្ភកថា

សៀវភៅណែនាំស្រាវជ្រាវប្រតិបត្តិ ស្តីពីការកសាងសន្តិភាព និងលើកកម្ពស់ការប្រាស្រ័យទាក់ទងបែបអហិង្សាក្នុងថ្នាក់រៀន ត្រូវបានរៀបចំឡើង ដើម្បីគាំទ្រ និងពង្រឹងសមត្ថភាពវិជ្ជាជីវៈរបស់គ្រូឧទ្ទេស នៅវិទ្យាស្ថានគរុកោសល្យបាត់ដំបង (វគប) ក្នុងការអនុវត្ត និងដឹកនាំស្រាវជ្រាវប្រតិបត្តិ (AR) ដោយផ្តោតជាពិសេសលើការលើកកម្ពស់បរិយាកាសថ្នាក់រៀនដែលមានសុវត្ថិភាព មិនប្រើអំពើហិង្សា និងពោរពេញដោយការគោរពគ្នាទៅវិញទៅមក។ សៀវភៅណែនាំនេះ ត្រូវបានរៀបចំឡើងជាពិសេសសម្រាប់ការសិក្សាផ្ទាល់ខ្លួនរបស់គ្រូឧទ្ទេស ហើយក៏មានតួនាទីជាមគ្គុទេសក៍អនុវត្តន៍សម្រាប់ការដឹកនាំគរុនិស្សិត ដែលត្រូវបំពេញការស្រាវជ្រាវប្រតិបត្តិ ជាផ្នែកមួយនៃលក្ខខណ្ឌសម្រាប់ការបញ្ចប់ការសិក្សា។

ក្រសួងអប់រំ យុវជន និងកីឬា នៃព្រះរាជាណាចក្រកម្ពុជា បានចេញផ្សាយនូវគោលការណ៍ណែនាំផ្លូវការស្តីពីការស្រាវជ្រាវប្រតិបត្តិ ជាតម្រូវការវិជ្ជាជីវៈសម្រាប់គរុនិស្សិត និងគ្រូបង្រៀនដែលកំពុងបម្រើការងារនៅតាមគ្រឹះស្ថានអប់រំសាធារណៈ។ គោលការណ៍ណែនាំទាំងនេះ ផ្តោតសំខាន់លើការឆ្លុះបញ្ចាំងអនុវត្ត ការកែលម្អការងារនៅក្នុងថ្នាក់រៀន និងការលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន។ សៀវភៅណែនាំនេះ មិនមានបំណងធ្វើការជំនួសគោលការណ៍ណែនាំរបស់ក្រសួងនោះទេ។ ផ្ទុយទៅវិញ វាត្រូវបានរៀបចំឡើងក្នុងចេតនា ដើម្បីធ្វើការរួមគ្នា និងជាឯកសារបន្ថែម ដល់គោលការណ៍ណែនាំរបស់ក្រសួង ដោយផ្តល់ការណែនាំជាក់លាក់ និងផ្តោតជាចម្បងលើការស្រាវជ្រាវប្រតិបត្តិសម្រាប់បង្កើនបរិយាកាសអហិង្សានៅក្នុងថ្នាក់រៀន ដែលជាបញ្ហានិងជាចំណុចចម្បង និងមានភាពបន្ទាន់នៅក្នុងបរិបទអប់រំកម្ពុជា។

ទោះបីជាមានគោលការណ៍ ឬគោលនយោបាយស្តីពីសាលាកុមារមាត្រី និងសាលាដែលគ្មានអំពើហិង្សាក៏ដោយ ការស្រាវជ្រាវ និងបទពិសោធន៍អនុវត្តនៅតែបង្ហាញថា អំពើហិង្សាទាំងផ្នែកពាក្យសំដី និងរាងកាយ រួមទាំងការស្រែកឬស្តីបន្ទោស ការបន្ទាបតម្លៃ និងការដាក់ទណ្ឌកម្មលើរាងកាយ នៅតែមានកើតឡើងនៅក្នុងថ្នាក់រៀនមួយចំនួន។ អំពើទាំងនេះ មានផលប៉ះពាល់ជាអវិជ្ជមានដល់សុខុមាលភាពផ្លូវអារម្មណ៍ អាកប្បកិរិយា ការលើកទឹកចិត្តក្នុងការសិក្សា និងទំនាក់ទំនងរវាងគ្រូ និងសិស្ស។ ការដោះស្រាយបញ្ហាទាំងនេះ មិនអាចអាស្រ័យលើការបណ្តុះបណ្តាល ឬការផ្សព្វផ្សាយគោលការណ៍តែប៉ុណ្ណោះបានឡើយ ប៉ុន្តែត្រូវការការស្រាវជ្រាវជាក់លាក់ មានការឆ្លុះបញ្ចាំង និងផ្អែកលើកស្តុតាង ពីសំណាក់គ្រូបង្រៀនខ្លួនឯង។ ការស្រាវជ្រាវប្រតិបត្តិ គឺជាវិធីសាស្ត្រដ៏មានអានុភាពមួយ ដែលអនុញ្ញាតឱ្យគ្រូឧទ្ទេស គរុនិស្សិត និងគ្រូបង្រៀនក្នុងថ្នាក់ អាចពិនិត្យវិភាគការអនុវត្តរបស់ខ្លួន សាកល្បងជម្រើសវិធីអហិង្សា និងកែលម្អវប្បធម៌ថ្នាក់រៀន តាមបរិបទពិតប្រាកដ។

ដោយហេតុនេះ សៀវភៅណែនាំការស្រាវជ្រាវប្រតិបត្តិមួយនេះ បានយកភាពអហិង្សាជាចំណុចស្នូល ដោយមិនបានយកនិងរៀបចំផ្តោតលើ ការលើកកម្ពស់ប្រសិទ្ធភាពបង្រៀនទូទៅនោះទេ។ ដំណើរការស្រាវជ្រាវប្រតិបត្តិដែលបង្ហាញនៅក្នុងសៀវភៅណែនាំនេះ ត្រូវបានរៀបចំឡើងជាពិសេស ដើម្បីជួយអ្នកអប់រំក្នុងការកំណត់អាកប្បកិរិយាដែលពាក់ព័ន្ធនឹងអំពើហិង្សានៅក្នុងថ្នាក់រៀន រៀបចំផែនការ និងអនុវត្តអន្តរាគមន៍មិនប្រើអំពើហិង្សា (ដូចជា វិន័យវិជ្ជមាន ការប្រាស្រ័យទាក់ទងដោយការគោរព និងការសិក្សាសហការ) ប្រមូលនិងវិភាគកស្តុតាងនៃការផ្លាស់ប្តូរ ហើយឆ្លុះបញ្ចាំងលទ្ធផល ដោយគោរពក្រមសីលធម៌និងវិជ្ជាជីវៈ។ ទោះបីជាការកែ

សហការចេងក្រងដោយ៖

លម្អការបង្រៀន និងការរៀនអាចបង្កើតលទ្ធផលជាវិជ្ជមានក៏ដោយ វាត្រូវបានចាត់ទុកថាជាផលប៉ះពាល់បន្ទាប់ដែលកើតឡើងពីការកែលម្អទំនាក់ទំនង អាកប្បកិរិយា និងសុវត្ថិភាពផ្លូវអារម្មណ៍នៅក្នុងថ្នាក់រៀនជាមុនសិន។

សៀវភៅណែនាំការស្រាវជ្រាវប្រតិបត្តិនេះ ប្រើប្រាស់គំរូស្រាវជ្រាវប្រតិបត្តិសម្របសម្រួលប្រើប្រាស់ ៦ដំណាក់កាល រួមមាន៖ ការកំណត់និងវិនិច្ឆ័យបញ្ហា ការរៀបចំផែនការសកម្មភាព ការអនុវត្តសកម្មភាព ការសង្កេតនិងប្រមូលទិន្នន័យ ការឆ្លុះបញ្ចាំងនិងបកស្រាយលទ្ធផល និងការកែសម្រួល និងចែករំលែក។ ជំហាននីមួយៗ ត្រូវបានពន្យល់យ៉ាងលម្អិត ព្រមទាំងមានឧទាហរណ៍ពីឧបករណ៍ ទម្រង់គំរូ និងស្ថានការណ៍ថ្នាក់រៀនក្នុងបរិបទកម្ពុជា ដើម្បីឱ្យគ្រូឧទ្ទេស អាចសិក្សាដោយខ្លួនឯង និងដឹកនាំគរុនិស្សិត ឱ្យអនុវត្តដំណើរការស្រាវជ្រាវប្រតិបត្តិទាំងមូលបានយ៉ាងមានទំនុកចិត្ត និងសមស្របតាមពេលវេលាជាក់ស្តែង។

សៀវភៅណែនាំនេះ ក៏បញ្ជាក់តួនាទីសំខាន់របស់គ្រូឧទ្ទេស ក្នុងនាមជាអ្នកណែនាំការស្រាវជ្រាវ និងជាអ្នកគាំពារក្រមសីលធម៌ស្រាវជ្រាវផងដែរ។ វាផ្តោតលើការពិចារណាក្រមសីលធម៌ស្រាវជ្រាវ សិទ្ធិកុមារ ការត្រួតពិនិត្យ ដឹកនាំដោយការឆ្លុះបញ្ចាំង និងប្រព័ន្ធតាមដានគាំទ្រ ដើម្បីធានាថា គរុនិស្សិតអាចបញ្ចប់ការស្រាវជ្រាវប្រតិបត្តិរបស់ខ្លួនដោយមានការទទួលខុសត្រូវទាន់ពេលវេលានិងមានគុណភាពតាមស្តង់ដារដែលបានកំណត់។ របាយការណ៍ស្រាវជ្រាវប្រតិបត្តិដែលរៀបចំឡើងក្នុងសៀវភៅណែនាំនេះ អាចត្រូវបានប្រើជាមាត្រដ្ឋានមួយ សម្រាប់ការបញ្ចប់ការសិក្សារបស់គរុនិស្សិត ហើយក៏រួមចំណែកដល់ការបង្កើតវប្ផធម៌អហិង្សាក្នុងថ្នាក់និងសាលារៀនផងដែរ។

សៀវភៅណែនាំស្រាវជ្រាវប្រតិបត្តិនេះ ត្រូវបានគាំទ្រថវិកាទាំងស្រុងដោយ អង្គការ forumZFD Cambodia ដែលបានអនុញ្ញាតឱ្យមានការអភិវឌ្ឍធនធានសិក្សា ដែលឆ្លើយតបទៅនឹងបរិបទ និងផ្អែកលើការអនុវត្តពិតប្រាកដ សម្រាប់អប់រំគ្រូបង្រៀននៅកម្ពុជា។ យើងសង្ឃឹមថា សៀវភៅណែនាំការស្រាវជ្រាវប្រតិបត្តិមួយនេះ នឹងមិនត្រឹមតែជួយពង្រឹងសមត្ថភាពរបស់គ្រូឧទ្ទេស និងគរុនិស្សិត វគប តែមួយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមចំណែកដល់ការកែលម្អអាកប្បកិរិយាសិស្ស ទំនាក់ទំនងរវាងគ្រូនិងសិស្ស និងសុខុមាលភាពក្នុងថ្នាក់រៀនរយៈពេលវែង ដើម្បីជាការគាំទ្រដ៏រឹងមាំសម្រាប់ការបង្រៀនប្រកបដោយប្រសិទ្ធភាព និងការរៀនសូត្រដែលពោរពេញដោយគុណភាពសម្រាប់កម្ពុជា។

ថ្ងៃ សុក្រ ៧កើត ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

បាត់ដំបង ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៥

នាយកវិទ្យាស្ថានគរុកោសល្យបាត់ដំបង

បណ្ឌិត ជា រដ្ឋា

មូលន័យសង្ខេប

អំពើហិង្សានៅក្នុងសាលារៀន មិនថាជាអំពើហិង្សាលើរាងកាយ ពាក្យសម្តី ឬទំនាក់ទំនងសង្គម នៅតែបន្តជះឥទ្ធិពលអវិជ្ជមាន លើសុខុមាលភាពផ្លូវចិត្ត ការចូលរួមក្នុងសកម្មភាពសិក្សា និងទំនាក់ទំនងរវាងសិស្ស និងគ្រូ ក្នុងបរិបទថ្នាក់រៀននៅកម្ពុជា។ ទោះបីជាក្រសួងអប់រំ យុវជន និងកីឬ្ឡា បាននិងកំពុងខិតខំប្រឹងប្រែងយ៉ាងសកម្ម តាមរយៈគោលនយោបាយលើកកម្ពស់សាលារៀនគំរូ និងកម្មវិធីអប់រំគ្រូបង្រៀន ដើម្បីលើកកម្ពស់គុណភាពបង្រៀនតាមរយៈការស្រាវជ្រាវប្រតិបត្តិក៏ដោយក្តី បញ្ហាជាច្រើននៅកម្រិតថ្នាក់រៀន ពាក់ព័ន្ធនឹងអហិង្សា ឥរិយាបថសិស្ស និងទំនាក់ទំនងរវាងគ្រូនិងសិស្ស នៅតែមិនទាន់ត្រូវបានដោះស្រាយបានទាន់ពេល និងមិនបានអនុវត្តបានជាក់ស្តែងនៅតាមគ្រឹស្ថានអប់រំ។

សៀវភៅណែនាំស្រាវជ្រាវប្រតិបត្តិ ស្តីពីការកសាងសន្តិភាព និងលើកកម្ពស់ការប្រាស្រ័យទាក់ទងបែបអហិង្សាក្នុងថ្នាក់រៀន បានអភិវឌ្ឍឡើងជាពិសេស ដើម្បីពង្រឹងសមត្ថភាពវិជ្ជាជីវៈរបស់គ្រូឧទ្ទេស គរុនិស្សិត និងគ្រូបង្រៀន នៅ វគប ក្នុងការរចនា អនុវត្តការស្រាវជ្រាវប្រតិបត្តិ ដែលផ្តោតលើការកាត់បន្ថយអំពើហិង្សា និងការលើកកម្ពស់បរិយាកាសថ្នាក់រៀនដែលមានសុវត្ថិភាព ការគោរព និងបរិយាយបន្ទ។ សៀវភៅនេះទទួលបានការគាំទ្រថវិកាពេញលេញពី អង្គការ forumZFD Cambodia ហើយបានបង្កើតឡើងដើម្បីឆ្លើយតបនឹងតម្រូវការសម្រាប់ឯកសារណែនាំដែលសមស្របនឹងបរិបទជាក់ស្តែង ផ្តោតលើការអនុវត្ត និងគាំទ្រទាំងតួនាទីសិក្សាផ្ទាល់ខ្លួនរបស់គ្រូឧទ្ទេស និងតួនាទីជាគ្រូណែនាំគរុនិស្សិត ក្នុងការបំពេញលក្ខខណ្ឌបញ្ចប់ការសិក្សាតាមរយៈការស្រាវជ្រាវប្រកបដោយគុណភាព ក្រមសីលធម៌ និងមានសមត្ថភាពអាចបន្តអនុវត្តការស្រាវជ្រាវប្រតិបត្តិដោយផ្ទាល់ខ្លួនប្រកបដោយទំនុកចិត្តខ្ពស់។

សៀវភៅណែនាំស្រាវជ្រាវប្រតិបត្តិនេះ មិនមានបំណងជំនួសសេចក្តីណែនាំស្តីពីការស្រាវជ្រាវប្រតិបត្តិរបស់ក្រសួងអប់រំ យុវជន និងកីឬ្ឡា នោះឡើយ។ ផ្ទុយទៅវិញ វាត្រូវបានរៀបចំឡើង ដើម្បីជំណើរការជាគូសហការ និងបន្ថែមលើគោលការណ៍ណែនាំរបស់ក្រសួង ដោយបានផ្តោតលើបញ្ហា "អហិង្សានៅក្នុងថ្នាក់រៀន" ដែលជាមូលដ្ឋានសំខាន់បំផុតសម្រាប់ប្រសិទ្ធភាពបង្រៀននិងរៀន ការចូលរួមរបស់សិស្ស និងលទ្ធផលសិក្សាវិជ្ជមានរយៈពេលវែង។

ខ្លឹមសារសៀវភៅណែនាំការស្រាវជ្រាវប្រតិបត្តិផ្តោតលើការបង្កើតបរិយាកាសអហិង្សាក្នុងថ្នាក់រៀន

សៀវភៅណែនាំស្រាវជ្រាវប្រតិបត្តិ ផ្តោតលើ ការយល់ដឹងអំពីអហិង្សានៅក្នុងន័យទូលំទូលាយ (ផ្លូវកាយ ពាក្យសម្តី ផ្លូវអារម្មណ៍ និងទំនាក់ទំនងសង្គម) ការដោះស្រាយបញ្ហាប្រចាំថ្ងៃនៅក្នុងថ្នាក់រៀន ដូចជាវិនិយ ការបដិសេធ ការលេងសើចបំបាក់ទឹកចិត្ត ការអាម៉ាស់ និងជម្លោះ ការគាំទ្រគ្រូបណ្តុះបណ្តាលគ្រូ ក្នុងការ

ណែនាំនិស្សិតគ្រូជាប្រព័ន្ធពីដំណាក់កាលមួយទៅមួយ និងការលើកកម្ពស់ការស្រាវជ្រាវដែលមានសីលធម៌ ផ្តោតលើកុមារ និងឆ្លើយតបនឹងវប្បធម៌មូលដ្ឋាន។

សៀវភៅនេះ ត្រូវបានរៀបចំសម្រាប់អ្នកអានសំខាន់បីក្រុម គឺ៖ គ្រូឧទ្ទេស សម្រាប់ការសិក្សាដោយខ្លួនឯង និងការត្រួតពិនិត្យណែនាំគរុនិស្សិត គរុនិស្សិត ជាអ្នកអនុវត្ត និងអ្នកស្រាវជ្រាវក្នុងអំឡុងពេលហ្វឹកហាត់បង្រៀន គ្រូបង្រៀនក្នុងថ្នាក់ ជាអ្នកអនុវត្តដែលចង់កែលម្អទំនាក់ទំនងក្នុងថ្នាក់រៀន។ បន្ថែមលើក្រុមអ្នកអានទាំងនេះ សៀវភៅណែនាំនេះក៏បម្រើជាធនធានដ៏សំខាន់សម្រាប់គ្រូឧទ្ទេស ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដែលរៀបចំឡើងដោយ វគ្គ និងអង្គារ forumZFD Cambodia នៅក្នុងខេត្តបាត់ដំបង ដើម្បីបញ្ចូលគោលការណ៍នៃការផ្លាស់ប្តូរជម្លោះ ទៅក្នុងការអនុវត្តវិជ្ជាជីវៈរបស់ពួកគេ។

ទោះបីជាក្រសួងអប់រំលើកទឹកចិត្តឱ្យប្រើការស្រាវជ្រាវប្រតិបត្តិ ដើម្បីកែលម្អការបង្រៀននិងការរៀនក៏ដោយ គ្រូឧទ្ទេស និងគរុនិស្សិត និងគ្រូបង្រៀនជាច្រើន នៅតែប្រឈមការលំបាកនៅពេលអនុវត្តការស្រាវជ្រាវប្រតិបត្តិលើបញ្ហាឥរិយាបថ និងទំនាក់ទំនង ជាពិសេសបញ្ហាដែលពាក់ព័ន្ធនឹងអំពើហិង្សា ឬបទពិសោធន៍រសើបរបស់សិស្ស។ បញ្ហាទូទៅរួមមាន៖ (១)ការលំបាកក្នុងការកំណត់បញ្ហាអហិង្សានៅក្នុងថ្នាក់រៀនដោយមានប្រព័ន្ធ (២)កង្វះឧបករណ៍សង្កេតឥរិយាបថ និងអន្តរកម្មសង្គម (៣)ការមិនប្រាកដចិត្តអំពីសីលធម៌នៅពេលស្រាវជ្រាវជាមួយកុមារ (៤)ការផ្តោតខ្លាំងលើបច្ចេកទេសបង្រៀន ជំនួសឱ្យបរិយាកាសថ្នាក់រៀន និង(៥) កង្វះប្រព័ន្ធត្រួតពិនិត្យ និងតាមដានគរុនិស្សិតក្នុងអំឡុងពេលអនុវត្ត។

ហេតុនេះហើយ សៀវភៅណែនាំស្រាវជ្រាវប្រតិបត្តិនេះ បង្កើតឡើង ដើម្បីបំពេញចន្លោះទាំងនេះដោយ (១)ផ្តល់ឧបករណ៍គំរូ និងឧទាហរណ៍ច្បាស់លាស់ (២)ផ្តោតលើការអប់រំបែបអហិង្សា និងវិន័យវិជ្ជមាន (៣)ផ្តល់ការណែនាំជាដំណាក់កាល សមស្របនឹងបរិបទបណ្តុះបណ្តាលគ្រូ (៤)គាំទ្រការអនុវត្តដែលមានសីលធម៌ និងការឆ្លុះបញ្ចាំង និង (៥)ពង្រឹងទំនាក់ទំនងរវាងគ្រូនិងសិស្ស ដែលជាមូលដ្ឋាននាំទៅរកការបង្រៀន និងការរៀនឱ្យបានប្រសើរឡើង។

របៀបប្រើប្រាស់សៀវភៅណែនាំនេះ

គ្រូឧទ្ទេស អាចប្រើសៀវភៅនេះតាមរបៀបពីរយ៉ាងសំខាន់៖ (១)សម្រាប់ការសិក្សាដោយខ្លួនឯង និងការអភិវឌ្ឍវិជ្ជាជីវៈ (២) សម្រាប់ការណែនាំ និងដឹកនាំគរុនិស្សិត។ ***សម្រាប់ការសិក្សាផ្ទាល់ខ្លួន*** សៀវភៅនេះជួយឱ្យគ្រូឧទ្ទេស (ក)យល់ដឹងអំពីការស្រាវជ្រាវប្រតិបត្តិសម្រាប់អហិង្សា (ខ)បង្កើនទំនុកចិត្តក្នុងការត្រួតពិនិត្យគរុនិស្សិត និង(គ)ឆ្លុះបញ្ចាំងលើការបង្រៀនក្នុងថ្នាក់។ ***សម្រាប់ការណែនាំ*** *និងដឹកនាំគរុនិស្សិត* សៀវភៅនេះជួយក្នុង (ក)ការណែនាំគរុនិស្សិតគ្រប់ដំណាក់កាលក្នុងការធ្វើការស្រាវជ្រាវប្រតិបត្តិ (ខ)តាមដានវឌ្ឍនភាព

ក្នុងរយៈពេលប្រហែល ៦ ខែ និង (គ)វាយតម្លៃរបាយការណ៍ការស្រាវជ្រាវប្រតិបត្តិ ដែលជាផ្នែកមួយនៃលក្ខខណ្ឌបញ្ចប់ការសិក្សា។ ស្រដៀងគ្នានេះដែរ គរុនិស្សិតអាចប្រើសៀវភៅនេះជាផែនទីណែនាំ ខណៈដែលគ្រូបង្រៀនអាចកែច្នៃឧបករណ៍ និងវិធីសាស្ត្រមួយចំនួនសម្រាប់អនុវត្តផ្ទាល់ខ្លួន។ ជាពិសេស គ្រូឧទ្ទេសនៅក្នុងគម្រោង «**ការផ្លាស់ប្តូរជម្លោះដោយអហិង្សា**» (NVCT) និងក្នុងវគ្គបណ្តុះបណ្តាលនានា អាចប្រើប្រាស់សៀវភៅណែនាំនេះជាមគ្គុទ្ទេសក៍អនុវត្តសម្រាប់ការធ្វើស្រាវជ្រាវប្រតិបត្តិនៅក្នុងថ្នាក់រៀនរបស់ពួកគេ។ ពួកគេនឹងប្រើប្រាស់សៀវភៅណែនាំនេះដើម្បី៖ (**ក**) ប្រមូលកស្តុតាងនៃការផ្លាស់ប្តូរនៅក្នុងថ្នាក់រៀនរបស់ពួកគេ ប្រកបដោយប្រព័ន្ធ (**ខ**) ចងក្រងឯកសារអំពីដំណើរការនៃការផ្លាស់ប្តូរ ដែលកើតចេញពីការចូលរួមរបស់ពួកគេជាមួយសិស្ស និង(**គ**) សម្របសម្រួលដល់ការឆ្លុះបញ្ចាំងជាបន្តបន្ទាប់ អំពីតួនាទីរបស់ពួកគេក្នុងនាមជាអ្នកកសាងសន្តិភាព និងជាអ្នកអប់រំ។

ជំហានទាំង ៦ ក្នុងការអនុវត្តការស្រាវជ្រាវប្រតិបត្តិ

ដើម្បីធានាភាពច្បាស់លាស់ ស្ថិរភាព និងភាពដែលអាចសម្រេចបាន សៀវភៅណែនាំនេះប្រើគំរូ ៦ ជំហាន ដែលរួមបញ្ចូលធាតុសំខាន់ពីគំរូការអនុវត្តការស្រាវជ្រាវប្រតិបត្តិផ្សេងៗ និងរៀបចំសម្របសម្រួលឱ្យសមស្របជាមួយនឹងបរិបទបណ្តុះបណ្តាលគ្រូនៅកម្ពុជា៖

<u>ជំហានទី១</u>៖ ការកំណត់ និងវិភាគបញ្ហា គ្រូឧទ្ទេសត្រូវអនុវត្តការសង្កេតអាកប្បកិរិយានៅក្នុងថ្នាក់រៀនឱ្យមានលក្ខណៈជាប្រព័ន្ធ ដោយប្រើប្រាស់ការទំនាក់ទំនងមិនផ្លូវការជាមួយគ្រូណែនាំ ការសង្កេតឆាប់រហ័ស ការស្ទង់មតិសិស្ស និងការពិនិត្យលំនាំអាកប្បកិរិយារបស់សិស្ស ដើម្បីកំណត់និងវាយតម្លៃបញ្ហានៅក្នុងថ្នាក់រៀនដែលពាក់ព័ន្ធនឹងអំពើអហិង្សា។ ដំណាក់កាលនេះមានសារៈសំខាន់ខ្លាំងក្នុងការយល់ដឹងអំពីមូលហេតុនៃបញ្ហា និងស្ថានភាពពិតប្រាកដនៃទំនាក់ទំនង និងអាកប្បកិរិយារបស់សិស្សនៅក្នុងបរិបទថ្នាក់រៀន។

<u>ជំហានទី២</u>៖ ការរៀបចំផែនការសកម្មភាព ដោយផ្អែកលើកស្តុតាង និងទិន្នន័យដែលប្រមូលបាន គ្រូឧទ្ទេសត្រូវរៀបចំយុទ្ធសាស្ត្រដែលមានលក្ខណៈជាក់ស្តែង មានក្រមសីលធម៌ និងសមស្របទៅនឹងបរិបទថ្នាក់រៀន។ យុទ្ធសាស្ត្រទាំងនេះអាចរួមមាន ការប្រើប្រាស់វិន័យវិជ្ជមាន ការសហការច្បាស់លាស់ មេរៀនខ្លីៗពីអប់រំសន្តិភាព និងការបង្រៀនការប្រើប្រាស់ភាសានិយាយដោយការគោរពគ្នាទៅវិញទៅមក ដើម្បីលើកកម្ពស់បរិយាកាសថ្នាក់រៀនដែលមានសុវត្ថិភាព និងគ្មានអំពើហិង្សា។

<u>ជំហានទី៣</u>៖ ការអនុវត្តសកម្មភាព ផែនការសកម្មភាពដែលបានរៀបចំរួច ត្រូវអនុវត្តនៅក្នុងមេរៀនប្រចាំថ្ងៃ ដោយប្រើប្រាស់សម្ភារៈដែលបានត្រៀមរួចជាស្រេច ដូចជាស្ត្រីបមេរៀន បទបញ្ជាការងារក្រុម ផ្ទាំងបង្ហាញអំពីអាកប្បកិរិយាដែលរំពឹងទុក និងសកម្មភាពសម្តែងតួ (Role-play)។ ការអនុវត្តដោយមានការរៀបចំ និងមាន

ការយកចិត្តទុកដាក់នេះ មានគោលបំណងបង្កើតការផ្លាស់ប្តូរប្រកបដោយសន្តិភាព និងមាននិរន្តរភាពនៅក្នុងវប្បធម៌ថ្នាក់រៀន។

<u>ជំហានទី៤</u>៖ ការសង្កេត និងការប្រមូលទិន្នន័យ ក្នុងជំហាននេះ គ្រូឧទ្ទេសត្រូវប្រើប្រាស់ប្រភពទិន្នន័យចម្រុះ ដើម្បីធានាបាននូវភាពទូលំទូលាយនិងភាពជឿជាក់នៃភស្តុតាង រួមមាន៖ ការស្ទង់មតិបុរេនិងក្រោយការអន្តរាគមន៍ កំណត់ត្រាសង្កេតក្នុងថ្នាក់ បញ្ជីត្រួតពិនិត្យភាពញឹកញាប់នៃអាកប្បកិរិយា ការឆ្លុះបញ្ចាំងរបស់សិស្ស និងសម្ភាសន៍ខ្លីៗជាមួយសិស្ស ឬគ្រូណែនាំ។ ការប្រមូលទិន្នន័យទាំងនេះ មានគោលបំណងបង្ហាញពីការផ្លាស់ប្តូរដែលកើតមានឡើងក្នុងបរិយាកាសថ្នាក់រៀន ដោយផ្អែកលើការអនុវត្តអន្តរាគមន៍ដោយមិនប្រើប្រាស់អំពើហិង្សា។

<u>ជំហានទី៥</u>៖ ការឆ្លុះបញ្ចាំង និងការបកស្រាយលទ្ធផល គ្រូឧទ្ទេសត្រូវធ្វើការវិភាគលំនាំនៃអាកប្បកិរិយា និងទំនាក់ទំនងរបស់សិស្សតាមរយៈពេល មិនផ្តោតលើព្រឹត្តិការណ៍បុគ្គលណាមួយជាក់លាក់ទេ។ ការប្រៀបធៀបទិន្នន័យមុន និងក្រោយការអន្តរាគមន៍ ជួយឱ្យគ្រូឧទ្ទេសយល់ដឹងអំពីកម្រិតនៃការផ្លាស់ប្តូរ។ ការបកស្រាយលទ្ធផលត្រូវធ្វើឡើងដោយស្មោះត្រង់ មិនដាក់កំហុសទៅលើសិស្ស ឬបុគ្គលណាមួយឡើយ ហើយត្រូវភ្ជាប់លទ្ធផលដែលរកឃើញទៅនឹងអក្សរសាស្ត្រពាក់ព័ន្ធ និងទ្រឹស្តីអប់រំ ដើម្បីពង្រឹងវិជ្ជាជីវៈនៃការស្រាវជ្រាវ។

<u>ជំហានទី៦</u>៖ ការកែសម្រួល និងការចែករំលែក ដោយផ្អែកលើលទ្ធផល និងការឆ្លុះបញ្ចាំង គ្រូឧទ្ទេសត្រូវកែសម្រួល និងបន្តអភិវឌ្ឍការអនុវត្តរបស់ខ្លួន ដើម្បីលើកកម្ពស់បរិយាកាសថ្នាក់រៀនដែលមានសុវត្ថិភាព គោរព និងគ្មានអំពើហិង្សា។ លទ្ធផលនៃការស្រាវជ្រាវត្រូវបានចែករំលែកតាមរយៈសិក្ខាសាលាស្រាវជ្រាវ ការពិភាក្សាជាមួយមិត្តរួមការងារ ឬការបង្ហាញនៅកម្រិតស្ថាប័នបណ្តុះបណ្តាលគ្រូ ដើម្បីរួមចំណែកក្នុងការបង្កើនចំណេះដឹងរួម និងវប្បធម៌វិជ្ជាជីវៈផ្អែកលើការឆ្លុះបញ្ចាំងនិងសន្តិភាព។

ដោយផ្តោតលើបរិយាកាសអហិង្សាជាមូលដ្ឋានសម្រាប់កាធានាប្រសិទ្ធភាពក្នុងការបង្រៀននិងរៀន សៀវភៅណែនាំនេះ គាំទ្រគ្រូឧទ្ទេស និងគរុនិស្សិត ក្នុងការដោះស្រាយបញ្ហាសំខាន់ដែលតែងតែត្រូវបានមើលរំលងនៅក្នុងជីវិតថ្នាក់រៀន។ នៅពេលគ្រូបង្រៀនអាចធ្វើការស្រាវជ្រាវ និងឆ្លើយតបចំពោះអំពើហិង្សា ការបដិសេធ និងការខ្វះការគោរព តាមរយៈការឆ្លុះបញ្ចាំង និងសកម្មភាពជាប្រព័ន្ធ ថ្នាក់រៀននឹងក្លាយជាកន្លែងពោរពេញដោយសុវត្ថិភាព ទំនាក់ទំនងកាន់តែប្រសើរឡើង ហើយការសិក្សាប្រកបដោយគុណភាពអាចកើតមានទៅបាន។

សៀវភៅណែនាំនេះ ជាលទ្ធផលនៃកិច្ចសហការរួម ដើម្បីពង្រឹងវិជ្ជាជីវៈគ្រូនៅកម្ពុជា ហើយចូលរួមគាំទ្រ ដើម្បីសម្រេចឱ្យបាននូវគោលដៅរបស់ក្រសួងអប់រំ ដោយបណ្តុះបណ្តាលគ្រូដែលមានការឆ្លុះបញ្ចាំង មានក្រមសីលធម៌ និងការអប់រំដោយផ្តោតលើកុមារឬអ្នកសិក្សា។

មាតិកា

គណៈកម្មការរៀបរៀង i

អ្នកចូលរួម និងផ្តល់ឆាតុចូល ii

អារម្ភកថា ..... **Error! Bookmark not defined.**

មូលន័យសង្ខេប viii

១. សេចក្តីផ្តើម 1

១.១ គោលបំណងនៃសៀវភៅណែនាំ 1

១.២ អ្នកដែលគួរប្រើសៀវភៅណែនាំនេះ 2

១.៣ តើការស្រាវជ្រាវប្រតិបត្តិជាអ្វី? 3

១.៤ ហេតុអ្វីបានជាយើងផ្តោតលើសន្តិភាព និងអំពើហិង្សាក្នុងថ្នាក់រៀន? 4

១.៥ របៀបប្រើប្រាស់សៀវភៅណែនាំ 7

២. ការស្វែងយល់ពីការស្រាវជ្រាវប្រតិបត្តិ 9

២.១ និយមន័យ និងលក្ខណៈសំខាន់ៗ 9

២.២. ការស្រាវជ្រាវប្រតិបត្តិស្តីពីអហិង្សា ធៀបនឹងការស្រាវជ្រាវប្រតិបត្តិ 11

២.២.១ គោលបំណង 11

២.២.២. ការផ្តោតសំខាន់ 11

២.២.៣. ដំណើរការស្រាវជ្រាវ និងការប្រមូលទិន្នន័យ 12

២.២.៤. តួនាទីរបស់គ្រូ 14

២.២.៥. ប្រភេទនៃការផ្លាស់ប្តូរដែលរំពឹងទុក 14

២.២.៦. ការចូលរួមរបស់ភាគីពាក់ព័ន្ធ 15

២.២.៧. ការពិចារណាលើក្រមសីលធម៌ 15

២.៣. អត្ថប្រយោជន៍សម្រាប់គ្រូឧទ្ទេស និងគរុនិស្សិត 17

២.៣.១. អត្ថប្រយោជន៍សម្រាប់គ្រូឧទ្ទេស 17

២.៣.២. អត្ថប្រយោជន៍សម្រាប់គរុនិស្សិត 18

២.៣.៣. អត្ថប្រយោជន៍សម្រាប់សិស្សានុសិស្សនៅកម្ពុជា 20

២.៣.៤. អត្ថប្រយោជន៍សម្រាប់គ្រួសារ និងសហគមន៍ 20

២.៤. ការពិចារណាប្រកបដោយក្រមសីលធម៌ 21
២.៤.១ គោលការណ៍ស្នូលនៃក្រមសីលធម៌ 21
២.៤.២. ការពិចារណាប្រកបដោយក្រមសីលធម៌ និងការណែនាំជាក់ស្តែងសម្រាប់ថ្នាក់រៀននៅកម្ពុជា 22
២.៤.៣. ការទទួលខុសត្រូវចំពោះក្រមសីលធម៌សម្រាប់គ្រូឧទ្ទេស គរុនិស្សិត និងគ្រូបង្រៀន 27
៣. ដំណើរការស្រាវជ្រាវប្រតិបត្តិ 29
៣.១. វដ្តនៃការស្រាវជ្រាវប្រតិបត្តិរបស់ លេវីន (Lewin's Action Research Cycle) 29
៣.១.១. ការរៀបចំផែនការ 29
៣.១.២. ការធ្វើសកម្មភាព 30
៣.១.៣. ការស្វែងរកការពិត(ការវាយតម្លៃ) 31
៣.២. គំរូការស្រាវជ្រាវប្រតិបត្តិរបស់លោក Kemmis និង McTaggart 33
៣.២.១. ទិដ្ឋភាពទូទៅនៃគំរូវង្វិលជុំ 33
៣.២.២. សេចក្តីពន្យល់លម្អិតពីជំហានទីមួយ 33
៣.២.៣. ការកែលម្អជាបន្តបន្ទាប់ 35
៣.៣. គំរូរបស់ស្ទ្រីងជឺ (Stringer's Model) 38
៣.៣.១. ទិដ្ឋភាពទូទៅនៃគំរូស្រាវជ្រាវប្រតិបត្តិរបស់ Stringer 39
៣.៣.២ សេចក្តីពន្យល់លម្អិតពីជំហាន់ទីមួយៗ 39
៣.៤. វដ្តនៃការស្រាវជ្រាវប្រតិបត្តិបែបចូលរួម (Participatory Action Research Cycle) 44
៣.៤.១. គោលការណ៍សំខាន់ៗនៃ ការស្រាវជ្រាវប្រតិបត្តិបែបចូលរួម 44
៣.៤.២. វដ្តនៃការស្រាវជ្រាវប្រតិបត្តិបែបសហការ របស់លោក Freire (PAR cycle) 45
៤. គំរូសំយោគ ៦ ជំហានក្នុងការអនុវត្តការស្រាវជ្រាវប្រតិបត្តិដើម្បីអហិង្សា 48
៤.១. ជំហាន ១៖ ការកំណត់អត្តសញ្ញាណ និងធ្វើរោគវិនិច្ឆ័យបញ្ហា 51
៤.២. ជំហាន ២៖ ការរៀបចំផែនការសម្រាប់សកម្មភាព 52
៤.៣. ជំហាន ៣៖ ការសម្រេចសកម្មភាព (ការអនុវត្ត) 53
៤.៤.ជំហាន ៤៖ ការសង្កេត និងប្រមូលទិន្នន័យ 54
៤.៥. ជំហាន ៥៖ ការឆ្លុះបញ្ចាំង និងបកស្រាយលទ្ធផល 55

៤.៦. ជំហាន ៦៖ ការកែលម្អ និងចែករំលែក 56

៥. បម្រុងប្រយ័ត្នសំខាន់ៗ នៃធ្វើការស្រាវជ្រាវប្រតិបត្តិ 59

៦. គោលការណ៍ណែនាំសម្រាប់គ្រូឧទ្ទេស 65

៦.១. ការកំណត់ និងវែកញែកបញ្ហា 66

៦.២. ការរៀបចំផែនការសកម្មភាព 74

៦.៣. ការអនុវត្តសកម្មភាព 80

៦.៤. ការសង្កេត និងការប្រមូលទិន្នន័យ 81

៦.៥. ការឆ្លុះបញ្ចាំង និងការបកស្រាយលទ្ធផល 87

៦.៦. ការកែសម្រួល និងការចែករំលែក 93

៦.៧. ប្រព័ន្ធតាមដាន និងការចុះជួយបន្តដែលបានស្នើឡើង សម្រាប់គ្រូឧទ្ទេស 95

៦.៧.១. ការតាមដាន និងការកិច្ច 95

៦.៧.២. បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការតាមដានជំហាននីមួយៗ សម្រាប់គ្រូឧទ្ទេស 97

៦.៧.៣. ការជួបពិភាក្សា ឬការតាមដានប្រចាំខែ 100

៧. ករណីសិក្សាគំរូ (Sample Case Studies) 105

៧.១. ករណីសិក្សាទី ១ (Showcase 1) 105

៧.២. ករណីសិក្សាទី ២ (Showcase 2) 111

៧.៣. ករណីសិក្សាទី៣ (Showcase 3) 117

៧.៤. ករណីសិក្សាទី ៤ (Showcase 4) 122

ឯកសារយោង 128

១. សេចក្តីផ្តើម

ការអប់រំនៅក្នុងសហសម័យ តួនាទីរបស់គ្រូបង្រៀនមិនមែនត្រឹមតែជាអ្នកផ្តល់មេរៀន ឬបង្រៀនតាមកម្មវិធីសិក្សាដែលបានរៀបចំ និងកំណត់នោះទេ។ ការបង្រៀនប្រកបដោយប្រសិទ្ធភាពតម្រូវឱ្យមានការខិតខំប្រឹងប្រែងធ្វើការឆ្លុះបញ្ចាំងការបង្រៀនរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកសិក្សានៅក្នុងបរិយាកាសថ្នាក់រៀនដ៏ស្មុគស្មាញដែលប្រែប្រួលឥតឈប់ឈរ និងធ្វើឱ្យគ្រូបង្រៀនចេះសម្របខ្លួនទៅនឹងបរិបទថ្មីៗទាំង នោះ ។ ការធ្វើការស្រាវជ្រាវប្រតិបត្តិបានផ្តល់ឱ្យគ្រូនូវសមត្ថភាព និងវិធីសាស្ត្រជាប្រព័ន្ធដើម្បីឆ្លុះបញ្ចាំងពីការអនុវត្តផ្ទាល់របស់ពួកគេ ក្នុងការវិភាគនូវបញ្ហាប្រឈម និងពិសោធន៍ដែលភ្ជាប់ជាមួយដំណោះស្រាយសមស្របទៅតាមបរិបទ (Kemmis et al., 2014) ។ ម្យ៉ាងវិញទៀត ការស្រាវជ្រាវប្រតិបត្តិនឹងក្លាយជា ឧបករណ៍វាយតម្លៃ និងផ្ទត់គំនិត៖ ការស្រាវជ្រាវនេះអនុញ្ញាតឱ្យគ្រូបង្រៀនមិនត្រឹមតែឆ្លុះបញ្ចាំងលើការអនុវត្តខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែជាអ្នកស្រាវជ្រាវនៃថ្នាក់រៀនរបស់ខ្លួនឯងផងដែរ។

ការអភិវឌ្ឍជំនាញស្រាវជ្រាវប្រតិបត្តិ មានទំនាក់ទំនងផ្ទាល់ទៅនឹងគុណភាពនៃការបង្រៀន និងការរៀន។ គ្រូបង្រៀនដែលអាចកំណត់បញ្ហានៅក្នុងថ្នាក់រៀនតាមរយៈកស្តុតាង សាកល្បងនូវយុទ្ធសាស្ត្រច្នៃប្រឌិតថ្មីៗ និងវាយតម្លៃការបង្រៀន ដើម្បីបង្កើតបរិយាកាសសិក្សារបស់សិស្សឱ្យកាន់ប្រសើរឡើង ដោយរួមបញ្ចូលការឆ្លើយតប និងការផ្លាស់ប្តូរការបង្រៀន (Mertler, 2019)។ ដំណើរការនៃការស្រាវជ្រាវកំពុងបន្តធ្វើឱ្យប្រសើរឡើងនូវវិជ្ជាជីវៈរបស់គ្រូបង្រៀន ក្នុងពេលដំណាលគ្នាបានការកែលម្អបទពិសោធក្នុងការអប់រំរបស់សិស្ស (Cochran-Smith & Lytle, 2009)។ សម្រាប់អ្នកបណ្តុះបណ្តាលគ្រូបង្រៀន ការណែនាំគរុនិស្សិតឱ្យធ្វើការស្រាវជ្រាវប្រតិបត្តិគឺជាការជំរុញឱ្យមានវប្បធម៌ស្រាវជ្រាវ ពីដំណាក់កាលដំបូងនៃដំណើរអាជីពរបស់ពួកគេ។ តាមរយៈការអនុវត្តការស្រាវជ្រាវប្រតិបត្តិ គរុនិស្សិតគឺរៀនពីរបៀបភ្ជាប់ទ្រឹស្តីជាមួយការអនុវត្ត ការសន្ទនតបញ្ហាប្រឈម និងបណ្តុះទម្លាប់នៃការអនុវត្តឆ្លុះបញ្ចាំងដែលទ្រទ្រង់អាជីពរបស់ពួកគេ (Zeichner, 2003) ។

១.១ គោលបំណងនៃសៀវភៅណែនាំ

គោលបំណងនៃសៀវភៅណែនាំនេះគឺដើម្បីផ្តល់ឱ្យគ្រូឧទ្ទេស និងគរុនិស្សិតនូវមគ្គុទ្ទេសក៍ជាក់ស្តែងក្នុងការយល់ដឹង និងអនុវត្តការស្រាវជ្រាវប្រតិបត្តិនៅក្នុងបរិបទវិជ្ជាជីវៈរបស់ពួកគេ។ ការស្រាវជ្រាវប្រតិបត្តិត្រូវបានរចនាឡើងមិនមែនគ្រាន់តែជាសេចក្តីយោងទ្រឹស្តីប៉ុណ្ណោះទេ ប៉ុន្តែជាធនធានការងារដែលគាំទ្រទាំងការរៀនជំនាញស្រាវជ្រាវ និងការរួមបញ្ចូលជំនាញក្នុងការអនុវត្តថ្នាក់រៀនប្រចាំថ្ងៃ។
ពិសេសជាងនេះទៅទៀត សៀវភៅណែនាំនេះបាន៖

- ណែនាំអំពីមូលដ្ឋានគំនិត និងដំណើរការនៃការស្រាវជ្រាវប្រតិបត្តិ។

- ណែនាំអ្នកអានជាជំហានៗតាមរយៈការរចនា ការអនុវត្ត និងដំណាក់កាលឆ្លុះបញ្ចាំងនៃគម្រោងស្រាវជ្រាវប្រតិបត្តិ។
- បង្ហាញច្បាស់ពីភាពទាក់ទងនៃការស្រាវជ្រាវប្រតិបត្តិ ទៅក្នុងការដោះស្រាយបញ្ហាសន្តិភាព និងអំពើហិង្សាក្នុងថ្នាក់រៀន។
- លើកទឹកចិត្តគ្រូបង្រៀន និងគរុនិស្សិតឱ្យចូលរួមក្នុងការឆ្លុះបញ្ចាំង និងការសន្ទនាដែលជាមធ្យោបាយនៃការកែលម្អទាំងការអនុវត្តវិជ្ជាជីវៈ និងលទ្ធផលក្នុងការអប់រំ (Stringer, 2014) ។
- គោលបំណងអ្នកប្រើប្រាស់៖ សៀវភៅណែនាំនេះអាចជារបស់មានតម្លៃសម្រាប់គ្រូបង្រៀនដែលបានបម្រើដល់គ្រូបង្រៀនក្នុងការបង្រៀន អ្នកដឹកនាំសាលា និងអ្នកបង្កើតគោលនយោបាយអប់រំ ក្នុងការកែលម្អការអប់រំដោយផ្អែកលើភស្តុតាងជាក់ស្តែង។

១.២ អ្នកដែលគួរប្រើសៀវភៅណែនាំនេះ

សៀវភៅណែនាំនេះ ត្រូវបានបង្កើតឡើងដោយផ្តោតលើក្រុមគោលដៅចម្បងចំនួនពីរ៖

១. គ្រូឧទ្ទេស៖ ប្រើប្រាស់វាជាឧបករណ៍គរុកោសល្យសម្រាប់តម្រង់ទិសគរុនិស្សិត ក្នុងការអភិវឌ្ឍជំនាញស្រាវជ្រាវប្រតិបត្តិ។ គ្រូឧទ្ទេសអាចប្រើប្រាស់វា ដើម្បីរៀបចំជាវគ្គសិក្សា សិក្ខាសាលា និងកិច្ចការផ្សេងៗដែលជំរុញការរៀនសូត្រតាមបែបការស្វែងយល់ (inquiry-based learning)។ សៀវភៅណែនាំនេះក៏គាំទ្រដល់តួនាទីអ្នកផ្តល់ប្រឹក្សា (mentors) ដោយជួយពួកគេក្នុងការផ្តល់ការណែនាំតាមរចនាសម្ព័ន្ធច្បាស់លាស់។ ក្នុងពេលជាមួយគ្នានោះក៏អនុញ្ញាតឱ្យគរុនិស្សិតមានភាពម្ចាស់ការលើដំណើរការស្រាវជ្រាវរបស់ពួកគេផងដែរ (Lankshear & Knobel, 2004)។

២. គរុនិស្សិត៖ សៀវភៅណែនាំនេះគឺជាធនធានសិក្សា និងជាមិត្តរួមដំណើរក្នុងការអនុវត្តផ្ទាល់។ វាផ្តល់នូវការពន្យល់ដែលងាយយល់អំពីគោលគំនិតនៃការស្រាវជ្រាវប្រតិបត្តិ ឧទាហរណ៍ជាក់ស្តែង និងកិច្ចការដែលតម្រូវឱ្យមានការត្រិះរិះពិចារណា ដែលអាចយកទៅអនុវត្តផ្ទាល់ក្នុងការបង្រៀន។ សៀវភៅណែនាំនេះបញ្ជាក់យ៉ាងច្បាស់ថា គរុនិស្សិតមិនមែនជាអ្នកទទួលចំណេះដឹងដោយអកម្មនោះទេ ប៉ុន្តែគឺជាអ្នកចូលរួមយ៉ាងសកម្មក្នុងការកែលម្អការបង្រៀន និងរៀននៅក្នុងថ្នាក់រៀនរបស់ពួកគេ (Burns, 2010)។

ទោះបីក្រុមទាំងពីរគឺជាគោលដៅចម្បងក៏ដោយ សៀវភៅណែនាំនេះក៏អាចមានតម្លៃផងដែរសម្រាប់គ្រូបង្រៀនដែលកំពុងបំពេញការងារនៅតាមសាលារៀន (in-service teachers) ថ្នាក់ដឹកនាំសាលា និងអ្នករៀបចំគោលនយោបាយអប់រំ ក្នុងការកែលម្អវិស័យអប់រំដោយផ្អែកលើភស្តុតាងជាក់ស្តែង។

១.៣ តើការស្រាវជ្រាវប្រតិបត្តិជាអ្វី ?

ការស្រាវជ្រាវប្រតិបត្តិ គឺជាទម្រង់នៃការស្រាវជ្រាវជាប្រព័ន្ធដែលធ្វើឡើងដោយអ្នកអនុវត្តផ្ទាល់ដើម្បីកែលម្អក្នុងការអនុវត្តលើចំណេះដឹងផ្ទាល់ បង្កើតចំណេះដឹងថ្មី និងបង្កើនលទ្ធផលនៃការងាររបស់ពួកគេ (Carr & Kemmis, 1986) ។ នៅក្នុងការអប់រំ ការស្រាវជ្រាវប្រតិបត្តិជាធម្មតាត្រូវបានអនុវត្តដោយគ្រូបង្រៀននៅក្នុងថ្នាក់រៀនរបស់ពួកគេផ្ទាល់។ ការអនុវត្តនេះពាក់ព័ន្ធនឹងដំណើរការវដ្តនៃការកំណត់បញ្ហា ការធ្វើផែនការ និងការអនុវត្តការអន្តរាគមន៍ ប្រមូលនិងវិភាគទិន្នន័យ ឆ្លុះបញ្ចាំងពីលទ្ធផល និងការអនុវត្តកែលម្អឱ្យកាន់តែប្រសើរឡើង (Mills, 2020)។

មុខងារសំខាន់ៗមួយចំនួនបែងចែកការស្រាវជ្រាវប្រតិបត្តិពីទម្រង់ស្រាវជ្រាវផ្សេងទៀត៖

- ការតម្រង់ទិសជាក់ស្តែង៖ ការស្រាវជ្រាវប្រតិបត្តិត្រូវបានភ្ជាប់ដោយផ្ទាល់ទៅនឹងការកែលម្អលើការអនុវត្តជាជាងបង្កើតទ្រឹស្តីអរូបី។
- ធម្មជាតិនៃការចូលរួម៖ គ្រូបង្រៀន និងសិស្សពេលខ្លះត្រូវបានចូលរួមដោយផ្ទាល់ក្នុងការកំណត់បញ្ហា និងលេចឡើងនូវដំណោះស្រាយ (McNiff & Whitehead, 2011)។
- វដ្តនៃដំណើរការ៖ ការស្រាវជ្រាវប្រតិបត្ត ដើរតាមវដ្តនៃការធ្វើផែនការ សកម្មភាព ការសង្កេត និងការឆ្លុះបញ្ចាំង ដែលអាចត្រូវបានធ្វើម្តងទៀត ដើម្បីសម្រេចបានការយល់ដឹងកាន់តែស៊ីជម្រៅ (Kemmis et al., 2014)។
- បម្រែបម្រួលសក្តានុពល៖ តាមរយៈការចូលរួមក្នុងស្រាវជ្រាវប្រតិបត្តិ គ្រូបង្រៀនមិនត្រឹមតែដោះស្រាយបញ្ហាភ្លាមៗប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតទម្លាប់នៃការសួរសំណួរបានយូរអង្វែង និងមានការអភិវឌ្ឍវិជ្ជាជីវៈផងដែរ (Cochran-Smith & Lytle, 2009)។

សម្រាប់គរុនិស្សិត ការចូលរួមក្នុងការស្រាវជ្រាវប្រតិបត្តិ មានន័យថាជាការរៀនសូត្រដើម្បីឈានទៅរកការបង្រៀន ដែលមិនមែនគ្រាន់តែជាសំណុំនៃវិធីសាស្ត្រថេរនោះទេ ប៉ុន្តែគឺជាវិជ្ជាជីវៈដ៏រស់រវើក និងផ្អែកលើភស្តុតាងជាក់ស្តែង ដែលក្នុងនោះការឆ្លុះបញ្ចាំង និងការពិសោធន៍គឺជាចំណុចស្នូល

១.៤ ហេតុអ្វីបានជាយើងផ្តោតលើសន្តិភាព និងអំពើហិង្សាក្នុងថ្នាក់រៀន?

ថ្នាក់រៀនមិនមែនជាកន្លែងដែលនៅដាច់ដោយឡែកនោះទេ ប៉ុន្តែវាគឺជាពិភពតូចមួយដែលឆ្លុះបញ្ចាំងពីសង្គមជារួម។ បញ្ហាសន្តិភាព និងអំពើហិង្សា មិនត្រូវបានបង្ហាញតាមរយៈការសម្លុត ការរើសអើង ការផាត់ចេញ ឬជម្លោះ ដែលប៉ះពាល់ដល់ទាំងបរិយាកាសផ្លូវចិត្ត និងលទ្ធផលសិក្សារបស់សិស្ស (UNESCO, 2017)។

ការដោះស្រាយបញ្ហាទាំងនេះមានសារៈសំខាន់ណាស់ក្នុងការធានាថាការអប់រំត្រូវបំពេញគោលបំណងរបស់ខ្លួនក្នុងការអប់រំប្រជាពលរដ្ឋឱ្យមានទំនួលខុសត្រូវ ការយល់ចិត្ত និងសកម្ម។ ថ្នាក់រៀននៅក្នុងប្រទេសកម្ពុជានៅបន្តជួបប្រទះនូវអំពើហិង្សាទាំងផ្លូវកាយ និងពាក្យសំដី ដែលបំផ្លាញសិទ្ធិទទួលការរៀនសូត្រ និងការអភិវឌ្ឍផ្លូវចិត្តកុមារ។ ការវាយតម្លៃ និងរបាយការណ៍កម្មវិធីជាតិ និងអន្តរជាតិធំៗ ចងក្រងជាឯកសារយ៉ាងខ្ជាប់ខ្ជួនពីការប៉ះពាល់ដោយអំពើហិង្សានៅផ្ទះ និងនៅសាលារៀនរបស់កុមារ។ ឧទាហរណ៍ ការត្រួតពិនិត្យថ្នាក់ជាតិ និងអង្គការសហប្រជាជាតិ កត់ចំណាំថា ការចែករំលែករបាយការណ៍ពីអំពើហិង្សាលើរាងកាយលើកុមារ និងការឃើញអំពើហិង្សាក្នុងគ្រួសារ សហគមន៍ និងសាលារៀនជាច្រើន។ ជាងពាក់កណ្តាលនៃយុវវ័យបានរាយការណ៍ថាខ្លួនធ្លាប់មានអំពើហិង្សាលើរាងកាយមុនអាយុ 18 ឆ្នាំ។ គំរូទាំងនេះឆ្លុះបញ្ចាំងពីបទដ្ឋានសង្គមដែលទទួលការដាក់ទណ្ឌកម្មលើរាងកាយ និងវិនិយ្ឆយពាក្យសំដីដ៏គ្រោតគ្រាតទៅជាវិធីសាស្ត្រស្របច្បាប់ក្នុងការការពារសណ្តាប់ធ្នាប់ (សូមមើល UNICEF, 2023a)។

ផលប៉ះពាល់នៃអំពើហិង្សាទាំងផ្លូវកាយ និងពាក្យសំដីនៅក្នុងសាលារៀនត្រូវបានចងក្រងជាឯកសារយ៉ាងល្អ៖ កុមារដែលជួបប្រទះ ឬឃើញអំពើហិង្សាបង្ហាញពីការចូលរួមនៅសាលាថយចុះ អវត្តមានខ្ពស់ និងហានិភ័យនៃការបោះបង់ការសិក្សា ការផ្តោតអារម្មណ៍នឹងលទ្ធផលសិក្សាកាន់តែទាប ផលប៉ះពាល់ផ្លូវចិត្តរយៈពេលវែង (ឧទាហរណ៍៖ ការភ័យខ្លាច ការអាម៉ាស់ ការឈ្លានពាន)។ នៅពេលដែលគ្រូបង្រៀនប្រើការដាក់ទណ្ឌកម្មលើរាងកាយ ឬភាសាដែលនាំឱ្យមានភាពអាម៉ាស់ បរិយាកាសក្នុងថ្នាក់រៀនផ្លាស់ប្តូរពីការចង់ដឹងចង់ឃើញ និងសុវត្ថិភាពទៅជាការភ័យខ្លាច និងការអនុវត្តតាមទៅជាការបំផ្លាញមូលដ្ឋានទំនាក់ទំនងចាំបាច់សម្រាប់ការបង្រៀន និងការរៀនសូត្របែបសកម្ម។ ការវាយតម្លៃកម្រិតអន្តរជាតិ និងជាតិបង្ហាញថា ការដាក់វិនិយ្ឆយជាវិជ្ជមាន ជំនួសការអនុវត្តការដាក់ទណ្ឌកម្ម និងការគ្រប់គ្រងថ្នាក់រៀនដែលផ្តោតលើកុមារ នាំទៅរកការ

កាត់បន្ថយការគំរាមកំហែង អំពើហិង្សាពីមិត្តភ័ក្តិ និងការធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាព និងការចូលរួមរបស់សិស្ស (សូមមើល UNICEF, 2019; 2023a)។

ការកត់សម្គាល់បែបបរិមាណវិស័យ បានបង្ហាញពីបញ្ហានៅក្នុងបរិបទកម្ពុជា។ របាយការណ៍ស្នង់មតិ និងវាយតម្លៃមានអាត្រាខ្ពស់ផងដែរ ឧ.ទ.ហ. ការណ៍ និងការសិក្សាបានចងបង្ហាញថា កុមារមួយភាគធំបានជួបប្រទះទណ្ឌកម្មលើរាងកាយនៅផ្ទះ (ការស្នង់មតិរបស់រដ្ឋាភិបាលថ្មីៗនេះបង្ហាញពីតួលេខថា ៤០-៤៥%) និងការស្នង់មតិតាមសាលារៀនបានរកឃើញថាប្រមាណ ៤៦% នៃកុមារទទួលរងនូវការរំលោកបំពានដោយពាក្យសំដី ឬការប្រើពាក្យសំដី និងអាកប្បកិរិយាមិនសមរម្យ។ ទិន្នន័យទាំងនេះបង្ហាញថា អំពើហិង្សាមិនមានលក្ខណៈតូចតាចទេ ប៉ុន្តែវាមានកម្រិតរីករាលដាលគ្រប់គ្រាន់ ដូច្នេះត្រូវមានការទាមទារឱ្យមានការផ្លាស់ប្តូរជាប្រព័ន្ធពីកម្រិតសាលារៀន(សូមមើល៖ CamboJA News, 2022)។

បញ្ហានេះ បានបង្ហាញថា ការស្រាវជ្រាវប្រតិបត្ត គឺមានភាពសមស្របក្នុងការដោះស្រាយអំពើហិង្សាក្នុងថ្នាក់រៀននៅក្នុងប្រទេសកម្ពុជា ដោយសារតែ៖

- បរិបទជាក់ស្តែង និងភាពជាម្ចាស់ការរបស់គ្រូបង្រៀន៖ អំពើហិង្សាត្រូវបានគាំទ្រដោយផ្នត់គំនិត និងជំនឿ តាមតំបន់ ទម្លាប់ក្នុងថ្នាក់រៀន និងជំនឿរបស់គ្រូម្នាក់ៗ។ ការស្រាវជ្រាវប្រតិបត្តិ បានលើកកម្ពស់គ្រូឧទ្ទេស និងគរុនិស្សិតធ្វើការស្រាវជ្រាវនៅកម្រិតថ្នាក់រៀនរបស់ពួកគេ ដើម្បីកំណត់បញ្ហា នៃឥរិយាបថ និងអាកប្បកិរិយា ដែលនាំឱ្យមានអំពើហិង្សាលើរាងកាយ និងការប្រើប្រាស់ពាក្យសំដីបែបហិង្សា។ ការអន្តរាគមន៍ដោយខ្លួនឯងនៅក្នុងតំបន់ផ្ទាល់ខ្លួន មានស្ថេរភាព និងសមស្រប ជាងការអន្តរាគមន៍ពីខាងក្រៅ។
- ការសាកល្បងធ្វើអ្វីដែលមានហានិភ័យតិចតួចម្តងហើយម្តងទៀត៖ ការស្រាវជ្រាវប្រតិបត្តិគឺជាការស្រាវជ្រាវដែលមានទំហំតូច (ឧទាហរណ៍៖ ផែនការ → សកម្មភាព → សង្កេត → ឆ្លុះបញ្ចាំង → ពិនិត្យឡើងវិញ) ដែលអនុញ្ញាតឱ្យគ្រូបង្រៀនសាកល្បងប្រើយុទ្ធសាស្ត្រវិន័យបែបវិជ្ជមាន(ឧទាហរណ៍៖ គោលការណ៍ថ្នាក់រៀនដែលធ្វើរួមគ្នាជាមួយសិស្សក្នុងថ្នាក់ ធ្វើការសន្ទនាកែលម្អឡើងវិញ ប្រើប្រាស់គោលការណ៍ជាក់ពិន័យបែបវិជ្ជមាន) និងកែលម្អដោយផ្អែកលើភស្តុតាងជាក់ស្តែង។ ការធ្វើការស្រាវជ្រាវប្រតិបត្តិលើកកម្ពស់វិជ្ជាជីវៈតាមរយៈការផ្លាស់ប្តូរផ្នត់គំនិត ឬបទដ្ឋានអនុវត្តន៍ការងារបន្តិចម្តងៗ។
- ការរៀនសូត្រប្រកបដោយវិជ្ជាជីវៈ និងការអនុវត្តការឆ្លុះបញ្ចាំង៖ ការធ្វើការស្រាវជ្រាវប្រតិបត្តិបណ្តុះទម្លាប់ឆ្លុះបញ្ចាំង តាមរយៈការប្រមូលភស្តុតាងជាប្រព័ន្ធ ការឆ្លុះបញ្ចាំងពីលទ្ធផល និងការកែសម្រួលការអនុវត្ត។ ការអនុវត្តទម្លាប់ឆ្លុះបញ្ចាំងជាប្រចាំជាចំណុចសំខាន់ក្នុងការផ្លាស់ប្តូរអាកប្បកិរិយាដែលធ្លាប់ចាត់ទុកការដាក់ទណ្ឌកម្មលើរាងកាយជាការចាំបាច់។ ភស្តុតាងនៃការវាយតម្លៃកម្មវិធីនៅក្នុង

ប្រទេសកម្ពុជាបានបង្ហាញថាការហ្វឹកហាត់ប្រើប្រាស់វិន័យបែបវិជ្ជមានរួមជាមួយនឹងការឆ្លុះបញ្ចាំងនឹងអាចជួយកាត់បន្ថយអំពើហិង្សា (RUPP, n/d)។

- ការបង្កើតភស្តុតាងសម្រាប់គោលនយោបាយ និងការពង្រីកវិសាលភាព៖ នៅពេលដែលគ្រូឧទ្ទេសនិងគរុនិស្សិតរៀបចំឯកសារអំពីវដ្តនៃសកម្មភាពរបស់ពួកគេ ពួកគេបានបង្កើតនូវភស្តុតាងដែលសម្ស្យូរបែបទៅតាមបរិបទ ដែលក្រសួងអប់រំ យុវជន និងកីឬា (MoEYS) វិទ្យាស្ថានគរុកោសល្យ និងអង្គការក្រៅរដ្ឋាភិបាលនានា អាចយកទៅប្រើប្រាស់ដើម្បីរៀបចំគោលនយោបាយ កម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ ព្រមទាំងឧបករណ៍ត្រួតពិនិត្យនានាដែលត្រូវបានរៀបចំឡើងឱ្យស្របទៅតាមស្ថានភាពថ្នាក់រៀននៅក្នុងប្រទេសកម្ពុជា។ របាយការណ៍សន្និបាតអប់រំជាតិបង្ហាញថា ការយកចិត្តទុកដាក់លើគោលនយោបាយកំពុងមានការកើនឡើង (ឧទាហរណ៍៖ ការប្តេជ្ញាចិត្តក្នុងការហាមឃាត់ការដាក់ទណ្ឌកម្មលើរាងកាយ និងការអនុវត្តវិន័យបែបវិជ្ជមាន) ប៉ុន្តែ ប្រសិទ្ធភាពនៃការអនុវត្ត គឺអាស្រ័យលើសមត្ថភាពនិងភស្តុតាងដែលទទួលបានពីអ្នកអនុវត្តផ្ទាល់ (សូមមើល UNICEF, 2023b)។

ការស្រាវជ្រាវប្រតិបត្តិដោយផ្តោតលើសន្តិភាព និងអំពើហិង្សាក្នុងថ្នាក់រៀន សៀវភៅណែនាំនេះសង្កត់ធ្ងន់លើគោលដៅសំខាន់២៖

- **ការបង្កើតបរិយាកាសសិក្សាដែលមានសុវត្ថិភាព៖** ថ្នាក់រៀនដែលមានសុវត្ថិភាពបណ្តុះនូវទំនុកចិត្ត ការគោរព និងការសហការ ដែលកត្តាទាំងនេះសុទ្ធសឹងតែជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានសម្រាប់ការសិក្សាប្រកបដោយប្រសិទ្ធភាព។ ការស្រាវជ្រាវបានបង្ហាញថា នៅពេលដែលសិស្សមានអារម្មណ៍ថាមានសុវត្ថិភាពផ្នែកផ្លូវចិត្ត ពួកគេនឹងមានការជំរុញទឹកចិត្តកាន់តែខ្លាំង និងចូលរួមយ៉ាងពេញលេញក្នុងការសិក្សា (Johnson & Johnson, 2005)។
- **ការកសាងសមត្ថភាពគ្រូបង្រៀនសម្រាប់ការអប់រំពីការបង្វែរទំនាស់៖** គ្រូបង្រៀនដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់របៀបដោះស្រាយជម្លោះ និងរបៀបដែលសិស្សរៀនធ្វើអន្តរកម្មជាមួយគ្នាទៅវិញទៅមក។ ការស្រាវជ្រាវប្រតិបត្តិ ផ្តល់ឱ្យគ្រូបង្រៀននូវវិធីសាស្ត្រដែលមានរចនាសម្ព័ន្ធ ដើម្បីពិនិត្យមើលពីមូលហេតុឫសគល់នៃហិង្សាក្នុងថ្នាក់រៀន សាកល្បងយុទ្ធសាស្ត្រសម្រាប់ដោះស្រាយជម្លោះ និងឆ្លុះបញ្ចាំងពីផលប៉ះពាល់នៃអន្តរាគមន៍របស់ពួកគេ (Salomon & Cairns, 2010)។

ការស្រាវជ្រាវប្រតិបត្តិមិនបានកំណត់ត្រឹមតែប្រធានបទដែលទាក់ទងនឹងសន្តិភាព និងអំពើហិង្សាប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជារបៀបដោះស្រាយនូវបញ្ហាក្នុងការអប់រំ និងសង្គមជាតិទាំងមូល។

១.៥ របៀបប្រើប្រាស់សៀវភៅណែនាំ

សៀវភៅណែនាំការស្រាវជ្រាវប្រតិបត្តិនេះរៀបចំឡើងដើម្បីគាំទ្រទាំងការធ្វើស្វ័យសិក្សា និងការប្រើប្រាស់ដើម្បីបង្រៀន។ ផ្នែកនីមួយៗរបស់សៀវភៅនេះបង្ហាញអំពីគោលគំនិតសំខាន់ៗ ផ្តល់នូវដំហានអនុវត្តជាក់ស្តែង និងលើកទឹកចិត្តធ្វើការឆ្លុះបញ្ចាំង និងការអនុវត្ត។ អ្នកអានគួរតែ៖

- **អានដោយសកម្ម៖** កត់ត្រាទុក ចោទជាសំណួរ និងផ្សារភ្ជាប់ខ្លឹមសារមេរៀនទៅនឹងបទពិសោធន៍បង្រៀនផ្ទាល់ខ្លួន។
- **ចូលរួមអនុវត្ត៖** អនុវត្តតាមដំហានដែលបានណែនាំនៅក្នុងបរិបទថ្នាក់រៀនជាក់ស្តែង ទោះបីជាក្នុងកម្រិតតូចតាចក៏ដោយ។
- **ឆ្លុះបញ្ចាំងជាប្រព័ន្ធ៖** ប្រើប្រាស់សំណួរឆ្លុះបញ្ចាំង ដើម្បីផ្សារភ្ជាប់បទពិសោធន៍ជាក់ស្តែងទៅនឹងទ្រឹស្តី។
- **សហការ៖** ប្រសិនបើអាចធ្វើទៅបាន គួរធ្វើការងារជាមួយមិត្តរួមការងារ គ្រូណែនាំ (school mentors) ឬគ្រូដឹកនាំ ដើម្បីរៀបចំ និងអនុវត្តគម្រោងស្រាវជ្រាវប្រតិបត្តិ។

គ្រូឧទ្ទេសអាចប្រើសៀវភៅណែនាំនេះដើម្បីរៀបចំវគ្គបណ្តុះបណ្តាល ចំណែកឯគរុនិស្សិតអាចអនុវត្តតាមសៀវភៅនេះ សម្រាប់បទពិសោធន៍ដំបូងរបស់ពួកគេក្នុងការអនុវត្តការស្រាវជ្រាវប្រតិបត្តិក្នុងថ្នាក់រៀន។ សៀវភៅណែនាំនេះ មិនមែនជាការបង្គាប់បញ្ជាដាច់ខាតនោះទេ ពោលគឺវាមានភាពបត់បែនតាមបរិបទ តម្រូវការ និងបញ្ហាប្រឈមជាក់ស្តែង។

២. ការស្វែងយល់ពីការស្រាវជ្រាវប្រតិបត្តិ

ការស្រាវជ្រាវប្រតិបត្តិ បានក្លាយជាវិធីសាស្ត្រស្នូលមួយក្នុងការអប់រំបណ្តុះបណ្តាលគ្រូបង្រៀន ពីព្រោះវាលើកកម្ពស់គ្រូបង្រៀន និងគរុនិស្សិតឱ្យក្លាយជាអ្នកអង្កេតយ៉ាងសកម្មលើការអនុវត្តផ្ទាល់ខ្លួនរបស់ពួកគេ។ ខុសពីទម្រង់នៃការស្រាវជ្រាវបែបវិទ្យាសាស្ត្រធម្មតា ដែលជារឿយៗត្រូវបានធ្វើឡើងដោយអ្នកស្រាវជ្រាវខាងក្រៅ ការស្រាវជ្រាវប្រតិបត្តិចាត់ទុកអ្នកអនុវត្តផ្ទាល់គឺជាអ្នកស្រាវជ្រាវផង និងជាភ្នាក់ងារនៃការផ្លាស់ប្តូរផងដែរ។ ផ្នែកនេះនឹងណែនាំអ្នកអានឱ្យស្គាល់នូវគោលគំនិតនៃការស្រាវជ្រាវប្រតិបត្តិ បង្ហាញពីលក្ខណៈសំខាន់ៗ ប្រៀបធៀបវាទៅនឹងការស្រាវជ្រាវបែបប្រពៃណី និងពិភាក្សាអំពីអត្ថប្រយោជន៍ ក៏ដូចជាការពិចារណាលើក្រមសីលធម៌នៃការស្រាវជ្រាវ។ តាមរយៈការបង្កើនការយល់ដឹងឱ្យកាន់តែស៊ីជម្រៅអំពីការស្រាវជ្រាវប្រតិបត្តិ គរុនិស្សិត និងគ្រូឧទ្ទេសអាចយល់ដឹងកាន់តែច្បាស់អំពីតម្លៃរបស់វា ដែលជាឧបករណ៍ផ្លាស់ប្តូរក្នុងការកែលម្អទាំងការអនុវត្តក្នុងថ្នាក់រៀន និងការអភិវឌ្ឍវិជ្ជាជីវៈ។

២.១ និយមន័យ និងលក្ខណៈសំខាន់ៗ

ពាក្យ "ការស្រាវជ្រាវប្រតិបត្តិ" ត្រូវបានបង្កើតឡើងដំបូងដោយអ្នកចិត្តវិទ្យាសង្គម លោក Kurt Lewin ក្នុងទសវត្សរ៍ឆ្នាំ ១៩៤០ ដែលលោកឱ្យនិយមន័យថាជាដំណើរការនៃ "ការស្រាវជ្រាវបែបប្រៀបធៀបលើលក្ខខណ្ឌ និងទម្រង់ផ្សេងៗនៃផលប៉ះពាល់របស់សកម្មភាពសង្គម និងការស្រាវជ្រាវដែលឈានទៅដល់ការអនុវត្តសកម្មភាពសង្គមផ្សេងៗ" (Lewin, 1946, p. 35)។ ចាប់តាំងពីពេលនោះមក គោលគំនិតនេះបានជ្រាបចូលទៅក្នុងវិស័យផ្សេងៗ ជាពិសេសក្នុងវិស័យអប់រំ។

និយមន័យមួយចំនួនបានរំលេចនូវធម្មជាតិ និងវិសាលភាពនៃការស្រាវជ្រាវប្រតិបត្តិដែលមានដូចជា៖

- Carr និង Kemmis (1986) ឱ្យនិយមន័យការស្រាវជ្រាវប្រតិបត្តិថាជា គឺជា"ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួនរបស់អ្នកអនុវត្ត ដើម្បីលើកកម្ពស់ កែលម្អភាពសមហេតុផល និងភាពមិនលម្អៀងនៃការអនុវត្តរបស់ខ្លួន និងធ្វើការស្វែងយល់ពីការអនុវត្តនិងស្ថានភាពទាំងនោះ" (ទំ. ១៦២)។
- Stringer (2014) ពន្យល់ថា ការស្រាវជ្រាវប្រតិបត្តិគឺជា "វិធីសាស្ត្រជាប្រព័ន្ធក្នុងការអង្កេត ដែលធ្វើឱ្យមនុស្សអាចស្វែងរកដំណោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះបញ្ហាដែលពួកគេជួបប្រទះក្នុងជីវភាពរស់នៅប្រចាំថ្ងៃ" (ទំ. ១)។
- Mills (2020) ឱ្យនិយមន័យ ការស្រាវជ្រាវប្រតិបត្តិក្នុងវិស័យអប់រំថា "ជាការស្វែងរកជាប្រព័ន្ធដែលធ្វើឡើងដោយគ្រូបង្រៀន អ្នកគ្រប់គ្រង ឬទីប្រឹក្សា ដើម្បីប្រមូលព័ត៌មានអំពីរបៀបដែលសាលារៀនរបស់ពួកគេដំណើរការ របៀបដែលពួកគេបង្រៀន និងរបៀបដែលសិស្សរបស់ពួកគេរៀនបានល្អ" (ទំ. ៦)។

ទោះបីគេប្រើពាក្យផ្សេងៗគ្នាក៏ដោយ ក៏និយមន័យនៃការស្រាវជ្រាវប្រតិបត្តិមានខ្លឹមសារតែមួយពោលគឺ ការស្រាវជ្រាវប្រតិបត្តិគឺជាទម្រង់នៃការចូលរួម ឆ្លុះបញ្ចាំង និងមានទំនោរជាការអនុវត្តនៃការចង់ដឹងដែលមានគោលបំណងធ្វើឱ្យការប្រតិបត្តិការងារកាន់តែប្រសើរឡើង។

លក្ខណៈពិសេសនៃការស្រាវជ្រាវប្រតិបត្តិ

លក្ខណៈពិសេសមួយចំនួនដែលធ្វើឱ្យ ការស្រាវជ្រាវប្រតិបត្តិ ខុសប្លែកពីវិធីសាស្ត្រស្រាវជ្រាវផ្សេងទៀត៖

- **ដំណើរការមានលក្ខណៈជាវដ្ត និងដដែលៗ** (Cyclic and iterative process): ជាទូទៅ ការស្រាវជ្រាវប្រតិបត្តិអនុវត្តទៅតាមវដ្តនៃការរៀបចំផែនការ ការអនុវត្ត ការសង្កេត និងការឆ្លុះបញ្ចាំង (Kemmis et al., 2014)។ វដ្តនីមួយៗបង្កើតឡើងដោយផ្អែកលើវដ្តមុន ដែលធ្វើឱ្យមានការកែលម្អការអនុវត្តជាបន្តបន្ទាប់។
- **ការរិះរកដែលធ្វើដោយអ្នកអនុវត្តផ្ទាល់** (Practitioner-led inquiry): គ្រូបង្រៀនខ្លួនឯងគឺជាអ្នកកំណត់បញ្ហា រៀបចំការអន្តរាគមន៍ និងវាយតម្លៃលទ្ធផល (Burns, 2010)។ ភាពម្ចាស់ការនេះធានាថាការស្រាវជ្រាវមានភាពពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបរិបទរបស់ពួកគេ។
- **ការផ្តោតលើបរិបទជាក់លាក់** (Context-specific focus): ការស្រាវជ្រាវប្រតិបត្តិ ផ្អែកលើតថភាពជាក់ស្តែងនៃថ្នាក់រៀន ជាមួយនឹងដំណោះស្រាយដែលត្រូវបានកែសម្រួលសម្រាប់ក្រុមសិស្ស និងស្ថានភាពជាក់លាក់ (McNiff & Whitehead, 2011)។
- **ធម្មជាតិនៃកិច្ចសហការ** (Collaborative nature): ទោះបីជា ការស្រាវជ្រាវប្រតិបត្តិ អាចជាដំណើរការជាបុគ្គលក៏ដោយ ក៏វាជារឿយៗពាក់ព័ន្ធនឹងកិច្ចសហការជាមួយសហការី សិស្ស ឬសហគមន៍ (Cochran-Smith & Lytle, 2009)។
- **ការផ្សារភ្ជាប់ទ្រឹស្តី និងការអនុវត្ត** (Integration of theory and practice): ការស្រាវជ្រាវប្រតិបត្តិផ្សារភ្ជាប់អ្វីដែលយើងរៀនក្នុងសៀវភៅ ទៅនឹងអ្វីដែលកើតឡើងជាក់ស្តែងក្នុងថ្នាក់រៀន។ វាធានាថាការបង្រៀនគឺផ្អែកលើការពិតដែលបានបង្ហាញរួចមកហើយ ប៉ុន្តែវានៅតែអាចផ្លាស់ប្តូរបានដើម្បីឱ្យសមស្របទៅតាមស្ថានភាពផ្សេងៗគ្នា។
- **ការផ្តោតលើការផ្លាស់ប្តូរ** (Transformative orientation): គោលបំណងចម្បងរបស់ការស្រាវជ្រាវប្រតិបត្តិមិនមែនត្រឹមតែដើម្បីដោះស្រាយបញ្ហាប៉ុណ្ណោះទេ ប៉ុន្តែគឺដើម្បីលើកកម្ពស់គុណភាពអប់រំ តាមរយៈការជួយឱ្យគ្រូបង្រៀនចេះត្រួតពិនិត្យ និងរៀនសូត្រពីការបង្រៀនរបស់ខ្លួនឯងឱ្យកាន់តែប្រសើរឡើង (Zeichner, 2003)។

២.២. ការស្រាវជ្រាវប្រតិបត្តិស្តីពីអហិង្សា ធៀបនឹងការស្រាវជ្រាវប្រតិបត្តិ

ការស្រាវជ្រាវទាំងពីរនេះប្រើប្រាស់ដំណើរការទៅមកជាមូលដ្ឋានដូចគ្នា ប៉ុន្តែវាមានភាពខុសគ្នាខ្លាំងនៅក្នុងគោលបំណង ការផ្តោតសំខាន់ ដំណើរការ ទិន្នន័យ ក្រមសីលធម៌ តួនាទីរបស់គ្រូ និងលទ្ធផលរំពឹងទុក។ការយល់ដឹងពីភាពខុសគ្នាទាំងនេះ ជួយដល់គ្រូឧទ្ទេស និងគរុនិស្សិត ក្នុងការជ្រើសរើសវិធីសាស្ត្រដែលសមស្របបំផុតសម្រាប់ដោះស្រាយបញ្ហាក្នុងថ្នាក់រៀនរបស់ពួកគេ។

២.២.១ គោលបំណង

គោលបំណងចម្បងនៃ ការស្រាវជ្រាវប្រតិបត្តិស្តីពីអហិង្សា គឺដើម្បីកាត់បន្ថយអំពើហិង្សា និងលើកកម្ពស់បរិយាកាសសិក្សាដែលមានសុវត្ថិភាព និងការគោរពគ្នា។ ការស្រាវជ្រាវនេះមានគោលបំណងផ្លាស់ប្តូរការប្រព្រឹត្តដែលបង្កគ្រោះថ្នាក់ ដូចជាការស្រែកគំហក ការប្រើរំពាត់ដើម្បីដាក់ទណ្ឌកម្ម ការហៅសិស្សថា "ខ្សោយ" ឬការបណ្តោយឱ្យមានការសម្ពុតកំហែង (Bullying) បន្តកើតមាន ។ ទោះជាយ៉ាងណាក៏ដោយ គោលបំណងនៃការស្រាវជ្រាវប្រតិបត្តិស្តីពីការបង្រៀន និងការរៀន គឺដើម្បីកែលម្អការរៀននិងបង្រៀន ដូចជាការបង្កើនការយល់ដឹងក្នុងការអាន ការធ្វើឱ្យពិន្ទុប្រឡងខ្ពស់ជាងមុន ឬការកែលម្អប្រសិទ្ធភាពនៃការងារក្រុមជាដើម។

ឧទាហរណ៍នៃគោលបំណងរបស់ការស្រាវជ្រាវប្រតិបត្តិស្តីពី៖

អហិង្សា	ការបង្រៀននិងការរៀន
គ្រូបង្រៀនថ្នាក់ទី៦ ម្នាក់បានកត់សម្គាល់ឃើញថាសិស្ស ឧស្សាហ៍ប្រើពាក្យសម្តីមិនល្អដាក់គ្នា។ គាត់ក៏បានចាប់ផ្តើមអនុវត្តការស្រាវជ្រាវប្រតិបត្តិមួយដោយដាក់ចេញនូវវិន័យបែបវិជ្ជមាន និងរៀបចំការប្រជុំក្នុងថ្នាក់រៀងរាល់សប្តាហ៍ ដើម្បីពិភាក្សាអំពីការប្រព្រឹត្តប្រកបដោយសីលធម៌។.	គរុនិស្សិតម្នាក់សង្កេតឃើញថាសិស្សពិបាកក្នុងការសរសេរកថាខណ្ឌ។ ការស្រាវជ្រាវរបស់គាត់ផ្តោតលើការសាកល្បងយុទ្ធសាស្ត្រណែនាំការសរសេរ ដើម្បីកែលម្អជំនាញសរសេរ។

២.២.២. ការផ្តោតសំខាន់

ការស្រាវជ្រាវប្រតិបត្តិស្តីពីអហិង្សា ពិនិត្យលើអាកប្បកិរិយា អន្តរកម្ម បរិយាកាសផ្លូវចិត្ត និងការអនុវត្តវិន័យ។ គោលដៅគឺដើម្បីផ្លាស់ប្តូរវប្បធម៌នៃថ្នាក់រៀន។ វាផ្តោតលើកត្តាសំខាន់ៗដែលត្រូវយកចិត្តទុកដាក់ រួមមានដូចខាងក្រោម៖

- ការកាត់បន្ថយទណ្ឌកម្មលើរាងកាយ
- ការជំនួសការប្រើភាសាទ្រគោះបោះបោកមកជាមតិយោបល់កែលម្អ

- ការបង្ការការសម្លុតគំរាមកំហែង (Bullying)
- ការលើកទឹកចិត្តឱ្យមានការប្រាស្រ័យទាក់ទងដោយការគោរព
- ការកែលម្អទំនាក់ទំនងរវាងគ្រូ និងសិស្ស

ការស្រាវជ្រាវប្រតិបត្តិស្តីពីការបង្រៀន និងការរៀន ផ្តោតលើការអនុវត្តការណែនាំ និងលទ្ធផលសិក្សា។ វាផ្តោតលើកត្តាសំខាន់ៗដែលត្រូវយកចិត្តទុកដាក់ រួមមានដូចខាងក្រោម៖

- ការកែលម្អបច្ចេកទេសសួរសំណួរ
- ការបង្កើនការចូលរួមរបស់សិស្ស
- ការពង្រឹងការរៀនវាក្យសព្ទ
- ការបង្កើនភាពស្ទាត់ជំនាញក្នុងការអាន
- ការប្រើប្រាស់ការងារក្រុមឱ្យមានប្រសិទ្ធភាព

ឧទាហរណ៍នៃគោលបំណងរបស់ការស្រាវជ្រាវប្រតិបត្តិស្តីពី៖

អហិង្សា	**ការបង្រៀននិងការរៀន**
គ្រូបង្រៀនម្នាក់បានផ្លាស់ប្តូរពីការគំរាមសិស្សថា «បើមិនស្តាប់ គ្រូនឹងវាយតុ!» មកប្រើទម្លាប់ក្នុងថ្នាក់ដែលច្បាស់លាស់ និងស្ងប់ស្ងាត់វិញ។ បន្ទាប់មក គាត់ក៏តាមដានមើលថាតើការរំខានរបស់សិស្សមានការថយចុះដែរឬទេ?	គ្រូបង្រៀនម្នាក់សាកល្បងប្រើវិធីសាស្ត្រ "គិត-ផ្ទូផ្ទង-ចែករំលែក" (Think–Pair–Share) ដើម្បីមើលថាតើវាបង្កើនចំនួនសិស្សដែលចូលរួមក្នុងសកម្មភាពនិយាយភាសាអង់គ្លេសដែរឬទេ។

២.២.៣. ដំណើរការស្រាវជ្រាវ និងការប្រមូលទិន្នន័យ

ប្រភេទនៃការស្រាវជ្រាវប្រតិបត្តិទាំងពីរខាងលើដើរតាមវដ្តដូចគ្នា (កំណត់បញ្ហា → រៀបចំផែនការ→ អនុវត្ត→សង្កេត→ឆ្លុះបញ្ចាំង→កែសម្រួល) ប៉ុន្តែប្រភេទនៃទិន្នន័យ និងកម្រិតនៃភាពរសើបមានភាពខុសគ្នា។ ក្នុងការស្រាវជ្រាវប្រតិបត្តិស្តីពីអហិង្សា ទិន្នន័យដែលគេប្រមូលបានច្រើនតែផ្តោតលើការពិនិត្យមើលទម្រង់នៃអារម្មណ៍ និងឥរិយាបថរបស់សិស្ស។ ឧបករណ៍ទូទៅដែលគេប្រើនៅក្នុងការស្រាវជ្រាវប្រភេទនេះមានដូចជា៖

- កំណត់ត្រានៃអាកប្បកិរិយាហិង្សា
- ការតាមដានភាពញឹកញាប់នៃសម្លេងខឹង ឬការស្រែក
- បញ្ជីផ្ទៀងផ្ទាត់ការសង្កេតលើអន្តរកម្មរបស់សិស្ស

- ការសម្ភាសន៍សិស្ស/មាតាបិតាអំពីសុវត្ថិភាព និង
- កំណត់ហេតុឆ្លុះបញ្ចាំងពីទម្លាប់របស់គ្រូ

ទោះជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវប្រតិបត្តិលើការបង្រៀន និងការរៀន គឺផ្តោតលើលទ្ធផលសិក្សារបស់សិស្ស ដែលយើងអាចប្រមូលទិន្នន័យបានតាមរយៈឧបករណ៍ដូចខាងក្រោម៖

- ការធ្វើតេស្តមុន និងក្រោយការបង្រៀន
- សន្លឹកកិច្ចការសិស្ស
- ការសង្កេតលើបច្ចេកទេសបង្រៀន
- ការសម្ភាសន៍អំពីការរៀនរបស់សិស្ស
- តារាងពិនិត្យការចូលរួមរបស់សិស្ស

ឧទាហរណ៍៖ ដំណើរការ និងការប្រមូលទិន្នន័យនៃការស្រាវជ្រាវប្រតិបត្តិស្តីពី៖

អហិង្សា	**ការបង្រៀននិងការរៀន**
គ្រូបង្រៀនម្នាក់បានរាប់ចំនួនដងដែលគាត់ប្រើពាក្យសម្តីអវិជ្ជមានក្នុងមួយសប្តាហ៍ នៅមុនពេល និងក្រោយពេលអនុវត្ត «ផែនការប្រើប្រាស់ភាសាបែបវិជ្ជមាន»។ <u>ចំណាំ</u>៖ ដោយសារបញ្ហាហិង្សាគឺជាបញ្ហាងាយរងគ្រោះ ការស្រាវជ្រាវនេះទាមទារឱ្យមានការប្រុងប្រយ័ត្នខ្ពស់ផ្នែកសីលធម៌ ដើម្បីចៀសវាងការបង្កផលប៉ះពាល់ដល់កុមារ។	គ្រូបង្រៀនម្នាក់ វាស់ស្ទង់ពីការរីកចម្រើននៃការចងចាំវាក្យសព្ទ (ពាក្យពេចន៍) បន្ទាប់ពីបានប្តូរមកប្រើប្រាស់សម្ភារឧបទេសដែលផ្អែកលើរូបភាពវិញ។ ចំណាំ៖ កង្វល់ផ្នែកសីលធម៌មានកម្រិតទាបបំផុត (មិនមែនជាបញ្ហាធំដុំឡើយ) ដរាបណាការវាយតម្លៃត្រូវបានធ្វើឡើងដោយយុត្តិធម៌ ហើយអត្តសញ្ញាណរបស់សិស្សត្រូវបានការពារ។

២.២.៤. តួនាទីរបស់គ្រូ

នៅពេលធ្វើការស្រាវជ្រាវប្រតិបត្តិស្តីអំពីអហិង្សា គ្រូដើរតួជាអ្នកការពារសុខុមាលភាពរបស់សិស្ស ជាគំរូនៃការប្រាស្រ័យទាក់ទងដោយសន្តិវិធី ជាភ្នាក់ងារនៃការផ្លាស់ប្តូរវប្បធម៌ ឬជាអ្នកអនុវត្តដែលចេះពិចារណាឆ្លុះបញ្ចាំងលើឥរិយាបថផ្ទាល់ខ្លួនរបស់ពួកគេ។ ផ្ទុយទៅវិញ នៅពេលធ្វើការស្រាវជ្រាវប្រតិបត្តិលើការបង្រៀន និងការរៀន គ្រូដើរតួជាអ្នករៀបចំការបង្រៀន ជាអ្នកពិសោធន៍លើវិធីសាស្ត្របង្រៀន ជាអ្នកវិភាគលើការរៀនសូត្ររបស់សិស្ស ឬជាគ្រូឧទ្ទេសដែលចេះពិចារណាឆ្លុះបញ្ចាំងដើម្បីកែលម្អគុរុកោសល្យបង្រៀន។

ឧទាហរណ៍៖ តួនាទីរបស់គ្រូបង្រៀននៅក្នុងការស្រាវជ្រាវប្រតិបត្តិស្តីពី៖

អហិង្សា	**ការបង្រៀន និងការរៀន**
គ្រូបង្រៀនធ្វើការពិចារណាឆ្លុះបញ្ចាំងដោយស្មោះត្រង់ លើទម្លាប់នៃការគំហកឬស្រែកជាក់សិស្សរបស់ខ្លួន រួចរៀបចំផែនការដើម្បីជំនួសការស្រែកនោះមកជាការប្រើសញ្ញាដៃ និងការរំលឹកដោយសម្តីទន់ភ្លន់ វិញ។	គ្រូបង្រៀនធ្វើការសាកល្បងវិធីសាស្ត្របង្រៀនអំណានពីររបៀបផ្សេងគ្នា ហើយធ្វើការប្រៀបធៀបថាតើវិធីសាស្ត្រមួយណាដែលជួយឱ្យសិស្សយល់អត្ថបទបានល្អជាង។

២.២.៥. ប្រភេទនៃការផ្លាស់ប្តូរដែលរំពឹងទុក

នៅក្នុងការស្រាវជ្រាវប្រតិបត្តិស្តីអំពីអហិង្សា ការផ្លាស់ប្តូរដែលរំពឹងទុកគឺផ្តោតលើ ឥរិយាបថ និងវប្បធម៌។ លទ្ធផលអាចរួមមាន៖

- ការកាត់បន្ថយហេតុការណ៍ហិង្សាផ្សេងៗ
- ការកែលម្អទំនាក់ទំនងក្នុងថ្នាក់រៀន
- ការបង្កើនទំនុកចិត្តលើខ្លួនឯងរបស់សិស្ស
- ការប្រាស្រ័យទាក់ទងគ្នាដោយការគោរពកាន់តែខ្លាំង
- បរិយាកាសថ្នាក់រៀនដែលមានភាពស្ងប់ស្ងាត់ និងសុវត្ថិភាពជាងមុន

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការស្រាវជ្រាវប្រតិបត្តិស្តីពីការបង្រៀន និងការរៀន ការផ្លាស់ប្តូរដែលរំពឹងទុកគឺផ្តោតលើលទ្ធផលសិក្សារបស់សិស្ស និងការណែនាំវិធីសាស្ត្របង្រៀន។ លទ្ធផលទាំងនេះអាចរួមមាន៖"

- ពិន្ទុតេស្តខ្ពស់ជាងមុន
- ការយល់ដឹងខ្លឹមសារមេរៀនបានល្អជាងមុន
- ការចូលរួមយ៉ាងសកម្មជាងមុន (ពីសំណាក់សិស្ស)

- ឯកវាជ្សភាពក្នុងការរៀនសូត្រកាន់តែខ្លាំង មានន័យថាសិស្សានុស្សិស អាចរៀនដោយខ្លួនឯងបានច្រើនជាងមុន។

ឧទាហរណ៍៖ តួនាទីរបស់គ្រូបង្រៀននៅក្នុងការស្រាវជ្រាវប្រតិបត្តិស្តីពី៖

អហិង្សា	ការបង្រៀននិងការរៀន
ក្រោយពេលប្រើប្រាស់ការសន្ទនាបែបផ្សះផ្សារួច សិស្សានុសិស្សបានចាប់ផ្តើមសុំទោសគ្នាទៅវិញទៅមក ជំនួសឱ្យការវាយតប់ ឬឈ្លោះប្រកែកគ្នា។	សិស្សានុសិស្សទទួលបានពិន្ទុអានប្រសើរជាងមុន បន្ទាប់ពីគ្រូបានដាក់ឱ្យអនុវត្តការសិក្សាជាក្រុមតូចៗ។

២.២.៦. ការចូលរួមរបស់ភាគីពាក់ព័ន្ធ

ការស្រាវជ្រាវប្រតិបត្តិស្តីពីអហិង្សា ជាញឹកញាប់តម្រូវឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធជាច្រើនរូប ដូចជាថ្នាក់ដឹកនាំសាលា មាតាបិតា គណៈកម្មការការពារកុមារ ក្រុមប្រឹក្សាឃុំសង្កាត់ និងមិត្តរួមការងារជាគ្រូបង្រៀន។ ផ្ទុយទៅវិញ ចំពោះការស្រាវជ្រាវប្រតិបត្តិស្តីពីការបង្រៀន និងការរៀន ភាគីពាក់ព័ន្ធអាចមានត្រឹមតែ គ្រូបង្រៀន សិស្ស និងជួនកាលមាតាបិតា (សម្រាប់ការជួយកិច្ចការគ្រូដាក់ឱ្យ ឬការជួយកូនអានសៀវភៅ) ប៉ុណ្ណោះ។

ឧទាហរណ៍៖ ភាគីពាក់ព័ន្ធនៅក្នុងការស្រាវជ្រាវប្រតិបត្តិស្តីពី៖

អហិង្សា	ការបង្រៀន និងការរៀន
គ្រូបង្រៀនអញ្ជើញមាតាបិតាសិស្សមកចូលរួមប្រជុំ ដើម្បីពន្យល់ពីមូលហេតុដែលសាលារៀនបញ្ឈប់ការប្រើទណ្ឌកម្មលើរាងកាយ (ការវាយដំ) និងរបៀបដែលពួកគាត់អាចជួយគាំទ្រដល់កូនៗនៅផ្ទះបន្ថែម។	គ្រូបង្រៀនបង្ហាញទិន្នន័យនៃការកើនចម្រើននៃពិន្ទុ តេស្តដល់សិស្សក្នុងថ្នាក់ និងពិភាក្សាគ្នាអំពីរបៀបដែលសិស្សអាចចូលរួមឱ្យកាន់តែសកម្មជាងមុនក្នុងការរៀនសូត្រ។

២.២.៧. ការពិចារណាលើក្រមសីលធម៌

កម្រិតខ្ពស់នៃភាពរសើបលើក្រមសីលធម៌ អាចត្រូវបានគេមើលឃើញនៅក្នុង ការស្រាវជ្រាវប្រតិបត្តិស្តីពីអហិង្សា ពីព្រោះវាពាក់ព័ន្ធនឹងទណ្ឌកម្មរាងកាយ ការឈឺចាប់ផ្នែកផ្លូវចិត្ត និងការរក្សាការសម្ងាត់។
លើសពីនេះ នៅក្នុងនីតិវិធីនៃការរាយការណ៍ គ្រូបង្រៀនត្រូវតែធានាថា៖

- មិនមានកុមារណាម្នាក់រងគ្រោះថ្នាក់ក្នុងអំឡុងពេលស្រាវជ្រាវឡើយ។
- ការសង្កេតមិនត្រូវធ្វើឱ្យសិស្សប្រឈមនឹងអំពើហិង្សាបន្ថែមទៀតនោះទេ។
- រាល់ហេតុការណ៍ហិង្សាទាំងឡាយ ត្រូវតែដោះស្រាយដោយសុវត្ថិភាព។

ចំពោះការស្រាវជ្រាវប្រតិបត្តិស្តីពីការបង្រៀន និងការរៀនវិញ បញ្ហាសីលធម៌គឺគ្រាន់តែធ្វើឱ្យសាមញ្ញដូចជា៖

- ការចៀសវាងការលំអៀងក្នុងការវាយតម្លៃ។
- ការការពារអត្តសញ្ញាណរបស់សិស្ស។
- ការធានាឱ្យមានមតិត្រឡប់ (Feedback) ដោយស្ម័គ្រចិត្ត។.

ឧទាហរណ៍៖ ក្រមសីលធម៌នៅក្នុងការស្រាវជ្រាវប្រតិបត្តិលើ៖

អហិង្សា	**ការបង្រៀននិងការរៀន**
ប្រសិនបើគ្រូបង្រៀនរកឃើញករណីនៃអំពើហិង្សា ឬការធ្វើបាបគ្នាយ៉ាងធ្ងន់ធ្ងរក្នុងចំណោមមិត្តភក្តិ (Peer bullying) គាត់ត្រូវតែរាយការណ៍ពីករណីនេះ ភ្លាមៗ ដោយមិនត្រូវរង់ចាំរហូតដល់វគ្គនៃការស្រាវជ្រាវត្រូវបានបញ្ចប់នោះឡើយ។	គ្រូបង្រៀនផ្តល់នូវកម្រងសំណួរស្ទង់មតិដែលមិនបញ្ចេញឈ្មោះ ដោយសាកសួរសិស្សថា តើវិធីសាស្ត្របង្រៀនមួយណាដែលពួកគេពេញចិត្តជាងគេ។

ទោះបីជាការស្រាវជ្រាវប្រតិបត្តិទាំងពីរប្រភេទនេះ មានទម្រង់រួមដូចគ្នាក៏ដោយ ក៏វាមានភាពខុសគ្នាខ្លាំងទៅលើ គោលបំណង ការផ្តោតសំខាន់ តួនាទីគ្រូ ទិន្នន័យ ក្រមសីលធម៌ និងលទ្ធផលរំពឹងទុក (សូមមើលតារាងខាងក្រោម)៖

- ការស្រាវជ្រាវប្រតិបត្តិស្តីពីអហិង្សា: ផ្តោតសំខាន់ទៅលើសុវត្ថិភាព ទំនាក់ទំនង និងសុខុមាលភាពផ្លូវចិត្ត។
- ការស្រាវជ្រាវប្រតិបត្តិស្តីពីការបង្រៀន និងការរៀន (Action research for teaching and learning): ផ្តោតសំខាន់ទៅលើគរុកោសល្យ ការណែនាំបង្រៀន និងវឌ្ឍនភាពនៃការសិក្សា។

តារាងទី ១៖ ការស្រាវជ្រាវប្រតិបត្តិស្តីពីអហិង្សា ប្រៀបធៀបនឹង ការស្រាវជ្រាវប្រតិបត្តិស្តីពីការបង្រៀន និងការរៀន

ទិដ្ឋភាព	ការស្រាវជ្រាវប្រតិបត្តិស្តីពីអហិង្សា	ការស្រាវជ្រាវប្រតិបត្តិស្តីពីការបង្រៀន និងការរៀន
គោលបំណង	ធានាសុវត្ថិភាព កាត់បន្ថយអំពើហិង្សា និងកែលម្អបរិយាកាសក្នុងថ្នាក់រៀន	កែលម្អសមិទ្ធផលសិក្សា និងគុណភាពនៃការណែនាំបង្រៀន
ការផ្តោត	ឥរិយាបថ ការប្រកបទំនងគ្នា វិន័យ និងបរិយាកាសផ្លូវចិត្ត	គរុកោសល្យ លទ្ធផលសិក្សា និងយុទ្ធសាស្ត្របង្រៀន

តួនាទីគ្រូ	អ្នកការពារ គំរូ អ្នកដឹកនាំផ្នែកផ្លូវចិត្ត/អ្នកកសាងទំនាក់ទំនង និងអ្នកផ្លាស់ប្តូរវិធានបទដ្ឋាន	គ្រូឧទ្ទេស អ្នករចនាកម្មវិធីសិក្សា និងអ្នកសម្របសម្រួល
ប្រភេទទិន្នន័យ	កំណត់ហេតុហេតុការណ៍ ការសង្កេតលើអន្តរកម្ម និងទិន្នន័យទំនាក់ទំនង	ការធ្វើតេស្ត សន្លឹកកិច្ចការ ទិន្នន័យនៃការចូលរួម និងការសង្កេតលើការបង្រៀន
ក្រមសីលធម៌	មានភាពរសើបកម្រិតខ្ពស់ និងចាំបាច់ត្រូវមានការការពារកុមារជាដាច់ខាត	មានភាពរសើបកម្រិតទាប ទៅមធ្យម
ភាគីពាក់ព័ន្ធ	មាតាបិតា ថ្នាក់ដឹកនាំសាលា និងសហគមន៍	ភាគច្រើនគឺគ្រូបង្រៀន និងសិស្ស
ការផ្លាស់ប្តូរដែលរំពឹងទុក	ការផ្លាស់ប្តូរផ្នែកផ្លូវចិត្ត និងវប្បធម៌	ការកែលម្អលើការណែនាំបង្រៀន

២.៣. អត្ថប្រយោជន៍សម្រាប់គ្រូឧទ្ទេស និងគរុនិស្សិត

ការលើកកម្ពស់ អហិង្សាក្នុងសាលារៀន មិនត្រឹមតែជាការទទួលខុសត្រូវផ្នែកសីលធម៌ និងវិជ្ជាជីវៈប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាវិថីដ៏មានឥទ្ធិពលសម្រាប់អភិវឌ្ឍគ្រូបង្រៀនឱ្យកាន់តែខ្លាំងក្លា សាលារៀនកាន់តែមានសុវត្ថិភាព និងសហគមន៍កាន់តែមានផាសុខភាព។ នៅពេលគ្រូឧទ្ទេស និងគរុនិស្សិតចូលរួមក្នុង ការស្រាវជ្រាវប្រតិបត្តិ (AR) ដើម្បីអហិង្សា ពួកគេបានធ្វើលើសពីការកាត់បន្ថយអាកប្បកិរិយាបង្កគ្រោះថ្នាក់។ ពួកគេបានកសាងសមត្ថភាពទំនុកចិត្ត និងអត្តសញ្ញាណវិជ្ជាជីវៈ ដែលគាំទ្រដល់វិធីសាស្ត្រអប់រំដោយសន្តិវិធី និងកុមារមជ្ឈមណ្ឌល។ ផលប៉ះពាល់នេះបានរីកសុសសាយលើសពីក្នុងថ្នាក់រៀន ដោយឈានទៅដល់គ្រួសារ និងសហគមន៍នានាទូទាំងប្រទេសកម្ពុជា។ ខាងក្រោមនេះគឺជាអត្ថប្រយោជន៍សំខាន់ៗសម្រាប់ក្រុមនីមួយៗ៖

២.៣.១. អត្ថប្រយោជន៍សម្រាប់គ្រូឧទ្ទេស

គ្រូឧទ្ទេសដើរតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលគ្រូបង្រៀននាពេលអនាគត។ ការស្រាវជ្រាវប្រតិបត្តិដើម្បីអហិង្សាជួយពង្រឹងការងាររបស់ពួកគេតាម ៤ របៀបសំខាន់ៗ៖

- **ពង្រឹងជំនាញវិជ្ជាជីវៈ និងភាពជឿជាក់៖** ការស្រាវជ្រាវប្រតិបត្តិអនុញ្ញាតឱ្យគ្រូឧទ្ទេសពិនិត្យមើលការអនុវត្តក្នុងថ្នាក់រៀនជាប្រព័ន្ធ និងសាកល្បងវិធីសាស្ត្រថ្មីៗនៃវិន័យបែបវិជ្ជមាន។ វាផ្តល់ឱ្យពួកគេនូវចំណេះដឹងស៊ីជម្រៅ និងភស្តុតាងផ្ទាល់ខ្លួន ដែលជួយពង្រឹងសម្លេងរបស់ពួកគេនៅពេលបណ្តុះបណ្តាលគរុនិស្សិត ឬដឹកនាំការកែទម្រង់សាលារៀន។

ឧទាហរណ៍៖ *គ្រូឧទ្ទេសដែលបានអនុវត្តការសន្ទនាឆ្លុះបញ្ចាំងកែលម្អការបង្រៀននិងរៀននៅតាមសាលាសហការ ដោយបង្កើនទំនុកចិត្តកម្មសិក្សាការី-ការិនី អំពីរបៀបប្រើប្រាស់ការសន្ទនាបែបស្ថាបនាជាជាងការដាក់ពិន័យ។*

- **បង្កើនសមត្ថភាពជាអ្នកប្រឹក្សា (Mentor) និងត្រួតពិនិត្យ៖** ការស្រាវជ្រាវប្រតិបត្តិផ្តល់ឱ្យគ្រូឧទ្ទេសនូវក្របខ័ណ្ឌ ឧបករណ៍ និងជំនាញសង្កេតកាន់តែច្បាស់។ ពួកគេរៀនពីរបៀបណែនាំគរុនិស្សិតឱ្យចេះកំណត់អត្តសញ្ញាណអំពើហិង្សា វិភាគហេតុការណ៍ ប្រមូលទិន្នន័យ និងឆ្លុះបញ្ចាំងប្រកបដោយសីលធម៌។ វាជួយពង្រឹងការត្រួតពិនិត្យនៅសាលាគរុកោសល្យ និងលើកកម្ពស់គុណភាពនៃការចុះអនុវត្ត។
- **ការរួមចំណែកដល់ការកែទម្រង់ស្ថាប័ន៖** គ្រូឧទ្ទេសបង្កើតភស្តុតាងអំពីយុទ្ធសាស្ត្រអហិង្សាដែលមានប្រសិទ្ធភាព ដែលអាចជះឥទ្ធិពលដល់ការរៀបចំកម្មវិធីសិក្សា និងគោលនយោបាយកម្រិតសាលារៀន។ ក្នុងបរិបទកម្ពុជា ការស្រាវជ្រាវនេះគាំទ្រដល់គោលនយោបាយគ្រូបង្រៀន និងគោលដៅការពារកុមារថ្នាក់ជាតិ។
- **ការកែចម្រើនផ្ទាល់ខ្លួន និងវិជ្ជាជីវៈ៖** គ្រូឧទ្ទេសខ្លួនឯងតែងតែរកឃើញការយល់ដឹងថ្មីៗអំពីការទំនាក់ទំនង ការយល់ចិត្ត និងការកសាងទំនាក់ទំនង។ មានរបាយយការណ៍ជាច្រើន បានកាត់បន្ថយនូវភាពតានតឹង និងមានភាពពេញចិត្តកាន់តែខ្លាំងក្នុងការបណ្តុះបណ្តាលគ្រូជំនាន់ក្រោយឱ្យធ្វើការដោយសន្តិវិធី។

២.៣.២. អត្ថប្រយោជន៍សម្រាប់គរុនិស្សិត

គរុនិស្សិត ដែលជាអ្នកដឹកនាំថ្នាក់រៀននាពេលអនាគត ទទួលបានអត្ថប្រយោជន៍ជាផ្លែផ្កាពីការធ្វើការស្រាវជ្រាវប្រតិបត្តិទៅលើអហិង្សា៖

- ការគ្រប់គ្រងថ្នាក់រៀនដោយគ្មានភាពភ័យខ្លាចឬការបំភិតបំភ័យ៖ ជំនួសឱ្យការស្រែកគំហក ឬការដាក់ទណ្ឌកម្ម គរុនិស្សិតរៀនអំពី៖ វិន័យវិជ្ជមាន, ការបង្កើតច្បាប់ក្នុងថ្នាក់រួមគ្នា, បច្ចេកទេសគ្រប់គ្រងអារម្មណ៍ និងការដោះស្រាយវិវាទដោយសន្តិវិធី។

លក្ខណៈសំខាន់ក្នុងស្រាវជ្រាវប្រតិបត្តិគឺការអនុវត្តដោយការឆ្លុះបញ្ចាំង (Reflective Practice) ដែលជំរុញឱ្យគ្រូធ្វើការពិនិត្យយ៉ាងជិតដល់ទៅលើសកម្មភាព និងការសន្និដ្ឋានផ្សេងៗរបស់ខ្លួន ដើម្បីកែលម្អការបង្រៀនឱ្យកាន់តែមានប្រសិទ្ធភាព (Schön,1983)។ តាមរយៈការស្រាវជ្រាវប្រតិបត្តិ គរុនិស្សិតអភិវឌ្ឍ៖

- ❖ ជំនាញសង្កេត៖ សង្កេតមើលគំរូនៃអាកប្បកិរិយា ឬការចូលរួមរបស់សិស្ស។
- ❖ ជំនាញឆ្លុះបញ្ចាំង៖ វិភាគមូលហេតុ និងវាយតម្លៃលទ្ធផលនៃយុទ្ធវិធីបង្រៀន។

- ○ ស្រាវជ្រាវប្រតិបត្តិបង្រៀនគរុនិស្សិតដើម្បីសួរ៖
  - ▪ តើមានអ្វីកើតឡើង?
  - ▪ ហេតុអ្វីបានជាវាកើតឡើង?
  - ▪ តើខ្ញុំអាចកែលម្អអ្វីខ្លះ?
- ○ ផ្នត់គំនិតនេះក្លាយជាទម្លាប់វិជ្ជាជីវៈពេញមួយជីវិត ដែលធ្វើឱ្យការបង្រៀនរបស់ពួកគេកាន់តែប្រសើរឡើងជារៀងរាល់ឆ្នាំ។

❖ ជំនាញដោះស្រាយបញ្ហា៖ រៀបចំ និងសាកល្បងការអន្តរាគមន៍ជាក់ស្តែង

ជំនាញទាំងនេះជួយគរុនិស្សិតឱ្យផ្លាស់ប្តូរលើសពីការផ្តល់មេរៀនជាប្រចាំឆ្ពោះទៅរកការអនុវត្តដែលមានគោលបំណង និងមានមូលដ្ឋានលើការស្រាវជ្រាវ។

- ការយល់ដឹងស៊ីជម្រៅអំពីចិត្តវិទ្យាកុមារនិងអាកប្បកិរិយា៖ តាមរយៈការវិភាគពីមូលហេតុដែលសិស្សមានអាកប្បកិរិយាមិនល្អ ពេលណាជម្លោះកើតឡើង ឬរបៀបដែលអំពើហិង្សាកើនឡើង គរុនិស្សិតទទួលបានចំណេះដឹងដែលសៀវភៅសិក្សាតែមួយមុខមិនអាចផ្តល់ជូនបាន។ ពួកគេយល់ពីតម្រូវការ អារម្មណ៍ និងការលើកទឹកចិត្តរបស់កុមារ ដែលជាចំណេះដឹងមិនអាចរកបានតែក្នុងសៀវភៅពុម្ព។
- ការកសាងអត្តសញ្ញាណវិជ្ជាជីវៈ និងសីលធម៌៖ នៅពេលដែលគរុនិស្សិតឃើញពីរបៀបដែលវិធីសាស្ត្រអហិង្សាផ្លាស់ប្តូរឥរិយាបថរបស់សិស្ស ពួកគេបង្កើតអត្តសញ្ញាណរឹងមាំជាអ្នកអប់រំដែលយកចិត្តទុកដាក់ មានសីលធម៌ និងការពារកុមារ។ នេះមានសារៈសំខាន់ណាស់ក្នុងបរិបទកម្ពុជា ដែលជំនឿបែបបុរាណខ្លះយល់ថាការវាយសិស្សជារឿងធម្មតា។ តាមរយៈការស្រាវជ្រាវប្រតិបត្តិ គរុនិស្សិតបានផ្លាស់ប្តូរពីវិន័យប្រពៃណីទៅជាការអនុវត្តទំនើបដែលផ្តោតលើកុមារ — ដោយក្លាយជាអ្នកដឹកនាំនៃការផ្លាស់ប្តូរវិជ្ជមាន។
- បង្កើនទំនុកចិត្តលើវិជ្ជាជីវៈ៖ ការអនុវត្តស្រាវជ្រាវប្រតិបត្តិ លើកកម្ពស់អារម្មណ៍នៃភាពជាភ្នាក់ងារក្នុងចំណោមគរុនិស្សិត។ នៅពេលពួកគេឃើញការផ្លាស់ប្តូរជាវិជ្ជមានតាមរយៈកស្តុតាងដែលពួកគេប្រមូលបាន ពួកគេកាន់តែមានទំនុកចិត្តលើសមត្ថភាពរបស់ខ្លួនក្នុងការគ្រប់គ្រងថ្នាក់រៀន (Burns, 2010)។ ទំនុកចិត្តនេះមិនត្រឹមតែពង្រឹងអត្តសញ្ញាណវិជ្ជាជីវៈរបស់ពួកគេប៉ុណ្ណោះទេ ថែមទាំងរៀបចំពួកគេសម្រាប់បញ្ហាប្រឈមនៃការបង្រៀនដោយឯករាជ្យផងដែរ។

២.៣.៣. អត្ថប្រយោជន៍សម្រាប់សិស្សានុសិស្សនៅកម្ពុជា

នៅទីបំផុត សិស្សានុសិស្សគឺជាបេះដូងនៃការងារនេះ។ នៅពេលដែលគ្រូបង្រៀនធ្វើការស្រាវជ្រាវប្រតិបត្តិ ដើម្បីកាត់បន្ថយហិង្សា អត្ថប្រយោជន៍សម្រាប់កុមារគឺទាំងភ្លាមៗ និងពេលអនាគត។

- **បង្កើនសុវត្ថិភាព និងសន្តិភាពផ្លូវចិត្ត៖** កុមាររៀនបានល្អបំផុតនៅពេលពួកគេមានអារម្មណ៍ថាមានសុវត្ថិភាព។ ការកាត់បន្ថយការស្រែកគំហក និងការដាក់ទណ្ឌកម្មធ្វើឱ្យសិស្សលែងសូវមានការព្រួយបារម្ភ និងហ៊ានបញ្ចេញមតិ។
- **កែលម្អលទ្ធផលសិក្សា៖** នៅពេលការដាក់ទណ្ឌកម្មត្រូវបានជំនួសដោយវិន័យបែបវិជ្ជមាន៖ អត្រាអវត្តមានថយចុះ, ការយកចិត្តទុកដាក់ប្រសើរឡើង និងលទ្ធផលសិក្សាកើនឡើង។
- **ជំនាញសង្គម និងអារម្មណ៍៖** សិស្សរៀនអំពី ការយល់ចិត្ត, ការទំនាក់ទំនងដោយសន្តិវិធី, ការគ្រប់គ្រងខ្លួនឯង និងការដោះស្រាយបញ្ហារួមគ្នា។
- **ការកាត់បន្ថយការរើសអើង និងហិង្សារវាងមិត្តភក្តិ៖** គ្រូធ្វើជាគំរូនៃអាកប្បកិរិយាសន្តិវិធី ដែលជួយកាត់បន្ថយការឈ្លោះប្រកែកគ្នារវាងសិស្ស និងសិស្ស។

ឧទាហរណ៍៖ ការប្រជុំកម្រិតថ្នាក់រៀនមួយដែលសិស្សពិភាក្សាអំពីបញ្ហាប្រចាំសប្តាហ៍ជួយបង្ការកុំឱ្យជម្លោះតូចតាចរីករាលដាលទៅជាការឈ្លោះប្រកែកគ្នាខ្លាំងក្លា។

២.៣.៤. អត្ថប្រយោជន៍សម្រាប់គ្រួសារ និងសហគមន៍

ថ្នាក់រៀនអហិង្សាពង្រីកឥទ្ធិពលហួសពីបរិវេណសាលា។

- **ការផ្លាស់ប្តូរបទដ្ឋានសង្គមអំពីហិង្សា៖** នៅពេលកុមារទទួលបានបទពិសោធន៍វិន័យអហិង្សានៅសាលា ពួកគេនាំយកការរំពឹងទុកថ្មីៗនេះទៅកាន់គ្រួសារ ដែលជួយឱ្យមាតាបិតាឆ្លុះបញ្ចាំងពីទម្លាប់នៃការដាក់ទណ្ឌកម្មផ្ទាល់ខ្លួន។
- **ការពង្រឹងទំនាក់ទំនងរវាងគ្រួសារ និងសាលារៀន៖** គ្រូបង្រៀនដែលប្រើប្រាស់វិន័យបែបវិជ្ជមាន អាចកសាងទំនុកចិត្តជាមួយមាតាបិតា។ ក្រុមគ្រួសារមានអារម្មណ៍ថា ពួកគេទទួលបានការគោរព និងត្រូវបានរាប់បញ្ចូល ដែលធ្វើឱ្យពួកគេកាន់តែមានធនធ:ក្នុងការសហការជាមួយសាលារៀន។ កត្តានេះបង្កើតឱ្យមានបណ្តាញគាំទ្រដ៏រឹងមាំមួយ ជុំវិញកុមារគ្រប់រូប។
- **ការកសាងសន្តិភាពនៅកម្រិតសហគមន៍៖** រាល់ថ្នាក់រៀនដែលមានសន្តិភាព គឺជាចំណែកមួយក្នុងការបង្កើតសហគមន៍ដែលមានសន្តិភាពកាន់តែខ្លាំង។ សិស្សានុសិស្សដែលរៀនពីរបៀបប្រព្រឹត្តប្រកបដោយ

ការគោរពគ្នា នឹងក្លាយជាមនុស្សពេញវ័យដែលចេះដោះស្រាយជម្លោះដោយមិនប្រើអំពើហិង្សា។ ទាំងនៅតំបន់ជនបទ និងតំបន់ទីប្រជុំជនក្នុងប្រទេសកម្ពុជា ដែលភាពតានតឹងក្នុងសង្គមអាចរីករាលដាលយ៉ាងឆាប់រហ័សនោះ **វប្បធម៌សន្តិភាព** នេះមានអត្ថប្រយោជន៍យូរអង្វែងសម្រាប់សង្គមជាតិទាំងមូល។

២.៤. ការពិចារណាប្រកបដោយក្រមសីលធម៌

ការអនុវត្តក្រមសីលធម៌បង្កើតជាមូលដ្ឋានគ្រឹះនៃការស្រាវជ្រាវប្រតិបត្តិណាមួយ ប៉ុន្តែវាមានសារៈសំខាន់ជាពិសេសនៅពេលដែលយើងផ្តោតអារម្មណ៍លើអហិង្សា។ ដោយសារតែការស្រាវជ្រាវប្រតិបត្តិសម្រាប់អហិង្សា ដោះស្រាយជាមួយអាកប្បកិរិយាប្រកាន់ខ្ជាប់ ថាមពលអំណាច និងអន្តរកម្មដែលផ្ទុកទៅដោយអារម្មណ៍ គ្រូបង្រៀន និងគរុនិស្សិតត្រូវតែធានាថាការស្រាវជ្រាវរបស់យើងការពារអ្នកចូលរួម គោរពសិទ្ធិ និងរក្សាសេចក្តីថ្លៃថ្នូររបស់បុគ្គលទាំងអស់។ នៅក្នុងបរិបទអប់រំកម្ពុជា ដែលឋានានុក្រមថ្នាក់រៀន ការរំពឹងទុកវប្បធម៌ និងទំនាក់ទំនងសហគមន៍ដើរតួនាទីយ៉ាងសំខាន់ ការឆ្លុះបញ្ចាំងក្រមសីលធម៌ត្រូវតែមានចេតនាឆ្លើយតបតាមវប្បធម៌ និងបន្តពេញមួយវដ្តនៃការស្រាវជ្រាវ។

និយាយឱ្យសាមញ្ញទៅ នៅពេលដែលគ្រូឧទ្ទេស គរុនិស្សិត ឬគ្រូបង្រៀនក្នុងថ្នាក់រៀនចូលរួមក្នុងការស្រាវជ្រាវប្រតិបត្តិដែលផ្តោតលើការកាត់បន្ថយអំពើហិង្សា និងការលើកកម្ពស់ថ្នាក់រៀនដែលមានសុវត្ថិភាព និងគួរឱ្យគោរព ពួកគេត្រូវតែចូលរួមដោយប្រុងប្រយ័ត្នចំពោះបញ្ហាក្រមសីលធម៌។ ការស្រាវជ្រាវអំពីអហិង្សា ជារឿយៗពាក់ព័ន្ធនឹងប្រធានបទរសើប (ការដាក់ទោស វិន័យ សុខុមាលភាពផ្លូវចិត្ត និងថាមពល) និងអាចពាក់ព័ន្ធនឹងកុមារ ដូច្នេះតម្រូវឱ្យមានការប្រកាន់ខ្ជាប់នូវគោលការណ៍ក្រមសីលធម៌ ដើម្បីការពារសិទ្ធិ សេចក្តីថ្លៃថ្នូរ និងសុវត្ថិភាពរបស់អ្នកចូលរួមក្នុងគ្រប់ដំណាក់កាលនៃដំណើរការស្រាវជ្រាវ។

២.៤.១ គោលការណ៍ស្នូលនៃក្រមសីលធម៌

ដោយផ្អែកលើក្របខ័ណ្ឌក្រមសីលធម៌ស្រាវជ្រាវដែលបានបង្កើតឡើង (ឧទាហរណ៍ គោលការណ៍ស្នូលទាំងបីនៃរបាយការណ៍ Belmont ការគោរពចំពោះបុគ្គល ការយកចិត្តទុកដាក់ និងយុត្តិធម៌) ក៏ដូចជាគោលការណ៍ណែនាំជាក់លាក់ចំពោះការស្រាវជ្រាវអប់រំ និងផ្តោតលើកុមារ ការស្រាវជ្រាវសម្រាប់អហិង្សាគួរតែត្រូវបានដឹកនាំដោយគោលការណ៍ស្នូលដូចខាងក្រោម៖

- **ការគោរពចំពោះបុគ្គល៖** ទទួលស្គាល់ស្វ័យភាព និងសេចក្តីថ្លៃថ្នូររបស់អ្នកចូលរួមទាំងអស់។ ចាត់ទុកពួកគេជាបុគ្គលដែលសមនឹងទទួលបានការគោរព រួមទាំងការទទួលបានការយល់ព្រម និងជំនួយដែលបានជូនដំណឹង ព្រមទាំងអនុញ្ញាតឱ្យមានការចូលរួមដោយស្ម័គ្រចិត្តដោយគ្មានសម្ពាធ។

- **គ្រោះថ្នាក់ និងកុំបង្កគ្រោះថ្នាក់៖** ធានាថាការស្រាវជ្រាវមិនបង្កគ្រោះថ្នាក់ដល់រាងកាយ អារម្មណ៍ សង្គម ឬផ្លូវចិត្ត ហើយតាមដែលអាចធ្វើទៅបាន រួមចំណែកជាវិជ្ជមានដល់សុខុមាលភាពរបស់អ្នកចូលរួម ឧទាហរណ៍ ការកែលម្អបរិយាកាសថ្នាក់រៀន ការពង្រឹងការការពារកុមារ (UNICEF, ២០១៨)។
- **យុត្តិធម៌ និងសមធម៌៖** ធានាឱ្យមានការប្រព្រឹត្តដោយយុត្តិធម៌ និងឱកាស ជៀសវាងការកេងប្រវ័ញ្ច ឬការលើសអើង និងប្រព្រឹត្តចំពោះអ្នកចូលរួមទាំងអស់ដោយការគោរពស្មើភាពគ្នា ដោយមិនគិតពីប្រវត្តិ ឬហានៈ (The Norman Ebenstein Institute, n/d)។
- **ឯកជនភាព ការសម្ងាត់ និងអនាមិក៖** ការពារអត្តសញ្ញាណរបស់អ្នកចូលរួម រក្សាទុកទិន្នន័យប្រកបដោយសុវត្ថិភាព និងរាយការណ៍អំពីការរកឃើញតាមរបៀបដែលរារាំងការកំណត់អត្តសញ្ញាណបុគ្គល (កូន ឬគ្រូបង្រៀន) ជាពិសេសនៅក្នុងសហគមន៍តូចៗ ឬការកំណត់ទៅតាមជនបទតឹងតែង។
- **តម្លាភាព ភាពស្មោះត្រង់ និងសុចរិតភាព៖** ពន្យល់យ៉ាងច្បាស់អំពីគោលបំណង វិធីសាស្ត្រ ហានិភ័យ និងអត្ថប្រយោជន៍នៃការស្រាវជ្រាវ ផ្តល់ការរាយការណ៍ការពិត ជៀសវាងការក្លែងបន្លំ ឬការបោកប្រាស់អ្នកចូលរួម ឬទិន្នន័យ និងបើកចំហអំពីដែនកំណត់ និងហានិភ័យដែលអាចកើតមាន។
- **ការការពារកុមារដោយផ្តោតលើកុមារ (នៅពេលធ្វើការជាមួយអនីតិជន)៖** នៅពេលដែលអ្នកចូលរួមជាកុមារ សូមយកចិត្តទុកដាក់បន្ថែមទទួលបានការយល់ព្រមពី ឪពុកម្តាយ អាណាព្យាបាល និងការយល់ព្រមពីកុមារ (នៅពេលដែលពួកគេអាចធ្វើបាន) ពន្យល់ពីការស្រាវជ្រាវជាភាសាសមស្របតាមអាយុ អនុញ្ញាតឱ្យដកខ្លួនចេញវិញនៅពេលណាមួយក៏បាន ហើយត្រូវប្រុងប្រយ័ត្នជាពិសេសអំពីប្រធានបទរសើប ឬទុក្ខព្រួយដែលអាចកើតមាន (សាកលវិទ្យាល័យកាតូលិកអូស្ត្រាលី ឆ្នាំ២០២៤)។

២.៤.២. ការពិចារណាប្រកបដោយក្រមសីលធម៌ និងការណែនាំជាក់ស្តែងសម្រាប់ថ្នាក់រៀននៅកម្ពុជា

ខាងក្រោមនេះគឺជាបញ្ជាក្រមសីលធម៌សំខាន់ៗដែលគ្រូឧទ្ទេស គរុនិស្សិត និងគ្រូបង្រៀនក្នុងថ្នាក់ត្រូវតែប្រមើលមើល និងដោះស្រាយ រួមជាមួយនឹងការផ្តល់យោបល់ជាក់ស្តែងនៃប្រទេសកម្ពុជា ឧទាហរណ៍ជាក់លាក់សម្រាប់ធ្វើដូច្នេះប្រកបដោយទំនួលខុសត្រូវ។

ការព្រមព្រៀងដែលបានជូនដំណឹង និងការចូលរួមដោយស្ម័គ្រចិត្ត

មុនពេលការស្រាវជ្រាវចាប់ផ្តើម អ្នកចូលរួមត្រូវតែយល់ពីអ្វីដែលការស្រាវជ្រាវពាក់ព័ន្ធ (គោលបំណង វិធីសាស្ត្រ រយៈពេល ហានិភ័យ ឬអត្ថប្រយោជន៍ដែលអាចកើតមាន)។ ការចូលរួមត្រូវតែស្ម័គ្រចិត្ត ពួកគេត្រូវតែដឹងថាពួកគេអាចបដិសេធ ឬដកខ្លួនចេញដោយមិនមានផលវិបាកអវិជ្ជមាន។

ចំពោះសិស្សដែលមិនទាន់គ្រប់អាយុ៖ ការយល់ព្រមត្រូវតែទទួលបានពីមាតាបិតា ឬអាណាព្យាបាល និងពីកុមារផ្ទាល់ ដោយប្រើប្រាស់ភាសាដែលសមស្របទៅតាមវ័យរបស់ពួកគេ។ អ្នកស្រាវជ្រាវត្រូវតែធានាថា កុមារមានអារម្មណ៍ថាមានសេរីភាពពេញលេញក្នុងការបដិសេធ ឬនិយាយថា "ទេ"។

<u>ចំណុចគួរពិចារណា</u>៖

ឧបមាថា អ្នកស្រាវជ្រាវជាគរុនិស្សិតម្នាក់ គាត់ចង់ស្ទាបស្ទង់សិស្សថ្នាក់ទី៤ ថាតើពួកគេធ្លាប់ស្រែកឬវាយដំគ្នាដែរឬទេ។

- អ្នកស្រាវជ្រាវគួរតែធ្វើលិខិតសុំការយល់ព្រមជាភាសាខ្មែរទៅកាន់មាតាបិតា ដើម្បីពន្យល់អំពីការសិក្សាស្រាវជ្រាវ និងទទួលបានការយល់ព្រមតាមរយៈហត្ថលេខា។ បន្ទាប់មកពន្យល់ទៅកាន់សិស្សានុសិស្សថា ការចូលរួមរបស់ពួកគេគឺធ្វើឡើងដោយស្ម័គ្រចិត្ត ហើយការបដិសេធមិនចូលរួមនឹងមិនប៉ះពាល់ដល់ពិន្ទុ ឬការរាប់អានចំពោះពួកគេឡើយ។

ការសម្ងាត់ ឯកជនភាព និងភាពអនាមិក

- ការស្រាវជ្រាវអំពីអំពើហិង្សាឬវិនិយអាចបង្ហាញព័ត៌មានដែលអាចធ្វើឱ្យអាម៉ាស់ មាក់ងាយ ឬអាចបង្កគ្រោះថ្នាក់ដល់បុគ្គល ប្រសិនបើអត្តសញ្ញាណត្រូវបានបង្ហាញ។
- ចាត់តាំងឈ្មោះក្លែងក្លាយ ឬលេខកូដដល់អ្នកចូលរួម លុបព័ត៌មានលម្អិតនៃការកំណត់អត្តសញ្ញាណ (ឈ្មោះ លេខសម្គាល់សាលារៀន លេខថ្នាក់ ឬបន្ទប់) រក្សាទុកទិន្នន័យរសើប (លេខសំឡេង វីដេអូ) ដោយសុវត្ថិភាព កំណត់ការចូលប្រើចំពោះតែបុគ្គលដែលមានការអនុញ្ញាតប៉ុណ្ណោះ។

<u>ចំណុចគួរពិចារណា</u>៖ នៅក្នុងសហគមន៍សាលារៀនជនបទតូចៗ (ឧទាហរណ៍ សាលារៀនភូមិមួយនៅខេត្តតាកែវ) សូម្បីតែព័ត៌មានលម្អិតតាមបរិបទតិចតួចក៏អាចអនុញ្ញាតឱ្យសមាជិកសហគមន៍ទាយអត្តសញ្ញាណបុគ្គលបានដែរ។

- ជំនួសឱ្យការសរសេរ សិស្សថ្នាក់ទី៥ នៃសាលាព្រៃកឫស្សី ពិពណ៌នាថាជា សិស្សថ្នាក់ទី៥ នៅសាលាបឋមសិក្សាសាធារណៈភូមិក្នុងស្រុកជនបទ។

ការការពារសុវត្ថិភាពផ្លូវចិត្ত និងផ្លូវកាយ (មិនបង្កគ្រោះថ្នាក់)

- ប្រធានបទដូចជាការដាក់ទណ្ឌកម្មលើរាងកាយ ការស្រែកគំហក ការធ្វើឱ្យប៉ះទង្គិចផ្លូវចិត្ত និងការគំរាមកំហែងទៅលើសេរីភាពគឺជាបញ្ហារសើបបំផុត។ ការសួរកុមារ ជាពិសេសកុមារដែលជាជនរង

គ្រោះ ឱ្យរៀបរាប់ពីបទពិសោធន៍ទាំងនេះឡើងវិញ អាចធ្វើឱ្យពួកគេមានវិបត្តិផ្លូវចិត្តជាថ្មី (Re-traumatize) ឬបង្ហាញឱ្យពួកគេសងសឹកពីមិត្តភ័ក្តិ ឬមនុស្សពេញវ័យ (យោងតាម Australian Catholic University, 2024; Jonsson et al., 2022)។

- ប្រើប្រាស់ភាសាទន់ភ្លន់និងមិនមានចរិតរិះគន់ឬវិនិច្ឆ័យផ្តល់ធនធានគាំទ្រ (ដូចជា អ្នកប្រឹក្សាយោបល់ ឬបុគ្គលិកសាលាដែលអាចទុកចិត្តបាន) ប្រសិនបើអ្នកចូលរួមមានអារម្មណ៍តក់ស្លុត អនុញ្ញាតឱ្យអ្នកចូលរួមរំលងសំណួរ ឬដកខ្លួនចេញពីការសិក្សាបានគ្រប់ពេល។ ចៀសវាងការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានលម្អិតដែលរសើប និងបង្កើតយន្តការបញ្ជូនបន្ត ឬរាយការណ៍ឱ្យបានច្បាស់លាស់ ប្រសិនបើមានការរំលោភបំពានធ្ងន់ធ្ងរត្រូវបានលាតត្រដាង។

<u>ចំណុចគួរពិចារណា</u>៖ អំឡុងពេលនៃការពិភាក្សាក្នុងថ្នាក់រៀនអំពីការអនុវត្តវិន័យ កុមារម្នាក់បានបង្ហើបឱ្យដឹងថា ជារឿយៗ ខ្លួនត្រូវបានគេទះកំផ្លៀងនៅផ្ទះ ដើម្បីជាការ "ការប្រដៅ"។

- អ្នកស្រាវជ្រាវគួរតែបញ្ឈប់ការសាកសួរដេញដោលបន្ថែមទៀត ធានារក្សាការសម្ងាត់ និង ប្រសិនបើគោលការណ៍តម្រូវ ត្រូវរាយការណ៍ករណីនេះទៅកាន់ជនបង្គោលការពារកុមារប្រចាំសាលា ឬ អាជ្ញាធរពាក់ព័ន្ធ ជាជាងការបង្ខំឱ្យកុមាររៀបរាប់ព័ត៌មានលម្អិតបន្ថែម។

អំណាចនៃឥទ្ធិពល និងភាពស្ម័គ្រចិត្ត

- ក្នុងបរិបទថ្នាក់រៀននៅកម្ពុជា៖ គ្រូបង្រៀនមានអំណាច និងឥទ្ធិពលខ្លាំង។ កុមារ (និងជួនកាលមាតាបិតា) អាចមានអារម្មណ៍ថា ពួកគេត្រូវតែអនុវត្តតាមការស្នើសុំរបស់គ្រូ។ កត្តានេះធ្វើឱ្យប៉ះពាល់ដល់ "គោលការណ៍ស្ម័គ្រចិត្ត" នៃការផ្តល់ការយល់ព្រម។

- ត្រូវបញ្ជាក់ឱ្យច្បាស់ថា ការមិនចូលរួមនឹងមិននាំឱ្យមានផលវិបាកអវិជ្ជមានណាមួយឡើយ។ ត្រូវប្រមូលទិន្នន័យតាមវិធីសាស្ត្រដែលកាត់បន្ថយសម្ពាធ (ឧទាហរណ៍៖ ការប្រើប្រាស់ប្រអប់ស្នង់មតិអនាមិក ការសម្ភាសន៍ជាក្រុមដោយស្ម័គ្រចិត្ត និងការសុំការយល់ព្រមពីកុមារដោយប្រើភាសាសមស្របតាមវ័យ)។

<u>ចំណុចគួរពិចារណា</u>៖ ប្រសិនបើគ្រូបង្រៀនម្នាក់កំពុងធ្វើការស្ទង់មតិអំពីវិន័យក្នុងថ្នាក់រៀនផ្ទាល់ខ្លួន គាត់គួរតែសង្កត់ធ្ងន់ថាការចូលរួមគឺការស្ម័គ្រចិត្ត ប្រមូលចម្លើយដោយអនាមិក និងមិនត្រូវឈរមើលសិស្សនៅពេលពួកគេកំពុងបំពេញទម្រង់បែបបទនោះទេ (ព្រោះវាអាចបង្កសម្ពាធដល់ពួកគេដោយអចេតនា)។

ការយល់ដឹងពីវប្បធម៌ និងការគោរព

- និយាមសង្គមកម្ពុជាច្រើនតែផ្តោតសំខាន់លើការគោរព ឋានានុក្រម និងសុខដុមរមនាក្នុងសង្គម។ សំណួរអំពីបទវិនិយ ឬអំពើហិង្សានៅក្នុងសាលារៀនអាចនឹងប៉ះពាល់ដល់ងងុំនឿដែលកប់យ៉ាងជ្រៅជាយូរណាស់មកហើយ។ អ្នកស្រាវជ្រាវត្រូវតែយល់ដឹងពីភាពផ្សេងគ្នានៃវប្បធម៌សង្គមនីមួយៗ ចៀសវាងការបន្ទោសបង្ខាំ ឬការវិនិច្ឆ័យ និងគោរពឱ្យតម្លៃនៃវប្បធម៌ក្នុងតំបន់ ព្រមទាំងលើកកម្ពស់សិទ្ធិកុមារក្នុងពេលជាមួយគ្នា (UNICEF, 2018)។

- ប្រើប្រាស់ភាសាប្រកបដោយក្តីគោរពនិងមិនមានចរិតស្តីបន្ទោស រៀបចំក្របខណ្ឌស្រាវជ្រាវក្នុងបំណងកែលម្អសុខុមាលភាព និងសុវត្ថិភាពក្នុងថ្នាក់រៀន" ជាជាង "លាតត្រដាងការរំលោភបំពាន" បញ្ជូលភាគីពាក់ពាក់ព័ន្ធមានដូចជា ឪពុកម្តាយ និងសហគមន៍ដោយភាពវៃឆ្លាតនិងទន់ភ្លន់ និងកែលម្អនីតិវិធីនៃការសុំការយល់ព្រមឱ្យសមស្របទៅតាមភាសា និងបរិបទក្នុងតំបន់។

<u>ចំណុចគួរពិចារណា</u>៖ នៅក្នុងសាលារៀននៅតំបន់ជនបទ ដែលចាត់ទុកទណ្ឌកម្មលើរាងកាយថាជា "រឿងធម្មតា" គរុនិស្សិតដែលចុះកម្មសិក្សាគួរតែចាប់ផ្តើមការស្រាវជ្រាវប្រតិបត្តិរបស់ខ្លួន ដោយពិភាក្សាជាមុនសិនជាមួយថ្នាក់ដឹកនាំសាលាក្នុងតំបន់ និងតំណាងមាតាបិតា ដោយពន្យល់ថា គោលបំណងគឺដើម្បីបង្កើតបរិយាកាសថ្នាក់រៀនដែលមានសុវត្ថិភាព និងការគោរពគ្នាឱ្យកាន់តែប្រសើរឡើង មិនមែនក្នុងន័យចាប់កំហុសឬធ្វើឱ្យអាប់ឧនកិត្តិយសគ្រូឡើយ។

ភាពត្រឹមត្រូវ ភាពស្មោះត្រង់ និងសុចរិតភាពក្នុងការប្រមូលទិន្នន័យ និងរាយការណ៍

- ទោះបីជាមានចេតនាល្អយ៉ាងណាក៏ដោយ ការរាយការណ៍ពីលទ្ធផលខុសពីការពិត ការកែសម្រួលទិន្នន័យ ឬការជ្រើសរើសរាយការណ៍យកតែលទ្ធផលវិជ្ជមាននោះ នឹងធ្វើឱ្យបាត់បង់តម្លៃ និងភាពជឿជាក់នៃការស្រាវជ្រាវប្រតិបត្តិ។

- រក្សាកំណត់ត្រាឱ្យបានត្រឹមត្រូវ ប្រើប្រាស់វិធីសាស្ត្រផ្ទៀងផ្ទាត់ទិន្នន័យពីច្រើនប្រភព (ការសង្កេត ការសម្ភាសន៍ និងមតិត្រឡប់របស់សិស្ស) សរសេររាយការណ៍ទាំងលទ្ធផលវិជ្ជមាន និងបញ្ហាប្រឈមនានា ក ទទួលស្គាល់នូវដែនកំណត់នៃការស្រាវជ្រាវ និងចៀសវាងការពង្រីកលទ្ធផល ដើម្បីផ្តាប់ចិត្តភាគីពាក់ព័ន្ធ។

<u>ចំណុចគួរពិចារណា</u>៖ ប្រសិនបើបន្ទាប់ពីអនុវត្តយុទ្ធសាស្ត្រវិន័យបែបវិជ្ជមាន ដែលធ្វើឱ្យថ្នាក់រៀនបានកាត់បន្ថយការស្រែកឡូឡា ប៉ុន្តែការគំរាមកំហែងក្នុងចំណោមមិត្តភក្តិនៅតែមាន ដូចនេះ អ្នកស្រាវជ្រាវគួររាយការណ៍ទាំងពីរ — មិនមែនត្រឹមតែភាពជោគជ័យនោះទេ — ដើម្បីផ្តល់រូបភាពពិតប្រាកដ និងជាក់ស្តែងដែលអាចផ្តល់ជាព័ត៌មានបន្ថែមក្នុងការឆ្លុះបញ្ចាំង និងធ្វើឱ្យមានភាពប្រសើរឡើងជាងមុន។

ការការពារ និងរាយការណ៍អំពីការគំរាមគំហែងឬការទំនួលខុសត្រូវអំពីកិច្ចការពារកុមារ

- ការស្រាវជ្រាវប្រតិបត្តិស្តីពីអហិង្សាអាចបង្ហាញពីករណីរំលោភបំពាន ឬការមិនអើពើធ្ងន់ធ្ងរ។ អ្នកស្រាវជ្រាវត្រូវតែត្រៀមខ្លួនជាស្រេចដើម្បីចាត់វិធានការ មិនមែនត្រឹមតែសង្កេតប៉ុណ្ណោះទេ (UNICEF, 2018)។
- បង្កើតនីតិវិធីបញ្ជូនដោយមានឯកសារយោងច្បាស់លាស់មុនពេលចាប់ផ្តើមការស្រាវជ្រាវ (ឧទាហរណ៍ ទៅកាន់គ្រូបង្គោលការពារកុមារប្រចាំសាលា ឬស្ថាប័នការពារកុមារពីខាងក្រៅ)។ ត្រូវធានាថាអ្នកចូលរួមដឹងពីរឿងនេះជាមុន។ ប្រសិនបើមានបញ្ហាធ្ងន់ធ្ងរកើតឡើង ត្រូវរាយការណ៍តាមគោលការណ៍ និងនីតិវិធីដែលបានកំណត់ សូម្បីតែត្រូវផ្អាកឬបញ្ឈប់ការស្រាវជ្រាវក៏ដោយ។

<u>ចំណុចគួរពិចារណា</u>៖ ឧបមាថាកុមារម្នាក់បានបង្ហាញក្នុងអំឡុងពេលសម្ភាស៍ថា ពួកគេកំពុងត្រូវបានដាក់ទណ្ឌកម្មរាងកាយនៅសាលាជាមួយរំពាត់។

- គរុនិស្សិតត្រូវតែអនុវត្តតាមគោលនយោបាយការពារកុមាររបស់សាលា៖ រាយការណ៍ករណីនេះទៅកាន់នាយកសាលា ឬ CPFP ដើម្បីធានាសុវត្ថិភាពរបស់កុមារ ហើយបញ្ឈប់ការសួរបន្ថែមទៀតអំពីបញ្ហានេះ។

សមធម៌ បរិយាបន្ន និងការមិនរើសអើង

- ការស្រាវជ្រាវគួររួមបញ្ចូលកុមារមកពីមជ្ឈដ្ឋានចម្រុះ (យេនឌ័រ ជាតិពន្ធុ ស្ថានភាពសេដ្ឋកិច្ច-សង្គម សមត្ថភាពកាយសម្បទា) ប្រកបដោយសមធម៌។ សិស្សានុសិស្សដែលងាយរងគ្រោះ ឬស្ថិតក្នុងក្រុមផ្ទាត់ចេញពីសង្គម មិនត្រូវទុកចោលឡើយ ហើយការជ្រើសរើសអ្នកចូលរួមមិនគួរផ្តល់អាទិភាពដល់អ្នកដែលងាយស្រួលទាក់ទងជាងនោះទេ (Attrash-Najjar & Friedman-Hauser, 2025)។
- ប្រើប្រាស់យុទ្ធសាស្ត្រជ្រើសរើសសំណាកគំរូដែលផ្តល់ឱកាសគ្រប់គ្នា រៀបចំឯកសារនិងសម្ភារៈឱ្យងាយយល់និងងាយប្រើប្រាស់ (ភាសា កម្រិតអក្ខរកម្ម) ត្រូវគោរពតាមតម្រូវការពិសេសសម្រាប់កុមារពិការភាព ឬក្រុមជនជាតិភាគតិច ធានាថាសំឡេងរបស់ពួកគេត្រូវបានឮ រួមទាំងរក្សាភាពសម្ងាត់ និងការគោរព។

<u>ចំណុចគួរពិចារណា</u>៖ នៅក្នុងសាលាដែលមានសិស្សពីក្រុមជនជាតិច្រើន រួមមានខ្មែរ និងជនជាតិដើមភាគតិច (ឧ. ពីក្រុមជនជាតិភាគតិចនៅខេត្តរតនគិរី) អ្នកស្រាវជ្រាវគួរផ្តល់ទម្រង់ការយល់ព្រមដែលបានបកប្រែ ឬត្រូវរកអ្នកបកប្រែ បើចាំបាច់ ដើម្បីធានាថាសិស្សទាំងអស់យល់ និងអាចសម្រេចចិត្តថាតើចូលរួមឬទេ។

២.៤.៣. ការទទួលខុសត្រូវចំពោះក្រមសីលធម៌សម្រាប់គ្រូឧទ្ទេស គរុនិស្សិត និងគ្រូបង្រៀន

ដោយសារតួនាទីរបស់គ្រូឧទ្ទេស គរុនិស្សិត និងគ្រូបង្រៀនមានភាពខុសៗគ្នារវាងអំណាច ការទំនួលខុសត្រូវ និងទំនាក់ទំនងវិជ្ជាជីវៈ ដូចនេះក្រុមនីមួយៗមានការទទួលខុសត្រូវចំពោះក្រមសីលធម៌ជាពិសេសនៅពេលអនុវត្តការស្រាវជ្រាវប្រតិបត្តិសម្រាប់អហិង្សា៖

- គ្រូឧទ្ទេស (នៅសាលាគរុកោសល្យ)៖ ត្រូវធានាថាសំណើការស្រាវជ្រាវរបស់គរុនិស្សិតគោរពតាមស្តង់ដាក្រមសីលធម៌ ពិនិត្យពីនីតិវិធីការយល់ព្រម និងការការពារទិន្នន័យ ចង្អុលបង្ហាញគរុនិស្សិតអំពីការការពារកុមារ និងការយល់ដឹងពីភាពផ្សេងគ្នានៃវប្បធម៌ ដើម្បីធានាថាការចុះអនុវត្តកម្មសិក្សាគរុកោសល្យ នៅតាមសាលា បានរៀបចំជាស្រេច គោរពគោលនយោបាយសាលា និងគាំទ្រការតាមដាន និងការឆ្លុះបញ្ចាំង មិនគ្រាន់តែការប្រមូលទិន្នន័យប៉ុណ្ណោះទេ។
- គរុនិស្សិត៖ ជាអ្នកប្រកបមុខរបរវិជ្ជាជីវៈគ្រាដំបូង ត្រូវតែប្រុងប្រយ័ត្នជាពិសេសអំពីការយល់ព្រម ការរក្សាការសម្ងាត់ ការការពារ ការចូលរួមដោយស្ម័គ្រចិត្ត និងត្រូវដឹងពីតួនាទីរបស់ខ្លួន គឺជាគ្រូបង្រៀនផង និងជាអ្នកស្រាវជ្រាវផង ដែលចំណុចនេះអាចធ្វើឱ្យមានការកន្ត្រេចឡំលើព្រំដែនតួនាទីនៅក្នុងកែវភ្នែករបស់សិស្ស។ ពួកគេគួរចៀសវាងការប្រើអំណាចតួនាទីក្នុងការជំរុញឱ្យមានការចូលរួម ហើយត្រូវស្វែងរកគោលការណ៍ណែនាំនៅពេលដែលកើតមានបញ្ហាមិនល្អដល់សិស្ស(ឧ. នៅពេលដែលក្មេងបង្ហាញអំពីបទពិសោធនៃរំលោភបំពាន)។
- គ្រូបង្រៀន (ដែលអាចធ្វើជាអ្នកស្រាវជ្រាវប្រតិបត្តិផងដែរ)៖ គួររក្សាព្រំដែនវិជ្ជាជីវៈ ចៀសវាងការបង្ខំ ឬដាក់សម្ពាធលើសិស្ស ធ្វើឱ្យមានតម្លាភាពអំពីតួនាទីទាំងពីររបស់ខ្លួន ធានាថាការប្រមូលទិន្នន័យ (ការសង្កេត សម្ភាស៍) មិនរាំងស្ទះដល់ទំនួលខុសត្រូវក្នុងការបង្រៀន ឬការរៀនសូត្ររបស់សិស្ស ហើយ ប្រកាន់ខ្ជាប់កាតព្វកិច្ចការពារកុមារឱ្យខ្ពស់ជាងគោលដៅស្រាវជ្រាវ។

លើសពីនេះទៅទៀត អ្នកទាំងអស់គ្នាត្រូវប្តេជ្ញាចិត្តលើការអនុវត្តការឆ្លុះបញ្ចាំង និងការពិនិត្យវាយតម្លៃពីក្រមសីលធម៌ផ្ទាល់ខ្លួនយ៉ាងល្អិតល្អន់ជាបន្តបន្ទាប់៖ ធ្វើការវាយតម្លៃឡើងវិញជាបន្តបន្ទាប់ថា តើការស្រាវជ្រាវនៅតែស្ថិតក្នុងផលប្រយោជន៍បំផុតរបស់អ្នកចូលរួមដែរឬទេ តើអាចមានគ្រោះថ្នាក់កើតឡើងឬទេ និងតើត្រូវការការផ្លាស់ប្តូរឬទេ។

ពេលណាដែលត្រូវស្វែងរកការត្រួតពិនិត្យក្រមសីលធម៌

ទោះបីជាគម្រោងស្រាវជ្រាវប្រតិបត្តិជាច្រើនដែលដឹកនាំដោយគ្រូបង្រៀន ឬអ្នកអនុវត្តផ្ទាល់ភាគច្រើនអាចត្រូវបានចាត់ទុកថាជា "ការកែលម្អថ្នាក់រៀន" ក៏ដោយ តែប្រសិនបើការស្រាវជ្រាវដោះស្រាយបញ្ហារសើប (អំពី

ហិង្សា ការពារកុមារ) ពាក់ព័ន្ធនឹងអនីតិជន ឬប្រមូលទិន្នន័យដែលអាចកំណត់អត្តសញ្ញាណបាន (ជាពិសេសរូបថត វីដេអូ ឬឈ្មោះ) មិនត្រឹមតែជាការអនុវត្តដ៏ល្អនោះទេ ប៉ុន្តែជួនកាលវាក៏ជាតម្រូវការជាចាំបាច់ដើម្បីដាក់ស្នើគម្រោងសម្រាប់ការត្រួតពិនិត្យអំពីក្រមសីលធម៌ដោយស្ថាប័នពាក់ព័ន្ធ (ឧ. គណៈកម្មការក្រមសីលធម៌តាមស្ថាប័ន (IEC) អាជ្ញាធរសាលាក្នុងតំបន់(LSAs) ឬគណៈកម្មការការពារកុមារតាមសហគមន៍ (CCPCs)។ នៅក្នុងប្រទេសកម្ពុជា នៅពេលធ្វើការនៅសាលារដ្ឋ ឬជាមួយភាគីពាក់ព័ន្ធខាងក្រៅ គ្រូឧទ្ទេស ឬគរុនិស្សិតគួរស្វែងរកលិខិតអនុញ្ញាត (ឬយ៉ាងហោចណាស់ការអនុញ្ញាតក្រៅផ្លូវការ) ពីថ្នាក់ដឹកនាំសាលា ហើយប្រសិនបើអាចធ្វើទៅបាន ត្រូវប្រតិបត្តិតាមគោលនយោបាយគាំពារកុមារថ្នាក់ជាតិ ដើម្បីធានាថាការស្រាវជ្រាវប្រតិបត្តិមិនផ្ទុយនឹងគោលការណ៍ណែនាំរបស់សាលា ឬរដ្ឋាភិបាលឡើយ។

ការស្រាវជ្រាវប្រតិបត្តិស្តីអំពីអហិង្សាមានសក្តានុពលយ៉ាងខ្លាំងក្នុងការប្រែក្លាយថ្នាក់រៀននៅកម្ពុជាឱ្យមានបរិយាកាសរៀនសូត្រប្រកបដោយសុខសុវត្ថិភាព ការគោរពគ្នា និងផ្តោតលើកុមារ។ ប៉ុន្តែប្រសិនបើគ្មានការអនុវត្តក្រមសីលធម៌ដោយប្រុងប្រយ័ត្ននោះទេ ការស្រាវជ្រាវនេះនឹងអាចបង្កជាហានិភ័យ និងផលប៉ះពាល់វិញ ដូចជា ធ្វើឱ្យសិស្សប៉ះទង្គិចផ្លូវចិត្តជាថ្មី ការរំលោភលើឯកជនភាព ការពង្រឹងតុល្យភាពអំណាចមិនស្មើគ្នា ឬការបង្កឱ្យមានផលវិបាកអវិជ្ជមានដែលមិនបានព្រាងទុក។ តាមរយៈការផ្អែកលើការស្រាវជ្រាវប្រតិបត្តិ ទៅលើគោលការណ៍នៃ **ការគោរព អត្ថប្រយោជន៍ យុត្តិធម៌ ការរក្សាការសម្ងាត់ ការការពារសុវត្ថិភាព ការយល់ដឹងវប្បធម៌ និងសុចរិតភាព** — ព្រមទាំងការបញ្ចូលនូវនីតិវិធីអនុវត្តជាក់ស្តែងសម្រាប់ការយល់ព្រមចូលរួម ការការពារទិន្នន័យ ការចូលរួមដោយស្ម័គ្រចិត្ត និងការរាយការណ៍។ គ្រូឧទ្ទេស គរុនិស្សិត និងគ្រូបង្រៀនក្នុងថ្នាក់ អាចប្រឹងប្រែងធ្វើឱ្យមានការផ្លាស់ប្តូរដ៏ធំ ស្របពេលនឹងការការពារសេចក្តីថ្លៃថ្នូរ និងសិទ្ធិរបស់អ្នកចូលរួមទាំងអស់ផងដែរ។ កាតព្វកិច្ចក្នុងការអនុវត្តក្រមសីលធម៌មិនមែនជាការដាក់សំពោធផ្លូវចិត្តនោះទេ ប៉ុន្តែជាមូលដ្ឋានគ្រឹះដ៏រឹងមាំមួយ៖ វាធានាថា ការផ្លាស់ប្តូរទៅកាន់ការអប់រំដោយគ្មានអំពើហិង្សា និងការប្រើប្រាស់វិន័យបែបវិជ្ជមាន ត្រូវបានអនុវត្តដោយមានការយកចិត្តទុកដាក់ ការគោរព និងប្រកបដោយវិជ្ជាជីវៈ។ អ្នកស្រាវជ្រាវគួរតែធ្វើជាគំរូ និងអនុវត្តជាក់ស្តែងនូវគោលការណ៍សីលធម៌ និងអាកប្បកិរិយាវិជ្ជមាន ដែលការសិក្សារបស់ពួកគេចង់លើកស្ទួយ ឬស្រាវជ្រាវ ដែលជាគំរូដ៏មានតម្លៃដែលការស្រាវជ្រាវនេះចង់លើកកម្ពស់។

៣. ដំណើរការស្រាវជ្រាវប្រតិបត្តិ

៣.១. វដ្តនៃការស្រាវជ្រាវប្រតិបត្តិរបស់ លេវីន (Lewin's Action Research Cycle)

ដើម្បីធ្វើការស្រាវជ្រាវប្រតិបត្តិប្រកបដោយប្រសិទ្ធភាព គ្រូបង្រៀន និងគរុនិស្សិតត្រូវការដំណើរការនៃការស្រាវជ្រាវមួយដែលមានលក្ខណៈច្បាស់លាស់ ដើម្បីយកទៅអនុវត្តតាមបាន។ Lewin (1946)ជាបុគ្គលដែលគេទទួលស្គាល់ជាទូទៅថាជា បិតានៃការស្រាវជ្រាវប្រតិបត្តិ បង្កើតនូវគំរូវដ្តនៃការស្រាវជ្រាវប្រតិបត្តិមួយ ហើយវាបានក្លាយជាមូលដ្ឋានគ្រឹះនៅក្នុងវិស័យស្រាវជ្រាវ។ នៅក្នុងក្របខ័ណ្ឌ របស់ លោកលេវីន (Lewin) ការស្រាវជ្រាវប្រតិបត្តិបែងចែកចេញជាបីដំណាក់កាលគឺ៖ការរៀបចំផែនការការ ធ្វើសកម្មភាព និងការស្វែងរកការពិត (ការវាយតម្លៃ)។ ក្របខ័ណ្ឌនេះអាចផ្តល់នូវវិធីសាស្ត្រដ៏ច្បាស់លាស់មួយដើម្បីកំណត់បញ្ហា សាកល្បងដោះស្រាយបញ្ហា និងឆ្លុះបញ្ចាំងពីលទ្ធផល។ នៅក្នុងផ្នែកខាងក្រោមនេះ នឹងពន្យល់លម្អិតអំពីវដ្តនៃស្រាវជ្រាវប្រតិបត្តិរបស់លេវីន និងបង្ហាញអំពីវិធីដែលគ្រូឧទ្ទេស និងគរុនិស្សិតអាចយកទៅអនុវត្តបាននៅក្នុងថ្នាក់រៀនរបស់ពួកគេ។

លោក Lewin បានបង្កើតការស្រាវជ្រាវប្រតិបត្តិនៅក្នុងអំឡុងទសវត្សឆ្នាំ១៩៤០ ដើម្បីដោះស្រាយបញ្ហាចម្បងៗរបស់សង្គម និងសហគមន៍។ គាត់បានបង្កើតវដ្តនៃការស្រាវជ្រាវប្រតិបត្តិដែលមានដំណាក់កាលចំនួនបីគឺ*ការរៀបចំផែនការ ការធ្វើសកម្មភាព និងការស្វែងរកការពិត* ។ អ្នកស្រាវជ្រាវអាចអនុវត្តលើសពីមួយវដ្តនៃការស្រាវជ្រាវប្រតិបត្តិនេះក្នុងករណីចាំបាច់ដើម្បីដោះស្រាយបញ្ហា និងបង្កើតចំណេះដឹងថ្មី (Lewin, 1940)។ ទោះបីជាគំរូការស្រាវជ្រាវនេះត្រូវបានគេអនុវត្តដំបូងបង្អស់គឺដើម្បីតែដោះស្រាយបញ្ហាសង្គមក៏ដោយ ប៉ុន្តែក្រោយមកគំរូនេះត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយក្នុងវិស័យអប់រំផងដែរ (Burns, 2010; Mertler, 2019). ។

វដ្តនេះមានបីដំណាក់ដែលមានអន្តរទំនាក់ទំនងនឹងគ្នា

1. *ការរៀបចំផែនការ*
2. *ការធ្វើសកម្មភាព*
3. *ការស្វែងរកការពិត*

៣.១.១. ការរៀបចំផែនការ

ដំណាក់កាលរៀបចំផែនការ គឺជាគ្រឹះនៃការស្រាវជ្រាវប្រតិបត្តិ។ ជាទូទៅគ្រូបង្រៀនចាប់ផ្តើមការស្រាវជ្រាវដោយការកំណត់បញ្ហា ឬក្តីបារម្ភរបស់ខ្លួននៅក្នុងថ្នាក់រៀន។ ឧទាហរណ៍នៃបញ្ហាទាំងនោះមានដូចជា ការមិនសូវចូលរួមរៀនរបស់សិស្ស ភាពលំបាកក្នុងការយល់ខ្លឹមសារមេរៀន ឥរិយាបថមិនសមរម្យរបស់សិស្ស ឬបញ្ហាទាក់ទងនឹងការប្រើប្រាស់សម្ភារៈឧបទេសជាដើម។

សកម្មភាពសំខាន់ៗក្នុងដំណាក់កាលរៀបចំផែនការ៖

- **ការកំណត់បញ្ហា**៖ ត្រូវកំណត់ឱ្យបានច្បាស់ពីបញ្ហាអ្វីមួយដែលចាំបាច់ត្រូវដោះស្រាយ។

- **ការប្រមូលទិន្នន័យ**៖ ការប្រមូលទិន្នន័យសង្កេតបឋម (initial observation) មតិត្រឡប់របស់សិស្ស ឬកំណត់ត្រាការសិក្សារបស់សិស្សដើម្បីស្វែងយល់ឱ្យបានច្បាស់លាស់ពីស្ថានភាព។
- **ការកំណត់គោលដៅ**៖ កំណត់អ្វីដែលគ្រូបង្រៀនសង្ឃឹមថានឹងអាចសម្រេចបាន (ឧ. បង្កើនការចូលរួមរបស់សិស្សក្នុងការងារក្រុម)។
- **រៀបចំការពិសោធ** (designing an intervention)៖ ការរៀបចំយុទ្ធសាស្ត្រ ឬការផ្លាស់អ្វីមួយ ដើម្បីយកទៅសាកល្បងដោះស្រាយបញ្ហានៅក្នុងថ្នាក់រៀន ដូចជាការរៀនបែបសហការ និងជំនួយផ្នែកមើលជាដើម (Visual aid)។

ការរៀបចំផែនការដែលមានប្រសិទ្ធភាព តម្រូវឱ្យមានការឆ្លុះបញ្ចាំងទាំងលើសកម្មភាពរបស់គ្រូ និងតម្រូវការរបស់សិស្ស។ យោងតាម McNiff និង Whitehead (2011) ការរៀបចំផែនការត្រូវធ្វើឡើងដោយប្រុងប្រយ័ត្ន និងធានាបានថាការស្រាវជ្រាវមានគោលបំណងច្បាស់លាស់ អាចអនុវត្តបាន និងពាក់ព័ន្ធជាមួយបរិបទអប់រំ ឬស្ថានភាពជាក់ស្តែង។

៣.១.២. ការធ្វើសកម្មភាព

ដំណាក់កាលទីពីរគឺជាការអនុវត្តផែនការពិសោធន៍ដែលបានគ្រោងទុកនៅក្នុងដំណាក់កាលការរៀបចំផែនការ។ គ្រូបង្រៀនយកយុទ្ធសាស្ត្ររបស់ពួកគេទៅអនុវត្តនៅក្នុងថ្នាក់រៀនជាក់ស្តែង។

ឧទាហរណ៍នៃសកម្មភាពពិសោធនៅក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនមានដូចជា៖

- ការអនុវត្តយុទ្ធសាស្ត្របង្រៀនថ្មី(ឧ៖ ការបង្រៀនគ្នាទៅវិញទៅមក (peer teaching) ការធ្វើផែនការជាក្រុម(group projects)
- ការកែប្រែវិធីសាស្ត្រគ្រប់គ្រងថ្នាក់រៀន
- ការប្រើប្រាស់ធនធានបង្រៀនថ្មី ដូចជាឧបករណ៍ឌីជីថល ឬសម្ភារៈជំនួយផ្នែកសិក្សាផ្សេងៗ។

ក្នុងដំណាក់កាលនេះ គ្រូបង្រៀនមិនត្រឹមតែដើរតួជាអ្នកបង្រៀនប៉ុណ្ណោះទេ ថែមទាំងធ្វើជាអ្នកស្រាវជ្រាវផងដែរ។ ពួកគេត្រូវសង្កេតមើលពីការឆ្លើយតប ឬប្រតិកម្មរបស់សិស្សចំពោះការពិសោធ ហើយនិងធ្វើការកែតម្រូវប្រសិនបើចាំបាច់។ Burns (2010) បានពន្យល់ដោយសង្កត់ធ្ងន់ថា សកម្មភាពនៅក្នុងការស្រាវជ្រាវគឺមិនមែនជាដំណើរការដែលរឹងធ្ពឹងមិនអាចបត់បែនបាននោះទេ តែជាដំណើរការបត់បែននិងកែប្រែបាន ដោយគ្រូបង្រៀនត្រូវតែប្តូរវិធីសាស្ត្ររបស់ពួកគេទៅតាមការប្រែប្រួលជាក់ស្តែងរបស់ថ្នាក់រៀន (classroom dynamics)។

៣.១.៣. ការស្វែងរកការពិត(ការវាយតម្លៃ)

បន្ទាប់ពីអនុវត្តសកម្មភាពពិសោធ គ្រូបង្រៀនត្រូវវាយតម្លៃផលនៃឥទ្ធិពលរបស់ការពិសោធនោះ។ ក្នុងដំណាក់កាលនេះរួមមានការប្រមូល និងវិភាគទិន្នន័យ ដើម្បីកំណត់ថាតើវិធីសាស្ត្រដែលបានប្រើក្នុងការពិសោធនោះបានសម្រេចនូវលទ្ធផលដែលបានគ្រោងទុកដែរឬអត់។

សកម្មភាពវាយតម្លៃទូទៅរួមមាន៖

- ការប្រមូលការងាររបស់សិស្ស
- ការសង្កេតពីការផ្លាស់ប្តូរឥរិយាបថ ឬការចូលរួម
- ការធ្វើការសួងមតិខ្លីៗ ឬសម្ភាសជាមួយសិស្ស
- ការឆ្លុះបញ្ចាំងតាមរយៈ ការឆ្លុះបញ្ចាំងរបស់គ្រូ (teacher Journal) ឬកំណត់ត្រាផ្សេងៗ។

ដំណាក់កាលស្វែងរកការពិតមានសារៈសំខាន់ខ្លាំងណាស់ក្នុងការកំណត់ថាអ្វីមានប្រសិទ្ធភាពនិងអ្វីមិនមានប្រសិទ្ធិភាព ហើយនិងអ្វីដែលអាចត្រូវកែសម្រួលនៅក្នុងវដ្តបន្ទាប់។ លោក Lewin (1946) បានសង្កត់ធ្ងន់ថាការវាយតម្លៃគួរតែមានលក្ខណៈជាប្រព័ន្ធ និងផ្អែកលើភស្តុតាងជាក់ស្តែង។ សម្រាប់គរុនិស្សិត ដំណាក់កាលនេះក៏ជួយអភិវឌ្ឍនូវជំនាញក្នុងការឆ្លុះបញ្ចាំង និងគិតស៊ីជម្រៅ (critical thinking) ផងដែរ។

ការអនុវត្តគំរូរបស់លេវីន នៅក្នុងការបណ្តុះបណ្តាលគ្រូ

សម្រាប់គ្រូឧទ្ទេស និងគរុនិស្សិត វដ្តរបស់លេវីន បានផ្តល់នូវគំរូសម្រាប់អនុវត្តដ៏ជាក់ស្តែងមួយ ដែលអាចផ្សារភ្ជាប់ទ្រឹស្តីជាមួយការអនុវត្ត។

- សម្រាប់គរុនិស្សិត៖ គំរូនេះផ្តល់នូវដំណើរការដែលអាចគ្រប់គ្រងបាន (manageable) ដើម្បីស្វែងយល់ពីបញ្ហាប្រឈមនានានៅក្នុងថ្នាក់រៀន ក្នុងអំឡុងពេលចុះកម្មសិក្សា ឬបទពិសោធន៍បង្រៀនដំបូង។
- សម្រាប់គ្រូឧទ្ទេស៖ គំរូនេះដើរតួជាឧបករណ៍គរុកោសល្យសម្រាប់បណ្តុះបណ្តាលគរុនិស្សិតតាមបែបវិធីសាស្ត្ររុករក (inquiry-based approaches) ដែលជំរុញឱ្យមានការឆ្លុះបញ្ចាំងអំពីការបង្រៀន និងការបង្រៀនផ្អែកលើភស្តុតាងជាក់ស្តែង។

ឧទាហរណ៍៖

- ការរៀបចំផែនការ៖ គរុនិស្សិតបានសង្កេតឃើញថាការចូលរួមរបស់សិស្សថ្នាក់ទី៦នៅមានកម្រិតទាប។ គរុនិស្សិតបានរៀបចំផែនការអនុវត្តការរៀនអានជាក្រុម។
- ការធ្វើសកម្មភាព៖ គរុនិស្សិតបានអនុវត្តការរៀនអានជាក្រុមចំនួនពីរដងក្នុងមួយសប្តាហ៍ដោយចាត់តាំងតួនាទីដល់សិស្ស។

- ការស្វែងរកការពិត៖ គរុនិស្សិតបានកត់ត្រាកម្រិតការចូលរួមរបស់សិស្ស និងសម្ភាសន៍សិស្សអំពីបទពិសោធរបស់ពួកគេក្នុងការរៀនអានជាក្រុម។ លទ្ធផលបង្ហាញថាមានការកែប្រែនៃការចូលរួមរបស់សិស្ស ប៉ុន្តែសិស្សមួយចំនួនមានការលំបាកនៅពេលដែលពួកគេត្រូវបានចាត់តាំងឱ្យមានតួនាទីនៅក្នុងការពិភាក្សាក្រុម។ បញ្ហាប្រឈមរបស់សិស្សពេលនេះ បានបង្ហាញថាការស្រាវជ្រាវនេះត្រូវបន្តទៅមួយវដ្តទៀត។

ជំណើរការនេះមានលក្ខណៈសមញ្ញ ប៉ុន្តែការធ្វើឡើងវិញម្តងហើយម្តងទៀតអាចធ្វើឱ្យមានការសិក្សាវិជ្ជាជីវៈ និងការកែលម្អថ្នាក់រៀនជាប្រចាំ។

ហេតុអ្វីយើងគួរប្រើវដ្តរបស់លេវីន (Lewin)?

- គំរូនេះបានផ្តល់ចំណុចចាប់ផ្តើមដ៏ច្បាស់លាស់ និងមានរចនាសម្ព័ន្ធសម្រាប់អ្នកដែលធ្វើការស្រាវជ្រាវដំបូង។
- ជំរុញឱ្យមានការឆ្លុះបញ្ចាំងដែលមានលក្ខណៈជាប្រព័ន្ធ និងផ្អែកលើទិន្នន័យជាក់ស្តែង។
- មានភាពបត់បែន និងអាចកែសម្រួលបានតាមជំនាញ និងបរិបទផ្សេងៗ។

អ្វីដែលត្រូវត្រិះរិះពិចារណានៅពេលប្រើវដ្តរបស់លេវីន (Lewin)?

- អ្នករិះគន់មួយចំនួនបានរិះគន់ថា គំរូនេះមានលក្ខណៈត្រង់ៗ (linear) និងសាមញ្ញពេក បើប្រៀបធៀបនឹងភាពស្មុគស្មាញជាក់ស្តែងនៃថ្នាក់រៀន (Kemmis & McTaggart, 1988)។
- មានគំរូក្រោយៗមកទៀត មានដូចជាគំរូវង្វិលជុំរបស់ Kemmis និង McTaggart's spiral បានពង្រីកពីគំរូរបស់លេវីន ដើម្បីបញ្ចូលវិធីសាស្ត្រដែលអាចធ្វើឡើងវិញបាន និងមានលក្ខណៈផ្អែកចូលរួមច្រើន។
- ទោះយ៉ាងណា វដ្តរបស់លេវីននៅតែជាចំណុចចាប់ផ្តើមដ៏មានតម្លៃសម្រាប់គ្រូឧទ្ទេស និងគរុនិស្សិត ដែលកំពុងធ្វើការស្រាវជ្រាវប្រតិបត្តិលើកដំបូង។

វដ្តនៃការស្រាវជ្រាវប្រតិបត្តិរបស់ Lewin (1946) ផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់គ្រូឧទ្ទេស និងគរុនិស្សិត។ ដំណាក់កាលទាំងបីរបស់លេវីនមានដូចជា *ការរៀបចំផែនការ ការធ្វើសកម្មភាព និងការស្វែងរកការពិត* បានបង្ហាញផ្លូវសម្រាប់អ្នកស្រាវជ្រាវក្នុងការកំណត់បញ្ហាប្រឈមក្នុងថ្នាក់រៀន អនុវត្តការពិសោធ និងវាយតម្លៃប្រសិទ្ធភាពរបស់វា។ ខណៈដែលគំរូក្រោយៗបានកែប្រែដោយប្រើគំរូរបស់លេវីន គំរូរបស់គាត់នៅតែបន្តដើរតួជាឧបករណ៍ចាំបាច់សម្រាប់ការកសាងការបង្រៀនដែលមានការឆ្លុះបញ្ចាំង និងការបង្រៀនបែករិះរកដែលអាចលើកកម្ពស់ទាំងការអភិវឌ្ឍគ្រូបង្រៀន និងការរៀនសូត្ររបស់សិស្ស។

៣.២. គំរូការស្រាវជ្រាវប្រតិបត្តិរបស់លោក Kemmis និង McTaggart

ខណៈពេលដែលវដ្តនៃការស្រាវជ្រាវប្រតិបត្តិបីដំណាក់កាលរបស់ លោក លេវីន (1946) បានបង្កើតជាគ្រឹះសម្រាប់ការស្រាវជ្រាវប្រតិបត្តិ អ្នកស្រាវជ្រាវក្រោយៗបានកែសម្រួលគំរូនេះ ដើម្បីឆ្លុះបញ្ចាំងពីភាពស្មុគស្មាញក្នុងបរិបទអប់រំឱ្យកាន់តែប្រសើរឡើង។ ក្នុងចំណោមការកែសម្រួលទាំងនេះ គំរូនៃការស្រាវជ្រាវដែលបង្កើតឡើងដោយKemmis និង McTaggart (1988; 2014) បានក្លាយជាគំរូដ៏មានឥទ្ធិពលមួយក្នុងវិស័យអប់រំ។ គំរូនេះបានសង្កត់ធ្ងន់លើភាពរង្វិលជុំ និងភាពច្រំដែលនៃការស្រាវជ្រាវប្រតិបត្តិដោយនៅក្នុងជំហាននីមួយៗជួយធ្វើឱ្យជំហានបន្តបន្ទាប់ទៀតកាន់តែច្បាស់លាស់ និងធ្វើឱ្យគ្រូបង្រៀនឧទ្ទេសអាចកែលម្អការការបង្រៀនរបស់ពួកគេជាប្រចាំ។ នៅផ្នែកខាងក្រោមនេះយើងពន្យល់ពីគំរូរង្វិលជុំរបស់ លោក Kemmis និង McTaggart (1988; 2014) ឱ្យបានលម្អិត និងបង្ហាញពីវិធីដែលគ្រូឧទ្ទេស និងគរុនិស្សិតអាចអនុវត្តបាននៅក្នុងថ្នាក់រៀនជាក់ស្តែង។

៣.២.១. ទិដ្ឋភាពទូទៅនៃគំរូរង្វិលជុំ

លោក Kemmis និង McTaggart (1988) បានពង្រីកវដ្តរបស់លេវីន ទៅជាលក្ខណៈរង្វិលជុំដែលអាចប្រែ ប្រួលបាន និងវិលទៅវិលមកបាន។ ដំណាក់កាលនៃគំរូនេះមានដូចខាងក្រោម៖

១. ការរៀបចំផែនការ

២. ការអនុវត្ត

៣. ការសង្កេត

៤. ការឆ្លុះបញ្ចាំង



គំរូរង្វិលជុំ (Kemmis & McTaggart, 1982, p. 8)

រូបភាពខាងលើបង្ហាញឱ្យឃើញថា ការស្រាវជ្រាវប្រតិបត្តិមិនមែនចប់នៅត្រឹមតែមួយវដ្តនោះទេ ប៉ុន្តែផ្ទុយទៅវិញ គឺវាឆ្លុះបញ្ចាំងលើវដ្តមួយ ហើយបញ្ជូនចំណេះដឹងពីវដ្តនោះទៅវដ្តបន្ទាប់ទៀតដោយបង្កើតជាដំណើរការនៃការកែលម្អជាបន្តបន្ទាប់ (Kemmis, McTaggart, & Nixon, 2014)។

៣.២.២. សេចក្តីពន្យល់លម្អិតពីជំហាននីមួយ

ការរៀបចំផែនការ

ការរៀបចំផែនការគឺជាចំណុចចាប់ផ្តើមនៃរង្វិលជុំ។ នៅដំណាក់កាលនេះ គ្រូបង្រៀនកំណត់បញ្ហា ឬចំណុចណាមួយដែលគួរឱ្យព្រួយបារម្ភនៅក្នុងថ្នាក់រៀន និងអភិវឌ្ឍផែនការសកម្មភាពដើម្បីដោះស្រាយវា។

ការរៀបចំផែនការត្រូវធ្វើឡើងដោយការសង្កេតបឋម បទពិសោធន៍ជ្ជាជីវៈ និងការស្វែងយល់តាមរយៈការលើកទ្រឹស្តីដែលអាចធ្វើទៅបាន។

កិច្ចការសំខាន់ៗរួមមាន៖

- ការកំណត់ពីចំណុចដែលចង់ស្រាវជ្រាវជាក់លាក់ (ឧទាហរណ៍៖ ការជំរុញទឹកចិត្តសិស្ស ការចូលរួមការងារក្រុម ការអានយល់ន័យ)។
- ការអានទ្រឹស្តី ឬការសិក្សាស្រាវជ្រាវផ្សេងៗដែលពាក់ព័ន្ធនឹងចំណុចដែលចង់ស្រាវជ្រាវ។
- រៀបចំវិធីសាស្ត្រពិសោធដែលជាក់ស្តែង និងអាចសម្រេចបានក្នុងបរិបទរបស់គ្រូបង្រៀន។
- ការបង្កើតលក្ខខណ្ឌវិនិច្ឆ័យ និងឧបករណ៍សម្រាប់វាយតម្លៃលទ្ធផលនៃការពិសោធ។

ចំពោះគរុនិស្សិត ដំណាក់កាលរៀបចំផែនការអាចនឹងតម្រូវឱ្យមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយគ្រូណែនាំ(mentor) ឬគ្រូដឹកនាំស្រាវជ្រាវ(supervisor)ដើម្បីធានាឱ្យបានថាវិធីសាស្ត្រពិសោធដែលបានគ្រោងនឹងធ្វើឡើងនោះមានភាពត្រឹមត្រូវតាមគោលការណ៍គរុកោសល្យ និងសមរម្យតាមក្រមសីលធម៌ (Burns, 2010)។

ការអនុវត្ត

នៅក្នុងដំណាក់កាលអនុវត្តនេះ គ្រូបង្រៀនត្រូវអនុវត្តផែនការពិសោធដែលបានគ្រោងទុក។ ការពិសោធនេះមានដូចជាការប្រើប្រាស់យុទ្ធសាស្ត្របង្រៀនថ្មីៗ ការកែលម្អរចនាសម្ព័ន្ធថ្នាក់រៀន ឬការពិសោធលើការប្រើប្រាស់សម្ភារៈឧបទេសជាដើម។

ឧទាហរណ៍

- ការប្រើប្រាស់វិធីសាស្ត្ររៀនបែបសហការ ដើម្បីបង្កើនការចូលរួមកិច្ចការក្រុម។
- ការបញ្ចូលសកម្មភាពបច្ចេកវិទ្យា ដើម្បីង្កើនការចូលរួមរបស់សិស្ស។
- ការកែលម្អទម្លាប់ថ្នាក់រៀន ដើម្បីកាត់បន្ថយឥរិយាបថរំខាន។

Kemmis និង McTaggart (1988) បានសង្កត់ធ្ងន់ថាការអនុវត្តដែលគួរតែមានលក្ខណៈគ្រោងទុកជាមុន និមានលក្ខណៈជាប្រព័ន្ធ ដែលអាចឱ្យគ្រូបង្រៀនសាកល្បងប្រើប្រាស់យុទ្ធសាស្ត្រជាក់លាក់ក្នុងទម្រង់ដែលអាចគ្រប់គ្រងបាន។ សំខាន់ជាងនេះទៀត ដំណាក់កាលអនុវត្តមិនមែនជាជំហានចុងក្រោយនោះទេ ពោលគឺជាជំហានមួយនៅក្នុងវដ្តដែលគេរំពឹងថានឹងមានការកែប្រែបន្តបន្ទាប់បន្ថែមទៀត។

ការសង្កេត

ការសង្កេតគឺពាក់ព័ន្ធទៅនឹង ការប្រមូលទិន្នន័យជាលក្ខណៈប្រព័ន្ធ អំពីការអនុវត្តសកម្មភាពនិងឥទ្ធិពលរបស់វាលើសិស្ស។ នៅក្នុងជំហាននេះ វាអាចផ្តល់នូវភស្តុតាង ដើម្បីកំណត់ថាតើវិធីសាស្ត្រដែលប្រើក្នុងការពិសោធនោះមានប្រសិទ្ធភាពឬអត់។

វិធីសាស្ត្រប្រមូលទិន្នន័យរួមមាន៖

- កម្រងបញ្ជីសង្កេតថ្នាក់រៀន។
- កំណត់ហេតុប្រចាំរបស់គ្រូបង្រៀន (Teacher Journal or field notes)
- គំរូកិច្ចការរបស់សិស្ស។
- ការថតសម្លេង/វីដេអូ។
- សម្ភាសន៍ ឬកម្រងសំណួរ។

ការសង្កេតត្រូវតែមានគោលបំណងច្បាស់លាស់ និងពាក់ព័ន្ធទៅនឹងសំណួរស្រាវជ្រាវ។ ឧទាហរណ៍៖ ប្រសិនបើគោលបំណងរបស់យើង គឺដើម្បីកែលម្អការចូលរួមរបស់សិស្ស គ្រូបង្រៀនអាចកត់ត្រាចំនួនសិស្សដែលចូលរួមក្នុងអំឡុងពេលពិភាក្សាក្រុម។ ការសង្កេតដោយប្រុងប្រយ័ត្ននឹងធានាថា ការឆ្លុះបញ្ចាំងក្រោយការសង្កេតគឺផ្អែកលើភស្តុតាងជាក់ស្តែង ជាជាងការធ្វើការសន្និដ្ឋានចេញពីការសន្មត (Mertler, 2019)។

ការឆ្លុះបញ្ចាំង

ពេលណាដែលត្រូវស្វែងរកការត្រួតពិនិត្យក្រមសីលធម៌

ការឆ្លុះបញ្ចាំងគឺជាដំណើរការវិភាគទិន្នន័យដែលប្រមូលបានក្នុងអំឡុងពេលសង្កេត និងពិចារណាថាតើវាមានន័យយ៉ាងដូចម្តេចសម្រាប់ការអនុវត្ត។ គ្រូបង្រៀនត្រូវពិនិត្យលទ្ធផលនៃការពិសោធនោះឱ្យបានស៊ីជម្រៅ៖ តើការពិសោធនោះបានសម្រេចលទ្ធផលដែលបានគ្រោងទុកដែរឬទេ? តើមានបញ្ហាប្រឈមអ្វីខ្លះទៀតដែលបានកើតឡើង? តើអ្វីខ្លះដែលអាចកែលម្អបាននៅក្នុងវគ្គបន្ទាប់?

ការឆ្លុះបញ្ចាំងអាចធ្វើឡើងបាន ជាបុគ្គល និងក្រុម។ គរុនិស្សិតអាចពិភាក្សាលើលទ្ធផលដែលរកឃើញជាមួយមិត្តភក្តិ ឬគ្រូណែនាំ ហើយគ្រូឧទ្ទេសដឹកនាំស្រាវជ្រាវអាចចូលរួមជាមួយដំណើរការនេះដើម្បីបង្កើតជាសមាគមវិជ្ជាជីវៈ។ ការឆ្លុះបញ្ចាំងគឺមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ ពីព្រោះវាអាចឱ្យគ្រូបង្រៀនផ្លាស់ប្តូរពីការយល់ឃើញតិចតួច ទៅរកការយល់ដឹងស៊ីជម្រៅអំពីសកម្មភាពបង្រៀនរបស់ពួកគេ (McNiff & Whitehead, 2011)។

៣.២.៣. ការកែលម្អជាបន្តបន្ទាប់

ខុសពីគំរូជំហានទាំងបីរបស់លេវីន គំរូរបស់ Kemmis and McTaggart បង្ហាញយ៉ាងច្បាស់លាស់ថា ដំណើរការនេះគឺ មានលក្ខណៈវិលជុំ និងបន្តឥតឈប់ឈរ (cyclical and ongoing)។ បន្ទាប់ពីការឆ្លុះបញ្ចាំងរួចរាល់ គ្រូបង្រៀនអាចត្រឡប់ទៅធ្វើដំណាក់កាលរៀបចំផែនការវិញ និងកែលម្អយុទ្ធសាស្ត្ររបស់ពួកគេ ហើយចាប់

ផ្តើមវដ្តថ្មីនៃការស្រាវជ្រាវ។ រាល់វដ្តនីមួយៗគឺផ្តើតឡើងពីមេរៀននៃវដ្តមុនៗ ដែលនាំទៅរកការកែលម្អដ៏យូរអង្វែងក្នុងការបង្រៀន និងការរៀនសូត្របន្តិចម្តងៗ។

ឧទាហរណ៍

វដ្តទី១៖ គ្រូបង្រៀនប្រើប្រាស់ការងារក្រុមដើម្បីបង្កើនការចូលរួមរបស់សិស្ស។ លទ្ធផលបង្ហាញថាទោះបីជាការចូលរួមមានការកើនឡើងក៏ដោយ សិស្សមួយចំនួនមានភាពលេចធ្លោជាច់គេ និងបានគ្រប់គ្រងសកម្មភាពពិភាក្សាលើសគេ។

វដ្តទី២៖ គ្រូបង្រៀនបានកែលម្អយុទ្ធសាស្ត្រការងារក្រុមថ្មី ដោយមានការចាត់តាំងតួនាទីផ្សេងៗគ្នាក្នុងក្រុម។ លទ្ធផលបានបង្ហាញថាការចូលរួមមានតុល្យភាពជាងមុន។

វដ្តទី៣៖ គ្រូបង្រៀនបញ្ជូលការវាយតម្លៃជាដៃគូ ដើម្បីបន្តពង្រឹងការទទួលខុសត្រូវ និងការចូលរួម។

ដំណើរការខាងលើនេះ បានផ្សារភ្ជាប់វិធីសាស្ត្រនៃការកសាងទ្រឹស្តីតាមបែបអនុវត្ត (Practice theory building approach) ដែលក្នុងនោះគ្រូបង្រៀនបន្តកែលម្អការអនុវត្តរបស់ពួកគេដោយផ្អែកលើភស្តុតាង និងការឆ្លុះបញ្ចាំង (Carr & Kemmis, 1986)។

ការអនុវត្តសម្រាប់គ្រូឧទ្ទេស និងគរុនិស្សិត

គ្រូឧទ្ទេស៖ គ្រូឧទ្ទេសអាចប្រើគំរូធ្វើលជុំនេះបានដើម្បីណែនាំគរុនិស្សិតនៅក្នុងការស្រាវជ្រាវដែលមានលក្ខណៈស្វែងរកជាប្រព័ន្ធ និងអនុវត្តការឆ្លុះបញ្ចាំងនៅក្នុងថ្នាក់រៀនជាក់ស្តែង។

គរុនិស្សិត៖ អាចទទួលយកគំរូនេះសម្រាប់ផែនការស្រាវជ្រាវថ្នាក់រៀនខ្នាតតូច (small Scale) ដោយអភិវឌ្ឍជំនាញក្នុងការកំណត់បញ្ហា ការប្រមូលទិន្នន័យជាប្រព័ន្ធ និងការឆ្លុះបញ្ចាំងឱ្យបានស៊ីម្រៅ។

គំរូនេះមានប្រសិទ្ធភាពនៅក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន ពីព្រោះវាធ្វើឱ្យមានតុល្យភាពរវាងការអនុវត្ត និងការឆ្លុះបញ្ចាំងផ្អែកលើទ្រឹស្តី ដែលជួយឱ្យគ្រូបង្រៀនថ្មីៗក្លាយទៅជាអ្នកអនុវត្ត និងអ្នកស្រាវជ្រាវនៃការអនុវត្តផ្ទាល់ខ្លួនរបស់ពួកគេ។

គំរូធ្វើលជុំរបស់Kemmis and McTaggart បានផ្តល់នូវ គំរូនៃការស្រាវជ្រាវប្រតិបត្តិមួយដែលមានលក្ខណៈបត់បែននិងងាយយល់។ ដំណាក់កាលទាំងបួនរបស់គំរូនេះ៖ការរៀបចំផែនការ ការអនុវត្ត ការសង្កេត និងការឆ្លុះបញ្ចាំង បានផ្តល់នូវជំហានច្បាស់លាស់ដែលមានលក្ខណៈជាប្រព័ន្ធ និងអាចធ្វើឡើងវិញ (iterative) បាន។ ដំណើរការបែបនេះអាចឱ្យគ្រូបង្រៀនកែលម្អការបង្រៀនរបស់ពួកគេជាប្រចាំ។ ចំពោះគ្រូឧទ្ទេសនិង

គរុនិស្សិត គំរូនេះគឺជាឧបករណ៍ដ៏មានប្រយោជន៍មួយសម្រាប់ ផ្សារភ្ជាប់ការអនុវត្តថ្នាក់រៀនទៅនឹងការស្រាវជ្រាវវិជ្ជាជីវៈ និងជាចុងក្រោយគឺវាជួយរួមចំណែកកែលម្អគុណភាពបង្រៀន និងរៀន។

តើហេតុអ្វីយើងគួរប្រើគំរូរបស់ Kemmis និង McTaggart?

- **ភាពដដែលៗនិងមានការឆ្លុះបញ្ចាំង** (iterative and Reflective)៖ គំរូរង្វិលជុំនេះសង្កត់ធ្ងន់លើវដ្តបន្ត បន្ទាប់នៃការរៀបចំផែនការ សកម្មភាព សង្កេត និងឆ្លុះបញ្ចាំង ដែលអាចធ្វើឱ្យគ្រូបង្រៀនកែលម្អការអនុវត្ត របស់ពួកគេតាមពេលវេលា។ លក្ខណៈវិលជុំនេះជំរុញឱ្យមានការសិក្សាស៊ីជម្រៅ និងការកែលម្អបន្ត ជាជាង ការពិសោធតែមួយដង (Kemmis & McTaggart, 1988; McNiff & Whitehead, 2011)។
- **ជាក់ស្តែងនិងទាក់ទងបរិបទ**៖ គំរូនេះមានឫសគល់ពីភាពជាក់ស្តែងនៃការអនុវត្តថ្នាក់រៀន។ គ្រូបង្រៀន ស្រាវជ្រាវបញ្ហាក្នុងថ្នាក់រៀនផ្ទាល់របស់ពួកគេ ដោយធានាថាវិធីសាស្ត្រពិសោធទាំងនោះមានលក្ខណៈ ជាក់លាក់នឹងផ្តែកលើបរិបទ និងភាពពាក់ព័ន្ធបច្ចុប្បន្ន (Burns, 2010).។
- **បញ្ចូលគ្នារវាងទ្រឹស្តី និងការអនុវត្ត**៖ តាមរយៈការភ្ជាប់សកម្មភាពជាមួយការឆ្លុះបញ្ចាំង គំរូរង្វិលជុំអាចធ្វើ ឱ្យគ្រូបង្រៀនផ្សារភ្ជាប់ទ្រឹស្តីអប់រំជាមួយការអនុវត្ត ដែលជំរុញការអភិវឌ្ឍវិជ្ជាជីវៈ និងការឆ្លុះបញ្ចាំង (Reflective thinking) (Carr & Kemmis, 1986)។
- **គាំទ្រការសិក្សាបែបសហការ** ៖ គំរូនេះលើកទឹកចិត្តឱ្យមានការសហការរវាងគ្រូឧទ្ទេស និងគរុនិស្សិត ហើយពេលខ្លះអាចសហការជាមួយសិស្សផងដែរ។ ការចូលរួមគ្នានេះបានលើកកម្ពស់ការរៀនរួមគ្នា និងកសាងសហគមន៍សិក្សាវិជ្ជាជីវៈ (Kemmis, McTaggart, & Nixon, 2014)។
- **ផ្តល់អំណាចដល់គ្រូបង្រៀនក្នុងនាមជាអ្នកស្រាវជ្រាវ**៖ គ្រូបង្រៀន និងគរុនិស្សិតអាចក្លាយជាតួអង្គសកម្ម ក្នុងការអភិវឌ្ឍវិជ្ជាជីវៈផ្ទាល់ខ្លួន។ គំរូនេះបណ្តុះឱ្យមានស្មារតីម្ចាស់ការ និងការទទួលខុសត្រូវក្នុងការកែលម្អ ថ្នាក់រៀន (Mertler, 2019)។

តើយើងត្រូវពិចារណាលើចំណុចអ្វីខ្លះមុនប្រើគំរូនេះ?

ចំណាយពេលច្រើន៖ ការរៀបចំផែនការ ការអនុវត្ត ការសង្កេត និងឆ្លុះបញ្ចាំងគឺត្រូវការធ្វើឡើងច្រើនដង ដូច្នេះវាអាចប្រើពេលវេលាច្រើន ហើយដែលអាចបង្កជាបញ្ហាប្រឈមសម្រាប់គរុនិស្សិត ឬគ្រូឧទ្ទេស គ្រូបង្រៀន ទូទៅដែលមានបន្ទុកការងារច្រើន (Mills, 2020)។

មានលក្ខណៈស្មុគស្មាញសម្រាប់អ្នកស្រាវជ្រាវដំបូង៖ គ្រូបង្រៀនថ្មីៗអាចនឹងគិតថាគំរូនេះមានលក្ខណៈ ស្មុគស្មាញជាពិសេសគឺការរក្សាតុល្យភាពទំនួលខុសត្រូវនៃការបង្រៀន និងការធ្វើការស្រាវជ្រាវក្នុងពេលតែមួយ។

ដើម្បីធ្វើការស្រាវជ្រាវដោយប្រើគំរូនេះបានគឺចាំបាច់ត្រូវការណែនាំ និងការដឹកនាំច្រើន (McNiff & Whitehead, 2011)។

ទាមទារការប្រមូលទិន្នន័យឱ្យបានត្រឹមត្រូវ៖ ប្រសិទ្ធភាពនៃគំរូនេះគឺអាស្រ័យលើការសង្កេតនិងការឆ្លុះបញ្ចាំងដែលមានលក្ខណៈជាប្រព័ន្ធ និងត្រឹមត្រូវ។ ការប្រមូលទិន្នន័យដែលមិនស៊ីសង្វាក់គ្នាអាចនាំឱ្យការសន្និដ្ឋានខុស និងក៏ធ្វើឱ្យភាពអាចទុកចិត្តបាននៃគំរូនេះមានដែនកំណត់ (Kemmis & McTaggart, 1988)។

លទ្ធផលជាក់លាក់តាមបរិបទ៖ ទោះបីគំរូនេះជំរុញឱ្យមានដំណោះស្រាយជាក់ស្តែងតាមបរិបទ ប៉ុន្តែលទ្ធផលប្រហែលជាមិនអាចយកទៅអនុវត្តឬធ្វើទូទៅកម្មបានក្នុងថ្នាក់រៀន ឬបរិបទផ្សេងៗបានឡើយ។ គ្រូបង្រៀនត្រូវតែទទួលស្គាល់ថា លទ្ធផលដែលទទួលបានគឺតម្រូវពិសេសប្រាប់បរិបទផ្ទាល់របស់ពួកគេតែប៉ុណ្ណោះ (Kemmis & McTaggart, 1988)។

ហានិភ័យនៃកម្រិតឆ្លុះបញ្ចាំងមិនស៊ីជម្រៅ៖ ប្រសិនបើការឆ្លុះបញ្ចាំងត្រូវបានធ្វើរហ័សឬលឿនពេក ឬត្រូវបានចាត់ទុកថាត្រឹមត្រូវ អត្ថប្រយោជន៍នៃគំរូនេះប្រហែលជាមិនសម្រេចពេញលេញនោះទេ។ គ្រូបង្រៀនត្រូវការការគាំទ្របន្ថែមដើម្បីបង្កើតការឆ្លុះបញ្ចាំងដែលមានលក្ខណៈពិតប្រាកដ (Burns, 2010)។

សរុបសេចក្តីមក គំរូរង្វិលជុំរបស់Kemmis and McTaggartបានផ្តល់នូវគោលការណ៍ដ៏រឹងមាំ និងអាចបត់បែនបានសម្រាប់ការស្រាវជ្រាវប្រតិបត្តិដែលធ្វើឡើងដោយគ្រូបង្រៀន។ ចំណុចខ្លាំងរបស់វាគឺ មានវដ្តវិលជុំ ពាក់ព័ន្ធនឹងបរិបទ ការបញ្ចូលគ្នារវាងទ្រឹស្តី និងការអនុវត្ត ផ្តោតលើការសហការ និងការផ្តល់អំណាចដល់គ្រូបង្រៀន ធ្វើឱ្យគំរូនេះសមស្របជាពិសេសសម្រាប់គ្រូឧទ្ទេស និងគរុនិស្សិត។ ស្របពេលជាមួយគ្នានេះដែរ គេត្រូវយកចិត្តទុកដាក់ទៅលើចំណុចខ្សោយរបស់វា ដូចជា តម្រូវការពេលវេលាច្រើន ភាពស្មុគស្មាញសម្រាប់អ្នកស្រាវជ្រាវថ្មីៗ និងផ្អែកតាមបរិបទ ដើម្បីធានាថាការស្រាវជ្រាវប្រតិបត្តិត្រូវបានគេអនុវត្តឱ្យមានប្រសិទ្ធភាព និងអាចកែលម្អសមត្ថភាពក្នុងថ្នាក់រៀន។

៣.៣. គំរូរបស់ស្ទ្រីងដ៏ (Stringer's Model)

គំរូរបស់ Lewin (1946) Kemmis និង McTaggart (1988) បានផ្តល់មូលដ្ឋានគ្រឹះយ៉ាងសំខាន់ៗសម្រាប់ការស្រាវជ្រាវប្រតិបត្តិ។ Ernest Stringer (1999; 2014) បានបង្កើតគំរូមួយដែល សមស្របជាពិសេសសម្រាប់ការប្រើប្រាស់ក្នុងបរិបទអប់រំ និងសហគមន៍។ ក្របខណ្ឌ (Framework) នេះដែលជាទូទៅត្រូវបានគេស្គាល់ថាជា គំរូ *មើល-គិត-ធ្វើ* ហើយគំរូនេះគឺជាគំរូដែលមានលក្ខណៈជាក់ស្តែង ងាយស្រួលប្រើ និងមានភាពបត់បែនខ្ពស់សម្រាប់គ្រូឧទ្ទេស និងគរុនិស្សិត។ គំរូរបស់ Stringer (1999; 2014) ផ្តោតសំខាន់លើភាពសាមញ្ញតែមានភាពតឹងរ៉ឹង ដែលធ្វើឱ្យវាសាកសមសម្រាប់អ្នកស្រាវជ្រាវថ្មីៗ ប៉ុន្តែវានៅតែមានលក្ខណៈជាការសិក្សាស្វែងយល់ជា

ប្រព័ន្ធ ដើម្បីកែលម្អការបង្រៀន និងការរៀន។ នៅក្នុងផ្នែកនេះយើងរៀបរាប់លម្អិតពី គំរូការស្រាវជ្រាវប្រតិត្តិរបស់ Stringer ដោយពន្យល់ពីដំណាក់កាលនីមួយៗឱ្យបានលម្អិត និងរំលេចនូវចំណុចសំខាន់នៃការអនុវត្តរបស់គំរូនេះ សម្រាប់គ្រូឧទ្ទេស និងគរុនិស្សិត។

៣.៣.១. ទិដ្ឋភាពទូទៅនៃគំរូស្រាវជ្រាវប្រតិបត្តិរបស់ Stringer

Stringer (1999; 2014) ឱ្យនិយមន័យនៃការស្រាវជ្រាវប្រតិបត្តិថាជា *"វិធីសាស្ត្រដែលមានលក្ខណៈប្រ ប្រព័ន្ធចំពោះការអង្កេត"* ដែលអនុញ្ញាតឱ្យគេ *"រកឃើញដំណោះស្រាយដ៏មានប្រសិទ្ធភាពចំពោះបញ្ហាដែលគេជួប ប្រទះនៅក្នុងជីវិតប្រចាំថ្ងៃរបស់គេ"*។ គំរូរបស់គាត់មានរចនាសម្ព័ន្ធដោយផ្អែកលើដំណាក់កាលសំខាន់ៗបី៖

១. មើល – ការប្រមូលព័ត៌មាន ដើម្បីស្វែងយល់ពីស្ថានភាព។
២. គិត – ការវិភាគ និងបកស្រាយព័ត៌មាន។
៣. ធ្វើ – ការរៀបចំផែនការ និងអនុវត្តដំណោះស្រាយជាក់ស្តែង។



The Stringer's action research model
(Stringer, 2007, p. 30)

ដំណើរនៃគំរូនេះអាចធ្វើឱ្យគ្រូបង្រៀនប្តូរពី ការសង្កេត ទៅ ការឆ្លុះបញ្ចាំង ហើយទៅ ការធ្វើសកម្មភាព តាមរបៀបដ៏ច្បាស់លាស់ និងអាចគ្រប់គ្រងបាន។ ភាពសាមញ្ញ នៃគំរូនេះ ធ្វើឱ្យមានភាព ងាយស្រួល ជាពិសេស សម្រាប់គរុនិស្សិតនិងគ្រូឧទ្ទេសដែលធ្វើការក្នុងបរិបទថ្នាក់រៀនចម្រុះគ្នា (Mertler, 2019)។

៣.៣.២ សេចក្តីពន្យល់លម្អិតពីជំហាន់នីមួយៗ

ការមើល

ដំណាក់កាល "មើល" គឺជាដំណាក់កាលពិនិត្យស្ថានភាពដោយប្រុងប្រយ័ត្ន ដើម្បីស្វែងយល់ឱ្យបាន ច្បាស់លាស់អំពីបញ្ហា។ គ្រូបង្រៀនប្រមូលព័ត៌មានពីប្រភពផ្សេងៗគ្នា ដើម្បីស្វែងយល់ពីអ្វីដែលកំពុងកើតឡើងនៅ ក្នុងថ្នាក់រៀន។

សកម្មភាពសំខាន់ៗរួមមាន៖

- **កំណត់ពីចំណុចដែលត្រូវសិក្សា៖** គ្រូបង្រៀនបញ្ជាក់ពីបញ្ហាដែលពួកគេចង់សិក្សា (ឧ. ការចូលរួមទាប ជម្លោះក្នុងថ្នាក់រៀន កង្វះការចូលរួមក្នុងការអាន)។
- **ការប្រមូលទិន្នន័យ៖** ជំហាននេះអាចមានដូចជាការសង្កេត គំរូការងារសិស្ស លទ្ធផលតេស្ត កំណត់ត្រា ឬ ការសន្ទនាផ្ទាល់ជាមួយសិស្ស។

- **ធ្វើផែនទីស្ថានភាព**៖ គ្រូបង្រៀនកត់ត្រាកស្តុតាងជាប្រព័ន្ធ ដោយជាញឹកញាប់ប្រើកំណត់ត្រាសង្កេត រូបថត ឬដ្យាក្រាម។

គោលដៅនៃជំហាននេះគឺដើម្បី ស្វែងយល់ឱ្យបានទូលំទូលាយនិងពិនិត្យមើលពីស្ថានភាពបច្ចុប្បន្នមុនពេលរៀបចំផែនការផ្លាស់ប្តូរ។ យោងតាម Stringer (2014)ការមើលស្ថានភាពយ៉ាងហ្មត់ចត់ ជួយបង្ការកុំឱ្យគ្រូបង្រៀនធ្វើការសន្និដ្ឋានតាមរយៈការសន្មត និងដើម្បីធានាថាការពិសោធផ្អែកលើកស្តុតាងពិតជាក់ស្តែង។

ការគិត

នៅក្នុងជំហាន "គិត" គ្រូបង្រៀនត្រូវវិភាគ និងបកស្រាយទិន្នន័យដែលប្រមូលបាន។ ដំណាក់កាលនេះផ្តោតទៅលើ ការឆ្លុះបញ្ចាំង និងការបកស្រាយ ជាជាងការរៀបរាប់អ្វីដែលត្រូវបានសង្កេតឃើញ។

សកម្មភាពសំខាន់ៗរួមមាន៖

- **ការវិភាគទិន្នន័យ**៖ កំណត់គំរូ ខ្លឹមសារគោល ឬបញ្ហាដែលបានកើតឡើងដដែលៗនៅក្នុងថ្នាក់រៀន។
- **ការបកស្រាយអត្ថន័យ**៖ ពិចារណាពីមូលហេតុដែលនោះបញ្ហាឮកើតឡើង។ ឧទាហរណ៍៖ ប្រសិនបើសិស្សស្ទាក់ស្ទើរក្នុងការចូលរួមក្នុងការពិភាក្សាក្រុម តើវាដោយសារកត្តាភាសា ការខ្វះទំនុកចិត្ត ឬការណែនាំរបស់គ្រូមិនច្បាស់លាស់?
- **ការសហការជាមួយអ្នកដទៃ**៖ ពិភាក្សាលទ្ធផលរកឃើញជាមួយអ្នករួមការងារ គ្រូណែនាំ ឬជាមួយសិស្ស ដើម្បីទទួលបានធាតុចូលកាន់តែច្រើន។

នៅក្នុងជំហាននេះបានផ្តល់ឱកាសសម្រាប់គរុនិស្សិតដើម្បី កសាងជំនាញការគិតស៊ីជម្រៅ និងដើម្បីផ្សារភ្ជាប់ការអនុវត្តការបង្រៀន ជាមួយនឹងទ្រឹស្តីនៃការរៀន និងគោលការណ៍គរុកោសល្យ។ Stringer (1999) បានលើកឡើងថាការឆ្លុះបញ្ចាំងគួរនាំទៅរកការយល់ដឹងពីមូលហេតុពិតប្រាកដរបស់បញ្ហា ជាជាងដឹងតែរោគសញ្ញានៃបញ្ហា។

ការធ្វើ

ជំហាននៃការ "ធ្វើ" គឺពាក់ព័ន្ធនឹងការអភិវឌ្ឍ និងអនុវត្តដំណោះស្រាយជាក់ស្តែង ដោយផ្អែកលើចំណេះដឹងដែលទទួលបានពីដំណាក់កាល "មើល" និង "គិត"។ គ្រូបង្រៀនរៀបចំយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាដែលបានកំណត់ ហើយយកវាទៅអនុវត្តនៅក្នុងថ្នាក់រៀនរបស់គេ។

សកម្មភាពសំខាន់ៗរួមមាន៖

- **ការរៀបចំផែនការសកម្មភាព៖** បង្កើតផែនការពិសោធច្បាស់លាស់ជាក់លាក់។ ឧទាហរណ៍៖ ដើម្បីដោះស្រាយបញ្ហាការចូលរួមទាបរបស់សិស្ស គ្រូបង្រៀនអាចរៀបចំសកម្មភាពក្រុមដែលមានរចនាសម្ព័ន្ធដោយចាត់តាំងតួនាទីសម្រាប់សិស្ស។
- **ការអនុវត្តផែនការ៖** អនុវត្តសកម្មភាពនៅក្នុងថ្នាក់រៀន ដោយយកចិត្តទុកដាក់ចំពោះចម្លើយ និងប្រតិកម្មរបស់សិស្ស។
- **ការវាយតម្លៃលទ្ធផល៖** ក្រោយពីការអនុវត្ត គ្រូបង្រៀនប្រមូលកស្តុតាងម្តងទៀត ដើម្បីពិនិត្យមើលថាតើសកម្មភាពនោះបានធ្វើឱ្យមានការប្រែប្រួលនៃការចូលរួមដែរឬទេ។

អ្វីដែលត្រូវចំណាំនោះគឺថា ជំហាន"ធ្វើ" គឺ មិនមែនចំណុចបញ្ចប់ដំណើរការនេះទេ។ គ្រូបង្រៀនត្រឡប់ទៅដំណាក់កាល "មើល" វិញ ដើម្បីវាយតម្លៃលទ្ធផល ដែលអាចនាំទៅរកវដ្តកែលម្អបន្ថែមទៀត។ ការធ្វើបែបនេះធ្វើឱ្យគំរូនេះទាំង មានលក្ខណៈវិលជុំ និងអាចអនុវត្តបានយូរ នៅក្នុងការកែលម្អការបង្រៀន និងការរៀន (Stringer, 2014)។

ការអនុវត្តសម្រាប់ការបណ្តុះបណ្តាលគ្រូ

សម្រាប់គ្រូឧទ្ទេស

គំរូរបស់លោក Stringer បានផ្តល់នូវគោលការណ៍ដែលមានលក្ខណៈសាមញ្ញសម្រាប់ពួកគេដើម្បីដឹកនាំគរុនិស្សិត តាមរយៈបទពិសោធន៍ដំបូងរបស់ពួកគេនៅក្នុងការស្រាវជ្រាវប្រតិបត្តិ។ ដោយសារដំណាក់កាលទាំងនេះមានភាពច្បាស់លាស់ និងងាយស្រួលយល់ វាជួយកាត់បន្ថយភាពស្មុគស្មាញនៃការរៀបចំរចនាបទស្រាវជ្រាវ។

សម្រាប់គរុនិស្សិត

- មានចំណុចចាប់ផ្តើមសាមញ្ញ ឆ្ពោះទៅកាន់ការស្រាវជ្រាវតាមរយៈជំហានដែលអាចគ្រប់គ្រងបាន។
- មានឱកាសក្នុងកសាងជំនាញក្នុងការសង្កេត ការឆ្លុះបញ្ចាំង និងការដោះស្រាយបញ្ហាថ្នាក់រៀន។
- ទទួលបានវិធីសាស្ត្រមួយក្នុងការភ្ជាប់ទ្រឹស្តីជាមួយការអនុវត្តក្នុងបរិយាកាសបង្រៀនពិត។

ឧទាហរណ៍៖

មើល៖គរុនិស្សិតបានសង្កេតឃើញថា សិស្សកម្រសួរសំណួរក្នុងអំឡុងម៉ោងបង្រៀនមេរៀនវិទ្យាសាស្ត្រ។

គិត៖ ការវិភាគបង្ហាញថា សិស្សខ្វះទំនុកចិត្ត និងខ្លាចធ្វើខុស។

ធ្វើ៖ គរុនិស្សិតបានប្រើប្រាស់ "ប្រអប់សំណួរ" ដែលសិស្សអាចដាក់សំណួរដោយអនាមិក។ សកម្មភាពនេះធ្វើឱ្យការចូលរួមកើនឡើង។

វិធីសាស្ត្រដែលជាក់ស្តែងដោយផ្អែកលើភស្តុតាងនេះ បានពង្រឹងទាំងជំនាញបង្រៀន និងសមត្ថភាពស្រាវជ្រាវ។

ហេតុអ្វីយើងគួរប្រើវិធីសាស្ត្រ របស់ លោក Stringer?

- ភាពសាមញ្ញ និងភាពងាយស្រួលអនុវត្ត

គុណសម្បត្តិមួយរបស់គំរូនេះគឺវាមានភាពច្បាស់លាស់។ វដ្តនៃដំណាក់កាលបី៖ មើល គិត ធ្វើ គឺសាមញ្ញ និងងាយយល់សម្រាប់អ្នកស្រាវជ្រាវថ្មីៗ និងគរុនិស្សិតប៉ុន្តែវានៅតែមានភាពតឹងរ៉ឹង (Mertler, 2019)។ ភាពងាយស្រួលក្នុងការអនុវត្តនេះធ្វើឱ្យគំរូនេះក្លាយជាចំណុចចាប់ផ្តើមមួយក្នុងការស្រាវជ្រាវជាក់ស្តែងសម្រាប់គ្រូឧទ្ទេសដែលមិនធ្លាប់ទទួលបានការបណ្តុះបណ្តាលផ្នែកស្រាវជ្រាវពេញលេញ។

- ពាក់ព័ន្ធនឹងបរិបទ

គំរូនេះបានសង្កត់ធ្ងន់លើការដោះស្រាយបញ្ហាជីវិតពិតដែលគ្រូបង្រៀនប្រឈមនៅក្នុងថ្នាក់រៀនរបស់ពួកគេ។ តាមរយៈការកំណត់ការស្រាវជ្រាវចេញពីការអនុវត្តជាក់ស្តែង វាធានាបានថាការស្រាវជ្រាវនៅតែ មានន័យពាក់ព័ន្ធ និងអាចអនុវត្តផ្ទាល់បាន (Stringer, 2014)។

- ទិសដៅជំរុញឱ្យមានកាសហការ

លោក Stringer បង្ហាញពីតម្លៃនៃអ្នកពាក់ព័ន្ធ ដូចជា សិស្ស មិត្តរួមការងារ ឪពុកម្តាយ និងសមាជិកសហគមន៍ — ក្នុងដំណើរការស្រាវជ្រាវ។ កិច្ចសហការនេះធ្វើឱ្យគំរូនេះសមស្របសម្រាប់ការស្រាវជ្រាវបែបចូលរួម (Participatory Research) ក្នុងវិស័យអប់រំ ដែលធាតុចូលឬយោបល់ច្រើនអាចរួមចំណែកដល់ការយល់ដឹង និងការដោះស្រាយបញ្ហា (Burns, 2010)។

- ដំណើរការវិលជុំ និងបត់បែនបាន

ទោះបីជាគំរូមានតែបីដំណាក់កាលក៏ដោយ វាគឺជាវិលជុំ(Cyclical)។ គ្រូបង្រៀនអាចឆ្លងកាត់វដ្ត មើល-គិត-ធ្វើ ច្រើនដងច្រើនសារ ដើម្បី កែលម្អការអនុវត្តរបស់ពួកគេជាបន្តបន្ទាប់។ ភាពបត់បែននេះបានជំរុញឱ្យមានការសិក្សាវិជ្ជាជីវៈ និងការសម្របខ្លួនជាប្រចាំ (Stringer, 2014)។

- ផ្តោតលើដំណោះស្រាយជាក់ស្តែង

ខុសពីគំរូស្រាវជ្រាវបុរាណខ្លះដែលសង្កត់ធ្ងន់លើការកសាងទ្រឹស្តី វិធីសាស្ត្ររបស់ Stringer ត្រូវបានសម្រួចទៅរកលទ្ធផលជាក់ស្តែង។ គ្រូបង្រៀនអាចអនុវត្តដំណោះស្រាយដោយផ្ទាល់ដើម្បីកែលម្អការរៀនសូត្ររបស់សិស្ស ដែលពង្រឹងទំនុកចិត្ត និងជំនាញវិជ្ជាជីវៈ (McNiff & Whitehead, 2011)។

អ្វីដែលត្រូវពិចារណានៅពេលប្រើគំរូរបស់ លោក Stringer

- ហានិភ័យនៃភាពសាមញ្ញពេក

ទោះបីជាភាពសាមញ្ញរបស់គំរូគឺជាចំណុចខ្លាំងក៏ដោយ វាក៏អាចជាចំណុចខ្សោយផងដែរ។ បញ្ហាអប់រំមានលក្ខណៈស្មុគស្មាញ ប្រហែលជាមិនចេះតែសាកសមនឹងដំណាក់កាលបីនេះយ៉ាងរលូនរហូតនោះទេ។ បើប្រៀប

ធៀបជាមួយគំរូរង្វិលជុំរបស់ Kemmis និង McTaggart គោលការណ៍របស់ Stringer មានជំហានតិចជាងសម្រាប់ការប្រមូលទិន្នន័យ និងការឆ្លុះបញ្ចាំងដ៏តឹងរ៉ឹង (Kemmis, McTaggart, & Nixon, 2014)។

- ពឹងផ្អែកលើជំនាញឆ្លុះបញ្ចាំងរបស់គ្រូ

ជោគជ័យនៃគំរូពឹងផ្អែកយ៉ាងខ្លាំងលើសមត្ថភាពរបស់គ្រូក្នុងការចូលរួមក្នុងការឆ្លុះបញ្ចាំងបានស៊ីជម្រៅ និងសមត្ថភាពវិភាគត្រិះរិះ។ ប្រសិនបើការឆ្លុះបញ្ចាំងមានលក្ខណៈសើ។ លទ្ធផលនិងអាចមានកម្រិត ហើយការស្រាវជ្រាវប្រហែលជាមិនអាចរកឃើញឬសគល់របស់បញ្ហាថ្នាក់រៀនបាននោះទេ(McNiff & Whitehead, 2011)។

- បញ្ហាប្រឈមអំពីពេលវេលា និងធនធាន

ទោះបីជាដំណាក់កាលមានលក្ខណៈសាមញ្ញក៏ដោយ តែវានៅតែទាមទារឱ្យពេលវេលាគ្រប់គ្រាន់សម្រាប់ការសង្កេត ការវិភាគ និងការរៀបចំផែនការ។ គ្រូបង្រៀនដែលមានបន្ទុកការងារបង្រៀនច្រើន ឬធនធាននៅមានកម្រិតនឹងអាចជួបការលំបាកក្នុងការអនុវត្តដំណាក់កាលនីមួយៗឱ្យមានប្រសិទ្ធភាព (Mills, 2020)។

- ការអនុវត្តទូទៅមានកម្រិត

ដោយសារគំរូ លោក Stringer មានលក្ខណៈជាក់លាក់តាមបរិបទខ្ពស់ លទ្ធផលស្រាវជ្រាវតែងតែមានដែនកំណត់សម្រាប់តែថ្នាក់រៀន ឬសាលារបស់ខ្លួនប៉ុណ្ណោះ។ ទោះបីជាគំរូនេះវាសមស្របសម្រាប់ការស្រាវជ្រាវប្រតិបត្តិក៏ដោយ ក៏លទ្ធផលប្រហែលជាមិនអាចយកទៅធ្វើទូទៅកម្មនៅក្នុងបរិបទអប់រំធំជាងនេះបានទេ (Burns, 2010)។

សរុបសេចក្តីមក គំរូ មើល-គិត-ធ្វើ របស់លោក Stringer គឺជាគោលការណ៍អនុវត្តដ៏ល្អប្រសើរមួយសម្រាប់គ្រូឧទ្ទេស និងគរុនិស្សិតដែលចាប់ផ្តើមការស្រាវជ្រាវប្រតិបត្តិ។ ចំណុចខ្លាំងរបស់វាគឺភាពសាមញ្ញ ភាពងាយស្រួលប្រើ និងពាក់ព័ន្ធផ្ទាល់ទៅនឹងការអនុវត្តថ្នាក់រៀនជាក់ស្តែង។ ទោះជាយ៉ាងណាក៏ដោយ អ្នកអប់រំត្រូវតែដឹងពីចំណុចខ្សោយរបស់វា ជាពិសេសហានិភ័យនៃភាពសាមញ្ញពេក និងតម្រូវការសមត្ថភាពឆ្លុះបញ្ចាំងរបស់គ្រូ និងពេលវេលា។ នៅពេលយើងគិតឱ្យស៊ីជម្រៅទៅ គំរូនេះបានផ្តល់នូវឧបករណ៍ដ៏មានឥទ្ធិពលមួយសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ និងការកែលម្អថ្នាក់រៀន។

៣.៤. វដ្តនៃការស្រាវជ្រាវប្រតិបត្តិបែបចូលរួម (Participatory Action Research Cycle)

ការស្រាវជ្រាវប្រតិបត្តិតាមបែបចូលរួម (PAR) កសាងឡើងលើមូលដ្ឋានគំនិតរបស់លោក Paulo Freire (1970) ដែលស្នាដៃរបស់លោកក្នុងសៀវភៅ "**គរុកោសល្យរបស់អ្នករងការជិះជាន់**" (Pedagogy of the Oppressed) បានសង្កត់ធ្ងន់លើកិច្ចសន្ទនា មនសិការរិះគន់ និងការផ្តល់អំណាចដល់ក្រុមដែលងាយរងគ្រោះតាមរយៈការស្រាវជ្រាវ និងការអនុវត្តរួមគ្នា។ ខុសពីគំរូស្រាវជ្រាវបែបប្រពៃណីដែលតែងតែបែងចែកអ្នកស្រាវជ្រាវដាច់ដោយឡែកពីអ្នកចូលរួម ការស្រាវជ្រាវប្រតិបត្តិតាមបែបចូលរួម ចាត់ទុកអ្នកពាក់ព័ន្ធទាំងអស់រួមមាន គ្រូបង្រៀន គរុនិស្សិត និងអ្នកសិក្សា គឺជា **"អ្នកស្រាវជ្រាវរួមគ្នា"**។ បែបបទប្រជាធិបតេយ្យនៃដំណើរការស្រាវជ្រាវនេះ ធ្វើឱ្យការស្រាវជ្រាវប្រតិបត្តិតាមបែបសហការ មានភាពពាក់ព័ន្ធយ៉ាងខ្លាំងក្នុងវិស័យអប់រំ ដែលសំឡេងរបស់សិស្ស និងគ្រូបង្រៀនត្រូវតែទទួលបានការទទួលស្គាល់ (Kemmis, McTaggart, & Nixon, 2014)។



សម្រាប់គ្រូឧទ្ទេស និងគរុនិស្សិត ការស្រាវជ្រាវប្រតិបត្តិបែបចូលរួមមិនត្រឹមតែជាវិធីសាស្ត្រស្រាវជ្រាវប៉ុណ្ណោះទេ ប៉ុន្តែក៏ជាឥរិយាបថគរុកោសល្យ (Pedagogical stance) ផងដែរ។ វាចាត់ទុកថ្នាក់រៀនជា "សហគមន៍នៃការស្រាវជ្រាវ" ដែលក្នុងនោះអំណាចត្រូវបានចែករំលែក កិច្ចសន្ទនាត្រូវបានលើកកម្ពស់ ហើយសកម្មភាពត្រូវបានអនុវត្តរួមគ្នាដើម្បីដោះស្រាយបញ្ហាសន្តិភាពជម្លោះ ឬវិសមភាព។

៣.៤.១. គោលការណ៍សំខាន់ៗនៃ ការស្រាវជ្រាវប្រតិបត្តិបែបចូលរួម

វិធីសាស្ត្ររបស់លោក Freire ត្រូវបានដឹកនាំដោយគោលការណ៍ដែលទាក់ទងគ្នាដូចខាងក្រោម៖

- **កិច្ចសន្ទនា** (Dialogue)៖ ការប្រាស្រ័យទាក់ទងគ្នាដោយស្មោះត្រង់ និងស្មើភាពរវាងគ្រូ និងសិស្សក្នុងនាមជាអ្នកសិក្សារួមគ្នា (Freire, 1970)។
- **មនសិការរិះគន់** (Critical Consciousness)៖ ការអភិវឌ្ឍសមត្ថភាពក្នុងការវិភាគពីឫសគល់នៃបញ្ហា ជាជាងការទទួលយកវាថាជារឿងធម្មជាតិ ឬជារឿងដែលមិនអាចកែប្រែបាន។
- **ការអនុវត្តឆ្លុះបញ្ចាំង** (Praxis)៖ វដ្តនៃការត្រិះរិះពិចារណា និងការអនុវត្តដែលប្រព្រឹត្តទៅជាបន្តបន្ទាប់ (ការរៀនពីអ្វីដែលបានធ្វើ រួចយកមកកែលម្អសកម្មភាពបន្ត)។
- **ការផ្តល់អំណាច** (Empowerment)៖ ការជឿនាថាអ្នកចូលរួមគឺជាម្ចាស់លើដំណើរការ និងលទ្ធផលនៃការស្រាវជ្រាវ (Fals-Borda & Rahman, 1991)។

៣.៤.២. វដ្តនៃការស្រាវជ្រាវប្រតិបត្តិបែបសហការ របស់លោក Freire (PAR cycle)

១. ការកំណត់បញ្ហា (ការស្តាប់ និងការដាក់ឈ្មោះ)

វដ្តនេះចាប់ផ្តើមដោយការស្តាប់អ្នកចូលរួមជាជាងការសន្មតដោយខ្លួនឯងថាអ្វីជាបញ្ហា។ អ្នកសម្របសម្រួលត្រូវបង្កើតកិច្ចសន្ទនាបើកចំហដើម្បីឱ្យអ្នកចូលរួមអាចលើកឡើងពីកង្វល់របស់ពួកគេ។ នេះត្រូវបានគេហៅថាដំណាក់កាល "ដាក់ឈ្មោះ" ដែលបញ្ហានានាដូចជា អំពើហិង្សាក្នុងថ្នាក់រៀន ការរើសអើង ឬការខ្វះការចូលរួមអាចនឹងលេចឡើង។ *ឧទាហរណ៍ ក្នុងបរិបទបណ្តុះបណ្តាលគ្រូនៅកម្ពុជា គរុនិស្សិត អាចកំណត់ឃើញថា ការពិភាក្សាក្រុមតែងតែត្រូវបានគ្រប់គ្រងដោយសិស្សមួយចំនួនតូច ដែលធ្វើឱ្យសិស្សស្ងប់ស្ងាត់បាត់បង់ឱកាសបញ្ចេញមតិ។*

ការសង្កត់ធ្ងន់គឺផ្តោតលើការទទួលស្គាល់បទពិសោធន៍ជីវិតជាក់ស្តែង និងការផ្តល់តម្លៃដល់បទពិសោធន៍ទាំងនោះ ដើម្បីយកមកធ្វើជាមូលដ្ឋានគ្រឹះសម្រាប់ការស្រាវជ្រាវ (Freire, 1970)។

២. ការឆ្លុះបញ្ចាំង និងការវិភាគ (កិច្ចសន្ទនាត្រិះរិះពិចារណាបែបរិះគន់)

បន្ទាប់ពីបញ្ហាត្រូវបានកំណត់ ដំណាក់កាលបន្ទាប់គឺការត្រិះរិះពិចារណាបែបរិះគន់។ អ្នកចូលរួមមិនត្រឹមតែរៀបរាប់ពីបញ្ហាប៉ុណ្ណោះទេ ប៉ុន្តែត្រូវវិភាគរកឫសគល់នៃបញ្ហានោះតាមរយៈការពិភាក្សា ការសរសេរកំណត់ហេតុ ឬសិក្ខាសាលារួមគ្នា។ *ឧទាហរណ៍ តាមរយៈការត្រិះរិះ គេអាចរកឃើញថា ឋានានុក្រមក្នុងថ្នាក់រៀន បទដ្ឋានវប្បធម៌ ឬទំនាក់ទំនងអំណាចរវាងគ្រូនិងសិស្ស គឺជាកត្តាដែលធ្វើឱ្យសិស្សខ្លះមិនហ៊ាននិយាយ* (Kemmis & McTaggart, 1988) *។*

៣. ការរៀបចំផែនការ និងការអនុវត្ត (ផ្លាស់ប្តូរការអនុវត្ត)

ក្នុងក្របខណ្ឌរបស់ Freire សកម្មភាពមិនអាចបំបែកចេញពីការត្រិះរិះបានទេ។ អ្នកចូលរួម រួមគ្នាបង្កើតយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាដែលបានរកឃើញ។ ផែនការទាំងនេះត្រូវបានបង្កើតឡើងដោយសហការគ្នាដើម្បីធានានូវភាពជាម្ចាស់ និងការទទួលខុសត្រូវ។ *សកម្មភាពដែលអាចកើតមានមានដូចជា៖*

- ការដាក់ចេញនូវប្រព័ន្ធប្តូរវេនគ្នានិយាយឱ្យបានច្បាស់លាស់។
- ការបណ្តុះបណ្តាលសិស្សឱ្យចេះស្តាប់ដោយយកចិត្តទុកដាក់។
- ការរៀបចំកិច្ចការក្រុមឡើងវិញដើម្បីធានាការចូលរួមដោយសមធម៌។

៤. ការសង្កេត និងការចងក្រងឯកសារ (ការតាមដានការផ្លាស់ប្តូរ)

នៅពេលអនុវត្តសកម្មភាព គេត្រូវមានការសង្កេត និងចងក្រងឯកសារឱ្យបានហ្មត់ចត់។ គ្រូដើរតួជាអ្នកអនុវត្ត និងអ្នកស្រាវជ្រាវ ដោយប្រើឧបករណ៍ដូចជា កំណត់ត្រាសង្កេត មតិកែលម្អពីសិស្ស ការថតសំឡេង ឬការស្ទង់មតិ ដើម្បីប្រមូលភស្តុតាងនៃការផ្លាស់ប្តូរ។

៥. ការត្រិះរិះពិចារណាម្តងទៀត (កិច្ចសន្ទនាបន្តបន្ទាប់)

បន្ទាប់ពីការអនុវត្ត សកម្មភាពនេះនឹងវិលត្រឡប់មកកាន់ការត្រិះរិះពិចារណាវិញ ប៉ុន្តែលើកនេះវាមានភាពស៊ីជម្រៅជាងមុន ដោយសារមានភស្តុតាងដែលបានប្រមូលទុក។ នេះគឺជាការត្រិះរិះកម្រិតខ្ពស់ ដែលអ្នកចូលរួមត្រូវសួរថា តើសកម្មភាពនោះបានបង្កើតការផ្លាស់ប្តូរដែលមានន័យដែរឬទេ? ហើយមានផលវិបាកដែលមិនបានរំពឹងទុកអ្វីខ្លះកើតឡើង? លក្ខណៈវិលជុំនៃ PAR ធានាថាវដ្តនេះមិនបញ្ចប់ត្រឹមសកម្មភាពមួយនោះទេ ប៉ុន្តែវានឹងបន្តអនុវត្តដដែលៗ។ គ្រូបង្រៀនអាចចូលទៅក្នុងវដ្តនេះវិញនៅចំណុចណាមួយ ដើម្បីកែសម្រួល ឬពង្រីកការស្រាវជ្រាវរបស់ពួកគេ។

៦. ការចែករំលែក និងការរក្សានិរន្តរភាពនៃលទ្ធផល

ជាចុងក្រោយ PAR របស់ Freire សង្កត់ធ្ងន់លើការចែករំលែកលទ្ធផលដែលរកឃើញជាមួយសហគមន៍។ លទ្ធផលមិនមែនគ្រាន់តែជាលក្ខណៈសិក្សាប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាឧបករណ៍សម្រាប់ផ្តល់អំណាចរួមគ្នាផងដែរ។ គរុនិស្សិតអាចបង្ហាញលទ្ធផលទៅកាន់មិត្តភក្តិ គ្រូឧទ្ទេស ឬសូម្បីតែសហគមន៍មូលដ្ឋាន ដើម្បីជំរុញកិច្ចសន្ទនាឱ្យកាន់តែទូលំទូលាយ និងរក្សានិរន្តរភាពនៃការផ្លាស់ប្តូរ។

ការផ្សព្វផ្សាយនេះពង្រឹងចក្ខុវិស័យរបស់ Freire លើការអប់រំថាជា "ការអនុវត្តសេរីភាព" ដែលចំណេះដឹងត្រូវបានបង្កើតរួមគ្នា និងចែករំលែកសម្រាប់ការផ្លាស់ប្តូរសង្គម (Freire, 1970)។

ហេតុអ្វីយើងគួរប្រើ វដ្តរបស់ការស្រាវជ្រាវប្រតិបត្តិបែបចូលរួម PAR បែប Freire?

- លក្ខណៈប្រជាធិបតេយ្យ និងបរិយាបន្ន៖ ធានាថាសំឡេងចម្រុះ ជាពិសេសសំឡេងដែលត្រូវបានគេបំភ្លេច ត្រូវបានដកស្រង់មកពិចារណា (Fals-Borda & Rahman, 1991)។
- ការផ្តល់អំណាច៖ បង្កើតភ្នាក់ងារសកម្ម ដល់គរុនិស្សិត និងអ្នកសិក្សា ដោយចាត់ទុកពួកគេជាអ្នកស្រាវជ្រាវរួមគ្នា។
- ឆ្លើយតបនឹងបរិបទជាក់ស្តែង៖ ដំណោះស្រាយកើតចេញពីតថភាពពិតនៃថ្នាក់រៀន ជាជាងការបង្គាប់បញ្ជាពីខាងក្រៅ។

- សក្តានុពលនៃការផ្លាស់ប្តូរ៖ ឈានទៅដោះស្រាយបញ្ហាសង្គម និងរចនាសម្ព័ន្ធដែលនៅពីក្រោយបញ្ហាបច្ចេកទេស (Kemmis, McTaggart & Nixon, 2014)។

ចំណុចដែលត្រូវពិចារណានៅពេលប្រើប្រាស់ការស្រាវជ្រាវតាមបែបចូលរួម បែប Freire

- ចំណាយពេលច្រើន៖ កិច្ចសន្ទនាពិតប្រាកដ និងកិច្ចសហការត្រូវការពេលវេលាច្រើន ដែលអាចជាបញ្ហាប្រឈមក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូដែលមានកាលវិភាគកំណត់ (Mertler, 2019)។
- ត្រូវការអ្នកសម្របសម្រួលដែលមានជំនាញ៖ បើគ្មានអ្នកសម្របសម្រួលខ្លាំងទេ វិសមភាពអំណាចអាចនឹងនៅបន្ត ហើយកិច្ចសន្ទនានឹងមិនអាចឈានទៅដល់ចំណុចស៊ីជម្រៅឡើយ។
- **បញ្ហាប្រឈមក្នុងបរិបទហានានុក្រម៖** ប្រព័ន្ធអប់រំដែលមានការគ្រប់គ្រងបែបបញ្ជាពីលើចុះក្រោម ការផ្តល់អំណាចដល់សិស្ស និងគ្រូបង្រៀនស្មើគ្នាអាចជាបញ្ហារសើបផ្នែកនយោបាយ។
- **ភាពស្មុគស្មាញនៃការវិភាគ៖** ការត្រិះរិះបែបរិះគន់ត្រូវការការគិតបែបអរូបីកម្រិតខ្ពស់ ដែលអាចជាការលំបាកសម្រាប់គរុនិស្សិតបើគ្មានការគាំទ្រគ្រប់គ្រាន់ (Burns, 2010)។

ការស្រាវជ្រាវប្រតិបត្តិតាមបែបចូលរួមដែលបំផុសគំនិតដោយលោក Freire ផ្តល់ឱ្យ គ្រូឧទ្ទេស និងគរុនិស្សិតនូវក្របខណ្ឌដ៏មានឥទ្ធិពលមួយសម្រាប់ការស្រាវជ្រាវក្នុងថ្នាក់រៀន។ តាមរយៈការផ្តល់អាទិភាពលើកិច្ចសន្ទនា ការត្រិះរិះពិចារណា និងសកម្មភាពរួមគ្នា គំរូនេះបានបោះជំហានហួសពីការគ្រាន់តែដោះស្រាយបញ្ហាធម្មតា ដើម្បីឆ្ពោះទៅរកការផ្លាស់ប្តូរទំនាក់ទំនង និងការអនុវត្តក្នុងវិស័យអប់រំ។ ទោះបីជាវាទាមទារពេលវេលា ជំនាញ និងការប្តេជ្ញាចិត្តខ្ពស់ក៏ដោយ ប៉ុន្តែសក្តានុពលរបស់វាក្នុងការផ្តល់អំណាចដល់គ្រូបង្រៀន និងសិស្ស បានធ្វើឱ្យវាក្លាយជាឧបករណ៍ដ៏មានតម្លៃបន្ថែមទៀតនៅក្នុងកញ្ចប់ឧបករណ៍ស្រាវជ្រាវប្រតិបត្តិ។

៤. គំរូសំយោគ ៦ ជំហានក្នុងការអនុវត្តការស្រាវជ្រាវប្រតិបត្តិដើម្បីអហិង្សា

ការស្រាវជ្រាវប្រតិបត្តិត្រូវបានទទួលស្គាល់ជាយូរមកហើយថាជាដំណើរការការអនុវត្ត ឆ្លុះបញ្ចាំង និងសហការសម្រាប់ការកែលម្អនៃការអនុវត្តកម្មអប់រំ។ វាអនុញ្ញាតឱ្យគ្រូឧទ្ទេស និងគរុនិស្សិត ស្រាវជ្រាវអំពីការបង្រៀនរបស់ពួកគេដោយមានប្រព័ន្ធ កំណត់បញ្ហា សាកល្បងដំណោះស្រាយ និងឆ្លុះបញ្ចាំងលើលទ្ធផល។

គំរូសំខាន់ៗ ៤ ដែលបានជំរុញការអភិវឌ្ឍការស្រាវជ្រាវប្រតិបត្តិដែលមានមូលដ្ឋានលើថ្នាក់រៀនមាន៖

- គំរូរបស់ Kurt Lewin (1946)
- គំរូរបស់ Kemmis and McTaggart (1988)
- គំរូរបស់ Stringer's Look–Think–Act (2007)
- វដ្តនៃការស្រាវជ្រាវប្រតិបត្តិបែបចូលរួម (PAR Cycle) ដែលទទួលបានការបំផុសគំនិតពីលោក Freire និងវិធីសាស្ត្រផ្តល់អំណាចផ្អែកលើសហគមន៍។

ទោះបីជាគំរូទាំងនេះមានរចនាសម្ព័ន្ធ និងសទ្ធានុក្រមខុសគ្នាបន្តិចបន្តួចក៏ដោយ ក៏ពួកវាមានគោលការណ៍រួមដូចគ្នា គឺ៖ ការរៀបចំផែនការ (*planning*) ការអនុវត្ត (*action*) ការសង្កេត (*observation*) ការឆ្លុះបញ្ចាំង (*reflection*) និងការចូលរួម (*participation*)។ គំរូដែលត្រូវបានសំយោគឡើងនេះ បានបញ្ចូលនូវចំណុចខ្លាំងសំខាន់ៗនៃក្របខ័ណ្ឌការស្រាវជ្រាវប្រតិបត្តិ (AR) លេចធ្លោចំនួនបួន រួមមាន៖ គំរូរបស់លោក Kurt Lewin (1946) Kemmis និង McTaggart's Spiral Model, គំរូ "មើល-គិត-ធ្វើ" (Look–Think–Act) របស់ Stringer និង ការស្រាវជ្រាវប្រតិបត្តិបែបសហការ។ គោលបំណងនៃសៀវភៅណែនាំនេះ គឺដើម្បីដាក់ចេញនូវ "វដ្ត AR សំយោគ" ដែលត្រូវបានរចនាឡើងយ៉ាងពិសេសសម្រាប់គ្រូឧទ្ទេស និងនិស្សិត ដើម្បីយកទៅប្រើប្រាស់ក្នុងថ្នាក់រៀនជាដំណើរការរួមគ្នា ឆ្លុះបញ្ចាំង និងមានលក្ខណៈជាវដ្តក្នុងគោលដៅកែលម្អការអនុវត្តតាមរយៈការលើកកម្ពស់សន្តិភាព អហិង្សា និងការចូលរួមរបស់អ្នកសិក្សា។

តារាង ២៖ តារាងម៉ាទ្រីសនៃគំរូការស្រាវជ្រាវប្រតិបត្តិទាំង ៤

គំរូ	ជំណាក់កាល	លក្ខណៈពិសេសសំខាន់
កឺត លីវីន Kurt Lewin	រៀបចំផែនការ → សកម្មភាព → ស្វែងយល់ពីការពិត (ការវាយតម្លៃ)	គំរូវដ្តដំបូងដែលដាក់ពិន្ទុលើការដោះស្រាយបញ្ហាដោយមានប្រព័ន្ធ។

ខេមីស & ម៉ាក់ធាហ្គាត Kemmis and McTaggart	ផែនការ → សកម្មភាព → សង្កេត → ឆ្លុះបញ្ចាំង (ផែនការឡើងវិញ)	ដាក់ពិន្ទុលើដំណើរការសហការ និងការឆ្លុះបញ្ចាំងដោយខ្លួនឯងដែលបង្កើតជារាងកង្វៀននៃការកែលម្អ។
ស្ត្រីងហ្គ៊ីរ Stringer	មើល → គិត → អនុវត្ត	ធ្វើឱ្យសាមញ្ញ និងអាចអនុវត្តបានខ្ពស់សម្រាប់ប្រើប្រាស់ក្នុងថ្នាក់រៀនឬសហគមន៍។
វដ្តនៃការស្រាវជ្រាវប្រតិបត្តិការបែបចូលរួម	ផែនការ → សកម្មភាព → សង្កេត → ឆ្លុះបញ្ចាំង → ផែនការឡើងវិញ *(ដោយដាក់ពិន្ទុលើការចូលរួម និងអំណាច)*	ដាក់ពិន្ទុលើការសន្ទនា និងការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់។

ការស្រាវជ្រាវប្រតិបត្តិផ្តល់ឱ្យគ្រូឧទ្ទេស គរុនិស្សិត និងគ្រូបង្រៀននៅកម្ពុជា ក្នុងការផ្លាស់ប្តូរថ្នាក់រៀនឱ្យទៅជាលំហដែលមានសុវត្ថិភាព ការចិញ្ចឹមបីបាច់ និងអហិង្សា។ ទោះបីជាក្របខ័ណ្ឌការស្រាវជ្រាវប្រតិបត្តិមានសទ្ធានុក្រមខុសៗគ្នាក៏ដោយ ក៏អ្នកប្រាជ្ញទាំងឡាយបានពិពណ៌នាស្របគ្នាថា វាគឺជាដំណើរការដែលមានលក្ខណៈជាវដ្តនៃការកំណត់បញ្ហា ការអនុវត្តសកម្មភាព ការសង្កេតមើលផលប៉ះពាល់ និងការកែលម្អការអនុវត្ត (Kemmis & McTaggart, 1988; Mills, 2017; Mertler, 2019)។ សៀវភៅណែនាំនេះណែនាំអំពី គំរូសំយោគដែលមាន ៦ ជំហាន ដែលត្រូវបានបង្កើតឡើងយ៉ាងពិសេសសម្រាប់ការស្រាវជ្រាវប្រតិបត្តិសម្រាប់អហិង្សានៅក្នុងសាលារៀនកម្ពុជា។ គំរូនេះគាំទ្រដល់ទាំងអ្នកអនុវត្តថ្មីថ្មោង និងអ្នកដែលមានបទពិសោធន៍ ហើយវាមានភាពស៊ីសង្វាក់គ្នាទៅនឹងតថភាពនៃការអប់រំក្នុងស្រុក រួមមាន វប្បធម៌សាលារៀនដែលមានឋានានុក្រម ធនធានដែលមានកម្រិត និងការប្តេជ្ញាចិត្តជាតិដែលកំពុងបន្តចំពោះកិច្ចការពារកុមារ៖

១. កំណត់អត្តសញ្ញាណ និងធ្វើរោគវិនិច្ឆ័យបញ្ហា

២. រៀបចំផែនការសម្រាប់សកម្មភាព

៣. សម្រេចសកម្មភាព (ការអនុវត្ត)

៤. សង្កេត និងប្រមូលទិន្នន័យ

៥. ឆ្លុះបញ្ចាំង និងបកស្រាយលទ្ធផល

៦. កែលម្អ និងចែករំលែក

Figure 1: Synthesized Model

នេះគឺជាដ្យាក្រាមវដ្ត។ គួរកត់សម្គាល់ថាជំហាននីមួយៗមានភ្ជាប់ទាក់ទងគ្នា បង្កើតជាវង្វិលបន្តនៃការស្វែងយល់ និងការកែលម្អដែលមានគ្រឹះលើការឆ្លុះបញ្ចាំង និងការចូលរួម។ គំរូសំយោគនេះជួយឱ្យគរុនិស្សិតតភ្ជាប់ទ្រឹស្តី និងការអនុវត្តតាមរយៈការបញ្ចូលគ្នានូវភាពតឹងតែងវិភាគរបស់លីរីន ការឆ្លុះបញ្ចាំងវដ្តរបស់ខេមីស និង ម៉ាក់ធាហ្គាត ការដាក់ពិន្ទុលើការចូលរួមរបស់ការស្រាវជ្រាវប្រតិបត្តិចូលរួម និងភាពច្បាស់លាស់អនុវត្តរបស់ស្ត្រីងហ្គ្រីរ។ វាក៏ផ្តល់អំណាចដល់គ្រូឧទ្ទេស គរុនិស្សិតព្រមទាំងគ្រូថ្នាក់រៀនឱ្យសម្រេចសកម្មភាពដោយឆ្លុះបញ្ចាំង លើកស្ទួយសន្តិភាព និងបង្កើតទីធ្លារៀនប្រជាធិបតេយ្យ។

១. កំណត់អត្តសញ្ញាណ និងធ្វើការវិនិច្ឆ័យ

- រុករកស្ថានភាពថ្នាក់រៀន
- កំណត់បញ្ហាដែលអាចស្រាវជ្រាវបានឱ្យបានច្បាស់
- ប្រមូលកស្តុតាងដំបូង (ការសង្កេត មតិត្រឡប់ពីសិស្ស)

➤ *មកពី*ៈ ដំណាក់កាល "រៀបចំផែនការ" របស់ លីរីន; "មើល" របស់ ស្ត្រីងហ្គ្រីរ; ការស្វែងយល់របស់ការស្រាវជ្រាវប្រតិបត្តិបែបសហការ

២. រៀបចំផែនការ

- អភិវឌ្ឍផែនការអន្តរាគមន៍ដោយសហការ
- កំណត់គោលដៅ ពេលវេលា សូចនាករ និងឧបករណ៍ប្រមូលទិន្នន័យ

➤ *មកពី*ៈ ដំណាក់កាល "រៀបចំផែនការ" របស់ លីរីន; "ផែនការ" របស់ ខេមីស និង ម៉ាក់ធាហ្គាត

៣. សកម្មភាព

- អនុវត្តយុទ្ធសាស្ត្រដែលបានរៀបចំផែនការនៅក្នុងថ្នាក់រៀន
- ធ្វើឱ្យសិស្សចូលរួមក្នុងការរៀនដោយសកម្ម សន្តិភាព និងរួមបញ្ចូល

➤ *មកពី*ៈ ដំណាក់កាល "សកម្មភាព" របស់ លីរីន; "អនុវត្ត" របស់ ស្ត្រីងហ្គ្រីរ

៤. សង្កេត

- ប្រមូលទិន្នន័យ និងតាមដានការផ្លាស់ប្តូរក្នុងថ្នាក់រៀនដោយមានប្រព័ន្ធ
- កត់ត្រាប្រតិកម្ម ការចូលរួម និងអាកប្បកិរិយារបស់សិស្ស

➤ *មកពី*៖ ដំណាក់កាល "សង្កេត" របស់ ខេមីស និង ម៉ាក់ធាហ្គាត; ការចងក្រងឯកសាររបស់ការស្រាវជ្រាវប្រតិបត្តិបែបសហការ

៥. ឆ្លុះបញ្ចាំង

- វិភាគការរកឃើញ និងពិភាក្សាជាមួយក្រុម ឬអ្នកណែនាំ
- កំណត់អត្ថបទដែលបានរៀន និងលទ្ធផលដែលមិនបានរំពឹងទុក

➤ *មកពី*៖ ដំណាក់កាល "ឆ្លុះបញ្ចាំង" របស់ ខេមីស និង ម៉ាក់ធាហ្គាត "គិត" របស់ ស្ត្រីងហ្គឺរ

៦. កែលម្អ និងចែករំលែក

- កែលម្អផែនការសម្រាប់វដ្តបន្ទាប់ដោយផ្អែកលើការឆ្លុះបញ្ចាំង
- ចែករំលែកលទ្ធផលជាមួយក្រុមការងារ ឬនៅក្នុងសិក្ខាសាលា

➤ *មកពី*៖ ដំណាក់កាល "ផែនការឡើងវិញ" របស់ការស្រាវជ្រាវប្រតិបត្តិបែបសហការ "ស្វែងយល់ពីការពិត" របស់ លីរ៉ីន

ត្រឡប់ទៅជំហាន ១(វដ្តថ្មីចាប់ផ្តើម)

- ការកែលម្អបន្តដើម្បីឆ្ពោះទៅរកថ្នាក់រៀនសន្តិភាព និងឆ្លុះបញ្ចាំង។

៤.១. ជំហាន ១៖ ការកំណត់អត្តសញ្ញាណ និងធ្វើរោគវិនិច្ឆ័យបញ្ហា

ជំហានដំបូងក្នុងការស្រាវជ្រាវប្រតិបត្តិពាក់ព័ន្ធនឹងការស្គាល់ បញ្ជាក់ឱ្យច្បាស់ និងយល់ពីបញ្ហាដែលប៉ះពាល់ដល់បរិស្ថានរៀនសូត្រ។ ចំពោះគំនិតផ្តួចផ្តើមអហិង្សា នេះមានន័យថាការកំណត់រូបរាងជាក់លាក់នៃអំពើហិង្សា — រាងកាយ ពាក្យសម្តី ផ្លូវចិត្ត ឬរចនាសម្ព័ន្ធ — ដែលកើតឡើងនៅក្នុងថ្នាក់រៀន ឬសាលា។ តាមរបាយការណ៍របស់មីល្ល៍ (២០១៧) ដំណាក់កាលរោគវិនិច្ឆ័យនេះធានាថាអ្នកស្រាវជ្រាវស្វែងយល់ពីបញ្ហាពិត ដែលជាក់លាក់តាមបរិបទ ហើយប៉ះពាល់ពិតដល់អ្នករៀន។

នៅក្នុងសាលាកម្ពុជា អំពើហិង្សាអាចមានដូចជាការស្រែក ការធ្វើឱ្យអាម៉ាស់ ការគំរាមកំហែង ការវាយដោយបន្ទះឈើ ការបង្ករគ្រោះថ្នាក់ដោយមិត្តភក្តិ ឬការរើសអើងមិនឱ្យចូលរួមក្នុងក្រុម។ ការស្រាវជ្រាវត្រូវតែចាប់ផ្តើមដោយការវាយតម្លៃដោយហ្មត់ចត់ និងស្មោះត្រង់នូវអ្វីដែលកំពុងកើតឡើង និងមូលហេតុដែលវាកើតឡើង។

គ្រូឧទ្ទេស និងគរុនិស្សិតអាចប្រើវិធីខាងក្រោមដើម្បីធ្វើរោគវិនិច្ឆ័យបញ្ហា។ Mertler (2019) ណែនាំឱ្យប្រើប្រាស់វិធីសាស្ត្រវិភាគប្រភពទិន្នន័យបី ដើម្បីចៀសវាងការសន្និដ្ឋានបែបអត្តនោម័ត និងធានាបាននូវសុក្រឹតភាពនៃព័ត៌មាន។

- ការសង្កេតថ្នាក់រៀន
- ការជជែកក្រៅផ្លូវការរួមគ្នាជាមួយសិស្ស
- ការពិភាក្សាក្រុមគោលដៅ
- ការពិនិត្យឡើងវិញលើកំណត់ត្រាវិន័យសាលា
- កំណត់ត្រាឆ្លុះបញ្ចាំង
- ការពិភាក្សាជាមួយគ្រូណែនាំ និងអ្នកដឹកនាំសាលា

ឧទាហរណ៍

ក្នុងអំឡុងពេលចុះកម្មសិក្សានៅខេត្តបាត់ដំបង គរុនិស្សិតម្នាក់សង្កេតឃើញថាសិស្សថ្នាក់ទី៥មួយចំនួនមានអាការៈព្រួយបារម្ភក្នុងម៉ោងសិក្សាភាសាអង់គ្លេស។ តាមរយៈការសង្កេត គាត់តែងតែលឺគ្រូបន្ទុកថ្នាក់ ស្រែកខ្លាំងៗថា "អត់ស្តាប់!"។ ក្រោយមកតាមរយៈសកម្មភាពគូររូប សិស្សមួយចំនួនបានបង្ហាញថាពួកគេ "មានអារម្មណ៍ភ័យខ្លាច" ក្នុងម៉ោងរៀន។ គរុនិស្សិតរូបនោះបានកំណត់ថា ការប្រើពាក្យសម្តីគំរាមកំហែង និងការប្រើវិន័យដែលបង្កឱ្យមានភាពភ័យខ្លាចគឺជាបញ្ហាស្នូល។

លទ្ធផលនៃដំហាន ១ៈ បញ្ហាអាចត្រូវបានធ្វើរោគវិនិច្ឆ័យ

សេចក្តីថ្លែងបញ្ហាដែលអាចស្រាវជ្រាវបានច្បាស់លាស់ ដូចជាៈ "*សិស្សជាច្រើននៅក្នុងថ្នាក់ទី៥ ក បង្ហាញសញ្ញានៃការភ័យខ្លាច និងការមិនចូលរួមដោយសារការជាក់ទណ្ឌកម្មតាមពាក្យសម្តី និងការស្រែកដែលត្រូវបានប្រើជាវិន័យញឹកញាប់។*"

៤.២. ដំហាន ២ៈ ការរៀបចំផែនការសម្រាប់សកម្មភាព

នៅពេលដែលបញ្ហាត្រូវបានធ្វើរោគវិនិច្ឆ័យយ៉ាងច្បាស់ ដំហានបន្ទាប់គឺការរចនាអន្តរាគមន៍ដែលមានគ្រឹះលើយុទ្ធសាស្ត្រអហិង្សា ដែលផ្តោតលើកុមារ និងបានបង្ហាញកស្តុតាង។ ការរៀបចំផែនការទាមទារការ *ពិនិត្យឡើងវិញអក្សរសាស្ត្រ ជ្រើសរើសយុទ្ធសាស្ត្រ* ដែលស្របជាមួយគោលការណ៍វិន័យវិជ្ជមាន និងធានាភាពអាចអនុវត្តបាន

នៅក្នុងថ្នាក់រៀនកម្ពុជា ដែលអាចមានអ្នកច្រើនពេក និងមានធនធានកំណត់។ ខេមីស និង ម៉ាក់ធាហ្គាត (១៩៨៨) ដាក់ពិន្ទុថាការរៀបចំផែនការគួរតែធ្វើជាក្រុមនៅពេលដែលអាចធ្វើទៅបាន ជាពិសេសនៅពេលដែលបញ្ហាពាក់ព័ន្ធនឹងបទប្បញ្ញត្តិវប្បធម៌រួមគ្នាជុំវិញវិន័យ។ ផែនការដ៏ទូលំទូលាយមួយរួមមាន៖

- គោលដៅជាក់លាក់ (ឧ. កាត់បន្ថយការស្រែក ៧០% ក្នុងរយៈពេលមួយខែ)
- យុទ្ធសាស្ត្រអន្តរាគមន៍ (ឧ. ការប្រើការពង្រឹងវិជ្ជមាន ការទំនាក់ទំនងអហិង្សា កិច្ចព្រមព្រៀងថ្នាក់រៀន)
- អ្នកទទួលខុសត្រូវ (គ្រូ គរុនិស្សិត គ្រូណែនាំ)
- ពេលវេលា
- ធនធានដែលត្រូវការ
- វិធីសាស្ត្រប្រមូលទិន្នន័យ
- ការការពារក្រមសីលធម៌

ឧទាហរណ៍

ក្រោយពីធ្វើរោគវិនិច្ឆ័យបញ្ហា គរុនិស្សិតបានប្រឹក្សាជាមួយគ្រូណែនាំរបស់គាត់ និងពិនិត្យឡើងវិញសម្ភារៈយូណីសេហ្វកម្ពុជាអំពីវិន័យវិជ្ជមាន។ នាងបានបង្កើតផែនការអន្តរាគមន៍រយៈពេលមួយខែ រួមមាន៖

- ការណែនាំ "កិច្ចព្រមព្រៀងគោរពគ្នាក្នុងថ្នាក់រៀន" ដែលសរសេររួមគ្នាជាមួយសិស្ស
    - ការប្រើការសរសើរ កាតស្គាល់ និងមតិត្រឡប់គាំទ្រ
    - ការជំនួសការស្រែកដោយសញ្ញាដៃ និងសញ្ញាសម្ងាត់ស្ងៀមស្ងាត់
    - យកពេលឈប់ ៣០ វិនាទីនៅពេលមានអារម្មណ៍ធុញទ្រាន់
    - ការប្រជុំថ្នាក់រៀនរៀងរាល់សប្តាហ៍ដើម្បីពិភាក្សាអំពីអារម្មណ៍

លទ្ធផលនៃជំហាន ២៖

ផែនការសកម្មភាពជាលាយឡំ ត្រៀមសម្រាប់ការអនុវត្តសកម្មភាពដែលបានរៀបចំផែនការខាងលើ។

៤.៣. ជំហាន ៣៖ ការសម្រេចសកម្មភាព (ការអនុវត្ត)

ក្នុងជំហាននេះ គរុនិស្សិត ឬគ្រូកាន់ថ្នាក់ ជាអ្នកស្រាវជ្រាវចាប់ផ្តើមអនុវត្តអន្តរាគមន៍ដែលបានរៀបចំផែនការ (សូមមើលជំហាន ២)។ នេះគឺជាកន្លែងដែលការផ្លាស់ប្តូរកើតឡើងពិតប្រាកដ។ តាមរបាយការណ៍របស់

មែតឡឺ (២០១៩) ការអនុវត្តត្រូវតែនៅតែមានភាពបត់បែនដើម្បីអនុញ្ញាតឱ្យមានការកែលម្អនៅពេលដែលបញ្ហាដែលមិនបានរំពឹងទុកកើតឡើង។ ខាងក្រោមនេះជាចំណុចចាំបាច់ដែលត្រូវពិចារណា៖

- រក្សាភាពស៊ីសង្វាក់គ្នា
- ទំនាក់ទំនងឱ្យបានច្បាស់ជាមួយសិស្ស
- តាមដានសុវត្ថិភាពផ្លូវចិត្ត
- ចងក្រងឯកសារស្តីពីសកម្មភាពដែលបានអនុវត្ត
- សម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយគ្រូណែនាំ
- ធ្វើជាគំរូនូវអាកប្បកិរិយាអហិង្សា

វាជារឿងសមរម្យក្នុងការរំលឹកថាគ្រូអប់រំគួរណែនាំគរុនិស្សិតឱ្យរក្សាភាពវិជ្ជាជីវៈ ខណៈដែលពួកគេសាកល្បងវិធីសាស្ត្រថ្មី។

ឧទាហរណ៍

ក្នុងអំឡុងសប្តាហ៍ដំបូង គរុនិស្សិតណែនាំ "*កិច្ចព្រមព្រៀងគោរពគ្នាក្នុងថ្នាក់រៀន*" ដោយធ្វើឱ្យសិស្សចូលរួមក្នុងការពិភាក្សាអំពី របៀបដែលពួកគេចង់ឱ្យគេប្រព្រឹត្តចំពោះខ្លួន។ គាត់សង្កេតឃើញថាសិស្សខ្លះអៀនអ្នកនិយាយ ដូច្នេះគាត់បានប្រើកាតរូបភាព (មុខសប្បាយ/ទុក្ខ/មិនប្រាកដ) ដើម្បីឱ្យពួកគេបង្ហាញអារម្មណ៍ដោយគ្មានពាក្យសម្តី ជាការកែលម្អដែលមានភាពយកចិត្តទុកដាក់ចំពោះវប្បធម៌។ គាត់អនុវត្តការប្រើសំឡេងស្ងៀមស្ងាត់ និងតន្ត្រីយាបទជំនួសឱ្យការស្រែក។ នៅលើព្រឹត្តិការណ៍ពីរដែលគាត់មានអារម្មណ៍ធុញទ្រាន់ គាត់យកពេលឈប់ ហើយប្រើបច្ចេកទេសដកដង្ហើម។ សិស្សរៀនយ៉ាងរហ័សដើម្បីឆ្លើយតបទៅនឹងសញ្ញាដៃថ្មីសម្រាប់ "ការយកចិត្តទុកដាក់ស្ងៀមស្ងាត់" ដែលជាការកាត់បន្ថយតម្រូវការឱ្យមានការដាក់ទណ្ឌកម្មតាមពាក្យសម្តី។

លទ្ធផលនៃជំហាន ៣៖

បរិស្ថានថ្នាក់រៀនដែលបានផ្លាស់ប្តូរចាប់ផ្តើមលេចឡើង ហើយអ្នកស្រាវជ្រាវទទួលបានការយល់ដឹងពីបទពិសោធន៍ទៅលើភាពជោគជ័យ និងបញ្ហាប្រឈម។

៤.៤.ជំហាន ៤៖ ការសង្កេត និងប្រមូលទិន្នន័យ

នៅពេលដែលសកម្មភាពកំពុងដំណើរការ អ្នកស្រាវជ្រាវប្រមូលកស្តុតាងនៃផលប៉ះពាល់របស់អន្តរាគមន៍។ ការសង្កេតជួយកំណត់ថាតើយុទ្ធសាស្ត្រទាំងនោះកាត់បន្ថយអំពើហិង្សា និងកែលម្អអាកប្បកិរិយា សុខុមាលភាពផ្លូវ

ចិត្ត និងការរៀនរបស់សិស្សឬទេ។ ការសង្កេតត្រូវតែមានប្រព័ន្ធ និងអនុវត្តដោយក្រមសីលធម៌ (មីល្ល៍, ២០១៧) ហើយការប្រើទិន្នន័យបីមុខពង្រឹងភាពគួរឱ្យទុកចិត្ត (មែតឡឺ, ២០១៩)។ វិធីសាស្ត្រប្រមូលទិន្នន័យដែលសមរម្យ សម្រាប់សាលា៖

- បញ្ជីត្រួតពិនិត្យសង្កេតដែលមានរចនាសម្ព័ន្ធ
- ការស្ទង់មតិមុន និងក្រោយអន្តរាគមន៍
- ការសម្ភាសន៍ ឬក្រុមផ្តោត
- កំណត់ត្រា ឬគំនូររបស់សិស្ស
- កំណត់ហេតុអាកប្បកិរិយា
- ការថតវីដេអូ សំឡេង (ដោយមានការយល់ព្រម)
- កំណត់ត្រាឆ្លុះបញ្ចាំងរបស់អ្នកស្រាវជ្រាវ

ឧទាហរណ៍

គរុនិស្សិតប្រើឧបករណ៍បី៖

- បញ្ជីត្រួតពិនិត្យសង្កេតដែលតាមដានចំនួនដងដែលគ្រូណែនាំ ឬគាត់ដំឡើងសំឡេង។
- គំនូរអារម្មណ៍សិស្សពីរដងក្នុងមួយសប្តាហ៍។
- ការសម្ភាសន៍ខ្លីជាមួយសិស្ស ៥ នាក់ដែលបានជ្រើសរើសដោយចៃដន្យ (ដោយយល់ព្រមពីឪពុកម្តាយ)។

ក្រោយពីបីសប្តាហ៍ ឧបទ្ទវហេតុស្រែកបានធ្លាក់ពី ១២ ក្នុងមួយសប្តាហ៍ទៅ ៣ ក្នុងមួយសប្តាហ៍។ គំនូររបស់សិស្សកាន់តែបង្ហាញពី "ថ្នាក់រៀនសប្បាយរីករាយ"។

ការសម្ភាសន៍បង្ហាញថាសិស្សមានអារម្មណ៍ "មានផាសុខភាពច្រើនជាង" និង "ខ្លាចតិចជាង"។

លទ្ធផលនៃជំហាន ៤៖

ការប្រមូលកស្តុតាងដែលមានសុពលភាព គួរឱ្យទុកចិត្ត និងប្រមូលដោយក្រមសីលធម៌។

៤.៥. ជំហាន ៥៖ ការឆ្លុះបញ្ចាំង និងបកស្រាយលទ្ធផល

ការឆ្លុះបញ្ចាំងអនុញ្ញាតឱ្យអ្នកស្រាវជ្រាវវិភាគទិន្នន័យ កំណត់អត្តសញ្ញាណភាពជោគជ័យ និងបញ្ហាប្រឈម ហើយបកស្រាយពីអត្ថន័យ និងផលប៉ះពាល់នៃការរកឃើញ។ ការឆ្លុះបញ្ចាំងគឺជាផ្នែកសំខាន់នៃការ

ស្រាវជ្រាវប្រតិបត្តិពីព្រោះ ដូចដែលខេមីស និង ម៉ាក់ធាហ្គាត (១៩៨៨) អះអាងថា សកម្មភាពទទួលបានតម្លៃតែតាមរយៈការបកស្រាយដោយគិតគូរ។ សំណួរឆ្លុះបញ្ចាំងទូទៅមាន៖

- តើអ្វីខ្លះបានផ្លាស់ប្តូរ?
- ហេតុអ្វីបានជាការផ្លាស់ប្តូរទាំងនេះកើតឡើង?
- តើបញ្ហាប្រឈមអ្វីខ្លះនៅតែបន្ត?
- តើសិស្សបានឆ្លើយតបយ៉ាងដូចម្តេចទាំងផ្លូវចិត្ត និងអាកប្បកិរិយា?
- តើខ្ញុំបានរៀនអ្វីខ្លះអំពីការបង្រៀន វិន័យ និងអារម្មណ៍របស់កុមារ?
- តើទិន្នន័យបង្ហាញពីអ្វីខ្លះអំពីជំហានបន្ទាប់?

ឧទាហរណ៍

គរុនិស្សិតកត់ត្រា៖

- ការស្រែកបានកាត់បន្ថយយ៉ាងច្រើន។
- សិស្សបានក្លាយជាសហការច្រើនជាងមុន។
- សិស្សពីរនាក់នៅតែបង្ហាញពីការថប់បារម្ភដោយសារអំពើហិង្សានៅផ្ទះ។
- គ្រូណែនាំជួនកាលធ្លាក់ទៅក្នុងការស្រែកវិញ ជាពិសេសនៅថ្ងៃដែលមានការងារច្រើន។

គាត់ឆ្លុះបញ្ចាំង ថាអន្តរាគមន៍មានប្រសិទ្ធភាព ប៉ុន្តែត្រូវការការពង្រឹង និងពង្រីក។ គាត់ក៏ទទួលស្គាល់ថាយុទ្ធសាស្ត្រអហិង្សាគឺជារឿងថ្មីសម្រាប់គ្រូខ្លះ ហើយត្រូវការការផ្លាស់ប្តូរផ្នែកគំនិត។

គាត់សន្និដ្ឋាន ថាវិន័យវិជ្ជមានបានរួមចំណែកដល់ថ្នាក់រៀនមួយដែលមានសុវត្ថិភាពជាង ប៉ុន្តែភាពគង់វង្សត្រូវការការសហការយ៉ាងរឹងមាំជាមួយគ្រូណែនាំរបស់គាត់។

លទ្ធផលនៃជំហាន ៥៖

រូបភាពច្បាស់លាស់នៃលទ្ធផល និងមេរៀនដែលបានរៀន ដែលបង្កើតជាមូលដ្ឋានសម្រាប់វដ្តបន្ទាប់។

៤.៦. ជំហាន ៦៖ ការកែលម្អ និងចែករំលែក

ជំហានចុងក្រោយបិទវដ្តការស្រាវជ្រាវ និងបើកទ្វារសម្រាប់វដ្តនាពេលអនាគត។ *"ការកែលម្អ"* មានន័យថាការលៃតម្រូវអន្តរាគមន៍ដោយផ្អែកលើការរកឃើញ។ *"ការចែករំលែក"* មានន័យថាការផ្សព្វផ្សាយលទ្ធផលទៅក្រុម

ការងារ ថ្នាក់ដឹកនាំសាលា កម្មវិធីអប់រំគ្រូ ឬសហគមន៍ធំជាង។ ការចែករំលែកបង្កើតសមត្ថភាពរួមគ្នាសម្រាប់អហិង្សា (មែតឡឺ, ២០១៩)។ ខាងក្រោមនេះជាទម្រង់ខ្លះនៃការចែករំលែកដែលអាចយកទៅអនុវត្តបាន៖

- ការប្រជុំបុគ្គលិក
- ការបង្ហាញសហគមន៍
- សិក្ខាសាលាបណ្តុះបណ្តាលគ្រូ
- ការពិភាក្សាជាមួយគ្រូណែនាំ
- ផ្ទាំងរូបភាព ឬវីដេអូ
- របាយការណ៍សរសេរ
- ការបង្ហាញនៅក្នុងវគ្គសិក្សានៃសាលាគរុកោសល្យ

គ្រូឧទ្ទេសគួរលើកទឹកចិត្តឱ្យគរុនិស្សិតចងក្រង និងចែករំលែកការរកឃើញការស្រាវជ្រាវប្រតិបត្តិរបស់ពួកគេដោយមានប្រព័ន្ធ។

ឧទាហរណ៍

គរុនិស្សិតកែលម្អផែនការរបស់គាត់ដោយបន្ថែម៖

- ការពិភាក្សាអំពីការបង្រៀនរួមគ្នាជាមួយគ្រូណែនាំរបស់គាត់ឱ្យកាន់តែច្រើន។
- "ជ្រុងស្ងប់ស្ងាត់" សម្រាប់សិស្សដែលមានអារម្មណ៍លើសលប់។
- ការប្រជុំឪពុកម្តាយរៀងរាល់ខែដើម្បីពិភាក្សាអំពីវិន័យវិជ្ជមាន។

គាត់បានចែករំលែកការរកឃើញការស្រាវជ្រាវប្រតិបត្តិរបស់គាត់ជាមួយសាលាបឋមសិក្សាទាំងមូលក្នុងអំឡុងការប្រជុំបុគ្គលិក ហើយក្រោយមកបានបង្ហាញនៅក្នុងសិក្ខាសាលាគរុកោសល្យសម្រាប់គរុនិស្សិតផ្សេងៗទៀត។ ទិន្នន័យរបស់គាត់បានលើកទឹកចិត្តឱ្យគ្រូពីរនាក់ទៀតសាកល្បងយុទ្ធសាស្ត្រវិន័យអហិង្សា។

លទ្ធផលនៃដំហាន ៦៖

ចំណេះដឹងរីកចម្រើន ការអនុវត្តកែលម្អ ហើយវដ្តនៃការឆ្លុះបញ្ចាំង និងសកម្មភាពបន្ត។

៥. បម្រុងប្រយ័ត្នសំខាន់ៗ នៃធ្វើការស្រាវជ្រាវប្រតិបត្តិ

ការធ្វើការស្រាវជ្រាវប្រតិបត្តិដើម្បីលើកកម្ពស់អហិង្សានៅក្នុងថ្នាក់រៀនក្នុងប្រទេសកម្ពុជា គឺជាការងារដែលមានអត្ថន័យជ្រាលជ្រៅ។ ប៉ុន្តែវាក៏ទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ លើទិដ្ឋភាពសីលធម៌ វប្បធម៌ នីតិវិធី និងទំនាក់ទំនងផងដែរ។ បំរុងប្រយ័ត្ន និងអនុសាសន៍ខាងក្រោមនេះ ជួយធានាថាការស្រាវជ្រាវមាន សុវត្ថិភាព ការគោរព ប្រសិទ្ធភាព និងផ្តល់ការផ្លាស់ប្តូរពិតប្រាកដ សម្រាប់គ្រូបង្រៀន និងសិស្ស។

ហានិភ័យនៃការធ្វើឱ្យសិស្សប៉ះពាល់ផ្លូវចិត្តឡើងវិញ៖ ការពិភាក្សាអំពីអហិង្សា (កាយ វាចា ចិត្ត ឬវេទនាសម្ព័ន្ធ) អាចរំលឹកដល់ការចងចាំដែលឈឺចាប់សម្រាប់អ្នករៀនមួយចំនួន។

សំណូមពរ៖

- ប្រើបច្ចេកទេសសាកសួរដែលរសើប (ឧទាហរណ៍៖ "ប្រសិនបើមាននរណាម្នាក់ជួបប្រទះ..." ជំនួសឱ្យការសួរថា "តើឯងធ្លាប់ត្រូវបានគេវាយដែរឬទេ?")។
- ផ្តល់សិទ្ធិឱ្យសិស្សរំលងសំណួរ ឬសកម្មភាពមួយចំនួន។
- ផ្តោតលើអាកប្បកិរិយាបច្ចុប្បន្ន និងដំណោះស្រាយជាវិជ្ជមាន។
- សូមស្វែងរកការគាំទ្រពីអ្នកប្រឹក្សាប្រចាំសាលា ឬមនុស្សពេញវ័យដែលអ្នកទុកចិត្ត នៅពេលដែលអ្នកត្រូវការជំនួយ។

អតុល្យភាពនៃអំណាច រវាងគ្រូនិងសិស្ស៖ សិស្សអាចមានសម្ពាធក្នុងការផ្តល់ចម្លើយ "ល្អ" ពីព្រោះគ្រូបង្រៀនក៏ជាអ្នកស្រាវជ្រាវដែរ។

សំណូមពរ៖

- ប្រើការប្រមូលទិន្នន័យដោយមិនបញ្ចេញឈ្មោះតាមដែលអាចធ្វើទៅបាន (ឧទាហរណ៍៖ ការស្ទង់មតិដាក់ក្នុងប្រអប់ជាដើម)។
- អញ្ជើញសិស្សឱ្យ "កែតម្រូវគ្រូ" ដោយចាត់ទុកទិន្នន័យជាការរៀនសូត្ររួមគ្នា, មិនមែនប្រើអំណាចគ្រូទេ។
- សង្កត់ធ្ងន់ថា ភាពស្មោះត្រង់ជួយកែលម្អថ្នាក់រៀន មិនមែនប៉ះពាល់ដល់ពិន្ទុឡើយ។

លក្ខណៈរសើបនៃហិង្សាក្នុងសាលា៖ ប្រធានបទដូចជាការស្រែកគំហក ការគំរាមកំហែង ការវាយដំ ឬការបង្អាប់ គឺជាបញ្ហាវិជ្ជាជីវៈ និងបញ្ហាស្ថាប័នដ៏ធ្ងន់ធ្ងរ។

សំណូមពរ៖

- ផ្តោតការស្រាវជ្រាវប្រតិបត្តិលើកំណែលម្អការអនុវត្ត មិនមែនស្តីបន្ទោសបុគ្គលណាមួយឡើយ។
- ត្រូវបញ្ជាក់ឱ្យច្បាស់ថា ការស្រាវជ្រាវមានគោលបំណងពង្រឹងការបង្រៀន មិនមែនដើម្បីវាយតម្លៃគ្រូបង្រៀនទេ។
- ចៀសវាងការបញ្ចេញឈ្មោះគ្រូជាក់លាក់។

ការភ័យខ្លាចចំពោះហានិភ័យវិជ្ជាជីវៈ៖ គ្រូមួយចំនួនអាចបារម្ភថា ការទទួលស្គាល់បញ្ហាប្រឈមក្នុងថ្នាក់រៀន នឹងប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ ឬការងាររបស់ពួកគេ។

សំណូមពរ៖

- ការពារអត្តសញ្ញាណគ្រូ ដោយប្រើឈ្មោះសម្គាល់ដូចជា "គ្រូ ក" ឬ "ថ្នាក់ ខ"ជាដើម។
- ចែករំលែកលទ្ធផលដែលស្រាវជ្រាវរកឃើញ ក្នុងន័យបង្ហាញពីការរីកចម្រើន មិនមែនបង្ហាញកំហុសទេ។
- សង្កត់ធ្ងន់ថា AR គឺជាឧបករណ៍សម្រាប់អភិវឌ្ឍវិជ្ជាជីវៈ។

ការប្រមូលទិន្នន័យពាក់ព័ន្ធនឹងអនីតិជន៖ ការស្រាវជ្រាវជាមួយកុមារត្រូវតែធានានូវសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរជានិច្ច។

សំណូមពរ៖

- សុំសច្ចានុម័តដោយផ្ទាល់មាត់ពីសិស្សដោយប្រើភាសាសមស្របតាមវ័យ។
- ប្រសិនបើសម្ភាសន៍កុមារ ត្រូវធ្វើក្នុងទីកន្លែងសាធារណៈ (ដូចជាថ្នាក់រៀនដែលបើកចំហ) ដើម្បីចៀសវាងការយល់ច្រលំ។
- ប្រើវិធីសាស្ត្រដែលកុមារមានភាពងាយស្រួលដូចជា ការគូររូប ការសម្តែងតួ ឬនិទានរឿងជាដើម។

ភាពរសើបផ្នែកវប្បធម៌ពាក់ព័ន្ធនឹងវិន័យ៖ ប្រទេសកម្ពុជា នៅតែមានបទដ្ឋានប្រពៃណីដែលទទួលយកការដាក់វិន័យតឹងរ៉ឹងដូចជា ការស្រែកគំហក ឬការវាយដំ។

សំណូមពរ៖

- ប្រើភាសាដែលទន់ភ្លន់និងគោរពវប្បធម៌ ដោយផ្តោតលើ "ការកែលម្អសុខដុមរមនា និងប្រសិទ្ធភាពក្នុងថ្នាក់រៀន"។
- ចៀសវាងបង្ហាញថា ការអនុវត្តនោះ "ខុស" ប៉ុន្តែត្រូវបង្ហាញពីជម្រើសផ្សេងៗដោយផ្អែកលើកស្តុតាងដែលជួយដល់ការសិក្សារៀនសូត្រ។

- ចូលរួមពិភាក្សាអំពីលទ្ធផលស្រាវជ្រាវ ជាមួយរៀមច្បង ឬថ្នាក់ដឹកនាំសាលា ដោយការគោរព។

ហានិភ័យនៃការរក្សាការសម្ងាត់ក្នុងសហគមន៍សាលាតូចៗ៖ នៅក្នុងសាលាតូចៗ វាងាយស្រួលក្នុងការទស្សន៍ទាយថានរណាជាអ្នកត្រូវបានគេសរសេររៀបរាប់បង្ហាញ។

សំណូមពរ៖

- ចៀសវាងព័ត៌មានលម្អិតដែលអាចកំណត់អត្តសញ្ញាណសិស្សបាន (ឧទាហរណ៍៖ "សិស្សដែលខ្ពស់ជាងគេក្នុងថ្នាក់ទី៥")។
- រក្សាទុកទិន្នន័យ(សំឡេង អក្សរ កម្រងសំណួរជាដើម) ក្នុងកន្លែងដែលមានសុវត្ថិភាពដោយមានចាក់សោរកំណត់លេខសម្ងាត់។
- ចែករំលែកតែទម្រង់រួមទូទៅ ឬប្រធានបទធំៗ មិនមែនករណីបុគ្គលជាក់លាក់ណាមួយឡើយ។

កង្វះជំនាញស្រាវជ្រាវក្នុងចំណោមគ្រូឧទ្ទេសនិងគរុនិស្សិត៖ អ្នកស្រាវជ្រាវមួយចំនួន អាចមិនមានទំនុកចិត្តលើការប្រមូល ឬវិភាគទិន្នន័យ។

សំណូមពរ៖

- ផ្តល់ឧបករណ៍សាមញ្ញៗ (តារាងផ្ទៀងផ្ទាត់ ទម្រង់សង្កេត គំរូលិខិតសច្ចានុម័ត)។
- សហការជាមួយរៀមច្បងដែលជាអ្នកណែនាំ។
- ចាប់ផ្តើមដោយវដ្ត AR ខ្នាតតូចជាមុនសិន ដើម្បីបង្កើតជំនឿទំនុកចិត្ត។

គម្រោងដែលមានមហិច្ឆតាធំពេក៖ ការព្យាយាមដោះស្រាយ "ហិង្សាទាំងអស់" ក្នុងពេលតែមួយ ធ្វើឱ្យការស្រាវជ្រាវមិនអាចទៅរួចទេ។

សំណូមពរ៖ សូមជ្រើសរើសបញ្ហាមួយដែលច្បាស់លាស់ និងអាចគ្រប់គ្រងបាន ដូចជា៖

- ការកាត់បន្ថយការស្រែកដាក់សិស្ស អំឡុងពេលសិស្សធ្វើការងារក្រុម
- ពង្រឹងការគោរពគ្នាក្នុងក្រុម អំឡុងពេលលេងល្បែងសិក្សា
- ការបង្ការការហៅឈ្មោះក្រៅមិនល្អ អំឡុងពេលបង្រៀន
- ចាប់ផ្តើមពីតូច និងកែលម្អជាបន្តបន្ទាប់។

ការកម្រិតពេលវេលាសម្រាប់គ្រូ៖ ការស្រាវជ្រាវប្រតិបត្តិ មិនគួរធ្វើឱ្យគ្រូមានបន្ទុកការងារធ្ងន់ធ្ងរពេកឡើយ។ ការស្រាវជ្រាវប្រតិបត្តិមិនគួរធ្វើឱ្យគ្រូមានអារម្មណ៍ធុញថប់នោះទេ។

សំណួមពរ៖

- បញ្ចូលការប្រមូលទិន្នន័យទៅក្នុងការបង្រៀនប្រចាំថ្ងៃ (ឧទាហរណ៍៖ សង្កេតអាកប្បកិរិយាអំឡុងពេលសកម្មភាពរៀនធម្មតាជាដើម)។
- ប្រើវដ្តតូច (2-3សប្តាហ៍)។
- ប្រើប្រាស់ឧបករណ៍ដែលចំណាយពេលមិនលើសពី 10នាទីក្នុងមួយថ្ងៃ។

ការបកស្រាយទិន្នន័យខុស៖ គ្រូ អាចនឹងយល់ច្រឡំលើអាកប្បកិរិយារបស់សិស្ស ឬធ្វើសេចក្តីសន្និដ្ឋានទូទៅហួសហេតុពេកចំពោះលទ្ធផលដែលរកឃើញ។

សំណួមពរ៖

- ប្រើប្រភពទិន្នន័យច្រើន (ការសង្កេត ខ្សែអាត់សំឡេងសិស្ស កំណត់ត្រាវង្វាយតម្លៃជាដើម)។
- ពិភាក្សាការបកស្រាយលទ្ធផលជាមួយរៀមច្បងណែនាំឬក្រុម។
- ផ្តោតលើលំនាំនៃសកម្មភាព មិនមែនលើរឿងរ៉ាវដែលកើតឡើងតែម្តងម្កាលនោះទេ។

ការបកស្រាយដែលមានភាពលំអៀងដោយសារជំនឿបុគ្គល៖ គ្រូបង្រៀនអាចនឹងបកស្រាយទិន្នន័យដោយផ្អែកលើការសន្មតផ្ទាល់ខ្លួនអំពី ពូជសាសន៍ យេនឌ័រ សមត្ថភាព ឬប្រវត្តិគ្រួសារ។

សំណួមពរ៖

- ឆ្លុះបញ្ចាំងពីភាពលំអៀងផ្ទាល់ខ្លួន មុនពេលចាប់ផ្តើមធ្វើការស្រាវជ្រាវប្រតិបត្តិ (ឧទាហរណ៍៖ តើខ្ញុំតែងតែសន្មតថា ក្មេងប្រុសចូលចិត្តបង្ការរំខានជាងក្មេងស្រីមែនទេ?)។
- ប្រើប្រាស់ភស្តុតាង ដើម្បីមកផ្ទៀងផ្ទាត់ ឬជំទាស់នឹងការសន្មតទាំងឡាយ។
- ផ្តល់អាទិភាពលើការអនុវត្តបែបសិស្សមជ្ឈមណ្ឌល និងផ្អែកលើសិទ្ធិជាមូលដ្ឋាន រាល់ការសម្រេចចិត្តទាំងអស់។

ជម្លោះដែលអាចកើតមានជាមួយអាណាព្យាបាល៖ ឪពុកម្តាយអាចយល់ច្រលំអំពីគោលបំណងនៃ ការស្រាវជ្រាវពាក់ព័ន្ធនឹងវិន័យថ្នាក់រៀន។

សំណួមពរ៖

- ពន្យល់ដោយពាក្យសាមញ្ញថា "យើងកំពុងសាកល្បងវិធីថ្មីៗដើម្បីពង្រឹងការគោរព សុវត្ថិភាព និងការចូលរួមរបស់សិស្ស"។

- ចៀសវាងការចែករំលែកទិន្នន័យរសើបរបស់សិស្ស។
- បង្ហាញឱ្យឃើញច្បាស់ ពីវិធីដែលការស្រាវជ្រាវប្រតិបត្តិមានគោលបំណងជួយដល់សហគមន៍សាលារៀនទាំងមូល។

ការរាយការណ៍ និងការចែករំលែកប្រកបដោយក្រមសីលធម៌៖ ការចែករំលែកលទ្ធផលស្រាវជ្រាវ អាចធ្វើឱ្យប៉ះពាល់ដល់បុគ្គលដោយអចេតនា។

សំណូមពរ៖

- ផ្តោតរបាយការណ៍លើលំនាំគំរូ ដំណោះស្រាយ និងការអនុវត្តដែលបានកែលម្អ។
- ប្រើប្រាស់ពាក្យសម្តីដោយមិនរិះគន់ឬវាយតម្លៃ។
- ចែករំលែកលទ្ធផល ជាសាច់រឿងដែលត្រូវរៀនសូត្រ មិនមែនជាការវាយតម្លៃនោះទេ។

៦. គោលការណ៍ណែនាំសម្រាប់ក្រូឧទ្ទេស

ក្នុងនាមជាអ្នកត្រួតពិនិត្យ អ្នកត្រូវបង្វឹក តាមដាន ជំរុញ និងគាំទ្រគរុនិស្សិត នៅពេលពួកគេអនុវត្តការស្រាវជ្រាវប្រតិបត្តិក្នុងថ្នាក់រៀន។ តួនាទីរបស់អ្នកគឺ ធានាថា ការស្រាវជ្រាវនោះអាចអនុវត្តបានជាក់ស្តែង ប្រកបដោយក្រមសីលធម៌ មានភាពម៉ឺងម៉ាត់ គ្រប់គ្រាន់សម្រាប់ការរៀនសូត្រ និងត្រូវបានបញ្ចប់ទាន់ពេលវេលា។

ការស្រាវជ្រាវប្រតិបត្តិ គឺជាឧបករណ៍អភិវឌ្ឍន៍វិជ្ជាជីវៈដ៏មានឥទ្ធិពលមួយ ដែលអនុញ្ញាតឱ្យគរុនិស្សិតសិក្សាពីបញ្ហាជាក់ស្តែងនៅក្នុងថ្នាក់រៀនរបស់ពួកគេ អនុវត្តសកម្មភាពជាក់ស្តែង និងឆ្លុះបញ្ចាំងពីឥទ្ធិពលនៃសកម្មភាពទាំងនេះ ដើម្បីកែលម្អបរិយាកាសសិក្សា (Stringer, 2014)។ នៅពេលផ្តោតលើការកាត់បន្ថយ ឬបង្ការអំពើហិង្សា ការស្រាវជ្រាវប្រតិបត្តិ មិនត្រឹមតែជាលំហាត់នៃការស្រាវជ្រាវប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការទទួលខុសត្រូវផ្នែកសីលធម៌ និងគរុកោសល្យ ដែលរួមចំណែកដោយផ្ទាល់ដល់សុខុមាលភាពកុមារ វិន័យវិជ្ជមាន និងបរិយាកាសសិក្សាប្រកបដោយសុវត្ថិភាពផងដែរ (UNICEF, 2019)។

គោលការណ៍ណែនាំនេះគាំទ្រដល់អ្នកគ្រូបង្រៀនក្នុងការណែនាំគ្រូសិក្សាឱ្យមានប្រសិទ្ធភាព ខណៈពេលដែលពួកគេកំពុងរៀបចំផែនការ អនុវត្ត និងរាយការណ៍ពីគម្រោងការស្រាវជ្រាវបណ្តុះបណ្តាលអនុវត្ត ដែលផ្តោតលើការលើកកម្ពស់អហិង្សាក្នុងថ្នាក់រៀន។ គំរូការស្រាវជ្រាវបណ្តុះបណ្តាលអនុវត្តដែលបានសម្របសម្រួលជា៦ជំហាន ដែលប្រើប្រាស់ក្នុងសៀវភៅណែនាំនេះ រួមមាន៖

ជំហានទី 1: កំណត់ និងវែកញែកបញ្ហា

ជំហានទី 2: រៀបចំផែនការសកម្មភាព

ជំហានទី 3: អនុវត្តសកម្មភាព (ការអនុវត្ត)

ជំហានទី 4: សង្កេត និងប្រមូលទិន្នន័យ

ជំហានទី 5: ឆ្លុះបញ្ចាំង និងបកស្រាយលទ្ធផល

ជំហានទី 6: ពិនិត្យឡើងវិញ និងចែករំលែក

គោលការណ៍ណែនាំនេះបង្ហាញពីគោលបំណង និយមន័យ ទស្សនៈ បញ្ហា និរន្តរភាព អន្តរកម្ម ការវាយតម្លៃ និងឧទាហរណ៍ដែលអ្នកគ្រូបង្រៀនអាចប្រើសម្រាប់ការណែនាំ និងការវាយតម្លៃនៃជំណាក់កាលនីមួយៗ។

៦.១. ការកំណត់ និងវែកញែកបញ្ហា

គោលបំណងនៃដំណាក់កាលនេះ គឺដើម្បីជួយគរុនិស្សិតឱ្យយល់ពី លក្ខណៈ មូលហេតុដើម និងទម្រង់នៃអំពើហិង្សា ក្នុងថ្នាក់រៀនដែលពួកគេបានទទួល។ ការយល់ដឹងទាំងនេះអាចជួយគរុនិស្សិតឱ្យត្រៀមខ្លួនយ៉ាងល្អសម្រាប់ដំណាក់កាលបន្ទាប់របស់ពួកគេ ជាពិសេសសម្រាប់ការអនុវត្តគមន៍របស់ពួកគេ។ ដូច្នេះ គ្រូឧទ្ទេសគួរតែណែនាំពួកគេឱ្យ៖

- បញ្ជាក់ពីអត្ថន័យនៃអំពើហិង្សាក្នុងថ្នាក់រៀនដែលពួកគេបានទទួល
    - អំពើហិង្សាលើរាងកាយ (ឧទាហរណ៍៖ វាយ ច្របាច់ គ្រវែងវត្ថុ ។ល។) និង/ឬអំពើហិង្សាដោយពាក្យសំដី (ឧទាហរណ៍៖ ស្រែក បញ្ជោទ្ធាអាជ្ញា ហៅឈ្មោះ គំរាមកំហែង)
    - អំពើហិង្សាផ្លូវចិត្ត (ឧទាហរណ៍៖ បន្ទូរបន្ថយសារៈសំខាន់ ដកចេញ ពាក្យឡកឡឹយ)
- គាំទ្រគរុនិស្សិតឱ្យបង្រួមបញ្ជាជាក់លាក់នៃអំពើហិង្សាដែលបានកំណត់
    - លើកទឹកចិត្តពួកគេឱ្យជៀសវាងការប្រើប្រាស់ប្រធានបទដែលមិនច្បាស់លាស់ ដូចជា «**អំពើហិង្សាក្នុងថ្នាក់រៀនរបស់ខ្ញុំ**» ហើយជំនួសមកវិញដោយការផ្តោតលើទម្រង់បញ្ជាក់ជាក់លាក់ណាមួយ។ ឧទាហរណ៍៖
    - ➔ *«ការដែលគ្រូឧស្សាហ៍ស្រែកខ្លាំងៗ ក្នុងអំឡុងពេលធ្វើការងារក្រុម»*
    - ➔ *«សិស្សានុសិស្សប្រើពាក្យសម្តីជេរប្រមាថគ្នា ក្នុងអំឡុងពេលធ្វើសកម្មភាពសិក្សា»*
    - ➔ *«សិស្សប្រុសៗបង្អាប់ ឬសើចចំអកឱ្យសិស្សស្រី ក្នុងអំឡុងពេលពិភាក្សាក្នុងថ្នាក់»*
- ដើម្បីជួយគរុនិស្សិតក្នុងការប្រមូលទិន្នន័យវិនិច្ឆ័យបឋម អ្នកអាចណែនាំឱ្យពួកគាត់ប្រើប្រាស់ឧបករណ៍សាមញ្ញៗដូចខាងក្រោម៖

ការសន្ទនាមិនផ្លូវការជាមួយគ្រូណែនាំនៅសាលា: ការប្រាស្រ័យទាក់ទងមិនផ្លូវការជាមួយគ្រូឧទ្ទេសនៅតាមសាលារៀន ជួយឱ្យគរុនិស្សិតទទួលបាននូវការយល់ដឹងស៊ីជម្រៅអំពីបរិបទ ប្រវត្តិរឿងរ៉ាវ និងទំនាក់ទំនងនានាដែលមិនអាចរកឃើញបានតាមរយៈការប្រើតារាងសង្កេត ឬការស្ទង់មតិតែមួយមុខនោះទេ។ គ្រូឧទ្ទេសមានចំណេះដឹង និងបទពិសោធន៍ដ៏មានតម្លៃអំពីទម្លាប់ឥរិយាបថរបស់សិស្សដែលកើតឡើង ដដែលៗ វិធានការវិន័យកាលពីមុន បទដ្ឋានក្នុងថ្នាក់រៀន និងវប្ប្ធម៌សាលា បរិបទគ្រួសារ និងសហគមន៍ របស់សិស្ស ព្រមទាំងធ្លាប់ដឹងថា តើវិធានការអនុវត្តគមន៍ណាខ្លះដែលត្រូវបានសាកល្បងរួចហើយ និងទទួលបានលទ្ធផលយ៉ាងណា។

ការប្រាស្រ័យទាក់ទងមិនផ្លូវការ អនុញ្ញាតឱ្យគរុនិស្សិតអាចរៀនសូត្របានដោយគ្មានការរិះគន់ កាត់បន្ថយការបន្ទោសទៅលើសិស្ស ឬគ្រូបង្រៀន និងជួយកំណត់បញ្ហានៃការស្រាវជ្រាវប្រតិបត្តិ ឱ្យស្របតាមតថភាពជាក់ស្តែង និងប្រកបដោយធម៌។ ក្នុងបរិបទប្រទេសកម្ពុជា ដែលការគោរពតាមហានានុក្រម និងសុខដុមរមនាមានសារៈ

សំខាន់ខ្លាំង ការប្រស្រ័យទាក់ទងមិនផ្លូវការច្រើនតែមានប្រសិទ្ធភាព និងសមស្របតាមវប្បធម៌ជាងការសម្ភាសន៍បែបផ្លូវការ នៅដំណាក់កាលវិនិច្ឆ័យដំបូងនេះ។

នៅក្នុងការស្រាវជ្រាវប្រតិបត្តិ «ការប្រស្រ័យទាក់ទងមិនផ្លូវការ» សំដៅលើការផ្លាស់ប្តូរមតិយោបល់តាមបែបធម្មជាតិ និងការជជែកគ្នាលេងរវាងគរុនិស្សិត និងគ្រូឧទ្ទេស ដែលកើតឡើងក្នុងអំឡុងពេលបំពេញការងារប្រចាំថ្ងៃនៅសាលារៀន ជាជាងការធ្វើសម្ភាសន៍ដែលមានរចនាសម្ព័ន្ធ ឬការប្រជុំផ្លូវការ។ ការសន្ទនាទាំងនេះជាធម្មតាមានរយៈពេលខ្លី បត់បែនតាមកាលៈទេសៈ ផ្អែកលើទំនាក់ទំនងល្អ មិនបង្កសម្ពាធ និងផ្តោតលើការយល់ដឹងពីបញ្ហាជាជាងការវាយតម្លៃ។

ចំណុចសំខាន់ៈ ការប្រស្រ័យទាក់ទងមិនផ្លូវការ មិនមែនជាការនិយាយដើម ការត្អូញត្អែរ ឬការរិះគន់បុគ្គលណាម្នាក់ឡើយ។ វាគឺជាការស្តាប់ដោយមានគោលបំណង និងការសាកសួរដោយថ្នមៗ ដើម្បីស្វែងយល់ពីឥរិយាបថក្នុងថ្នាក់ និងបញ្ហាវិន័យដែលពាក់ព័ន្ធនឹងអំពើហិង្សា ឬអហិង្សា។

ទោះបីជាមានវិធីសាស្ត្រជាច្រើនក្នុងការធ្វើទំនាក់ទំនងមិនផ្លូវការរវាងគរុនិស្សិត និងគ្រូឧទ្ទេសក៏ដោយ គ្រូឧទ្ទេសនៃគ្រឹះស្ថានបណ្តុះបណ្តាលគ្រូអាចណែនាំគរុនិស្សិតតាមរយៈជំហានដូចខាងក្រោមៈ

- ជំហានទី ១ៈ ជ្រើសរើសពេលវេលាដែលសមស្របៈ គរុនិស្សិតគួរស្វែងរកឱកាសដែលកើតឡើងតាមបែបធម្មជាតិ ដើម្បីកាត់បន្ថយសម្ពាធ និងធ្វើឱ្យការសន្ទនាកាន់តែមានភាពស្និទ្ធស្នាល និងបើកចំហដូចជា ក្រោយបញ្ចប់ម៉ោងបង្រៀន ក្នុងអំឡុងពេលម៉ោងសម្រាក ក្រោយពេលចេញពីសាលា ក្នុងអំឡុងពេលត្រៀមកិច្ចតែងការបង្រៀនជាមួយគ្នា ការជជែកគ្នាលេងនៅក្នុងបន្ទប់សម្រាកគ្រូបង្រៀន។
- ជំហានទី ២ៈ ចាប់ផ្តើមដោយការកោតសរសើរ និងការចង់រៀនសូត្រៈ ក្នុងជំហាននេះ គ្រូឧទ្ទេសគួរលើកទឹកចិត្តគរុនិស្សិតឱ្យចាប់ផ្តើមការសន្ទនាដោយក្តីគោរព ដើម្បីសាងទំនុកចិត្ត និងជៀសវាងការយល់ច្រឡំថាជាការរិះគន់។ ឧទាហរណ៍ៈ«ខ្ញុំរៀនសូត្របានយ៉ាងច្រើនតាមរយៈការសង្កេតមើលការបង្រៀននៅក្នុងថ្នាក់របស់លោកគ្រូ/អ្នកគ្រូ។ ខ្ញុំចង់ស្វែងយល់បន្ថែមអំពីឥរិយាបថរបស់សិស្ស ដើម្បីឱ្យខ្ញុំអាចកែលម្អការអនុវត្តការបង្រៀនរបស់ខ្ញុំឱ្យកាន់តែប្រសើរឡើង។»
- ជំហានទី ៣ៈ សួរសំណួរបើកចំហ និងមិនមានលក្ខណៈរិះគន់ៈ សំណួរគួរតែជាសំណួរដែលជំរុញឱ្យមានការឆ្លុះបញ្ចាំងជាជាងការរកលេសដោះស្រាយ។ អ្នកគួរដាស់តឿនគរុនិស្សិតឱ្យយល់ថា ពួកគេគួរជៀសវាងការប្រើសំណួរដែលឆ្លើយបានត្រឹមតែ «បាទ/ចាស» ឬ «ទេ» ព្រោះវាមិនអាចជួយឱ្យពួកគេឈ្វេងយល់ពីស្ថានភាពឱ្យបានស៊ីជម្រៅនោះទេ។ សូមពិចារណាលើឧទាហរណ៍នៃសំណួរបើកចំហខាងក្រោមៈ

"តើប្រភេទនៃបញ្ហាលើឥរិយាបថណាកើតឡើងញឹកញាប់បំផុតក្នុងថ្នាក់រៀននេះ?"

"នៅពេលសិស្សឈ្លោះប្រកែកឬស្រែក តើជាធម្មតាអ្វីជាបុព្វហេតុ?"

"តើសិស្សជាធម្មតាតបការឆ្លើយតទៅវិន័យ ឬការកែតម្រូវយ៉ាងដូចម្តេច?"

"តើបញ្ហានេះកើតមានឡើងអស់រយៈពេលយូរមកហើយ ឬថ្មីៗនេះ?"

- ជំហានទី 4៖ ស្តាប់ច្រើនជាងនិយាយ: បន្ទាប់ពីដោះស្រាយសំណួរ គ្រូសិក្សាគួរតែត្រូវបានណែនាំឱ្យស្តាប់ដោយយកចិត្តទុកដាក់។ ពួកគេគួរតែជៀសវាងការរំខាន ជៀសវាងការកែតម្រូវ ឬផ្តល់ដំបូន្មានសរសេរកំណត់ត្រាខ្លីៗបន្ទាប់ពីនោះ សង្កេតគំរូ និងប្រធានបទដែលធ្វើឡើងដដែលៗ។
- ជំហានទី 5៖ ឆ្លុះបញ្ចាំង និងបង្រួមបញ្ជូលការសង្កេត: ជំហាននេះមានសារៈសំខាន់ដើម្បីទទួលបានបញ្ហាពិតប្រាកដ។ នេះជួយជៀសវាងការលំអៀង និងការពឹងផ្អែកយ៉ាងហួសហេតុលើទស្សនៈតែមួយ។ ដូច្នេះ បន្ទាប់ពីការសន្ទនា គ្រូសិក្សាគួរតែប្រៀបធៀបអ្វីដែលពួកគេបានឮជាមួយនឹងការសង្កេតថ្នាក់រៀនផ្ទាល់ខ្លួនរបស់ពួកគេ កំណត់ត្រាអាកប្បកិរិយាសិស្ស ការផ្តល់មតិពីសិស្ស (មិនផ្លូវការ) ។ល។

1. បញ្ជីត្រួតពិនិត្យការសង្កេត៖ ជាឧបករណ៍រហ័សសម្រាប់គ្រូឧទ្ទេស និងគរុនិស្សិត ដើម្បីចាប់យកសញ្ញាដែលអាចមើលឃើញនៃអំពើហិង្សាផ្លូវកាយ និងពាក្យសម្តី បរិយាកាសក្នុងថ្នាក់រៀន និងសក្តានុពលនៃទំនាក់ទំនង។ ជាមួយនឹងបញ្ជីសង្កេត វាជួយឱ្យអ្នកសង្កេតការណ៍កំណត់យ៉ាងរហ័សនូវគំរូនៃអាកប្បកិរិយាមិនហិង្សា ឬហិង្សា បរិយាកាសផ្លូវអារម្មណ៍ និងអន្តរកម្មរបស់គ្រូសិស្ស អំឡុងពេលទស្សនាថ្នាក់រៀន 15-20 នាទី។

បញ្ជីធាតុសង្កេតរហ័ស:

បញ្ជីធាតុសង្កេត

អនុវត្តការសង្កេតខ្លីៗចំនួន ២–៣ នាក្នុងពេលវេលាផ្សេងគ្នា។ អ្នកអាចពិចារណាប្រើសញ្ញាសម្គាល់ដើម្បីតំណាងឱ្យអំពើហិង្សាដែលបានសង្កេត (√ = បាទ/ចាស់ × = ទេ ? = មិនប្រាកដ) ។ អ្នកអាចបន្ថែមកំណត់ត្រាខ្លីៗបាន ប្រសិនបើចាំបាច់។ គ្រូសិក្សាអាចប្រើបញ្ជីធាតុសង្កេតនេះ ដើម្បីជួយពួកគេកំណត់បញ្ហាជាក់លាក់ (ឧទាហរណ៍៖ "ការហៅឈ្មោះដៃគូរួមក្រុមញឹកញាប់នៅក្នុងក្រុមទី ៣" "គ្រូប្រើពាក្យជាក់ទោសជាសាធារណៈ" ។ល។)

<u>អាកប្បកិរិយារបស់គ្រូ</u>

ជាតុសង្កេត	*✓ , × , ?*	*កំណត់ត្រា*
គ្រូប្រើទឹកដមសំឡេងគួរឱ្យគោរព។		
គ្រូបន្លឺសំឡេងខ្លាំងៗដាក់សិស្ស។		
គ្រូប្រើការគំរាមកំហែង (ឧ. "ខ្ញុំនឹងដាក់ទោសអ្នក!")។		
គ្រូប្រើការគ្រប់គ្រងរាងកាយ (ទាញ រុញ វាយ)។		
គ្រូពន្យល់ពីច្បាប់យ៉ាងច្បាស់ និងវិជ្ជមាន។		
គ្រូគំរូនៃការប្រាស្រ័យទាក់ទងដោយគ្មានហិង្សា។		
គ្រូដោះស្រាយជម្លោះដោយយុត្តិធម៌។		
……		

<u>អាកប្បកិរិយារបស់សិស្ស</u>

ជាតុសង្កេត	*✓ , × , ?*	*កំណត់ត្រា*
សិស្សស្រែក ចំអក ឬហៅឈ្មោះមិត្តភក្តិ។		
សិស្សវាយគ្នា ឬប្រើការឈ្លានពានខាងរាងកាយ។		
សិស្សមិនអើពើនឹងច្បាប់ថ្នាក់រៀន។		
សិស្សសហការជាក្រុម។.		
សិស្សបង្ហាញការគោរពក្នុងពេលពិភាក្សា។		
សិស្សខ្លះដកខ្លួនចេញ ឬមើលទៅគួរឱ្យភ័យខ្លាច។		
……		

<u>បរិយាកាសថ្នាក់រៀន</u>

ជាតុសង្កេត	*✓ , × , ?*	*កំណត់ត្រា*
ការរៀបចំកន្លែងអង្គុយគាំទ្រអន្តរកម្មវិជ្ជមាន។		
ច្បាប់ថ្នាក់រៀនអាចមើលឃើញ។		
បរិយាកាសអារម្មណ៍ស្ងប់ស្ងាត់។		
ទម្លាប់ច្បាស់លាស់ត្រូវបានប្រើ (ចូល ដំណើរផ្លាស់ប្តូរ ការងារជាក្រុម)។		
សិស្សមានអារម្មណ៍ស្រួលក្នុងការសួរសំណួរ។		

សិស្សខ្លះដកខ្លួនចេញ ឬមើលទៅគួរឱ្យភ័យខ្លាច។		
……		

បន្ទាប់មកគរុនិស្សិតអាចចាប់ផ្តើមសង្ខេបជាពីរប្រភេទដោយផ្អែកលើចំនួនសញ្ញា (√)

<u>ការសង្ខេប</u>

**បញ្ហាចម្បងដែលបានសង្កេត*

- …….
- …….

** បុព្វហេតុដែលអាចកើតមាន*

- …….
- …….

1. **ការស្នង់មតិសិស្សអនាមិកខ្លី:**

<u>គំរូកម្រងសំណួរស្នង់មតិសិស្ស</u>

ផ្នែក ក៖ អារម្មណ៍សុវត្ថិភាព (សូមគូសរង្វង់ជុំវិញជម្រើសមួយ)

(១) ខ្ញុំមានអារម្មណ៍ថាមានសុវត្ថិភាពនៅក្នុងថ្នាក់រៀននេះ។

😊 បាទ/ចាស (យល់ព្រម) 😐 ជួនកាល ☹️ ទេ (មិនយល់ព្រម)

(២) សិស្សនៅក្នុងថ្នាក់នេះ ប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកដោយការគោរព។

😊 បាទ/ចាស (យល់ព្រម) 😐 ជួនកាល ☹️ ទេ (មិនយល់ព្រម)

(៣) លោកគ្រូ/អ្នកគ្រូ និយាយទៅកាន់សិស្សដោយភាពស្ងប់ស្ងាត់ និងដោយការគោរព។

😊 បាទ/ចាស (យល់ព្រម) 😐 ជួនកាល ☹️ ទេ (មិនយល់ព្រម)

ផ្នែក ខ៖ បទពិសោធន៍ទាក់ទងនឹងអំពើហិង្សា

(៤) តើប្អូនធ្លាប់ឃើញសិស្សដទៃត្រូវបានគេបង្អាប់ ជេរប្រមាថ ឬសើចចំអកឱ្យដែរឬទេ?

□ ញឹកញាប់ □ ជួនកាល □ មិនដែលសោះ

(៥) តើប្អូនធ្លាប់ឃើញមានការវាយគ្នា រុញច្រានគ្នា ឬឈ្លោះប្រកែកគ្នាដែរឬទេ?

□ ញឹកញាប់ □ ជួនកាល □ មិនដែលសោះ

(៦) តើមាននរណាម្នាក់ធ្វើឱ្យប្អូនមានអារម្មណ៍ភ័យខ្លាច ឬមិនមានផាសុកភាព (ទើសទាល់) នៅក្នុងថ្នាក់រៀនដែរឬទេ?

<u>ផ្នែក គ៖ [មតិយោបល់បន្ថែម]</u>

(៧) តើគួរមានការផ្លាស់ប្តូរអ្វីខ្លះ ដើម្បីធ្វើឱ្យថ្នាក់រៀនរបស់យើងកាន់តែមានសុវត្ថិភាព និងមានភាពស្និទ្ធស្នាលជាងមុន?_____

_____

(៨) តើមានរឿងអ្វីផ្សេងទៀតដែលប្អូនចង់ឱ្យលោកគ្រូ/អ្នកគ្រូបានដឹងដែរឬទេ?_____

2. **ការពិនិត្យឡើងវិញនូវកំណត់ត្រាអាកប្បកិរិយា ឬលំនាំនៃប្លង់កន្លែងអង្គុយ៖** វិធីសាស្ត្រដែលមានប្រព័ន្ធក្នុងការកត់ត្រានូវរាល់ហេតុការណ៍ដែលកើតឡើង ការកំណត់សម្គាល់នូវលំនាំនៃបញ្ហា និងការផ្សារភ្ជាប់បញ្ហាទាំងនោះទៅនឹងការរៀបចំកន្លែងអង្គុយ ថាមវន្តក្រុម ឬតំបន់ដែលងាយកើតមានជម្លោះ។ ឧបករណ៍នេះអាចជួយគរុនិស្សិតក្នុងការ៖
   - តាមដានអាកប្បកិរិយាដែលកើតឡើងដដែលៗ (ឧទាហរណ៍៖ ការជេរប្រមាថ ឬការឈ្លោះប្រកែកគ្នា)។

- ○ កំណត់អត្តសញ្ញាណបុគ្គល ឬទីតាំងជាក់លាក់ដែលជាកន្លែងដែលអំពើហិង្សាតែងតែធ្លាប់កើតមាន។
- ○ ស្វែងយល់ពីមូលហេតុបង្ក (ការធ្វើការងារក្រុម ម៉ោងសម្រាក ឬនៅពេលដែលគ្រូអវត្តមាន)។
- ○ រៀបចំផែនការអន្តរាគមន៍អហិង្សាដោយផ្អែកលើកស្តុតាងជាក់ស្តែង។

ឧបករណ៍នេះអាចត្រូវបានប្រើប្រាស់ជា កំណត់ហេតុនៃហេតុការណ៍ (Incident log) រាល់ពេលដែលមានអំពើហិង្សាតាមរយៈពាក្យសម្តី ឬរូបរាងកាយកើតឡើង ហើយត្រូវធ្វើបច្ចុប្បន្នភាពលើ ប្លង់កន្លែងអង្គុយ (Seating-plan map) បន្ទាប់ពីមានហេតុការណ៍នីមួយៗ។

បន្ទាប់ពីប្រមូលទិន្នន័យបាន ១ ទៅ ២ សប្តាហ៍ ត្រូវធ្វើការវិភាគលើលំនាំនៃបញ្ហា៖

«ហេតុការណ៍ភាគច្រើនកើតឡើងនៅក្បែរជ្រុងខាងក្រោយថ្នាក់។»

«សិស្សប្រុសពីរនាក់ដដែល តែងតែឈ្លោះគ្នាក្នុងអំឡុងពេលធ្វើការងារក្រុម។»

«សិស្សានុសិស្សបង្ហាប់ ឬសើចចំអកជាក់អ្នកដែលរៀនខ្សោយជាង។»

<u>តារាងកត់ត្រាព្រឹត្តិការណ៍ឥរិយាបថ</u>

កាលបរិច្ឆេទ	ម៉ោង	ប្រភេទឥរិយាបទ	សិស្សចូលរួម	ទីតាំងក្នុងថ្នាក់	សកម្មភាព	វិធីដោះស្រាយ	កំណត់ត្រាផ្សេងៗ
20-11-25	7—8	ការស្រែកឡូឡា					
	8—9	ការជេរប្រមាថ					
21-11-25	7—8	ការគ្រវែងរបស់របរ					
……	……	……					

ឧបករណ៍វិភាគគំរូនៃប្លង់អង្គុយ

ជំហានទី ១៖ គូរដ្យាក្រាមប្លង់ថ្នាក់រៀន

កំណត់សម្គាល់/និយមន័យ

X = ទីតាំងដែលកើតមានព្រឹត្តិការណ៍

! = សិស្សដែលពាក់ព័ន្ធក្នុងព្រឹត្តិការណ៍ច្រើនលើក

- ជំហានទី ២៖ កត់សម្គាល់រាល់ហេតុការណ៍

  ឧទាហរណ៍៖

  - ដាក់សញ្ញា (X) នៅលើកន្លែងអង្គុយដែលមានជម្លោះកើតឡើង។
  - ដាក់សញ្ញា (!!!) ប្រសិនបើមានហេតុការណ៍ច្រើនដងកើតឡើងនៅកន្លែងដដែល ឬពាក់ព័ន្ធនឹងសិស្សដដែល។
  - ប្រើ សញ្ញាព្រួញ ដើម្បីបង្ហាញពីសកម្មភាព (ឧទាហរណ៍៖ «ដារ៉ា ដើរទៅរក រ៉ា: ដើម្បីបង្ហាប់គេ»)។

- ជំហានទី ៣៖ កំណត់សម្គាល់លំនាំនៃបញ្ហា

  គរុនិស្សិតអាចកំណត់សម្គាល់នូវលំនាំទូទៅនៃបញ្ហា។ ឧទាហរណ៍នៃលទ្ធផលដែលរកឃើញ៖

  1. តំបន់ដែលងាយកើតមានជម្លោះ (Hotspot zone)៖ «ជម្លោះភាគច្រើនកើតឡើងនៅជ្រុងខាងឆ្វេងផ្នែកខាងក្រោយថ្នាក់។»
  2. លំនាំនៃទំនាក់ទំនងរវាងមិត្តភក្តិ៖ «សិស្សមួយគូដដែលៗ តែងតែបង្ហាប់សិស្សស្រីម្នាក់ដដែលៗ។»
  3. បញ្ហាក្នុងក្រុម៖ «ក្រុមទី ៣ តែងតែឈ្លោះប្រកែកគ្នានៅពេលធ្វើការងារក្រុម។»
  4. ឥទ្ធិពលនៃវត្តមានគ្រូ៖ «ហេតុការណ៍កើនឡើង នៅពេលដែលគ្រូកំពុងសរសេរនៅលើក្តារខៀន។»

  ចំណាំ៖ ដើម្បីពង្រឹងជំហានដំបូង (ការកំណត់អត្តសញ្ញាណ និងការធ្វើរោគវិនិច្ឆ័យបញ្ហា) ទិន្នន័យពីឧបករណ៍ទាំងបីអាចត្រូវបានរួមបញ្ចូលគ្នា ដើម្បីឱ្យគ្រូកម្មសិក្សាទទួលបាន៖

- ភស្តុតាងដែលផ្ទៀងផ្ទាត់ពីច្រើនប្រភព (អ្នកសង្កេតការណ៍, សិស្ស, និងកំណត់ហេតុអាកប្បកិរិយា)។

- បញ្ហាជាក់លាក់ និងច្បាស់លាស់ ដែលអាចយកទៅបង្កើតជាសំណួរស្រាវជ្រាវប្រតិបត្តិ (Action Research)។
- ទិន្នន័យមូលដ្ឋានជាក់ស្តែង សម្រាប់យកទៅប្រៀបធៀបនៅពេលក្រោយ។
- មូលដ្ឋានគ្រឹះដ៏រឹងមាំ សម្រាប់រៀបចំផែនការអន្តរាគមន៍អហិង្សា។

ឧទាហរណ៍

គ្រូកម្មសិក្សាម្នាក់ដែលបង្រៀននៅថ្នាក់ទី ៦ បានកត់សម្គាល់ឃើញថា ក្នុងអំឡុងពេលធ្វើការងារក្រុម សិស្សមួយចំនួនបានហៅគ្នាថា «ឆ្លួត» ឬ «លូង» ដែលបណ្តាលឱ្យមានការប៉ះពាល់ផ្លូវចិត្ត។ ការសង្កេតដំបូងបង្ហាញថា រឿងនេះកើតឡើងញឹកញាប់បំផុតនៅពេលដែលសិស្សកំពុងប្រកួតប្រជែងគ្នាដើម្បីឆ្លើយសំណួរឱ្យបានលឿន។

សាកល្បងវិធីនេះ៖ អ្នកអាចគិតពីរបៀបដែលអ្នកអាចជួយគ្រូកម្មសិក្សារបស់អ្នកក្នុងការ៖

- កែសម្រួលសំណួរស្រាវជ្រាវ ឱ្យកាន់តែច្បាស់លាស់។
- ធានានូវការសម្ងាត់ និងការយល់ដឹងអំពីក្រមសីលធម៌។
- បញ្ជាក់ថាបញ្ហានោះមានលក្ខណៈសមស្រប អាចគ្រប់គ្រងបាន និងពាក់ព័ន្ធទៅនឹងការមិនប្រើអំពើហិង្សា។

៦.២. ការរៀបចំផែនការសកម្មភាព

បន្ទាប់ពីបញ្ហាត្រូវបានកំណត់អត្តសញ្ញាណ ការរៀបចំផែនការ និងការរចនាសកម្មភាពដើម្បីបង្កើតទំនាក់ទំនងឡើងវិញជាមួយសិស្សនឹងត្រូវចាប់ផ្តើម។ គោលបំណងគឺដើម្បីរៀបចំអន្តរាគមន៍ដែលជាក់ស្តែង សមស្របទៅនឹងបរិបទវប្បធម៌ កាត់បន្ថយអំពើហិង្សា និងលើកកម្ពស់វិន័យវិជ្ជមាន។ គ្រូឧទ្ទេសអាចពិចារណាណែនាំគរុនិស្សិត៖

- ផ្សារភ្ជាប់ផែនការទៅនឹងទ្រឹស្តី និងកស្តុតាង៖ គ្រូកម្មសិក្សាគួរអានឯកសារយោងខ្លីៗ (ឧទាហរណ៍៖ សាលាកុមារមេត្រី, គោលការណ៍ណែនាំស្តីពីវិន័យវិជ្ជមាន, អក្សរសិល្ប៍ស្រាវជ្រាវ និងទ្រឹស្តីដែលពាក់ព័ន្ធ)។
- ជ្រើសរើសយុទ្ធសាស្ត្រអន្តរាគមន៍ ដូចជា៖

○ បច្ចេកទេសវិន័យបែបវិជ្ជមាន (Positive discipline techniques)៖ វិន័យបែបវិជ្ជមាន សំដៅលើវិធីសាស្ត្រអហិង្សា និងការគោរពគ្នា ក្នុងការគ្រប់គ្រងអាកប្បកិរិយារបស់សិស្ស ដែលផ្តោតលើការបង្រៀននូវអាកប្បកិរិយាសមរម្យ ជាជាងការដាក់ទណ្ឌកម្មលើកំហុស។ វាសង្កត់ធ្ងន់លើការណែនាំ ការធ្វើអ្វីៗឱ្យមានភាពស៊ីសង្វាក់គ្នា (សង្គតិភាព) ការយល់ចិត្ត និងលទ្ធផលបែបតក្កវិជ្ជា ជំនួសឱ្យការស្រែកគំហក ការធ្វើឱ្យអាម៉ាស់ ឬការដាក់ទណ្ឌកម្មលើរាងកាយ។ ការស្រាវជ្រាវបង្ហាញថា ការដាក់ទណ្ឌកម្មលើរាងកាយ និងការប្រើសម្តីអសុរសខ្លាំងៗនាំឱ្យមានការកើនឡើងនូវភាពឆេវឆាវ ការភ័យខ្លាច និងការបោះបង់ការរៀនសូត្រ ខណៈដែលវិន័យវិជ្ជមានជួយ

ដល់សុវត្ថិភាពផ្លូវចិត្ត និងលទ្ធផលសិក្សាកាន់តែប្រសើរ (Gershoff, 2017)។ លក្ខណៈគន្លឹះនៃវិន័យវិជ្ជមាន រួមមាន៖

- មានបទបញ្ញាផ្ទៃក្នុងថ្នាក់រៀនច្បាស់លាស់ ដែលបានព្រមព្រៀងជាមួយសិស្ស។
- ការកែតម្រូវដោយប្រើសម្ដីទន់ភ្លន់ និងស្ងប់ស្ងាត់ ជាជាងការស្រែកគំហក។
- ការប្រើលទ្ធផលបែបតក្កវិជ្ជា និងបែបស្ថានីតិសម្បទា (ឧទាហរណ៍៖ ការសុំទោស ការជួសជុលកំហុសដែលបានធ្វើ)។
- ការសរសើរ និងការលើកទឹកចិត្តចំពោះអាកប្បកិរិយាវិជ្ជមាន។
- ការចេះគ្រប់គ្រងខ្លួនឯង និងការគ្រប់គ្រងអារម្មណ៍របស់គ្រូបង្រៀន។

ឧទាហរណ៍

ក្នុងអំឡុងពេលធ្វើការងារក្រុម គ្រូកម្មសិក្សាម្នាក់បានកត់សម្គាល់ឃើញថា មានការស្រែកឡូឡា និងការបង្អាប់គ្នាជាញឹកញាប់។ ជំនួសឱ្យការស្រែកគំហកដាក់សិស្ស គ្រូបានអនុវត្តដូចខាងក្រោម៖

- រួមគ្នាបង្កើតបទបញ្ញាក្នុងថ្នាក់ ងាយៗ ២ ឬ ៣ ជាមួយសិស្ស (ឧទាហរណ៍៖ «និយាយពាក្យផ្អែមល្អែម», «ប្រើដៃសម្រាប់ជួយគ្នា»)។
- ប្រើសញ្ញាស្ងប់ស្ងាត់ (ការលើកដៃ ឬប្រើកណ្ដឹង) ដើម្បីឱ្យសិស្សងាកមកចាប់អារម្មណ៍វិញ។
- សរសើរអាកប្បកិរិយាដែលផ្ដល់ការគោរព ជាសាធារណៈ។
- រំលឹកសិស្សដោយឡែកពីគ្នា (ជាបុគ្គល) អំពីការរំពឹងទុករបស់គ្រូ នៅពេលដែលមានបញ្ហាកើតឡើង។

សម្រាប់គ្រូឧទ្ទេស ដើម្បីធានាឱ្យដំណើរការនេះប្រព្រឹត្តទៅបានល្អ ពួកគាត់អាចណែនាំគ្រូកម្មសិក្សាឱ្យ៖

- ឆ្លុះបញ្ចាំងពីប្រតិកម្មផ្ទាល់ខ្លួនរបស់ពួកគេ ចំពោះអាកប្បកិរិយាមិនសមរម្យរបស់សិស្ស។
- សួរខ្លួនឯងនូវសំណួរមួយចំនួន ឧទាហរណ៍៖ «តើអាកប្បកិរិយាមួយណាដែលខ្ញុំកំពុងព្យាយាមបង្រៀន (ឱ្យសិស្សធ្វើតាម) ជាជាងគ្រាន់តែចង់បញ្ឈប់វា?»
- ចងចាំថា វិន័យវិជ្ជមានទាមទារការអនុវត្ត និងភាពស៊ីសង្វាក់គ្នា (សង្គតិភាព) មិនមែនទាមទារភាពឥតខ្ចោះនោះទេ។

○ ការរៀនតាមបែបសហការដែលមានបទបញ្ញាច្បាស់លាស់

ការរៀនតាមបែបសហការ គឺជាការឱ្យសិស្សធ្វើការងារជាមួយគ្នាក្នុងក្រុមតូចៗ ដោយមានតួនាទី បទបញ្ញា និងគោលដៅរួមច្បាស់លាស់។ នៅពេលដែលវាត្រូវបានរៀបចំឡើងយ៉ាងត្រឹមត្រូវ វាជួយកាត់បន្ថយការប្រកួតប្រជែង ការរើសអើង និងអាកប្បកិរិយាឆេវឆាវ តាមរយៈការលើកកម្ពស់ការទទួលខុស

ត្រូវរួមគ្នា និងការគាំទ្រគ្នារវាងមិត្តភក្តិ។ ទោះជាយ៉ាងណាក៏ដោយ ការងារក្រុមដែលគ្មានរចនាសម្ព័ន្ធច្បាស់លាស់ អាចបង្កើនជម្លោះ ការគំរាមកំហែង ឬការជិះជាន់ពីសំណាក់សិស្សដែលខ្លាំងជាង។ លក្ខណៈនៃការរៀនតាមបែបសហការ រួមមាន៖

- ក្រុមតូចៗ (សិស្សពី ៣ ទៅ ៥ នាក់)។
- មានការបែងចែកតួនាទីច្បាស់លាស់ (ប្រធានក្រុម, អ្នកកត់ត្រា, អ្នករក្សាម៉ោង, អ្នករាយការណ៍)។
- មានបទបញ្ជាផ្ទែកអាកប្បកិរិយាច្បាស់លាស់សម្រាប់ការសហការគ្នា។
- មានការតាមដាន និងការណែនាំពីសំណាក់គ្រូបង្រៀន។
- ការផ្តុះបញ្ចាំងលើអាកប្បកិរិយារបស់ក្រុម មិនមែនផ្តោតតែលើលទ្ធផលសិក្សាប៉ុណ្ណោះទេ។

ឧទាហរណ៍

ដើម្បីកាត់បន្ថយការរុញច្រានគ្នា និងការជេរប្រមាថ/បង្អាប់ឈ្មោះគ្នា គរុនិស្សិតអាច៖

- រៀបចំក្រុមដែលមានសមត្ថភាពចម្រុះ៖ បង្កើតក្រុមដែលរួមមានសិស្សពូកែ និងសិស្សមធ្យមនៅជាមួយគ្នា។
- បែងចែកតួនាទីវិលជុំ៖ ដាក់វេនគ្នាឱ្យសិស្សម្នាក់ៗធ្វើជាប្រធានក្រុម អ្នកកត់ត្រា ឬអ្នករាយការណ៍។
- បិទផ្សាយច្បាប់ក្នុងក្រុម៖ ដាក់រូបភាព ឬអត្ថបទខ្លីៗដូចជា «ស្តាប់មុននឹងនិយាយ» និង «ជួយគ្នា មិនមែនបន្ទោសគ្នា»។
- សង្កេតមើលអន្តរកម្ម៖ តាមដានការជជែកគ្នា និងផ្តល់មតិកែលម្អភ្លាមៗទៅលើកិច្ចសហការដែលប្រកបដោយការគោរព។

ស្រដៀងគ្នានេះដែរ គ្រូឧទ្ទេសអាចផ្តល់ការណែនាំដល់គរុនិស្សិតដូចជា៖

- រំលឹកគរុនិស្សិតថា «ច្បាប់ត្រូវតែបង្រៀនឱ្យច្បាស់លាស់»៖ ច្បាប់មិនមែនគ្រាន់តែបិទលើជញ្ជាំងនោះទេ គឺត្រូវពន្យល់ និងបង្ហាញជាគំរូដល់សិស្ស។
- លើកទឹកចិត្តឱ្យប្រើសំណួរផ្តុះបញ្ចាំងខ្លីៗ៖ ដូចជា «តើក្រុមរបស់ប្អូនបានប្រព្រឹត្តចំពោះគ្នាដូចម្តេចខ្លះ?» ឬ «តើអ្វីដែលជួយឱ្យក្រុមរបស់ប្អូនធ្វើការងារដោយសន្តិវិធីនៅថ្ងៃនេះ?»
- សង្កត់ធ្ងន់ថា «ការរៀនតាមបែបសហការ» គឺជាអន្តរាគមន៍ទាំងផ្ទែកវិជ្ជាសម្បទា និងផ្ទែកឥរិយាបថ៖ វាជួយឱ្យសិស្សរៀនមេរៀនផង និងរៀនរស់នៅជាមួយគ្នាដោយអហិង្សាផង។

- មេរៀនអប់រំសន្តិភាពខ្នាតតូច៖ មេរៀនខ្នាតតូច គឺជាមេរៀនខ្លីៗដែលផ្តោតលើខ្លឹមសារជាក់លាក់ (រយៈពេលពី ៥ ដល់ ១៥ នាទី) ដើម្បីបង្រៀនសិស្សនូវជំនាញពាក់ព័ន្ធនឹង៖ ការយល់ដឹងពីអារម្មណ៍, ការដោះស្រាយជម្លោះ, សេចក្តីមេត្តា (ការយល់ចិត្តអ្នកដទៃ), ការប្រស្រ័យទាក់ទងដោយអហិង្សា និងការគោរពចំពោះភាពខុសគ្នា។ មេរៀនទាំងនេះអាចអនុវត្តបានតាមទម្រង់ផ្សេងៗដូចជា៖
  - ខ្លី និងទៀងទាត់៖ អនុវត្តម្តង ឬពីរដងក្នុងមួយសប្តាហ៍។
  - មានអន្តរកម្ម៖ តាមរយៈការនិទានរឿង ការសម្តែងតួអង្គ (Role-play) និងការពិភាក្សា។
  - ភាសាសមស្របតាមវ័យ៖ ប្រើពាក្យពេចន៍ដែលងាយយល់សម្រាប់កុមារ។
  - ផ្សារភ្ជាប់ផ្ទាល់ទៅនឹងស្ថានភាពក្នុងថ្នាក់៖ លើកយកបញ្ហាដែលកើតឡើងជាក់ស្តែងមកពិភាក្សា។

មេរៀនទាំងនេះជួយឱ្យសិស្សរៀនពីជម្រើសផ្សេងៗក្រៅពីការប្រើអំពើហិង្សា ជាពិសេសនៅក្នុងបរិបទដែលអំពើហិង្សាត្រូវបានគេយល់ថាជារឿងធម្មតា។

ឧទាហរណ៍៖គរុនិស្សិតម្នាក់សង្កេតឃើញថា មានការជេរប្រមាថគ្នាជាញឹកញាប់ក្នុងអំឡុងពេលលេង។ ពួកគាត់អាចរៀបចំមេរៀនខ្នាតតូចមួយស្តីពី៖

- ការសម្គាល់អារម្មណ៍ (ឧទាហរណ៍៖ កំហឹង សេចក្តីសោកសៅ ការខកចិត្ត)។
- យុទ្ធសាស្ត្រ «ឈប់–គិត–និយាយ» (Stop–Think–Speak) មុននឹងឆ្លើយតប។
- ការសម្តែងតួអង្គអំពីរបៀបបង្ហាញការមិនយល់ស្រប ដោយមិនប្រើពាក្យជេរប្រមាថ។

គ្រូឧទ្ទេសអាចពិចារណាប្រើប្រាស់ការណែនាំខាងក្រោម ដើម្បីជួយគរុនិស្សិត៖

- លើកទឹកចិត្តគរុនិស្សិតឱ្យរៀបចំមេរៀនឱ្យសាមញ្ញ និងអាចអនុវត្តបាន៖ កុំឱ្យវាមានលក្ខណៈទ្រឹស្តីពេក។
- ផ្សារភ្ជាប់មេរៀនទៅនឹងបញ្ហាដែលបានសង្កេតឃើញ (ពីជំហានទី ១)៖ បង្រៀនអ្វីដែលសិស្សកំពុងជួបប្រទះជាក់ស្តែង។
- រំលឹកពួកគេថាការអប់រំសន្តិភាពគឺជាវិធានការបង្ការ៖ វាមិនមែនគ្រាន់តែជាការឆ្លើយតបនៅពេលមានបញ្ហាកើតឡើងនោះទេ ប៉ុន្តែជាការកសាងទម្លាប់ល្អជាមុន។

- ការបង្រៀនឱ្យចំៗអំពីការប្រើប្រាស់ភាសាប្រកបដោយការគោរព៖ ការបង្រៀនឱ្យចំៗ មានន័យថាជាការបង្រៀនសិស្សដោយផ្ទាល់អំពីរបៀបដែលភាសាប្រកបដោយការគោរពត្រូវបានប្រើប្រាស់ ជាជាងការសន្មតថាពួកគេបានដឹងរួចជាស្រេច។ សិស្សជាច្រើនតែងតែនិយាយតាមអ្វីដែលពួកគេបានឮពីផ្ទះ ពីសហគមន៍ ឬតាមអ៊ីនធឺណិត ដោយមិនបានយល់អំពីផលប៉ះពាល់អវិជ្ជមានរបស់វា។ គរុនិស្សិតអាចជំរុញចំណុចនេះតាមរយៈ៖
  - ធ្វើជាគំរូក្នុងការប្រើឃ្លាប្រកបដោយការគោរព៖ គ្រូត្រូវនិយាយស្តីដោយសុភាពរាបសារជាមុន។

- បង្រៀនពាក្យជំនួសឱ្យការជេរប្រមាថ ឬស្រែកគំហក៖ ផ្តល់ជម្រើសពាក្យល្អៗសម្រាប់សិស្ស ប្រើប្រាស់។
- អនុវត្តតាមរយៈការសម្តែងតួអង្គ (Role-play)៖ ឱ្យសិស្សសាកល្បងនិយាយក្នុងស្ថានភាពផ្សេងៗ។
- កែតម្រូវការប្រើប្រាស់ភាសាដោយភាពស្ងប់ស្ងាត់ និងទៀងទាត់៖ នៅពេលសិស្សនិយាយមិនសមរម្យ គ្រូត្រូវកែតម្រូវភ្លាមៗដោយមិនប្រើកំហឹង។
- បិទបង្ហាញ «ឃ្លាសម្រាប់ចាប់ផ្តើមសន្ទនា» (Sentence starters) នៅក្នុងថ្នាក់រៀន។

<u>ឧទាហរណ៍</u>

ជំនួសឱ្យការបណ្តាយឱ្យសិស្សប្រើពាក្យសម្តីដូចជា «ឯងលូងណាស់» គ្រូត្រូវបង្រៀននូវឃ្លាជំនួសវិញ ដូចជា៖ «ខ្ញុំមិនយល់ស្របទេ» «សូមឈប់ធ្វើបែបហ្នឹង» និង «ខ្ញុំមានអារម្មណ៍មិនសប្បាយចិត្ត នៅពេលដែល...»។ ពួកគេត្រូវអនុវត្តឃ្លាទាំងនេះតាមរយៈការសម្តែងតួអង្គ (Role-play) និងរំលឹកពង្រឹងការប្រើប្រាស់វាឱ្យបានជាប់លាប់ក្នុងអំឡុងពេលមេរៀន។

ក្នុងនាមជាអ្នកត្រួតពិនិត្យ គ្រូឧទ្ទេសអាចលើកទឹកចិត្តគរុនិស្សិតឱ្យធ្វើជាគំរូដោយផ្ទាល់ក្នុងការប្រើប្រាស់ភាសាប្រកបដោយការគោរព និងជំរុញឱ្យពួកគេឆ្លុះបញ្ចាំងថា៖ «តើពាក្យសម្តីរបស់ខ្ញុំជួយកាត់បន្ថយ ឬបង្កើនភាពតានតឹង?» ព្រមទាំងសង្កត់ធ្ងន់ថា ភាសាគឺជាអ្នកកំណត់រូបរាងវប្បធម៌នៅក្នុងថ្នាក់រៀន។

- ការរៀបចំសម្ភារសម្រាប់អនុវត្ត
  - ស្ត្រីបមេរៀន: សម្ភារនេះសំដៅលើកិច្ចតែងការបង្រៀនខ្លី (ដែលរួមមាន ៥ ជំហានតាមការកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា) ដែលប្រើសម្រាប់ពង្រឹងឥរិយាបថវិជ្ជមានដែលសិស្សគួរអនុវត្តនៅក្នុងថ្នាក់រៀន។
  - ប័ណ្ណប្រកាសអំពីការរំពឹងទុកនៃឥរិយាបថ: ឧទាហរណ៍ គរុនិស្សិតចង់ផ្តោតលើការបង្កើត «ថ្នាក់រៀនដែលមានសុវត្ថិភាព និងការគោរព»។ ពួកគាត់អាចសហការជាមួយសិស្សដើម្បីបង្កើត «កិច្ចព្រមព្រៀងក្នុងថ្នាក់រៀន» ឬ «វប្បធម៌ក្នុងថ្នាក់»។ ខាងក្រោមនេះជាឧទាហរណ៍ខ្លះៗ៖
    - យើងនិយាយស្តីដោយសប្បុរស និងដោយការគោរព
    - យើងស្តាប់នៅពេលអ្នកដទៃកំពុងនិយាយ
    - យើងមិនប្រើដៃ ឬជើងប៉ះពាល់អ្នកដទៃ (រក្សាសណ្តាប់ធ្នាប់រាងកាយ)
    - យើងជួយគ្នា មិនមែនធ្វើបាបគ្នា
    - យើងដោះស្រាយបញ្ហាដោយសន្តិវិធី

ផ្ទុយទៅវិញ នៅពេលមាននរណាម្នាក់រំលោភកិច្ចព្រមព្រៀង ពួកគេគួរតែទទួលបានការរំលឹកពីគ្រូ ឬមិត្តភក្តិ ឬទទួលបានការគាំទ្រឱ្យធ្វើការផ្ទុះបញ្ចាំងពីខ្លួនឯងតាមរយៈសំណួរ៖ តើមានរឿងអ្វីកើតឡើង? តើខ្ញុំអាចធ្វើឱ្យប្រសើរជាងនេះដោយរបៀបណា? លើសពីនេះ ការសន្ទនាបែបផ្ទុះបញ្ចាំងកែលម្អ (Restorative conversation) គួរតែត្រូវបានធ្វើឡើងរវាងគរុនិស្សិត និងសិស្សដែលពាក់ព័ន្ធ (ដោយមិនមានការវាយដំ ស្រែកគំហក ឬធ្វើឱ្យអាម៉ាស់ឡើយ)។

- ច្បាប់សម្រាប់ការងារក្រុម (Group work rules): ចំណុចនេះអាចចាត់ទុកថាជាដំហានច្បាស់លាស់សម្រាប់ដំណាក់កាលនីមួយៗ៖ មុនពេល អំឡុងពេល និងក្រោយពេលធ្វើការងារក្រុម។
- មុនពេលធ្វើការងារក្រុម៖ គ្រប់គ្នាមានតួនាទី ត្រូវស្តាប់ និងត្រូវមានការគោរព ហើយតួនាទីត្រូវបានកំណត់ (ដូចជា៖ ប្រធានក្រុម អ្នកកាន់ពេល អ្នកកត់ត្រា និងអ្នកជួយសម្របសម្រួលសន្តិភាព [ជួយដោះស្រាយជម្លោះតូចតាចរវាងសមាជិកក្នុងពេលធ្វើការងារក្រុម])។ តួនាទីទាំងនេះគួរផ្លាស់ប្តូរគ្នាជារៀងរាល់សប្តាហ៍។
- អំឡុងពេលធ្វើការងារក្រុម៖ និយាយម្នាក់ម្តងៗ បង្ហាញការមិនយល់ស្របដោយសុភាព ជួយសមាជិកក្រុមមិនសើចចំអកឱ្យគ្នា និងប្រើពាក្យសម្តីសមរម្យនៅពេលសុំជំនួយ។
- ក្រោយពេលធ្វើការងារក្រុម៖ ការប្រើបច្ចេកទេសផ្ទុះបញ្ចាំងជាក្រុមគឺជាវិធីសាស្ត្រដ៏ល្អ ព្រោះវាជួយឱ្យពួកគេរៀនសូត្រពីសកម្មភាពរបស់ខ្លួន និងរៀបចំផែនការសម្រាប់សកម្មភាពឱ្យកាន់តែល្អនៅពេលក្រោយ។ គរុនិស្សិតអាចលើកទឹកចិត្តឱ្យក្រុមនីមួយៗសួរសំណួរខ្លួនឯងដូចជា៖ តើអ្វីដែលយើងធ្វើបានល្អ? តើយើងបាននិយាយស្តីរកគ្នាដោយការគោរពដែរឬទេ?
    - សម្ភារសម្រាប់ការសម្តែងតួអង្គ (Role-play materials): ការសម្តែងតួអង្គអនុញ្ញាតឱ្យសិស្សអនុវត្តការឆ្លើយតបដោយអហិង្សាប្រកបដោយសុវត្ថិភាព បណ្តុះសេចក្តីមេត្តា រៀនដំនាញដោះស្រាយជម្លោះ និងបញ្ចេញអារម្មណ៍ដោយមិនមានការដាក់ទោស។ បច្ចេកទេសនេះមានប្រសិទ្ធភាពបំផុតសម្រាប់អំពើហិង្សាតាមរយៈពាក្យសម្តី។ ឧទាហរណ៍៖ បញ្ហាអំពី «ការប្រើប្រាស់សម្ភារក្នុងថ្នាក់រួមគ្នា»។ សិស្សពីរនាក់ចង់ប្រើសៀវភៅតែមួយ។ សិស្សម្នាក់ (សិស្ស B) បានស្រែកដាក់គេ។
- គរុនិស្សិតអាចរៀបចំឱ្យសិស្សម្នាក់ធ្វើជាសិស្ស A ម្នាក់ទៀតជាសិស្ស B និងម្នាក់ទៀតជាអ្នកសង្កេត។
- គរុនិស្សិតផ្តល់ការណែនាំដល់សិស្ស A ឱ្យសម្តែងដោះស្រាយបញ្ហាដោយប្រើភាសាប្រកបដោយការគោរព និងសាកល្បងរកដំណោះស្រាយដោយសន្តិវិធីយ៉ាងហោចណាស់ឱ្យបានពីរ។
- ចំណែកអ្នកសង្កេតការណ៍ ត្រូវកត់ត្រាអំពីពាក្យពេចន៍ដែលបង្ហាញពីការគោរព ភាសាកាយវិការ និងរបៀបដែលជម្លោះត្រូវបានដោះស្រាយ។

៦.៣. ការអនុវត្តសកម្មភាព

បន្ទាប់ពីបានកំណត់បញ្ហាដែលត្រូវកែលម្អ និងរៀបចំផែនការអន្តរាគមន៍រួចរាល់ហើយ ដល់ពេលដែលត្រូវអនុវត្តអ្វីដែលបានគ្រោងទុកទៅតាមលំដាប់លំដោយ។ ដំណាក់កាលនេះមានគោលបំណងសាកល្បងវិធានការអន្តរាគមន៍នៅក្នុងស្ថានភាពថ្នាក់រៀនជាក់ស្តែង។ ដើម្បីធានាថាការអនុវត្តអន្តរាគមន៍ប្រព្រឹត្តទៅដោយរលូន គ្រូឧទ្ទេសគួរពិចារណាណែនាំគរុនិស្សិតឱ្យ៖

- ជំរុញឱ្យមានភាពហ្មត់ចត់ក្នុងការអនុវត្ត (Fidelity of implementation)៖ គរុនិស្សិតគួរអនុវត្តតាមផែនការសកម្មភាពដែលបានគ្រោងទុកឱ្យបានខ្ជាប់ខ្ជួន ប៉ុន្តែត្រូវមានភាពបត់បែនទៅតាមស្ថានភាពជាក់ស្តែងក្នុងថ្នាក់រៀន។
- លើកកម្ពស់ការឆ្លុះបញ្ចាំងវិជ្ជាជីវៈក្នុងអំឡុងពេលអនុវត្ត៖ គរុនិស្សិតគួររក្សាកំណត់ហេតុឆ្លុះបញ្ចាំងប្រចាំថ្ងៃ (Reflective Journal) ដែលរួមមានសំណួរដូចជា៖
  - តើអ្វីខ្លះដែលដំណើរការល្អនៅថ្ងៃនេះ?
  - តើមានបញ្ហាប្រឈមអ្វីខ្លះបានកើតឡើង?
  - តើសិស្សមានប្រតិកម្មយ៉ាងណា ចំពោះផ្នែកអារម្មណ៍ និងឥរិយាបថ?

កំណត់ហេតុឆ្លុះបញ្ចាំងរបស់គ្រូ

កាលបរិច្ឆេទ:	ថ្ងៃចន្ទ ទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥
ថ្នាក់/មុខវិជ្ជា៖	គណិតវិទ្យា
យុទ្ធសាស្ត្រឥរិយាបថវិជ្ជមានដែលបានប្រើនៅថ្ងៃនេះ៖	……..
ស្ថានភាពដែលខ្ញុំបានជៀសវាងការប្រើវិន័យតឹងរ៉ឹង/ហិង្សា	……..
ប្រតិកម្មរបស់សិស្ស/លទ្ធផលទទួលបាន	……..
ការឆ្លុះបញ្ចាំង (ការយល់ឃើញផ្ទាល់ខ្លួន)	……..
ជំហានបន្ទាប់/ការកែសម្រួលសម្រាប់ថ្ងៃស្អែក	……..

កំណត់ហេតុឆ្លុះបញ្ចាំងរបស់សិស្ស

កាលបរិច្ឆេទ៖ ថ្ងៃចន្ទ ទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥	យល់ព្រម	មិនច្បាស់	មិនយល់ព្រម
សេចក្តីថ្លែងការណ៍យល់ព្រមមធ្យមមិនយល់ព្រមខ្ញុំមានអារម្មណ៍ថា លោកគ្រូ/អ្នកគ្រូ ប្រព្រឹត្តមកលើខ្ញុំដោយយុត្តិធម៌	√		
ចំណុចវិជ្ជមានមួយដែលខ្ញុំចាប់អារម្មណ៍អំពីវិនិយ្ឆយក្នុងថ្នាក់គឺ...			
ការផ្លាស់ប្តូរមួយដែលខ្ញុំនៅតែប្រាថ្នាចង់បានគឺ...			
ម្តង ……			

សម្គាល់៖មិនមានទម្រង់កំណត់ហេតុឆ្លុះបញ្ចាំងណាមួយដែលថេរនោះទេដូច្នេះគរុនិស្សិត ឬគ្រូឧទ្ទេសអាចបង្កើតទម្រង់ថ្មីដែលឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ខ្លួនបាន។

- ការធានានូវក្រមសីលធម៌ក្នុងការអនុវត្ត
- ជៀសវាងការធ្វើឱ្យសិស្សមានភាពអាម៉ាស់៖ ចំពោះសិស្សដែលបង្ហាញឥរិយាបថហិង្សា។
- រក្សាការសម្ងាត់៖ រាល់ព័ត៌មានដែលបានកត់ត្រាទុកជាលាយលក្ខណ៍អក្សរ។
- ការពារសេចក្តីថ្លៃថ្នូររបស់សិស្ស៖ គ្រប់ពេលវេលា និងគ្រប់កាលៈទេសៈ។

ឧទាហរណ៍៖

ក្នុងអំឡុងពេលអនុវត្ត គរុនិស្សិតសង្កេតឃើញថាសិស្សមួយចំនួននៅតែខ្សឹបជេរប្រមាថគ្នា។ គាត់ក៏បានប្រើបច្ចេកទេសសម្រួលស្ថានការណ៍ដោយប្រើ «សញ្ញាដៃ» ដើម្បីរំលឹកសិស្សឱ្យ «ឈប់ផ្ទាក និងនិយាយពាក្យផ្អែមល្ហែម»។

ដើម្បីគាំទ្រគរុនិស្សិតក្រោមការត្រួតពិនិត្យរបស់អ្នក គ្រូឧទ្ទេសគួរតែលើកទឹកចិត្តពួកគាត់ឱ្យ៖

1. ចុះសង្កេតការបង្រៀនក្នុងថ្នាក់៖ ដើម្បីមើលពីការអនុវត្តជាក់ស្តែង។
2. ផ្តល់មតិកែលម្អ៖ លើទឹកដមសំឡេង ការប្រើប្រាស់ភាសា និងវិធីសាស្ត្រវិនិយ្ឆយអហិង្សា។
3. ជួយគរុនិស្សិតកែសម្រួលសកម្មភាព៖ នៅពេលដែលចាំបាច់។

៦.៤. ការសង្កេត និងការប្រមូលទិន្នន័យ

នៅពេលអនុវត្តសកម្មភាពដែលបានគ្រោងទុក គរុនិស្សិតតម្រូវឱ្យសង្កេតមើលសកម្មភាពរបស់ខ្លួន និងប្រមូលទិន្នន័យទាំងអស់។ ដំណាក់កាលនេះជួយពួកគេក្នុងការប្រមូលកស្តុតាងដ៏សម្បូរបែប ដើម្បីស្វែងយល់ពីឥទ្ធិ

ពលនៃអន្តរាគមន៍។ នៅក្នុងការស្រាវជ្រាវប្រតិបត្តិដើម្បីអហិង្សា ការប្រមូលទិន្នន័យមិនមែនធ្វើឡើងដើម្បីការដាក់ទណ្ឌកម្ម ការត្រួតពិនិត្យ ឬការស្តីបន្ទោសនោះទេ ប៉ុន្តែគឺដើម្បីស្វែងយល់អំពីគំរូនៃឥរិយាបថក្នុងថ្នាក់រៀន ការតាមដានការផ្លាស់ប្តូរ និងការផ្តល់ព័ត៌មានសម្រាប់ការឆ្លុះបញ្ចាំង និងការកែលម្អ។ ដើម្បីធានាបាននូវភាពជឿជាក់ និងភាពម៉ឹងម៉ាត់ផ្នែកសីលធម៌ គរុនិស្សិតត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់ប្រភពទិន្នន័យជាច្រើន (ត្រីកោណកម្ម) ដោយរួមបញ្ចូលការសង្កេត សំឡេងសិស្ស និងកំណត់ត្រាឥរិយាបថ (McNiff & Whitehead, 2011; Burns, 2010)។ ក្នុងដំណាក់កាលនេះ គ្រូឧទ្ទេសគួរតែធ្វើការណែនាំ៖

- គរុនិស្សិតត្រូវប្រើប្រាស់ប្រភពទិន្នន័យជាច្រើន ដូចជា៖
    - ការស្ទង់មតិមុន និងក្រោយ (Pre- and post-surveys)៖ នៅក្នុងការស្រាវជ្រាវប្រតិបត្តិបែបអហិង្សា ការស្ទង់មតិគួរតែមានលក្ខណៈខ្លី មិនបញ្ចេញឈ្មោះ សមស្របតាមអាយុ និងមិនបង្កការភ័យខ្លាច។ ការស្ទង់មតិមុន និងក្រោយនេះ អាចចំណាយពេលប្រហែល ៤ ទៅ ៨ សប្តាហ៍ ឬអាចយូរជាងនេះ អាស្រ័យលើប្រភេទនៃបញ្ហាដែលអ្នកចង់ធ្វើការផ្លាស់ប្តូរ។ ប្រភេទនៃការស្ទង់មតិនេះ ជួយឱ្យគរុនិស្សិត៖
        - ស្វែងយល់ពីការយល់ឃើញរបស់សិស្សអំពីសុវត្ថិភាព ការគោរព និងវិន័យ។
        - វាស់វែងការផ្លាស់ប្តូរតាមពេលវេលា បន្ទាប់ពីអន្តរាគមន៍បែបអហិង្សាត្រូវបានអនុវត្ត។
        - ផ្តល់ឱ្យសិស្សនូវសិទ្ធិបញ្ចេញមតិក្នុងការវាយតម្លៃបរិយាកាសថ្នាក់រៀន។

ចំណាំ៖ នៅពេលអនុវត្តការស្ទង់មតិមុន និងក្រោយនេះ គរុនិស្សិត និងគ្រូឧទ្ទេសគួរកត់សម្គាល់អំពីក្រមសីលធម៌មួយចំនួន ដូចជាមិនត្រូវស្នើសុំឱ្យសិស្សបញ្ចេញឈ្មោះគ្រូ ឬមិត្តរួមថ្នាក់ឡើយ និងត្រូវពន្យល់ឱ្យច្បាស់ថា ចម្លើយនឹងមិនប៉ះពាល់ដល់ពិន្ទុ ឬការប្រព្រឹត្តមកលើសិស្សនោះទេ។

គំរូកម្រងសំណួរ

សូមគូសសញ្ញា (√) លើចម្លើយដែលត្រូវនឹងអារម្មណ៍របស់អ្នកបំផុត។

របាយការណ៍/ល្ហ:ៈ	ជានិច្ច	ញឹកញាប់	ជួនកាល	មិនដែល
ខ្ញុំមានអារម្មណ៍សុវត្ថិភាពនៅក្នុងថ្នាក់រៀននេះ។	√			
គ្រូរបស់ខ្ញុំនិយាយទៅកាន់សិស្សដោយការគោរព។		√		

សិស្សទទួលបានការប្រព្រឹត្តដោយស្មើភាពគ្នានៅក្នុងថ្នាក់នេះ។	√			
នៅពេលមានបញ្ហាកើតឡើង យើងពិភាក្សាគ្នាដំនួសឱ្យការដាក់ទណ្ឌកម្ម។	√			
ខ្ញុំមានអារម្មណ៍ស្រួលចិត្តក្នុងការសួរសំណួរ។			√	
……..				

កំណត់សម្គាល់៖ គំរូដូចគ្នានេះអាចប្រើបានទាំងសម្រាប់ការស្ងង់មតិមុន និងក្រោយ។ អ្នកគួរប្រើកូដសម្គាល់ការស្ងង់មតិណាមួយ (ឧទាហរណ៍ St001) ដើម្បីធានាបាននូវភាពមិនបញ្ចេញឈ្មោះ។ ប្រសិនបើអាច អ្នកអាចបង្កើតសំណួរបែបបើកចំហនៅខាងចុងការស្ងង់មតិ ដើម្បីឱ្យសិស្សអាចផ្តល់ព័ត៌មានបន្ថែមដល់អ្នក ឧទាហរណ៍៖

សំណួរបែបបើកចំហជាជម្រើស៖

តើអ្វីដែលធ្វើឱ្យអ្នកមានអារម្មណ៍ថាមានសុវត្ថិភាព ឬគ្មានសុវត្ថិភាពនៅក្នុងថ្នាក់រៀននេះ?

_____

_____

- កំណត់ត្រាការសង្កេត៖ ការសង្កេតអាចមានប្រយោជន៍ខ្លាំងណាស់នៅក្នុងប្រទេសកម្ពុជា ដែលការអនុវត្តហិង្សាមួយចំនួនអាចក្លាយជារឿងធម្មតា និងមិនត្រូវបានកត់សម្គាល់ លុះត្រាតែមានការកត់ត្រាជាប្រព័ន្ធ។ កំណត់ត្រានេះអនុញ្ញាតឱ្យគរុនិស្សិត ឬគ្រូឧទ្ទេសកត់ត្រាអន្តរកម្មជាក់ស្តែងក្នុងថ្នាក់រៀន កំណត់ដើមហេតុនៃជម្លោះពាក្យសម្តី ឬរាងកាយ ព្រមទាំងចងក្រងឯកសារអំពីការឆ្លើយតបរបស់គ្រូ និងប្រតិកម្មរបស់សិស្ស។

កំណត់ត្រាការសង្កេតក្នុងថ្នាក់រៀន

អ្នកសង្កេតគួរពណ៌នាអំពីអ្វីដែលអ្នកឃើញ និងឮ មិនមែនជាការវិនិច្ឆ័យទេ ហើយក៏គួរជៀសវាងពាក្យដូចជា "អាក្រក់" "ខ្ជិល" ឬ "រពឹស/ខូច" ផងដែរ។

កាលបរិច្ឆេទ៖	មេរៀន៖		អ្នកសង្កេត៖ ……..	
ម៉ោង	ព្រឹត្តិការណ៍ដែលបានកើតឡើង (ការពណ៌នាជាក់ស្តែង)	ប្រភេទនៃឥរិយាបថ	ការឆ្លើយតបរបស់គ្រូ	កំណត់សម្គាល់
8:15	សិស្សពីរនាក់បានឈ្លោះប្រកែកគ្នាកំឡុងពេលធ្វើការងារក្រុម	ជម្លោះពាក្យសម្តី	គ្រូបានរំលឹកពីវិន័យដោយស្ងប់ស្ងាត់	ជម្លោះបានបញ្ឈប់
8:30	សិស្សស្រែកឆ្លើយដោយមិនលើកដៃ	ការរំខាន	គ្រូមិនអើពើ ហើយសរសើរសិស្សផ្សេងទៀត	ឥរិយាបថ (រំខាន) បានថយចុះ
8:45	……	……	……	……
9:00	……	……	……	……

- បញ្ជីផ្ទៀងផ្ទាត់ភាពញឹកញាប់នៃឥរិយាបថ៖ ឧបករណ៍នេះជួយកំណត់បរិមាណឥរិយាបថ ដោយតាមដានថាតើឥរិយាបថជាក់លាក់ណាមួយកើតឡើងញឹកញាប់ប៉ុណ្ណា ប្រៀបធៀបភាពញឹកញាប់មុន និងក្រោយអន្តរាគមន៍ និងគាំទ្រការសន្និដ្ឋានដោយផ្អែកលើភស្តុតាង។ ម្យ៉ាងទៀត វាមានប្រយោជន៍ជាពិសេសនៅពេលដោះស្រាយបញ្ហាដូចជា ការស្រែកគំហក ការឈ្លានពានផ្លូវកាយ និងឥរិយាបថវិជ្ជមាន (ឧទាហរណ៍ ៖ ការជួយគ្នា ការនិយាយស្តីដោយការគោរព)។

<u>ក្រដាសតាមដានឥរិយាបថ</u>

សប្តាហ៍៖			ថ្នាក់៖ ……			
ឥរិយាបថ	ចន្ទ	អង្គារ	ពុធ	ព្រហស្បតិ៍	សុក្រ	សរុប
ការស្រែក	√			√		2
ការរុញ / វាយ	√					1
ការប្រើពាក្យសម្តីគួរសម		√	√		√	3
ការជួយមិត្តភក្តិ	√	√	√	√		4
ការចំអក/ឡេបខាយ						
….						

ចំណាំ៖ (√) ឥរិយាបថដែលបានសង្កេតឃើញយ៉ាងហោចណាស់ម្តងក្នុងអំឡុងពេលមេរៀន។

- គំរូនៃការឆ្លុះបញ្ចាំងរបស់សិស្ស (Samples of student reflections)៖ ការឆ្លុះបញ្ចាំងរបស់សិស្សអាចជួយឱ្យគរុនិស្សិតយល់ពីអារម្មណ៍របស់សិស្សចំពោះការផ្លាស់ប្តូរក្នុងថ្នាក់រៀន ថាតើពួកគេយល់ពីគុណតម្លៃនៃអហិង្សាដែរឬទេ និងថាតើអន្តរាគមន៍ដ៏ឥទ្ធិពលយ៉ាងណាដល់អារម្មណ៍ ទំនាក់ទំនង និងការរៀនសូត្រ។ ការឆ្លុះបញ្ចាំងទាំងនេះអាចធ្វើឡើងជាការសរសេរ ការគូររូប ឬការថតសំឡេង អាស្រ័យលើអាយុ។

ក្រដាសឆ្លុះបញ្ចាំងរបស់សិស្ស (ជម្រើស & មិនបញ្ចេញឈ្មោះ)

(១) រឿងមួយដែលខ្ញុំចូលចិត្តអំពីថ្នាក់រៀនរបស់យើងឥឡូវនេះគឺ៖ ..... (២) រឿងមួយដែលជួយយើងដោះស្រាយបញ្ហាដោយសន្តិវិធីគឺ៖ ..... (៣) នៅពេលមានជម្លោះ ខ្ញុំមានអារម្មណ៍ថា៖ □ ស្ងប់ស្ងាត់ □ ភ័យខ្លាច □ ច្របូកច្របល់ □ សប្បាយចិត្ত □ ផ្សេងទៀត៖ ..... (សូមបញ្ជាក់)

អ្នកអាចពិចារណាឱ្យសិស្ស (ជាពិសេសសិស្សតូចៗ) គូររូបអំពីថ្នាក់រៀនដែលមានសន្តិភាព ព្រោះរូបភាពអាចបរិយាយពីអារម្មណ៍របស់ពួកគេបានល្អជាង។

- កិច្ចសម្ភាសន៍ខ្លីៗជាមួយសិស្ស ឬគ្រូណែនាំ៖ កិច្ចសម្ភាសន៍ផ្តល់នូវការយល់ដឹងស៊ីជម្រៅ និងការបកស្រាយដែលការស្ទង់មតិមិនអាចចាប់យកបាន ដូចជា៖ ហេតុអ្វីបានជាយុទ្ធសាស្ត្រខ្លះមានប្រសិទ្ធភាព ឬមិនមានប្រសិទ្ធភាព និងរបៀបដែលសិស្សយល់ឃើញពីការផ្លាស់ប្តូរឥរិយាបថរបស់គ្រូ។ កិច្ចសម្ភាសន៍គួរតែមានរយៈពេលខ្លី (ប្រហែល ៥-១០ នាទី) និងមានលក្ខណៈសន្ទនា (ការសន្ទនាពីរផ្លូវ); ទោះយ៉ាងណាក៏ដោយ រយៈពេលនៃកិច្ចសម្ភាសន៍អាចប្រែប្រួលទៅតាមក្រុមអាយុ ឬបញ្ហាដែលអ្នកចង់សាកសួរ។ គួរកត់សម្គាល់ថា កិច្ចសម្ភាសន៍មួយទល់នឹងមួយ គឺជាយុទ្ធសាស្ត្រដ៏ល្អបំផុតសម្រាប់ការស្រាវជ្រាវប្រតិបត្តិបែបអហិង្សា ជាជាងការពិភាក្សាក្រុម។ វាគួរតែធ្វើឡើងក្នុងភាពរួសរាយរាក់ទាក់ មិនផ្លូវការ និងជៀសវាងសំណួរបែបដឹកមុខ (កុំផ្តល់តម្រុយ ដើម្បីកុំឱ្យសិស្សឆ្លើយតាមអ្វីដែលអ្នកចង់បាន ជាជាងការនិយាយការពិតពីអារម្មណ៍របស់ពួកគេ)។

សំណួរសម្ភាសន៍ខ្លីៗ (សិស្ស)

(១) តើប្អូនមានអារម្មណ៍សុវត្ថិភាពជាងមុនទេនៅក្នុងថ្នាក់ឥឡូវនេះ? ហេតុអ្វី ឬហេតុអ្វីមិនមាន?

.....

(២) តើគ្រូធ្វើអ្វីនៅពេលមានបញ្ហាកើតឡើង?

.....

(៣) តើអ្វីដែលជួយឱ្យសិស្សចុះសម្រុងគ្នាបានល្អជាងមុន?

.....

មគ្គុទ្ទេសក៍សម្ភាសន៍ (គ្រូណែនាំ)

(១) តើអ្នកកត់សម្គាល់ឃើញមានការផ្លាស់ប្តូរអ្វីខ្លះនៅក្នុងឥរិយាបថសិស្ស?

.....

(២) តើយុទ្ធសាស្ត្រមួយណាដែលហាក់ដូចជាមានប្រសិទ្ធភាពបំផុត?

.....

(៣) តើនៅសល់បញ្ហាប្រឈមអ្វីខ្លះ?

.....

(៤) តើអ្នកមានដំបូន្មានអ្វីខ្លះដល់គរុនិស្សិត?

.....

- គរុនិស្សិតត្រូវធានាថាទិន្នន័យមិនត្រូវបង្កើតការភ័យខ្លាច ឬសម្ពាធឡើយ។ ការប្រមូលទិន្នន័យត្រូវជៀសវាងការបញ្ជាក់អត្តសញ្ញាណសិស្សជាក់លាក់នៅពេលរាយការណ៍។ ដូចគ្នាដែរ ការសង្កេតគួរតែមានលក្ខណៈអព្យាក្រឹត និងជាការពណ៌នា។

ឧទាហរណ៍នៃការប្រមូលទិន្នន័យបង្ហាញថា៖

- ការជេរប្រមាថដោយពាក្យសម្តីថយចុះពី ១២ ករណីក្នុងមួយសប្តាហ៍ មកត្រឹម ៤។
- សិស្សរាយការណ៍ថា "មានអារម្មណ៍សប្បាយរីករាយជាងមុនក្នុងការងារក្រុម"។
- គ្រូណែនាំរាយការណ៍ថា "បរិយាកាសក្នុងថ្នាក់មានភាពទន់ភ្លន់ជាងមុន"។

ចំណាំ៖ វាអាចមានប្រយោជន៍ខ្លាំងណាស់សម្រាប់គរុនិស្សិតរបស់អ្នក ប្រសិនបើអ្នកដែលជាគ្រូឧទ្ទេស អាចពិចារណា៖ (១)បង្រៀនគរុនិស្សិតពីរបៀបកត់ត្រាទិន្នន័យជាប្រព័ន្ធ។ (២)ពិនិត្យមើលគុណភាព និងភាពត្រឹមត្រូវនៃកស្តុតាងដែលប្រមូលបាន។ (៣)ក្រើនរំលឹកពួកគេឱ្យធានានូវការរក្សាទុកទិន្នន័យប្រកបដោយក្រមសីលធម៌។

៦.៥. ការឆ្លុះបញ្ចាំង និងការបកស្រាយលទ្ធផល

ជំណាក់កាលនេះគឺជាបេះដូងនៃការស្រាវជ្រាវប្រតិបត្តិ។ នៅក្នុងការស្រាវជ្រាវប្រតិបត្តិដើម្បីអហិង្សា ការឆ្លុះបញ្ចាំងមិនគ្រាន់តែសួរថា "តើអន្តរាគមន៍មានប្រសិទ្ធភាពដែរឬទេ?" នោះទេ។ វាសួរសំណួរវិជ្ជាជីវៈ:ស៊ីជម្រៅដូចជា៖

(១) តើគំរូនៃហិង្សា ឬឥរិយាបថនៃការគោរពមានការផ្លាស់ប្តូរយ៉ាងដូចម្តេច?

(២) ហេតុអ្វីបានជាមានការផ្លាស់ប្តូរ (ឬមិនមានការផ្លាស់ប្តូរ) កើតឡើង?

(៣) តើចំណុចនេះមានអត្ថន័យយ៉ាងណាចំពោះការអនុវត្តការបង្រៀនរបស់ខ្ញុំ? និង

(៤) តើគួរកែលម្អអ្វីខ្លះនៅក្នុងវដ្តបន្ទាប់?

ជំហាននេះជួយគ្រូឧទ្ទេស និងគរុនិស្សិតផ្លាស់ប្តូរពីទិន្នន័យធៅទៅជាការរៀនសូត្របែបវិជ្ជាជីវៈ និងពីហេតុការណ៍ដាច់ដោយឡែកក្នុងថ្នាក់រៀន ទៅជាការកែលម្អដោយផ្អែកលើភស្តុតាង។ វាទាមទារឱ្យគរុនិស្សិតមានជំនាញផ្សេងៗគ្នា ដូចជាការវិភាគ និងប្រៀបធៀបទិន្នន័យ/គំរូ និងការបកស្រាយអត្ថន័យពីលទ្ធផល។ គរុនិស្សិតជាច្រើនជួបប្រទះបញ្ហាប្រឈមនៅក្នុងជំណាក់កាលនេះ។ ដូច្នេះ អ្វីដែលអ្នកជាគ្រូឧទ្ទេស ឬអ្នកត្រួតពិនិត្យអាចធ្វើបាន គឺណែនាំ ឬធ្វើការសហការជាមួយពួកគេដើម្បី៖

- វិភាគគំរូ មិនមែនហេតុការណ៍បុគ្គល (Analyze patterns, not individual incidents): "ហេតុអ្វីបានជាគំរូមានសារៈសំខាន់នៅក្នុងការស្រាវជ្រាវប្រតិបត្តិដើម្បីអហិង្សា?" គឺជាសំណួរដែលគេសួរញឹកញាប់។ នៅក្នុងថ្នាក់រៀននៅកម្ពុជា ហេតុការណ៍ដាច់ដោយឡែក (ឧទាហរណ៍៖ សិស្សម្នាក់ស្រែក, គ្រូម្នាក់ដំឡើងសំឡេង) អាចកើតឡើងដោយសារកត្តាជាច្រើន៖ ការអស់កម្លាំង សម្ពាធនៃការប្រឡង ចំនួនសិស្សក្នុងថ្នាក់ ឬភាពតានតឹងផ្លូវចិត្ត។ ការស្រាវជ្រាវប្រតិបត្តិមិនគួរវិនិច្ឆ័យបុគ្គលទេ ប៉ុន្តែជំនួសមកវិញនូវការកំណត់គំរូដដែលៗដែលបង្ហាញពីបញ្ហាបរិយាកាសក្នុងថ្នាក់រៀន។ ហេតុដូច្នេះ ការផ្តោតលើគំរូជួយ៖
    - កាត់បន្ថយការស្តីបន្ទោស និងការការពារខ្លួន
    - លើកកម្ពស់ការឆ្លុះបញ្ចាំងបែបវិជ្ជាជីវៈ
    - កំណត់ពីមូលហេតុរចនាសម្ព័ន្ធ ឬការណែនាំដែលបង្កឱ្យមានអំពើហិង្សា
    - អនុលោមតាមគោលការណ៍វិន័យវិជ្ជមាន (Gershoff, 2017)

បន្ទាប់ពីសំណួរ៖ ហេតុអ្វីបានជាគំរូមានសារៈសំខាន់ គរុនិស្សិតគួរត្រូវបានណែនាំតាមរយៈជំហាននីមួយៗ នៃ "របៀបវិភាគគំរូ"។ មានវិធីផ្សេងៗគ្នាសម្រាប់ចំណុចនេះ ទោះយ៉ាងណាក៏ដោយ ខាងក្រោមនេះគឺជាជំហានសាមញ្ញទាំង ៤ សម្រាប់ការវិភាគគំរូ៖

- ជំហានទី ១៖ ដាក់ទិន្នន័យស្រដៀងគ្នាជាក្រុម (Group Similar Data)
  - ដាក់ហេតុការណ៍ជាក្រុមតាមប្រភេទ ឧទាហរណ៍៖
    - ការឈ្លានពានដោយពាក្យសម្តី (ការស្រែក, ការជេរប្រមាថ)
    - ការឈ្លានពានផ្លូវកាយ (ការវាយ, ការរុញ)
    - ភាសាដែលមិនគោរព
    - ជម្លោះរវាងមិត្តភក្តិ និងមិត្តភក្តិ
- ជំហានទី ២៖ ស្វែងរកនិន្នាការនៃភាពញឹកញាប់ (Look for Frequency Trends)
  - ដើម្បីចាប់ផ្តើមជំហាននេះ អ្នកអាចបន្តសួរខ្លួនឯងនូវសំណួរខាងក្រោម ហើយឆ្លើយសំណួរនីមួយៗដោយទិន្នន័យ ឬកស្តុតាងដែលអ្នកបានប្រមូល ឧទាហរណ៍៖
    - តើឥរិយាបថមួយណាកើតឡើងញឹកញាប់ជាងគេ?
    - នៅម៉ោងណានៃថ្ងៃ?
    - ក្នុងអំឡុងពេលសកម្មភាពអ្វី (ការងារក្រុម, ការផ្លាស់ប្តូរវេន, ការប្រឡង)?
    - ...
- ជំហានទី ៣៖ កំណត់ដើមហេតុ/កត្តាជំរុញ (Identify Triggers): កត្តាជំរុញទូទៅអាចរួមមាន៖
  - ការណែនាំមិនច្បាស់លាស់
  - កិច្ចការដែលមានលក្ខណៈប្រកួតប្រជែង
  - ការរៀបចំកន្លែងអង្គុយ
  - ភាពតានតឹងរបស់គ្រូ ឬសម្ពាធពេលវេលា
- ជំហានទី ៤៖ សង្ខេបគំរូ (Summarize Patterns): ជំហាននេះអាចតម្រូវឱ្យអ្នកណែនាំគរុនិស្សិតរបស់អ្នកឱ្យសរសេរជាល្អះសង្ខេបខ្លីៗ ដូចជា៖ "ការស្រែកគំហកបានកើតឡើងញឹកញាប់បំផុតក្នុងអំឡុងពេលផ្លាស់ប្តូរការងារក្រុម ជាពិសេសនៅពេលដែលតួនាទីមិនច្បាស់លាស់។"

- ប្រៀបធៀបទិន្នន័យមុន និងក្រោយអន្តរាគមន៍ (Compare data before and after the intervention): ចំណុចនេះស្របតាមគោលការណ៍ស្រាវជ្រាវប្រតិបត្តិនៃការសាកសួរជាប្រព័ន្ធ (Kemmis & McTaggart,

2005)។ ការប្រៀបធៀបទិន្នន័យ (រវាងទិន្នន័យមុន និងទិន្នន័យក្រោយ) គឺចាំបាច់ណាស់ ព្រោះវាអនុញ្ញាតឱ្យគ្រូដែលជាអ្នកស្រាវជ្រាវអាច៖

- បង្ហាញភស្តុតាងនៃការផ្លាស់ប្តូរ
- ជៀសវាងការពឹងផ្អែកលើចំណាប់អារម្មណ៍ផ្ទាល់ខ្លួន
- បង្ហាញការកែលម្អ (ឬកង្វះការកែលម្អ) ដោយតម្លាភាព

អ្នកក៏គួរណែនាំគរុនិស្សិតរបស់អ្នកឱ្យយល់ពីជំហានទូទៅមួយចំនួននៅពេលប្រៀបធៀបទិន្នន័យផងដែរ។

- ជំហានទី ១៖ កំណត់ទិន្នន័យមូលដ្ឋាន (Identify Baseline Data): សំណុំទិន្នន័យនេះអាចរួមមាន៖ លទ្ធផលនៃការស្ទង់មតិមុន កំណត់ត្រានៃការសង្កេតដំបូង និងចំនួនភាពញឹកញាប់នៃឥរិយាបថក្នុងអំឡុងពេលអន្តរាគមន៍របស់អ្នក។
- ជំហានទី ២៖ ប្រមូលទិន្នន័យក្រោយអន្តរាគមន៍ (Collect Post-Intervention Data): សំណុំទិន្នន័យនេះត្រូវបានប្រមូលដោយប្រើឧបករណ៍ដូចគ្នា បន្ទាប់ពីអន្តរាគមន៍របស់អ្នកបានបញ្ចប់។ អ្នកអាចប្រើសំណួរស្ទង់មតិដូចគ្នា បញ្ជីផ្ទៀងផ្ទាត់ការសង្កេតដូចគ្នា និងប្រភេទឥរិយាបថដូចគ្នា។
- ជំហានទី ៣៖ ប្រៀបធៀបទល់មុខគ្នា (Compare Side-by-Side): វាអាស្រ័យលើគោលបំណងរបស់អ្នក ឬរបៀបដែលអ្នកចង់បង្ហាញទិន្នន័យរបស់អ្នក ដើម្បីងាយស្រួលសម្រាប់អ្នកក្នុងការសង្កេតភាពខុសគ្នារវាងទិន្នន័យមុន និងទិន្នន័យក្រោយ។ អ្នកអាចពិចារណាបង្កើតតារាង ឬគំនូសតាងសាមញ្ញ (សូមមើលតារាងខាងក្រោមជាឧទាហរណ៍)។ អ្នកក៏អាចគិតអំពីការប្រៀបធៀបទិន្នន័យរបស់អ្នកជាប្រភេទផ្សេងៗគ្នា ឧទាហរណ៍ បរិមាណ (លេខ ភាគរយ ភាពញឹកញាប់) គុណភាព (មតិយោបល់សិស្ស ការឆ្លុះបញ្ចាំង) និងចម្រុះ (រួមបញ្ចូលគ្នារវាងលេខ និងសំឡេង/មតិ)។

ការប្រៀបធៀប មុន និងក្រោយ អន្តរាគមន៍

ឥរិយាបថ	មុនអន្តរាគមន៍	ក្រោយអន្តរាគមន៍	ការប្រៀបធៀប
គ្រូស្រែក	១២ ដង/សប្តាហ៍	៤ ដង/សប្តាហ៍	-៨ ដង/សប្តាហ៍
ការដេរប្រមាថរបស់សិស្ស	១៥ ករណី	៦ ករណី	-៩ ករណី
ការនិយាយបែបសហការ	៥ ករណី	១៨ ករណី	+១៣ ករណី
.....			

- បកស្រាយថាហេតុអ្វីបានជាមាន ឬមិនមានការផ្លាស់ប្តូរកើតឡើង៖ អ្នកគួរណែនាំពួកគេឱ្យបកស្រាយទិន្នន័យក្នុងលក្ខណៈដែលមានតុល្យភាព និងផ្អែកលើភស្តុតាង។ និយាយឱ្យសាមញ្ញ ពួកគេគួរធានាថាការបកស្រាយមានមូលដ្ឋាននៅក្នុងទ្រឹស្តី ឬឯកសារស្រាវជ្រាវ។ ការបកស្រាយមានន័យថាការឈានទៅហួសពី "វាមានប្រសិទ្ធភាព" ឬ "វាមិនមានប្រសិទ្ធភាព" ដូច្នេះអ្នកគួររំលឹកគរុនិស្សិតរបស់អ្នកថា ការបកស្រាយឆ្លើយតបនឹងសំណួរថា ហេតុអ្វី មិនមែនគ្រាន់តែ អ្វី នោះទេ។ ពួកគេអាចសួរសំណួរខាងក្រោម ហើយបន្ទាប់មកពន្យល់ថាហេតុអ្វីបានជាយុទ្ធសាស្ត្រនោះមានប្រសិទ្ធភាពជាង និងប៉ះពាល់ដល់លទ្ធផល៖
    - តើទិដ្ឋភាពណាខ្លះនៃអន្តរាគមន៍បានជះឥទ្ធិពលដល់ការផ្លាស់ប្តូរ?
    - តើយុទ្ធសាស្ត្រណាខ្លះដែលមានប្រសិទ្ធភាពបំផុត?
    - តើកត្តាបរិបទអ្វីខ្លះដែលប៉ះពាល់ដល់លទ្ធផល?

ខាងក្រោមនេះគឺជាជំហានមួយចំនួនដែលអ្នកអាចប្រើដើម្បីណែនាំគរុនិស្សិតរបស់អ្នកក្នុងអំឡុងពេលដំណើរការបកស្រាយ។

- ជំហានទី ១៖ ភ្ជាប់ការផ្លាស់ប្តូរទៅនឹងអន្តរាគមន៍: ឧទាហរណ៍៖ ការប្រើប្រាស់ភាសាប្រកបដោយការគោរពរបស់សិស្សបានកើនឡើង បន្ទាប់ពីការបង្រៀនច្បាស់លាស់ និងការដើរតួ។
- ជំហានទី ២៖ ពិចារណាបរិបទថ្នាក់រៀន: អ្នកអាចពិចារណាពន្យល់ពីមូលហេតុ (WHY) ដោយផ្អែកលើបរិបទផ្សេងៗគ្នា ដូចជាចំនួនសិស្សក្នុងថ្នាក់ សមត្ថភាពចម្រុះរបស់សិស្ស រដូវកាលប្រឡង និង/ឬ បទពិសោធន៍របស់គ្រូ ជាដើម។
- ជំហានទី ៣៖ ពិចារណាការផ្លាស់ប្តូរដោយផ្នែក ឬគ្មានការផ្លាស់ប្តូរ: មិនមែនរាល់ការផ្លាស់ប្តូរដែលអ្នកចង់ឃើញសុទ្ធតែលេចឡើងនៅក្នុងការស្រាវជ្រាវប្រតិបត្តិរបស់អ្នកនោះទេ។ គ្មានការផ្លាស់ប្តូរមិនមែនមានន័យថាបរាជ័យទេ។ ទោះជាយ៉ាងណាក៏ដោយ វាអាចបង្ហាញពីពេលវេលាមិនគ្រប់គ្រាន់ដែលអ្នកបានវិនិយោគលើអន្តរាគមន៍របស់អ្នក ឬតម្រូវឱ្យមានការកែតម្រូវខ្លះនៅក្នុងអន្តរាគមន៍/ឧបករណ៍/បច្ចេកទេសរបស់អ្នក ឬតម្រូវឱ្យមានការផ្តោតអារម្មណ៍ជាប្រព័ន្ធដែលស៊ីជម្រៅជាងមុនទៅលើបញ្ហាដែលបានកំណត់។ ចំណុចណាមួយក្នុងចំណោមចំណុចទាំងនេះ អាចបម្រើជាដែនកំណត់របស់អ្នក ឬអនុសាសន៍របស់អ្នកសម្រាប់វដ្តបន្ទាប់នៃការស្រាវជ្រាវប្រតិបត្តិរបស់អ្នក។
- ជំហានទី ៤៖ ភ្ជាប់ទៅនឹងឯកសារស្រាវជ្រាវ/អក្សរសិល្ប៍: អ្នកអាចភ្ជាប់ការរកឃើញទៅនឹងការស្រាវជ្រាវផ្សេងទៀតដោយសង្ខេប ឧទាហរណ៍៖ ការរកឃើញនេះស្របជាមួយនឹង Gershoff

(2017) ដែលបានរកឃើញថា វិន័យវិជ្ជមានកាត់បន្ថយការឈ្លានពានមានប្រសិទ្ធភាពជាងការដាក់ទណ្ឌកម្ម។

- លើកទឹកចិត្តឱ្យមានការឆ្លុះបញ្ចាំងដោយស្មោះត្រង់ និងមិនស្តីបន្ទោស/មិនទម្លាក់កំហុស (Encourage honest, non-blaming reflection): ការងាររបស់អ្នកគឺជួយពួកគេឱ្យទទួលស្គាល់ទាំងភាពជោគជ័យ និងចំណុចដែលត្រូវការការកែលម្អ។ នៅកម្ពុជា ដែលការគោរពចំពោះអ្នកមានអំណាច/សិទ្ធិអំណាចមានកម្រិតខ្ពស់ គ្រូអាចមានអារម្មណ៍ខ្មាសអៀន ឬភ័យខ្លាចនៅពេលពិភាក្សាអំពីអំពើហិង្សា ដូច្នេះការឆ្លុះបញ្ចាំងដោយមិនស្តីបន្ទោសដើរតួនាទីយ៉ាងសំខាន់សម្រាប់ការកែលម្អវិជ្ជាជីវៈ។ ការស្រាវជ្រាវប្រតិបត្តិត្រូវតែមានសុវត្ថិភាព គាំទ្រ និងអភិវឌ្ឍន៍។ ការឆ្លុះបញ្ចាំងគួរតែផ្តោតលើការអនុវត្ត មិនមែនបុគ្គលិកលក្ខណៈទេ។ សំណួរឆ្លុះបញ្ចាំងមួយចំនួនដែលអ្នកគួរលើកទឹកចិត្តគរុនិស្សិតរបស់អ្នកឱ្យឆ្លុះបញ្ចាំងនៅក្នុង 'ការអនុវត្តវិជ្ជាជីវៈ' របស់ពួកគេគឺចេញពីខ្លួនពួកគេ និងសិស្សរបស់ពួកគេ។ ខាងក្រោមនេះគឺជាឧទាហរណ៍ខ្លះៗ៖
    - តើខ្ញុំបានធ្វើអ្វីខុសប្លែកពីមុន?
    - តើមានអារម្មណ៍ប្រឈមអ្វីខ្លះ?
    - តើមានអ្វីធ្វើឱ្យខ្ញុំភ្ញាក់ផ្អើល?
    - តើសិស្សមានប្រតិកម្មផ្លូវអារម្មណ៍យ៉ាងដូចម្តេច?
    - តើនរណាទទួលបានអត្ថប្រយោជន៍ច្រើនជាងគេ?
    - តើនរណានៅតែជួបការលំបាក?

  ជួនកាល រឿងខ្លះមិនកើតឡើងដូចការរំពឹងទុករបស់អ្នក ដោយសារបញ្ហាក្រមសីលធម៌មួយចំនួន។ ដូច្នេះជាការល្អដែលត្រូវលើកទឹកចិត្តគរុនិស្សិតរបស់អ្នកឱ្យបន្តសួរខ្លួនឯងនូវសំណួរខាងក្រោម៖
    - តើសិស្សមានអារម្មណ៍សុវត្ថិភាពទេ?
    - តើការចូលរួមគឺជាការស្ម័គ្រចិត្តដែរឬទេ?
    - តើការស្រាវជ្រាវបានកាត់បន្ថយគ្រោះថ្នាក់/ផលប៉ះពាល់ដែរឬទេ?

ឧទាហរណ៍

ករណីសិក្សា៖

- ថ្នាក់៖ ថ្នាក់ទី ៥ ក្នុងសាលាបឋមសិក្សារដ្ឋមួយនៅខេត្តបាត់ដំបង។
- ចំនួនសិស្ស៖ ៤២ នាក់

- បញ្ហាដែលបានកំណត់៖ ការស្រែកជាញឹកញាប់ដោយគ្រូ និងជម្លោះពាក្យសម្តីក្នុងចំណោមសិស្សអំឡុងពេលធ្វើការងារក្រុម។

ចំណងជើងដែលបានស្នើឡើង៖ ការកាត់បន្ថយការណ្ឌានពានដោយពាក្យសម្តីនៅក្នុងថ្នាក់ទី ៥ តាមរយៈវិន័យវិជ្ជមាន និងការរៀនសូត្របែបសហការ។

ការស្រាវជ្រាវប្រតិបត្តិនេះមានគោលបំណង៖

(១) កាត់បន្ថយការណ្ឌានពានដោយពាក្យសម្តី (ការស្រែក, ការជេរប្រមាថ) នៅក្នុងថ្នាក់រៀន។

(២) បង្កើនភាសាប្រកបដោយការគោរពក្នុងចំណោមសិស្ស។

(៣) កែលម្អបរិយាកាសថ្នាក់រៀនក្នុងអំឡុងពេលសកម្មភាពក្រុម។

ដើម្បីសម្រេចបាននូវវត្ថុបំណងដែលបានគ្រោងទុក យុទ្ធសាស្ត្រអន្តរាគមន៍ខាងក្រោមត្រូវបានប្រើប្រាស់នៅក្នុងការស្រាវជ្រាវប្រតិបត្តិនេះ៖

(១) ការបង្រៀនយ៉ាងច្បាស់លាស់អំពីភាសាប្រកបដោយការគោរព។

(២) ការរៀនសូត្របែបសហការជាមួយវិន័យក្រុមច្បាស់លាស់។

(៣) បច្ចេកទេសវិន័យវិជ្ជមាន (ការសរសើរ, ការរំលឹកដោយស្ងប់ស្ងាត់)។

(៤) សកម្មភាពដើរតួស្តីពីការដោះស្រាយជម្លោះ។

ទិន្នន័យដែលបានប្រមូល

១. បញ្ជីផ្ទៀងផ្ទាត់ភាពញឹកញាប់នៃឥរិយាបថ (មធ្យមភាគប្រចាំសប្តាហ៍)

ឥរិយាបថ	មុនអន្តរាគមន៍	ក្រោយអន្តរាគមន៍
គ្រូស្រែក	១០	៣
ការជេរប្រមាថរបស់សិស្ស	១៤	៥
ការដោះស្រាយជម្លោះដោយស្ងប់ស្ងាត់	៤	១៦

២. ការស្ទង់មតិសិស្ស (ដោយប្រើសំណួរដែលបានជ្រើសរើស)

- សំណួរ៖ ខ្ញុំមានអារម្មណ៍សុវត្ថិភាពក្នុងការនិយាយនៅក្នុងថ្នាក់។
  - មុន៖ ៤៨% នៃអ្នកចូលរួមបានជ្រើសរើស 'យល់ព្រម'
  - ក្រោយ៖ ៧៨% នៃអ្នកចូលរួមបានជ្រើសរើស 'យល់ព្រម'

៣. ការឆ្លុះបញ្ចាំងរបស់សិស្ស

- មុន៖ គ្រូខឹងនៅពេលយើងធ្វើខុស។
- ក្រោយ៖ គ្រូនិយាយដោយស្ងប់ស្ងាត់ និងជួយយើងដោះស្រាយបញ្ហា។

ការវិភាគទិន្នន័យ

១. ការវិភាគគុំរ៉ូ

- ការណ្ណានពានដោយពាក្យសម្តីបានថយចុះនៅតាមប្រភពទិន្នន័យជាច្រើន។
- ការទំនាក់ទំនងប្រកបដោយការគោរពបានកើនឡើងក្នុងអំឡុងពេលធ្វើការងារក្រុម។
- ការកែលម្អមានភាពស៊ីសង្វាក់គ្នា មិនមែនជាច់ដោយឡែកនោះទេ។

២. ការប្រៀបធៀប មុន-ក្រោយ

- មុន៖ ការស្រែក និងការជេរប្រមាថមានកម្រិតខ្ពស់។
- ក្រោយ៖ ការកើនឡើងនូវទំនុកចិត្ត និងការចូលរួមរបស់សិស្ស។

ការបកស្រាយលទ្ធផល

ការថយចុះនៃការណ្ណានពានដោយពាក្យសម្តីហាក់ដូចជាភ្ជាប់ទៅនឹង (១) ការរំពឹងទុកអំពីឥរិយាបថច្បាស់លាស់ (២) ការធ្វើគំរូភាសាប្រកបដោយការគោរព និង (៣) តួនាទីការងារក្រុមដែលមានរចនាសម្ព័ន្ធ។ ការរកឃើញទាំងនេះគាំទ្រដល់ការស្រាវជ្រាវដែលមានស្រាប់ដែលបង្ហាញថា វិន័យវិជ្ជមាន និងការរៀនសូត្របែបសហការកាត់បន្ថយអំពើហិង្សាក្នុងថ្នាក់រៀន (Gershoff, 2017; UNICEF, 2019)។ ទោះជាយ៉ាងណាក៏ដោយ ជម្លោះមួយចំនួននៅតែកើតមានក្នុងអំឡុងពេលសកម្មភាពដែលមានការប្រកួតប្រជែង ដែលបង្ហាញពីតម្រូវការសម្រាប់ការកែលម្អបន្ថែមទៀតនៅក្នុងវដ្តបន្ទាប់។

សេចក្តីសន្និដ្ឋានបែបឆ្លុះបញ្ចាំង (មិនស្តីបន្ទោស)*

ការស្រាវជ្រាវប្រតិបត្តិនេះបានជួយឱ្យខ្ញុំដឹងថា ប្រតិកម្មរបស់ខ្ញុំបានជះឥទ្ធិពលដល់ឥរិយាបថរបស់សិស្ស។ នៅពេលដែលខ្ញុំរក្សាភាពស្ងប់ស្ងាត់ និងរៀបចំសកម្មភាពបានច្បាស់លាស់ សិស្សបានឆ្លើយតបដោយការគោរព។ ខ្ញុំនឹងបន្តកែលម្អយុទ្ធសាស្ត្ររបស់ខ្ញុំ ជាជាងការស្តីបន្ទោសសិស្ស*។

៦.៦. ការកែសម្រួល និងការចែករំលែក

បន្ទាប់ពីបញ្ចប់វដ្តទីមួយនៃអន្តរាគមន៍របស់អ្នក អ្នកប្រាកដជាមើលឃើញនូវអ្វីដែលត្រូវបានផ្លាស់ប្តូរ និងអ្វីដែលទាមទារឱ្យមានសកម្មភាពបន្ថែមទៀត (សូមមើលឧទាហរណ៍ក្នុងជំហានទី ៥)។ ដូចដែលអ្នកបានដឹងហើយថា ការស្រាវជ្រាវប្រតិបត្តិទាមទារយ៉ាងហោចណាស់ឱ្យមានលើសពីមួយវដ្ត ឬវាអាចនឹងបន្តទៅមុខជានិច្ច។ ដូច្នេះឥឡូវនេះដល់ពេលដែលអ្នកត្រូវគាំទ្រគរុនិស្សិតរបស់អ្នកឱ្យធ្វើការឆ្លុះបញ្ចាំង និងរៀបចំផែនការឡើងវិញ។ ដំណាក់កាលនេះត្រូវបានប្រើដើម្បីកែលម្អអន្តរាគមន៍សម្រាប់ការប្រើប្រាស់នាពេលអនាគត និងរួមចំណែកដល់ចំណេះដឹងវិជ្ជាជីវៈរបស់សាលារៀន។

អ្នកគួរណែនាំគរុនិស្សិតរបស់អ្នកឱ្យពិចារណាកែសម្រួលផែនការសកម្មភាព ដោយលើកទឹកចិត្តពួកគេឱ្យសួរសំណួរមួយចំនួនដូចខាងក្រោម៖

- តើចំណុចអ្វីខ្លះដែលគួររក្សាទុក?
- តើចំណុចអ្វីខ្លះដែលគួរកែប្រែ?
- តើចំណុចអ្វីខ្លះដែលគួរជៀសវាងនៅពេលក្រោយ?

ក្នុងពេលជាមួយគ្នានេះ អ្នកគ្រូវលើកទឹកចិត្តពួកគេឱ្យចែករំលែកការរកឃើញរបស់ពួកគេប្រកបដោយវិជ្ជាជីវៈជាមួយមិត្តរួមការងារ ឬគ្រូបង្រៀននៅសាលាដែលពួកគេបានចុះកម្មសិក្សា ក៏ដូចជាចែករំលែកជាមួយគរុនិស្សិត និងគ្រូឧទ្ទេសនៅសាលាគរុកោសល្យរបស់ពួកគេផ្ទាល់។ ពួកគេអាចចែករំលែកជាទម្រង់ របាយការណ៍ស្រាវជ្រាវ សង្ខេប បទបង្ហាញនៅសាលាគរុកោសល្យ ឬសន្និសីទ ការតាំងបង្ហាញប័ណ្ណប្រកាស (Poster session) ឬកិច្ចប្រជុំចែករំលែកជាមួយមិត្តរួមថ្នាក់ ឬគ្រូណែនាំ។

នៅពេលចែករំលែកលទ្ធផល និងការរកឃើញរបស់ពួកគេ អត្ថប្រយោជន៍ជាច្រើនទៀតអាចរួមចំណែកដល់សិស្ស (អ្នកចូលរួម) ដូចជាការពង្រីកមេរៀនស្តីពីការទំនាក់ទំនងវិជ្ជមានទៅកាន់សាលាទាំងមូល និងការបណ្តុះបណ្តាលសិស្សច្បង/សិស្សធំៗឱ្យក្លាយជា 'អ្នកគាំទ្រការទំនាក់ទំនងក្នុងចំណោមមិត្តភក្តិ។

៦.៧. ប្រព័ន្ធតាមដាន និងការចុះជួយបន្តដែលបានស្នើឡើង សម្រាប់គ្រូឧទ្ទេស

៦.៧.១. ការតាមដាន និងការកិច្ច

ដូចដែលលោកអ្នកបានជ្រាបហើយថា ការស្រាវជ្រាវប្រតិបត្តិគឺជាដំណើរការបែបវដ្ត មិនថាអ្នកអនុវត្តតាមគំរូណាមួយឡើយ ដូច្នេះវាអាចនឹងត្រូវការពេលវេលាដើម្បីសម្រេចបាននូវគោលបំណងដែលបានកំណត់នៅពេលចាប់ផ្តើម ។ នៅក្នុងឯកសារនេះ ខ្ញុំសន្មតថាគរុនិស្សិតរបស់លោកអ្នកមានរយៈពេល ៦ ខែ ដើម្បីបញ្ចប់របាយការណ៍ស្រាវជ្រាវប្រតិបត្តិរបស់ពួកគេ ហេតុនេះខ្ញុំបានរៀបចំផែនការមួយទុកជាឧទាហរណ៍ ។

ការកំណត់កាលបរិច្ឆេទគឺពិតជាមានសារៈសំខាន់ណាស់ ព្រោះគរុសិស្សត្រូវបញ្ចប់របាយការណ៍ឱ្យទាន់ពេលវេលា បើមិនដូច្នោះទេ ពួកគេអាចនឹងជួបបញ្ហាក្នុងការបំពេញរបាយការណ៍កម្មសិក្សា ឬខ្វះពេលវេលាក្នុងការសង្កេតមើលការផ្លាស់ប្តូរដែលពួកគេបានគ្រោងទុក ។ ដើម្បីធានាបាននូវជោគជ័យនេះ លោកអ្នកដែលជាគ្រូឧទ្ទេសត្រូវដើរតួនាទីយ៉ាងសកម្មក្នុងដំណើរការស្រាវជ្រាវប្រតិបត្តិរបស់គរុនិស្សិត។ ដូចនេះ គ្រូឧទ្ទេសគួរកំណត់កាលវិភាគជួបពិភាក្សាប្រចាំខែ (យ៉ាងតិច ៦ ដង) រួមជាមួយការប្រជុំត្រួតពិនិត្យធំៗចំនួន ២ លើក (ការពិនិត្យគម្រោងស្នើសុំ និងការពិនិត្យរបាយការណ៍បញ្ចប់) ។

ប្រព័ន្ធតាមដាន និងការចុះជួយបន្តដែលច្បាស់លាស់នឹងជួយលោកអ្នកធានាបានថា៖

- គរុសិស្សមានវឌ្ឍនភាពថេរលើគ្រប់ជំហានទាំង ៦ នៃដំណើរការស្រាវជ្រាវប្រតិបត្តិ។
- លោកអ្នកអាចផ្តល់ការគាំទ្រ មតិកែលម្អ និងការណែនាំបានទាន់ពេលវេលា ។
- ការស្រាវជ្រាវរបស់គរុសិស្សរក្សាបាននូវស្តង់ដារសីលធម៌របស់ស្ថាប័ន។
- បញ្ហាប្រឈមជាក់ស្តែង (ការយឺតយ៉ាវ បរិបទ ឬឧបសគ្គក្នុងថ្នាក់រៀន) ត្រូវបានរកឃើញ និងដោះស្រាយបានរហ័ស ។

តារាងទី ៣៖ សង្ខេបការកិច្ច និងលទ្ធផលរំពឹងទុក

ខែ	ការកិច្ចគន្លឹះដែលត្រូវអនុវត្ត	លទ្ធផល/អ្វីដែលត្រូវបញ្ចប់
ខែទី ១	ការតម្រង់ទិស	សេចក្តីថ្លែងបញ្ជា, ទិន្នន័យបឋម, សេចក្តីព្រាងគម្រោង AR
ខែទី២	ការរៀបចំផែនការសកម្មភាព, ការរៀបចំវិធីសាស្ត្រអន្តរាគមន៍ និងឧបករណ៍ស្រាវជ្រាវ	ផែនការសកម្មភាពសម្រេច, ឧបករណ៍ប្រមូលទិន្នន័យ, ទម្រង់ការយល់ព្រម
ខែទី៣	ការអនុវត្ត (វដ្តទី ១)	កំណត់ហេតុប្រចាំថ្ងៃ, បញ្ជីសង្កេត

ខែទី៤	បន្តការអនុវត្ត និងការប្រមូលទិន្នន័យ	របាយការណ៍ពាក់កណ្តាលវដ្ត, ការប្រមូលទិន្នន័យបឋមបានបញ្ចប់
ខែទី៥	ការវិភាគទិន្នន័យ, ការឆ្លុះបញ្ចាំង និងការកែសម្រួល	លទ្ធផលបឋម, ផែនការអន្តរាគមន៍ដែលបានកែសម្រួល
ខែទី៦	សរសេររបាយការណ៍បញ្ចប់ និងត្រៀមការបទបង្ហាញ	របាយការណ៍ពេញលេញ, ស្លាយបទបង្ហាញ, វគ្គចែករំលែកបទពិសោធន៍

រយៈពេល ៦ ខែអាចនឹងកន្លងផុតទៅយ៉ាងលឿន ប្រសិនបើសកម្មភាពទាំងអស់ប្រព្រឹត្តទៅតាមផែនការដែលបានគ្រោងទុក ។ ទោះជាយ៉ាងណាក៏ដោយ វានឹងមិនមែនជាការងាយស្រួលនោះទេ ប្រសិនបើអ្វីៗមិនប្រព្រឹត្តទៅដូចការរំពឹងទុក ។ ខាងក្រោមនេះគឺជាការកិច្ចរួមមួយចំនួន ដែលលោកអ្នកគួរអនុវត្តក្នុងអំឡុងពេល ៦ ខែនេះ ។ ការកិច្ចទាំងនេះនឹងជួយឱ្យលោកអ្នកអាចបន្ថែមទៅក្នុងទម្រង់ផែនការខាងលើ ដើម្បីឱ្យកាន់តែមានភាពច្បាស់លាស់តាមបំណងប្រាថ្នារបស់លោកអ្នក

តារាងទី ៤៖ ប្រភេទនៃកិច្ចការ

កិច្ចការ	ការប្រជុំតម្រូវ	ការជួបគាំទ្រ	ការទទួលខុសត្រូវរបស់លោកអ្នក
ការប្រជុំតម្រង់ទិស៖ ការតម្រង់ទិសការស្រាវជ្រាវប្រតិបត្តិសម្រាប់អហិង្សា	☑		
ការប្រជុំពិនិត្យគម្រោងស្នើសុំ [ចុងខែទី ១]	☑		✓ការពិនិត្យលើកទី ១
ការតាមដានប្រចាំខែ [ខែទី ២ ដល់ទី ៦]	☑		
ការប្រជុំពិនិត្យរបាយការណ៍បញ្ចប់ [ចុងខែទី ៦]	☑		✓ការពិនិត្យលើកទី ២
ការចុះសង្កេតក្នុងថ្នាក់រៀន		☑✪	
វគ្គផ្តល់មតិកែលម្អជាក្រុមជាមួយមិត្តភក្តិ		☑✪	
ការពិនិត្យតាមអនឡាញ/ទូរសព្ទ នៅពេលមានបញ្ហាប្រឈម		✪	

ពិនិត្យរាល់ការងារដែលបានដាក់ស្នើជាលាយលក្ខណ៍អក្សរ			✓
ផ្តល់មតិកែលម្អក្នុងរយៈពេល ៧ ថ្ងៃ (តាមការជាក់ស្តែង)			✓
តាមដានការអនុវត្តតាមក្រមសីលធម៌			✓
ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃស្នាដៃរបស់គរុសិស្ស			✓
អនុម័តជំហាននីមួយៗមុននឹងបន្តទៅជំហានបន្ទាប់			✓

Note:

☑ = required ☑✪ = *either required or optional*

✪ = *optional* ✓ = *highly required*

៦.៧.២. បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការតាមដានជំហាននីមួយៗ សម្រាប់គ្រូឧទ្ទេស

ការធ្វើការស្រាវជ្រាវប្រតិបត្តិសម្រាប់អហិង្សា ឬសម្រាប់ប្រសិទ្ធភាពនៃការបង្រៀន និងការរៀន ត្រូវចំណាយពេលយូរដើម្បីបង្កើតការផ្លាស់ប្តូរដែលអ្នកចង់ឃើញ បន្ទាប់ពីបញ្ហាត្រូវបានកំណត់ ។ បន្ថែមពីនេះ សកម្មភាពជាបន្តបន្ទាប់ត្រូវតែធ្វើឡើងដើម្បីកំណត់បញ្ហា ។ និយាយឱ្យសាមញ្ញ សកម្មភាព និងការប្តេជ្ញាចិត្តជាច្រើនត្រូវបានទាមទារនៅក្នុងគ្រប់ជំហាននៃការស្រាវជ្រាវប្រតិបត្តិ ហើយជំហាននីមួយៗមិនអាចរំលងបានឡើយ ។ ដូច្នេះ កិច្ចសហការរវាងផែនការ និងសកម្មភាពគួរត្រូវបានតាមដាន និងគាំទ្រឱ្យទាន់ពេលវេលា ។ ខាងក្រោមនេះគឺជាបញ្ជីផ្ទៀងផ្ទាត់លម្អិតដែលគ្រូឧទ្ទេសអាចប្រើដើម្បីតាមដានវឌ្ឍនភាព។

តារាងទី៥: បញ្ជីផ្ទៀងផ្ទាត់សម្រាប់គ្រូឧទ្ទេសប្រើប្រាស់ ដើម្បីតាមដានវឌ្ឍនភាពការស្រាវជ្រាវប្រតិបត្តិរបស់គរុនិស្សិត

<u>ការតាមដានលទ្ធផលសម្រេចបានតាមជំហាន</u>

គ្រូឧទ្ទេសអាចប្រើប្រាស់ការគូសសញ្ញា (Tick) ក្នុងប្រអប់ណាមួយដែលត្រូវនឹងកម្រិតគុណភាពនៃការកិច្ចនីមួយៗ។ សូមអានអត្ថន័យនៃជម្រើសនីមួយៗខាងក្រោម។ លោកអ្នកអាចរៀបចំតារាងនេះសម្រាប់គរុនិស្សិតម្នាក់ៗដែលស្ថិតក្រោមការចុះជួយរបស់លោកអ្នក។

- ធ្វើឡើងវិញ (Re-Do): គរុនិស្សិតត្រូវបានតម្រូវឱ្យអាន សរសេរ និងរៀបចំរចនាសម្ព័ន្ធឡើងវិញ។
- មធ្យម (Okay): មើលទៅល្អ ប៉ុន្តែព័ត៌មានចាំបាច់ត្រូវមានភាពជាក់លាក់ជាងនេះ។
- កែសម្រួល (Revised): ត្រូវការការយកចិត្តទុកដាក់បន្ថែម ហើយគរុសិស្សចាំបាច់ត្រូវធ្វើឱ្យវាមានភាពច្បាស់លាស់ជាងមុន។
- យល់ព្រម (Accepted): ល្អគ្រប់គ្រាន់ អាចបន្តទៅជំហានបន្ទាប់បាន។

ជំហានទី ១៖ ការកំណត់ និងវិភាគបញ្ហា	ធ្វើឡើងវិញ	មធ្យម	កែសម្រួល	យល់ព្រម
ការពិពណ៌នាច្បាស់លាស់អំពីបញ្ហាដែលពាក់ព័ន្ធនឹងអំពើហិង្សា				
ផ្អែកលើភស្តុតាង (ការសង្កេតបឋម, ការសន្ទនា, ការស្នង់មតិ)				
អាចអនុវត្តបានសម្រាប់ការស្រាវជ្រាវប្រតិបត្តិរយៈពេល ៦ ខែ				
ឫសគល់នៃបញ្ហាត្រូវបានកំណត់				
ការវាយតម្លៃលើហានិភ័យផ្អែកក្រមសីលធម៌				
ការបង្កើតសំណួរស្រាវជ្រាវ				
ជំហានទី ២៖ ការរៀបចំផែនការសកម្មភាព	**ធ្វើឡើងវិញ**	**មធ្យម**	**កែសម្រួល**	**យល់ព្រម**
ការពិពណ៌នាអំពីអន្តរាគមន៍បានច្បាស់លាស់				
មានទ្រឹស្តី ឬការស្រាវជ្រាវយោងដើម្បីគាំទ្រដល់អន្តរាគមន៍				
សម្ភារឧបទេស ឧបករណ៍ និងកាលវិភាគត្រូវបានរៀបចំរួចរាល់				
អ្នកពាក់ព័ន្ធត្រូវបានជូនដំណឹង (គ្រូណែនាំ, នាយកសាលា)				
ការបញ្ចូលការពិចារណាលើក្រមសីលធម៌ (ការយល់ព្រម, ការរក្សាសម្ងាត់)				
ទទួលបានការអនុម័តពីគ្រូឧទ្ទេសមុនពេលអនុវត្ត				
ជំហានទី ៣៖ ការអនុវត្ត	**ធ្វើឡើងវិញ**	**មធ្យម**	**កែសម្រួល**	**យល់ព្រម**
អន្តរាគមន៍ត្រូវបានអនុវត្តតាមផែនការ				
ការបំពេញកំណត់ហេតុឆ្លុះបញ្ចាំងប្រចាំថ្ងៃ/ប្រចាំសប្តាហ៍				

ការកត់ត្រាបញ្ហាប្រឈម រួមជាមួយដំណោះស្រាយដែលអាចធ្វើទៅបាន				
មិនមានសកម្មភាពបង្ករគ្រោះថ្នាក់ ឬការដាក់ពិន័យត្រូវបានសង្កេតឃើញ				
ជំហានទី ៤៖ ការសង្កេត និងការប្រមូលទិន្នន័យ	ធ្វើឡើងវិញ	មធ្យម	កែសម្រួល	យល់ព្រម
ឧបករណ៍ប្រមូលទិន្នន័យត្រូវបានប្រើប្រាស់ត្រឹមត្រូវ				
ភស្តុតាងត្រូវបានប្រមូលពីច្រើនប្រភព (Triangulation)				
ទិន្នន័យត្រូវបានរក្សាទុកដោយសុវត្ថិភាព និងតាមក្រមសីលធម៌				
ទិន្នន័យឆ្លុះបញ្ចាំងទាំងលទ្ធផលវិជ្ជមាន និងអវិជ្ជមាន				
និន្នាការបឋមនៃលទ្ធផលត្រូវបានកំណត់				
ជំហានទី ៥៖ ការឆ្លុះបញ្ចាំង និងការបកស្រាយ	ធ្វើឡើងវិញ	មធ្យម	កែសម្រួល	យល់ព្រម
ការប្រៀបធៀបលទ្ធផលដែលរកឃើញជាមួយនឹងទិន្នន័យបឋម				
ការវិភាគឆ្លុះបញ្ចាំងបង្ហាញពីភាពស្មោះត្រង់ និងការគិតបែបវិភាគ				
មានភស្តុតាងច្បាស់លាស់គាំទ្រដល់សេចក្ដីសន្និដ្ឋាន				
ការទទួលស្គាល់នូវកម្រិតកំណត់នៃការស្រាវជ្រាវ				
សេចក្ដីព្រាងផែនការដែលបានកែសម្រួល (ប្រសិនបើពេលវេលាអនុញ្ញាត)				
ជំហានទី ៦៖ ការកែសម្រួល និងការចែករំលែក	ធ្វើឡើងវិញ	មធ្យម	កែសម្រួល	យល់ព្រម
ការបង្ហាញគំនិតដែលបានកែសម្រួល (ទោះបីមិនទាន់បានអនុវត្ត)				
របាយការណ៍ស្រាវជ្រាវប្រតិបត្តិពេញលេញត្រូវបានបញ្ចប់				

បទបង្ហាញចុងក្រោយត្រូវបានរៀបចំរួចរាល់				
គរុសិស្សចែករំលែកលទ្ធផលជាមួយ៖				
• គ្រូណែនាំនៅសាលាកម្មសិក្សា	*(គូសសញ្ញាទីនេះ មានន័យថាបានរួចរាល់)*			
• មិត្តភក្តិរួមជំនាន់	*(គូសសញ្ញាទីនេះ មានន័យថាបានរួចរាល់)*			
• សាលារៀន ឬវិទ្យាស្ថាន (ប្រសិនបើមាន)	*(គូសសញ្ញាទីនេះ មានន័យថាបានរួចរាល់)*			
គ្រូឧទ្ទេសបញ្ជាក់ពីការបញ្ចប់ការងារទាំងស្រុង				

៦.៧.៣. ការជួបពិភាក្សា ឬការតាមដានប្រចាំខែ

ដូចដែលបានសន្មតខាងលើ ក្នុងអំឡុងពេល ៦ ខែនៃការធ្វើស្រាវជ្រាវប្រតិបត្តិលើការអប់រំអហិង្សា គ្រូឧទ្ទេសគួរមានការជួបពិភាក្សាជាទៀងទាត់យ៉ាងហោចណាស់ម្តងក្នុងមួយខែ (មិនរាប់បញ្ចូលការប្រជុំធំ ២ លើកដើម្បីអនុម័តគម្រោងស្នើសុំ និងរបាយការណ៍បញ្ចប់) ក្នុងគោលបំណងតាមដានវឌ្ឍនភាពរបស់គរុសិស្ស។ លោកអ្នកអាចយោងតាមរបាយការណ៍ត្រួតពិនិត្យ ឬទម្រង់ដែលលោកអ្នកស៊ាំបំផុត ឬទម្រង់ដែលបានណែនាំដោយស្ថាប័នរបស់លោកអ្នក។

ខាងក្រោមនេះគឺជាទម្រង់ត្រួតពិនិត្យមួយ ដែលអាចជួយលោកអ្នកក្នុងការតាមដានវឌ្ឍនភាពការស្រាវជ្រាវប្រតិបត្តិរបស់គរុសិស្ស។ ទម្រង់នេះត្រូវបំពេញដោយលោកអ្នកក្នុងអំឡុងពេលជួបពិភាក្សាប្រចាំខែនីមួយៗ។ ទម្រង់នេះមាន ៧ ផ្នែកគឺ៖ សង្ខេបវឌ្ឍនភាព, ឯកសារដែលបានពិនិត្យ, ចំណុចខ្លាំងដែលបានសង្កេតឃើញក្នុងខែនេះ, បញ្ហាប្រឈម/ការព្រួយបារម្ភ, មតិកែលម្អរបស់គ្រូឧទ្ទេស, សកម្មភាពដែលត្រូវធ្វើមុនការជួបគ្នាលើកក្រោយ និងការអនុម័តរបស់គ្រូឧទ្ទេស។

កំណត់ត្រានៅក្នុងទម្រង់នេះ អាចប្រើប្រាស់ជាមធ្យោបាយទំនាក់ទំនងផ្លូវការរវាងលោកអ្នក និងគរុសិស្ស ក្នុងដំណើរការស្រាវជ្រាវប្រតិបត្តិ។ លើសពីនេះ លោកអ្នកអាចប្រើវាជាបាយការណ៍សិក្សារបស់បុគ្គលម្នាក់ៗសម្រាប់ស្ថាប័ន ឬសម្រាប់គ្រូណែនាំនៅមណ្ឌលកម្មសិក្សា ក្នុងករណីចាំបាច់ ឬមានការសាកសួរ។

ឧទាហរណ៍ទី ១៖

<u>ទម្រង់ត្រួតពិនិត្យប្រចាំខែ (លម្អិត)</u>

ឈ្មោះគរុសិស្ស៖ _____ គ្រូឧទ្ទេស៖ _____ (បើមាន)

ខែ៖ _____ [កាលបរិច្ឆេទ៖ _____]

១. សង្ខេបវឌ្ឍនភាព

- តើបច្ចុប្បន្នអ្នកកំពុងបញ្ចប់ជំហានណា?

  _____

- តើអ្នកសម្រេចបានអ្វីខ្លះ តាំងពីការជួបគ្នាលើកមុន?

  _____

២. ឯកសារដែលបានពិនិត្យ

☐ ការវិភាគបញ្ហា ☐ កំណត់ហេតុប្រចាំថ្ងៃ ☐ ឧបករណ៍ប្រមូលទិន្នន័យ

☐ ផែនការសកម្មភាព ☐ កំណត់ត្រាសង្កេតការណ៍ ☐ សេចក្ដីព្រាងផ្នែកខ្លះនៃរបាយការណ៍

៣. ចំណុចខ្លាំងដែលបានសង្កេតឃើញក្នុងខែនេះ (ឧទាហរណ៍៖ លម្អិតនៃការសង្កេត, ភាពហ៍សរហួនផ្នែកក្រមសីលធម៌, ភាពច្នៃប្រឌិត)

---

៤. បញ្ហាប្រឈម/ការព្រួយបារម្ភ (ឧទាហរណ៍៖ ការគ្រប់គ្រងពេលវេលា, ការប្រមូលទិន្នន័យ, ការតវ៉ារបស់សិស្ស)

---

៥. មតិកែលម្អរបស់គ្រូឧទ្ទេស (ការណែនាំជាក់ស្ដែង និងក្នុងន័យស្ថាបនាសម្រាប់ការកែលម្អ)

---

៦. សកម្មភាពដែលត្រូវធ្វើមុនការជួបគ្នាលើកក្រោយ (ឧទាហរណ៍៖ កែសម្រួលផែនការ, ប្រមូលទិន្នន័យបន្ថែម, ដោះស្រាយបញ្ហាក្រមសីលធម៌)

---

៧. ការអនុម័តរបស់គ្រូឧទ្ទេស

☐ គរុសិស្សកំពុងដើរតាមផែនការ

☐ ត្រូវការការចុះជួយចំគោលដៅ

☐ ប្រឈមនឹងការយឺតយ៉ាវ (ត្រូវការអន្តរាគមន៍ដោះស្រាយ)

ក្នុងករណីដែលលោកអ្នកចង់ឱ្យទម្រង់នៃការតាមដាន និងការចុះជួយមានលក្ខណៈសាមញ្ញជាងមុន លោកអ្នកអាចពិចារណាប្រើប្រាស់ឧទាហរណ៍ខាងក្រោម។ ទម្រង់នេះមានលក្ខណៈសន្សំសំចៃជាងមុន ដោយលោកអ្នកអាចតាមដានវឌ្ឍនភាពរបស់គរុសិស្សច្រើនជាងម្នាក់នៅលើក្រដាសដែលបានបោះពុម្ពតែមួយសន្លឹក។ លោកអ្នកគ្រាន់តែគូសសញ្ញា (Tick) ក្នុងប្រអប់ ប្រសិនបើគរុសិស្សបានបញ្ចប់ជំហាននីមួយៗ និងប្រសិនបើគរុសិស្សរូបនោះបានអនុវត្តតាមរាល់តម្រូវការផ្នែកក្រមសីលធម៌។ ទោះជាយ៉ាងណាក็ដោយ លោកអ្នកអាចសរសេរមតិយោបល់អំពីចំណុចដែលលោកអ្នកចង់ឱ្យពួកគេកែលម្អ ឬត្រៀមខ្លួនឱ្យរួចរាល់ មុនការចុះតាមដាន/ការជួបពិភាក្សាលើកក្រោយ នៅក្នុងជួរឈរ «កំណត់ចំណាំ/មតិយោបល់របស់អ្នក»។

ឧទាហរណ៍ទី ២៖

ទម្រង់ត្រួតពិនិត្យប្រចាំខែ (បែបសាមញ្ញ)

ឈ្មោះគរុនិស្សិត៖ _____ គ្រូឧទ្ទេស៖ _____

ជំហានក្នុង AR	ការអនុវត្តតាមក្រមសីលធម៌	កម្រិតហានិភ័យ	កំណត់ចំណាំ/មតិយោបល់របស់អ្នក
ជំហានទី ១ ☐	☐	គ្មាន / ទាប / មធ្យម / ខ្ពស់	
ជំហានទី ២ ☐	☐	គ្មាន / ទាប / មធ្យម / ខ្ពស់	
ជំហានទី ៣ ☐	☐	គ្មាន / ទាប / មធ្យម / ខ្ពស់	
ជំហានទី ៤ ☐	☐	គ្មាន / ទាប / មធ្យម / ខ្ពស់	
ជំហានទី ៥ ☐	☐	គ្មាន / ទាប / មធ្យម / ខ្ពស់	
ជំហានទី ៦ ☐	☐	គ្មាន / ទាប / មធ្យម / ខ្ពស់	

ទម្រង់ខាងក្រោមនេះអាចជាជម្រើស ប្រសិនបើស្ថាប័នរបស់លោកអ្នកមិនមានតម្រូវការជាដាច់ខាត។ ទម្រង់ត្រួតពិនិត្យចុងក្រោយនេះ អាចប្រើប្រាស់ជាបាយការណ៍សង្ខេប ឬបាយការណ៍វាយតម្លៃ ដើម្បីបញ្ជាក់ថា តើគរុសិស្សដែលស្ថិតក្រោមការចុះជួយរបស់លោកអ្នក មានសមត្ថភាពគ្រប់គ្រាន់ ឬបានបញ្ចប់គម្រោងរបស់ពួកគេ

ដោយជោគជ័យក្នុងកំឡុងពេលដែលបានកំណត់ដែរឬទេ។ ក្នុងករណីកំណត់រយៈពេល ៦ ខែ ទម្រង់នេះត្រូវបំពេញនៅពេលបញ្ចប់នៃរយៈពេល ៦ ខែនៃការស្រាវជ្រាវ។

ឧទាហរណ៍3៖

ទម្រង់សង្ខេបការត្រួតពិនិត្យចុងក្រោយ (Final Supervision Summary Form)

ឈ្មោះគរុសិស្ស៖ _____

ចំណងជើងស្រាវជ្រាវប្រតិបត្តិ (AR Title)៖ _____

១. គុណភាពនៃការស្រាវជ្រាវប្រតិបត្តិ (AR) ជារួម

☐ ល្អណាស់ (Excellent) ☐ ពេញចិត្ត/មធ្យម (Satisfactory)

☐ ល្អ (Good) ☐ ត្រូវការកែលម្អ (Needs improvement)

២. ការបញ្ចប់ជំហានទាំង ៦ (Completion of All Six Steps) ☐ បញ្ចប់ទាំងស្រុង (Yes) ☐ បញ្ចប់បានខ្លះ (Partially) ☐ មិនទាន់បញ្ចប់ (No)

៣. ការអនុវត្តក្រមសីលធម៌ (Ethical Conduct) ☐ អនុវត្តត្រឹមត្រូវតាមក្រមសីលធម៌ទាំងស្រុង ☐ មានបញ្ហាក្តីបារម្ភតិចតួច (មិនបង្គ្រោះថ្នាក់) ☐ មានបញ្ហាក្តីបារម្ភធំៗ (តម្រូវឱ្យមានអន្តរាគមន៍ដោះស្រាយ)

៤. ចំណុចខ្លាំងនៃគម្រោងស្រាវជ្រាវ៖ (រៀបរាប់ពីឥទ្ធិពល, នវានុវត្តន៍, ការរួមចំណែកដល់ការអប់រំអហិង្សា)

_____

_____

៥. ចំណុចដែលត្រូវកែលម្អ៖ (វិធីសាស្ត្រស្រាវជ្រាវ, ការរៀបចំទុកដាក់, ការវិភាគ, ការសរសេរ)

_____

_____

៦. ការផ្តល់អនុសាសន៍សម្រាប់ការបញ្ចប់ការសិក្សា (Recommendation for Graduation)

☐ យល់ព្រមឱ្យបញ្ចប់ការសិក្សា (Recommended)

☐ យល់ព្រមឱ្យបញ្ចប់ ដោយមានការកែសម្រួលតិចតួច (Recommended with minor revision)

☐ មិនទាន់យល់ព្រមឱ្យបញ្ចប់ (ត្រូវដាក់ស្នើឡើងវិញ - Resubmission required)

ករណីសិក្សា

៧. **ករណីសិក្សាគំរូ** (Sample Case Studies)

៧.១. ករណីសិក្សាទី ១ (Showcase 1)

ការហៅគ្នាដោយប្រើត្រកូល (ការប្រមាថដោយសម្តី)

ក្នុងថ្នាក់ទី ៦ នៃសាលាបឋមសិក្សាមួយក្នុងខេត្តបាត់ដំបង គរុនិស្សិតបានសង្កេតឃើញថា នៅពេលម៉ោងសម្រាក សិស្សានុសិស្សតែងតែហៅគ្នាទៅវិញទៅមកដោយប្រើឈ្មោះត្រកូល ។ ក្នុងវប្បធម៌ខ្មែរ ការហៅមិត្តភក្តិដោយប្រើត្រកូលជារឿងមិនសមរម្យ អាចចាត់ទុកថាជាការចំអក ការមិនគោរព ឬជាការប្រមាថ ។

ករណីនេះអាចសង្កេតឃើញថា យូរៗទៅ ឥរិយាបថនេះ (ការហៅគ្នាដោយប្រើត្រកូល) បាននាំឱ្យមានផលប៉ះពាល់មួយចំនួនដូចជា ៖

- ការធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍ និងបង្កជម្លោះផ្លូវចិត្តក្នុងចំណោមសិស្ស
- សិស្សមួយចំនួនបដិសេធមិនព្រមនិយាយរកគ្នា ឬធ្វើការងារជាមួយគ្នា
- ការកើនឡើងនូវភាពតានតឹងក្នុងអំឡុងពេលធ្វើការងារក្រុម និង/ឬ ការកាត់បន្ថយការសហការគ្នា និងសុខដុមរមនាក្នុងថ្នាក់រៀន

ទោះបីជាឥរិយាបថនេះមិនពាក់ព័ន្ធនឹងអំពើហិង្សាខាងរូបរាងកាយក៏ដោយ ប៉ុន្តែវាគឺជាទម្រង់នៃអំពើហិង្សាដោយសម្តី និងផ្លូវចិត្ត ដែលជះឥទ្ធិពលអវិជ្ជមានដល់ទំនាក់ទំនងរវាងសិស្ស និងការសិក្សារៀនសូត្រ ។ ហេតុដូច្នេះហើយ គរុនិស្សិត ដោយមានការណែនាំពីគ្រូឧទ្ទេស និងគ្រូណែនាំនៅសាលារៀន បានសម្រេចចិត្តធ្វើការស្រាវជ្រាវសកម្ម (Action Research - AR) ដើម្បីដោះស្រាយបញ្ហានេះ ។

<u>សំណើស្រាវជ្រាវប្រតិបត្តិProposed Action Research</u>

ចំណងជើង៖ ការកាត់បន្ថយការប្រមាថដោយសម្តី តាមរយៈការអនុវត្តការប្រើប្រាស់ភាសាប្រកបដោយការគោរពក្នុងចំណោមសិស្សថ្នាក់ទី ៦

នៅពេលសង្កេត និងកំណត់អំពីបញ្ហាក្នុងករណីនេះ អ្នកអាចពិចារណាសម្រេចឱ្យបាននូវគោលបំណងមួយចំនួនដូចខាងក្រោម (បញ្ជាក់៖ អ្នកអាចជ្រើសរើសគោលបំណងមួយ ឬពីរក្នុងចំណោមគោលបំណងទាំងនេះ)៖

- ដើម្បីស្វែងយល់ ថា តើការហៅឈ្មោះត្រកូលត្រូវបានចាត់ទុកថាជាការប្រមាថយ៉ាងដូចម្តេច និងដោយសារមូលហេតុអ្វី ក្នុងចំណោមសិស្សថ្នាក់ទី ៦

- ដើម្បីកាត់បន្ថយ ភាពញឹកញាប់នៃការហៅឈ្មោះត្រកូលគ្នា ក្នុងអំឡុងពេលម៉ោងសម្រាក និងម៉ោងសិក្សាក្នុងថ្នាក់
- ដើម្បីលើកកម្ពស់ ការប្រើប្រាស់ភាសាប្រកបដោយការគោរព និងការកសាងទំនាក់ទំនងវិជ្ជមានរវាងមិត្តភក្តិ
- ដើម្បីកែលម្អ កិច្ចសហប្រតិបត្តិការក្នុងថ្នាក់រៀន និងការចូលរួមក្នុងការងារក្រុម

ជំហានទី ១៖ ការកំណត់ និងការធ្វើការវិនិច្ឆ័យបញ្ហា (Identifying and Diagnosing the Problem)

គរុនិស្សិតគួរតែធ្វើសកម្មភាពដូចជា៖

- ពិភាក្សាផ្លូវការតិចតួចជាមួយគ្រូណែនាំនៅសាលារៀន អំពីឥរិយាបថរបស់សិស្សក្នុងអំឡុងពេលម៉ោងសម្រាក
- សង្កេតមើលសិស្សក្នុងអំឡុងពេលម៉ោងលេង និងកត់ត្រាទុកនូវទម្លាប់នៃការហៅគ្នាដោយប្រើត្រកូល
- សន្ទនាជាលក្ខណៈមិនផ្លូវការក្នុងរយៈពេលខ្លីជាមួយសិស្សមួយចំនួន ដើម្បីស្វែងយល់ពីអារម្មណ៍របស់ពួកគេ
- កត់ត្រានូវរាល់ហេតុការណ៍ដែលបានកើតឡើងក្នុងសៀវភៅកំណត់ហេតុសង្កេត (ដោយមិនបញ្ជាក់ឈ្មោះសិស្ស)

គរុនិស្សិតចាប់ផ្តើមធ្វើការវិនិច្ឆ័យលើបញ្ហានេះថា៖ បញ្ហានេះត្រូវបានកំណត់ថាជាអំពើហិង្សាដោយសម្តី ដែលមានឫសគល់មកពី៖

- ការខ្វះការយល់ដឹង អំពីការប្រើប្រាស់ភាសាប្រកបដោយការគោរព
- ទម្លាប់នៃការឌឹដងចំអកគ្នា ដែលបានក្លាយជារឿងធម្មតាសម្រាប់មិត្តភក្តិ
- ការខ្វះខាតនូវបទដ្ឋាន ឬវិន័យច្បាស់លាស់ក្នុងថ្នាក់រៀន អំពីរបៀបហៅគ្នាឱ្យបានគួរសម

ក្នុងនាមជាគ្រូឧទ្ទេស លោកគ្រូ អ្នកគ្រូគួរតែ៖

- រំលឹកគរុនិស្សិត មិនឱ្យបិទស្លាកសិស្សថាជាក្មេង «ខូច» ឬ «អាក្រក់» ឡើយ។
- ធានាថាបញ្ហានេះត្រូវបានកំណត់ថាជា «ទម្រង់នៃឥរិយាបថ» មិនមែនជាការប្រព្រឹត្តខុសរបស់បុគ្គលសិស្សម្នាក់ៗនោះទេ។
- លើកទឹកចិត្តឱ្យមានការបកស្រាយដោយយកចិត្តទុកដាក់លើផ្នែកវប្បធម៌ (ព្រោះការហៅត្រកូលអាចមានអត្ថន័យខុសៗគ្នាទៅតាមបរិបទជាក់ស្តែង)។

ជំហានទី ២៖ ការរៀបចំផែនការសកម្មភាព

គរុនិស្សិតរៀបចំនូវវិធានការអនុវត្តន៍មួយចំនួនដូចជា៖

- ការបង្រៀនដោយផ្ទាល់ អំពីការប្រើប្រាស់ភាសាប្រកបដោយការគោរព (ការប្រើឈ្មោះខ្លួន រួមជាមួយពាក្យហៅក្រៅដែលគួរសម)
- ការពិភាក្សាក្នុងថ្នាក់ អំពីរបៀបដែលពាក្យសម្តីអាចធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍អ្នកដទៃ
- សកម្មភាពសម្តែងតួ ដែលបង្ហាញពីភាពខុសគ្នារវាងការប្រើសម្តីគួរសម និងមិនគួរសម
- ការបង្កើតកិច្ចព្រមព្រៀងក្នុងថ្នាក់ ស្តីពីការទំនាក់ទំនងប្រកបដោយការគោរព

ឧបករណ៍មួយចំនួនខាងក្រោមអាចត្រូវបានយកមកប្រើប្រាស់៖

- កិច្ចតែងការបង្រៀន ដែលមានបញ្ចូលនូវមេរៀនខ្លីៗអំពីការអប់រំសន្តិភាព (Peace Education)
- ផ្ទាំងរូបភាពស្តីពីការរំពឹងទុកនៃឥរិយាបថ៖ "យើងនិយាយដោយប្រើពាក្យសម្តីគួរសម"
- ប័ណ្ណសម្តែងតួ ដែលមានដាក់បញ្ចូលនូវស្ថានភាពជាក់ស្តែងផ្សេងៗក្នុងសាលារៀន

ក្នុងនាមជាគ្រូឧទ្ទេស លោកគ្រូ អ្នកគ្រូគួរតែ៖

- ធានាថាវិធានការអន្តរាគមន៍មានលក្ខណៈអប់រំ មិនមែនជាលក្ខណៈដាក់ទណ្ឌកម្មនោះទេ។
- ជួយគរុនិស្សិតក្នុងការជ្រើសរើសយុទ្ធសាស្ត្រណាដែលសាមញ្ញ និងសមស្របទៅតាមវ័យរបស់សិស្ស។
- បញ្ជាក់ឱ្យច្បាស់ថា សកម្មភាពដែលបានគ្រោងទុកគឺស្របតាមវប្បធម៌សាលារៀន និងមានការឯកភាពពីគ្រូណែនាំ។

ជំហានទី ៣៖ ការអនុវត្តសកម្មភាព

ចូរស្រមៃថា ផែនការនេះត្រូវបានយកទៅអនុវត្តជាមួយថ្នាក់រៀននោះក្នុងរយៈពេល ៤ សប្តាហ៍៖

- សកម្មភាពដែលត្រូវបានអនុវត្ត៖
  - មេរៀនរយៈពេល ៣០ នាទី ស្តីពីភាសាប្រកបដោយការគោរព និងអារម្មណ៍។
  - សិស្សបានចែករំលែកបទពិសោធន៍ អំពីការឈឺចាប់ដែលបង្ក្ដឡើងដោយពាក្យសម្តី។
- សកម្មភាពសម្តែងតួ ក្នុងអំឡុងពេលម៉ោងសិក្សា។
  - ការបិទផ្ទាំងរូបភាព នៅក្នុងថ្នាក់រៀនដើម្បីជាការរំលឹកស្មារតី។
  - គ្រូធ្វើជាគំរូ ក្នុងការប្រើប្រាស់ពាក្យហៅក្រៅដែលគួរសមជាប្រចាំ។

ក្នុងនាមជាគ្រូឧទ្ទេស លោកគ្រូ អ្នកគ្រូគួរតែ៖

- រំលឹកគរុនិស្សិត ឱ្យធ្វើខ្លួនជាគំរូក្នុងការប្រើប្រាស់ភាសាប្រកបដោយការគោរពដោយផ្ទាល់ខ្លួនឯងតែម្តង។
- ជៀសវាងការបង្ខំសិស្ស ឱ្យសារភាពកំហុស ឬសុំទោសជាសាធារណៈ។
- លើកទឹកចិត្តឱ្យមានការអនុវត្តជាប្រចាំ ជាជាងការធ្វើសកម្មភាពតែមួយដងរួចហើយមិនបន្តធ្វើទៀត។

ជំហានទី ៤៖ ការសង្កេត និងការប្រមូលទិន្នន័យ (Observing and Collecting Data)

ប្រភពទិន្នន័យដែលបានប្រើប្រាស់៖

- តារាងផ្ទៀងផ្ទាត់ការសង្កេត (ដើម្បីពិនិត្យភាពញឹកញាប់នៃការហៅឈ្មោះត្រកូលគ្នា មុនពេល និងក្រោយពេលអនុវត្ត)
- ការស្នង់មតិខ្លីៗបែបអនាមិក ជាមួយសិស្ស (មិនដាក់ឈ្មោះសិស្ស)
- កំណត់ត្រាឥរិយាបថ ក្នុងអំឡុងពេលម៉ោងសម្រាក និងការងារក្រុម
- មតិយោបល់បែបមិនផ្លូវការ ពីគ្រូណែនមកនៅសាលារៀន

ទិន្នន័យគំរូ (សេចក្ដីសង្ខេប)៖

- មុនពេលអនុវត្តវិធានការអន្តរាគមន៍៖ ការហៅឈ្មោះត្រកូលគ្នាត្រូវបានសង្កេតឃើញពី ៨ ទៅ ១០ ដងក្នុងមួយម៉ោងសម្រាក។
- ក្រោយពេលអនុវត្តវិធានការអន្តរាគមន៍៖ បានថយចុះមកត្រឹម ២ ទៅ ៣ ដង ក្នុងមួយម៉ោងសម្រាក។
- លទ្ធផល៖ ៧៥% នៃសិស្សបានរាយការណ៍ថា ពួកគេមានអារម្មណ៍ថា «ត្រូវបានគេគោរពកាន់តែច្រើន» ពីសំណាក់មិត្តរួមថ្នាក់។

ក្នុងនាមជាគ្រូឧទ្ទេស លោកគ្រូ អ្នកគ្រូគួរតែ៖

- ធានាឱ្យបាននូវការរក្សាការសម្ងាត់ (អនាមិក) ជាពិសេសនៅក្នុងការស្នង់មតិសិស្ស។
- លើកទឹកចិត្តឱ្យប្រើប្រាស់ប្រភពទិន្នន័យចម្រុះ មិនមែនពឹងផ្អែកតែលើការសង្កេតមួយមុខនោះទេ។
- រំលឹកគរុនិស្សិតឱ្យប្រមូលទិន្នន័យ ទាំងមុនពេល និងក្រោយពេលអនុវត្តវិធានការអន្តរាគមន៍។

ជំហានទី ៥៖ ការឆ្លុះបញ្ចាំង និងការបកស្រាយលទ្ធផល (Reflecting and Interpreting Results)

ការឆ្លុះបញ្ចាំងដោយគរុនិស្សិត៖

- សិស្សចាប់ផ្តើមមានការយល់ដឹងកាន់តែច្បាស់ ថាពាក្យសម្តីអាចបង្ក្ដឱ្យមានការឈឺចាប់ដល់អ្នកដទៃ។
- បរិយាកាសក្នុងថ្នាក់រៀនមានភាពស្ងប់ស្ងាត់ជាងមុន។
- ការចូលរួមក្នុងការងារក្រុម មានភាពប្រសើរឡើង។
- សិស្សមួយចំនួននៅតែបន្តប្រើឈ្មោះត្រកូលហៅគ្នាម្តងម្កាល ដោយសារតែភាពធ្លាប់ខ្លួន (ទម្លាប់)។

ការបកស្រាយលទ្ធផល (Interpretation)

- ការផ្លាស់ប្តូរបានកើតឡើង ដោយសារតែមានការបង្រៀនដោយផ្ទាល់ ការធ្វើជាគំរូរបស់គ្រូ និងការកំណត់បទដ្ឋានរួមគ្នា (វិន័យក្នុងថ្នាក់)។
- ឥរិយាបថដែលនៅសេសសល់ បានបង្ហាញឱ្យឃើញពីភាពចាំបាច់នៃការបន្តពង្រឹងការអនុវត្តបន្ថែមទៀត។

ក្នុងនាមជាគ្រូឧទ្ទេស លោកគ្រូ អ្នកគ្រូគួរតែ៖

- តម្រង់ទិសការឆ្លុះបញ្ចាំង កុំឱ្យផ្តោតលើការបន្ទោសសិស្ស (ឧទាហរណ៍៖ ការនិយាយថា «សិស្សរឹងរូស» ជាដើម)
- លើកទឹកចិត្តឱ្យមានការឆ្លុះបញ្ចាំង ទៅលើអ្វីដែលបានសម្រេចជោគជ័យ អ្វីដែលមិនទាន់ជោគជ័យ និងមូលហេតុដែលនាំឱ្យមានលទ្ធផលបែបនោះ។
- ភ្ជាប់លទ្ធផលដែលរកឃើញ ទៅនឹងឯកសារយោង ឬទ្រឹស្តីស្តីពី «វិន័យវិជ្ជមាន» (Positive Discipline) និង «ទំនាក់ទំនងប្រកបដោយការគោរព»។

ជំហានទី ៦៖ ការកែសម្រួល និងការចែករំលែក (Revising and Sharing)

ការកែសម្រួលផែនការ (Revisions Planned):

- បន្តការរំលឹកស្មារតី ក្នុងអំឡុងពេលសកម្មភាពពេលព្រឹកជាប្រចាំ។
- បន្ថែមចំណុចរំលឹក អំពីការប្រើប្រាស់ភាសាប្រកបដោយការគោរព ទៅក្នុងវិន័យនៃការធ្វើការងារក្រុម។
- បញ្ជូលតួនាទីប្រធានថ្នាក់ ឱ្យជួយគាំទ្រ និងលើកទឹកចិត្តដល់ការប្រើប្រាស់ភាសាវិជ្ជមាន។

ការចែករំលែកលទ្ធផល (Sharing Results):

- ចែករំលែកលទ្ធផលដែលរកឃើញ ជាមួយគ្រូណែនាំនៅសាលារៀន។
- ធ្វើបទបង្ហាញសង្ខេប នៅក្នុងសិក្ខាសាលានៃវិទ្យាស្ថានបណ្តុះបណ្តាលគ្រូ។
- សរសេររបាយការណ៍ស្រាវជ្រាវប្រតិបត្តិដើម្បីដាក់ជូនជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវសម្រាប់ការបញ្ចប់ការសិក្សា។

ក្នុងនាមជាគ្រូឧទ្ទេស លោកគ្រូ អ្នកគ្រូគួរតែ៖

- ជានាថាការចែករំលែកលទ្ធផល ត្រូវតែការពារអត្តសញ្ញាណរបស់សិស្ស (រក្សាការសម្ងាត់)។
- លើកទឹកចិត្តឱ្យមានការចែករំលែកនូវ «មេរៀនដែលទទួលបាន» ជាជាងការបញ្ជាក់ឈ្មោះបុគ្គលម្នាក់ៗ។
- គាំទ្រគរុនិស្សិតឱ្យយល់ឃើញថា ការស្រាវជ្រាវប្រតិបត្តិ គឺជាដំណើរការនៃការកែលម្អជាបន្តបន្ទាប់ មិនមែនជា «ចម្លើយចុងក្រោយ» ឬការបញ្ចប់ការងារនោះទេ។

កំណត់សម្គាល់សម្រាប់គ្រូឧទ្ទេស

ករណីសិក្សានេះបានបង្ហាញឱ្យឃើញថា បញ្ហាដែលមិនមែនជាអំពើហិង្សាដោយផ្ទាល់ ដូចជាការប្រមាថដោយសម្តី ដែលជារឿយៗត្រូវបានគេមើលរំលងថាជាបញ្ហា «តូចតាច» ឬជា «រឿងធម្មតា» នោះ តាមពិតវាអាចជះឥទ្ធិពលយ៉ាងខ្លាំងដល់ទំនាក់ទំនងក្នុងថ្នាក់រៀន និងការរៀនសូត្ររបស់សិស្ស។ តាមរយៈការធ្វើការស្រាវជ្រាវប្រតិបត្តិជាប្រព័ន្ធ គរុនិស្សិតនឹងរៀនសូត្របាននូវរបៀប សម្គាល់ដឹង នូវទម្រង់នៃអំពើហិង្សាដែលបង្កប់ខ្លួន (Hidden forms of violence)។ ឆ្លើយតប វិញដោយប្រើប្រាស់យុទ្ធសាស្ត្របែបអប់រំ និងការស្តារទំនាក់ទំនងឡើង

វិញ (Restorative strategies)។ ឆ្លុះបញ្ចាំង យ៉ាងមានវិជ្ជាជីវៈ និងប្រកបដោយក្រមសីលធម៌។ កសាង បរិយាកាសថ្នាក់រៀនឱ្យកាន់តែមានសុវត្ថិភាព និងមានការគោរពគ្នាទៅវិញទៅមកកាន់តែប្រសើរឡើង។

៧.២. ករណីសិក្សាទី ២ (Showcase 2)

ការបដិសេធមិនបំបែកក្រុម (ការរើសអើងសង្គម និងជម្លោះរវាងមិត្តភក្តិ)

នៅក្នុងថ្នាក់រៀនថ្នាក់ទី ៧ នៃសាលាអនុវិទ្យាល័យ មានសិស្ស ៤ នាក់ តែងតែបដិសេធមិនព្រមចូលរួមការងារក្រុមឡើយ លុះត្រាតែពួកគេត្រូវបានអនុញ្ញាតឱ្យធ្វើការជាមួយគ្នាជាក្រុមដដែលទាំង ៤ នាក់នោះ។ នៅពេលដែលគ្រូដាក់ចេញនូវការបែងចែកក្រុមតាមសមត្ថភាពចម្រុះ ឬការផ្លាស់ប្តូរសមាជិកក្រុម សិស្សទាំងនេះតែងតែប្រឆាំងនឹងការចូលរួមជាមួយក្រុមថ្មី។ **នៅពេលដែលគ្រូបង្ខំឱ្យពួកគេបំបែកក្រុម សិស្ស ២ នាក់** បានដកខ្លួនចេញទាំងស្រុង ដោយអង្គុយស្ងៀមស្ងាត់ និងមិនព្រមចូលរួមចំណែកក្នុងកិច្ចការឡើយ។ **សិស្ស ២ នាក់ទៀត** បានក្លាយជាអ្នករំខាន ដោយការធ្វើដង ឬបង្ករការរំខានដល់សមាជិកក្រុមថ្មី និងមានចេតនាបំពានកិច្ចព្រមព្រៀងក្រុម។ ជា**លទ្ធផល** សិស្សដទៃទៀតមានអារម្មណ៍ធុញទ្រាន់ និងមួរម៉ៅ។ ក្រុមខ្លះបានបដិសេធមិនទទួលយកសិស្សទាំងនេះឱ្យចូលក្នុងក្រុមរបស់ពួកគេដោយចំហ។ បញ្ហានេះបានបង្កើតឱ្យមានភាពតានតឹង ការរើសអើង និងជម្លោះដោយសម្ដី ដែលធ្វើឱ្យបរិយាកាសក្នុងថ្នាក់រៀនកាន់តែមានភាពមិនស្រណុកសុខស្រួល និងខ្វះកិច្ចសហប្រតិបត្តិការ។

ទោះបីជាគ្មានអំពើហិង្សាខាងរូបរាងកាយកើតឡើងក៏ដោយ ប៉ុន្តែការរើសអើងសង្គម ជម្លោះរវាងមិត្តភក្តិ ការដកខ្លួនចេញពីសកម្មភាព និងឥរិយាបថរំខាននានា គឺជាសញ្ញាដែលបង្ហាញឱ្យឃើញយ៉ាង ច្បាស់។ ឥរិយាបថទាំងនេះគឺជាទម្រង់នៃអំពើហិង្សាដែលមិនមែនជារូបរាងកាយ ដែលវាបានជះឥទ្ធិពលអវិជ្ជមានដល់សេចក្ដីថ្លៃថ្នូរ ទំនាក់ទំនង និងការរៀនសូត្ររបស់សិស្ស។

<u>សំណើស្រាវជ្រាវប្រតិបត្តិ (Proposed Action Research)</u>

ចំណងជើង៖ ការកាត់បន្ថយការរើសអើងនិងជម្លោះក្នុងការងារក្រុមតាមរយៈការរៀនតាមបែបសហការក្នុងថ្នាក់ទី ៧

នៅពេលសង្កេត និងកំណត់បញ្ហានៅក្នុងករណីសិក្សានេះ លោកអ្នកអាចពិចារណាសម្រេចឱ្យបាននូវគោលបំណងមួយចំនួនដូចខាងក្រោម (បញ្ជាក់៖ លោកអ្នកអាចជ្រើសរើសយកតែមួយ ឬពីរគោលបំណងក៏បាន)៖

- ដើម្បីកំណត់រកមូលហេតុ នៃការបដិសេធរបស់សិស្ស ក្នុងការចូលរួមជាមួយការចាត់តាំងក្រុមថ្មីៗ។
- ដើម្បីកាត់បន្ថយការរើសអើង ការដកខ្លួនចេញពីសកម្មភាព និងឥរិយាបថរំខាននានា ក្នុងអំឡុងពេលធ្វើការងារក្រុម។
- ដើម្បីលើកកម្ពស់អន្តរកម្មប្រកបដោយការគោរព និងកិច្ចសហប្រតិបត្តិការ ក្នុងចំណោមសិស្សថ្នាក់ទី ៧។
- ដើម្បីកែលម្អបរិយាកាសក្នុងថ្នាក់រៀន តាមរយៈការអនុវត្តយុទ្ធសាស្ត្រការងារក្រុមបែបបរិយាបន្ន និងអហិង្សា។

ជំហានទី ១៖ ការកំណត់ និងការវិភាគបញ្ហា (Identifying and Diagnosing the Problem)

គរុនិស្សិតត្រូវបានណែនាំឱ្យអនុវត្តនូវចំណុចដូចខាងក្រោម៖

- ពិភាក្សាបែបមិនផ្លូវការជាមួយគ្រូណែនាំ អំពីប្រវត្តិឥរិយាបថរបស់សិស្សទាំង ៤ នាក់នោះ (តើពួកគេធ្លាប់មានបញ្ហាបែបនេះពីមុនមកដែរឬទេ?)។
- ប្រើប្រាស់តារាងផ្ទៀងផ្ទាត់ការសង្កេតបែបហ័ស ក្នុងអំឡុងពេលមេរៀនដែលមានការងារក្រុមចំនួន ៣ ដង។
- កត់ត្រានូវព្រឹត្តិការណ៍ដែលបានកើតឡើង រួមមាន៖
    - ការបដិសេធមិនព្រមចូលរួមក្នុងក្រុម។
    - ការដកខ្លួនចេញពីសកម្មភាព (ឧទាហរណ៍៖ ការអង្គុយស្ងៀមស្ងាត់ មិនចូលរួមធ្វើកិច្ចការ)។
    - សកម្មភាពបង្ការរំខាន (ឧទាហរណ៍៖ ការឆឹដងមិត្តភក្តិ ការរំខាននៅក្នុងក្រុម)។
- រៀបចំការសន្ទនាបែបមិនផ្លូវការជាមួយសិស្ស (នៅក្រៅម៉ោងសិក្សា ក្នុងលក្ខណៈមិនគំរាមកំហែង ឬក្នុងបរិយាកាសដែលមានសុវត្ថិភាពសម្រាប់ពួកគេក្នុងការនិយាយការពិត)។

លទ្ធផលដែលរកឃើញអំពីករណីសិក្សានេះ បន្ទាប់ពីបានអនុវត្តសកម្មភាពខាងលើ អាចនឹងមិនដូចអ្វីដែលគរុនិស្សិតបានឃើញនៅពេលដំបូងឡើយ (បញ្ហាអាចមានជម្រៅជ្រៅជាងអ្វីដែលយើងឃើញនៅផ្នែកខាងក្រៅ)។ ខាងក្រោមនេះគឺជា របកគំហើញសំខាន់ៗ៖

- សិស្សទាំង ៤ នាក់នោះ មានអារម្មណ៍ថា «មានសុវត្ថិភាព» លុះត្រាតែពួកគេនៅជាមួយគ្នា។
- ពួកគេភ័យខ្លាចនៅពេលត្រូវបាននរណាម្នាក់មករិះគន់ ឬការបដិសេធ ពីសំណាក់មិត្តរួមថ្នាក់ដទៃទៀត។
- សិស្សដទៃទៀតយល់ថា សិស្សទាំង ៤ នាក់នោះជាមនុស្ស «ពិបាកចុះសម្រុង» និង «មិនសហការ»។
- ការបង្ខំឱ្យចូលក្រុម កាន់តែបង្កើនការប្រឆាំង និងជម្លោះកាន់តែខ្លាំង។

សេចក្តីសន្និដ្ឋានតាមរយៈទស្សនៈអហិង្សា (Non-Violence Lens): «បញ្ហានេះ មិនមែនជាការមិនស្តាប់បង្គាប់ (អទណ្ឌកម្ម) នោះទេ ប៉ុន្តែវាគឺជាបញ្ហានៃអសន្តិសុខក្នុងសង្គមថ្នាក់រៀន ការរើសអើង និងការបាត់បង់ទំនុកចិត្តរវាងមិត្តភក្តិ។»

ក្នុងនាមជាគ្រូឧទ្ទេស លោកគ្រូ អ្នកគ្រូគួរតែ៖

- រំលឹកគរុនិស្សិត មិនឱ្យបិទស្លាកសិស្សថាជា «សិស្សបង្កបញ្ហា» (Problematic) នោះទេ។
- សង្កត់ធ្ងន់លើការវិភាគរកទម្រង់នៃឥរិយាបថ ជាជាងការបន្ទោសទៅលើបុគ្គលម្នាក់ៗ។
- លើកទឹកចិត្តឱ្យប្រើប្រាស់ប្រភពទិន្នន័យចម្រុះ មិនមែនផ្អែកលើព្រឹត្តិការណ៍តែមួយលើកនោះទេ។

ជំហានទី ២៖ ការរៀបចំផែនការសកម្មភាព (Planning for Action)

- គរុនិស្សិតចាប់ផ្តើមពិនិត្យឡើងវិញនូវឯកសារ ការស្រាវជ្រាវមុនៗ ឬទ្រឹស្តីនានា រួចចាប់ផ្តើមរៀបចំផែនការអន្តរាគមន៍។ ឧទាហរណ៍ គរុនិស្សិតគ្រោងនឹងអនុវត្តនូវចំណុចដូចខាងក្រោម៖

- ការរៀនតាមបែបសហការដោយកំណត់តួនាទីច្បាស់លាស់៖ សមាជិកក្រុមម្នាក់ៗមានតួនាទីជាក់លាក់ (ឧទាហរណ៍៖ ប្រធានក្រុម, អ្នកកត់ត្រា, អ្នកកាន់ពេល, និងអ្នកលើកទឹកចិត្ត)។
- យុទ្ធសាស្ត្រនៃការបញ្ចូលការធ្វើការក្រុមជាជំហានៗ (Gradual mixing)៖ ឱ្យសិស្សធ្វើការជាគូសិន បន្ទាប់មកទើបបង្កើនទៅជាក្រុមចម្រុះតូចៗ។
- ការបង្រៀនឱ្យបានច្បាស់លាស់អំពីបទដ្ឋានការងារក្រុម៖ ការប្រើប្រាស់ភាសាប្រកបដោយការគោរព ការស្តាប់គ្នា និងការមិនរើសអើង (បរិយាបន្ន)។
- មេរៀនខ្នាតតូចស្តីពីការអប់រំសន្តិភាព៖ ការពិភាក្សាខ្លីៗអំពីការរាប់អានគ្នា (បរិយាបន្ន) ការយល់ចិត្តគ្នា (Empathy) និងការធ្វើការងារជាក្រុម។
- ការប្រើប្រាស់វិន័យបែបវិជ្ជមាន៖ ការប្រើប្រាស់ការលើកទឹកចិត្ត និងការឆ្លុះបញ្ចាំងពីកំហុស ជាជាងការដាក់ទណ្ឌកម្ម។

ក្នុងនាមជាគ្រូឧទ្ទេស លោកគ្រូ អ្នកគ្រូគួរតែ៖

- ជានាថាវិធានការអន្តរាគមន៍អាចអនុវត្តបានជាក់ស្តែង ក្នុងអំឡុងពេលដែលគរុនិស្សិតចុះកម្មសិក្សា។
- ជៀសវាងរាល់វិធានការណាដែលធ្វើឱ្យសិស្សមានភាពអាម៉ាស់ជាសាធារណៈ។
- លើកទឹកចិត្តឱ្យមានការរៀបចំផែនការដែលជួយកាត់បន្ថយភាពភ័យខ្លាច ជាជាងការប្រើអំណាចបង្ខំឱ្យសិស្សស្តាប់បង្គាប់។

ជំហានទី ៣៖ ការអនុវត្តសកម្មភាព (Taking Action/Implementation)

សូមស្រមៃថា ផែនការនេះត្រូវបានអនុវត្តជាមួយថ្នាក់រៀននោះក្នុងរយៈពេល ៤ សប្តាហ៍។

- បន្ទាប់ពីរៀបចំផែនការអន្តរាគមន៍រួចរាល់ ឥឡូវនេះគរុនិស្សិតអាចចាប់ផ្តើមអនុវត្តផែនការរបស់ពួកគេបានហើយ។ ខាងក្រោមនេះគឺជាសកម្មភាពមួយចំនួនដែលត្រូវអនុវត្តក្នុងអំឡុងពេលអន្តរាគមន៍នេះ៖
  - ណែនាំវិន័យការងារក្រុមតាមរយៈរូបភាព (Poster)៖ បិទផ្សាយច្បាប់ក្នុងថ្នាក់ឱ្យសិស្សមើលឃើញច្បាស់។
  - ធ្វើជាគំរូក្នុងការប្រើប្រាស់ភាសាគួរសមក្នុងក្រុម៖ គ្រូបង្ហាញពីរបៀបនិយាយ និងការផ្តល់យោបល់ប្រកបដោយការគោរព។
  - ចាប់ផ្តើមពីការងារជាគូ៖ ឱ្យសិស្សធ្វើការ ២ នាក់សិន មុននឹងឈានទៅដល់ការបង្កើតក្រុមដែលមានសមាជិកច្រើន។
  - ចាត់តាំងមិត្តភក្តិដែលចេះជួយគ្នាចូលក្នុងក្រុមដោយមានយុទ្ធសាស្ត្រ៖ ដាក់សិស្សដែលរួសរាយ និងចេះជួយគ្នា ឱ្យនៅជាមួយសិស្សដែលពិបាកចុះសម្រុង។

- ○ ផ្តល់ការសរសើរចំពោះកិច្ចខំប្រឹងប្រែងវិជ្ជមាន៖ សរសើររាល់ពេលដែលសិស្សព្យាយាមសហការគ្នា។
- ○ ប្រើប្រាស់សំណួរឆ្លុះបញ្ចាំងបន្ទាប់ពីបញ្ចប់ការងារក្រុម៖
  - តើអ្វីខ្លះដែលយើងបានធ្វើបានល្អ?
  - តើយើងបានជួយគ្នាទៅវិញទៅមកដោយរបៀបណា?

ក្នុងអំឡុងពេលនៃដំណើរការអន្តរាគមន៍ គរុនិស្សិតបានសង្កេតឃើញការផ្លាស់ប្តូរមួយចំនួនដូចជា៖

- សិស្សទាំង ៤ នាក់ បង្ហាញពីការប្រឆាំងតិចជាងមុន នៅពេលដែលការផ្លាស់ប្តូរក្រុមត្រូវបានធ្វើឡើងជាដំហានៗ។
- ការដកខ្លួនចេញពីសកម្មភាពមានការថយចុះ នៅពេលដែលតួនាទីរបស់សមាជិកម្នាក់ៗត្រូវបានកំណត់យ៉ាងច្បាស់លាស់។
- ឥរិយាបថរំខានមានការកាត់បន្ថយ នៅពេលដែលការរំពឹងទុក (ឬវិន័យ) ត្រូវបានពន្យល់យ៉ាងច្បាស់លាស់ និងចំៗ។

ក្នុងនាមជាគ្រូឧទ្ទេស លោកគ្រូ អ្នកគ្រូគួរតែ៖

តាមដានយ៉ាងយកចិត្តទុកដាក់ លើសុវត្ថិភាពផ្នែកផ្លូវចិត្តរបស់សិស្ស (ធានាថាគ្មានសិស្សណាម្នាក់មានអារម្មណ៍ថាត្រូវបានគេទុកចោល ឬធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍ខ្លាំងពេកនោះទេ)។

- រំលឹកគរុនិស្សិតឱ្យរក្សាភាពម៉ឹងម៉ាត់និងខ្ជាប់ខ្ជួន (Stay consistent) ចំពោះផែនការ និងមិនត្រូវមានប្រតិកម្មខ្លាំងៗតាមអារម្មណ៍ (Not reactive) នៅពេលសិស្សមិនសហការ។
- លើកទឹកចិត្តឱ្យមានការសរសេរកំណត់ហេតុឆ្លុះបញ្ចាំង (Reflective journaling) ក្នុងអំឡុងពេលនៃការអនុវត្តផែនការនេះ។

ជំហានទី ៤៖ ការសង្កេត និងការប្រមូលទិន្នន័យ (Observing and Collecting Data)

- ▪ ក្នុងអំឡុងពេលជំហាននេះ គរុនិស្សិតអាចពិចារណាប្រមូលទិន្នន័យពីប្រភពផ្សេងៗគ្នាដូចជា៖
  - ○ កំណត់ហេតុនៃការសង្កេត (Observation logs)៖ កត់ត្រាឥរិយាបថសិស្សទាំងមុន និងក្រោយពេលអនុវត្តអន្តរាគមន៍ ដើម្បីធ្វើការប្រៀបធៀប។
  - ○ តារាងធ្វៀងផ្ទាត់ភាពញឹកញាប់នៃឥរិយាបថ (Behavior frequency checklist)៖ កត់ត្រាចំនួនដងដែលសិស្សបានបង្ហាញឥរិយាបថវិជ្ជមាន (ដូចជាការសហការ) ឬឥរិយាបថអវិជ្ជមាន (ដូចជាការរំខាន)។
  - ○ ការស្ទង់មតិខ្លីៗពីសិស្សដោយមិនបញ្ចេញឈ្មោះ (Short anonymous student survey)៖ ដើម្បីដឹងពីអារម្មណ៍ពិតរបស់សិស្សចំពោះការធ្វើការងារក្រុមថ្មី។

- មតិត្រឡប់ពីគ្រូណែនាំ (Mentor teacher feedback)៖ ការផ្តល់យោបល់ និងការសង្កេតបន្ថែមពីគ្រូដែលមានបទពិសោធន៍។

ទិន្នន័យអាចត្រូវបានសង្ខេបដោយប្រើតារាងខាងក្រោម៖

សូចនាករ	មុនពេលអន្តរាគមន៍ Before Intervention	ក្រោយពេលអន្តរាគមន៍ After Intervention	ការផ្លាស់ប្តូរដែលសង្កេតឃើញ Change Observed
ការបដិសេធមិនចូលរួមក្រុម	ញឹកញាប់	កម្រ	បាទ/ចាស -> ល្អ
ឥរិយាបថដកខ្លួនចេញ	ខ្ពស់	មធ្យម–ទាប	បាទ/ចាស -> ល្អ
សកម្មភាពបង្ការរំខាន	ញឹកញាប់	ម្តងម្កាល	បាទ/ចាស -> ល្អ (Okay)
ការគ្នាញ្ញែរពីមិត្តភក្តិ	ខ្ពស់	កាត់បន្ថយ	បាទ/ចាស -> ល្អ

ក្នុងនាមជាគ្រូឧទ្ទេស លោកគ្រូ អ្នកគ្រូគួរតែ៖

- រំលឹកគរុនិស្សិត មិនគួរបំផ្លើសពីភាពជោគជ័យនៃលទ្ធផលឡើយ។
- ទិន្នន័យត្រូវតែឆ្លុះបញ្ចាំងពីអ្វីដែលបានកើតឡើងពិតប្រាកដ មិនមែនជាអ្វីដែលយើងរំពឹងទុកថានឹងឱ្យកើតឡើងនោះទេ។
- លើកទឹកចិត្តឱ្យមានការប្រើប្រាស់វិធីសាស្ត្រត្រីកោណកម្មទិន្នន័យ (Triangulation of data) (ការផ្ទៀងផ្ទាត់ទិន្នន័យពីប្រភពខុសៗគ្នា ដើម្បីធានានូវភាពត្រឹមត្រូវ)។

ជំហានទី ៥៖ ការឆ្លុះបញ្ចាំង និងការបកស្រាយលទ្ធផល (Reflecting and Interpreting Results)

បន្ទាប់ពីដំណើរការប្រមូលទិន្នន័យត្រូវបានបញ្ចប់ គរុនិស្សិតត្រូវ៖

- ប្រៀបធៀបទិន្នន័យ មុន និងក្រោយពេលអនុវត្តន៍។
- កំណត់រកទម្រង់នៃឥរិយាបថ (Patterns) ជាជាងការមើលលើព្រឹត្តិការណ៍ដែលកើតឡើងតែម្តងម្កាល។
- ឆ្លុះបញ្ចាំងលើចំណុចសំខាន់ៗ៖ 1. ហេតុអ្វីបានជាការបែងចែកក្រុមជាជំហានៗ (Gradual grouping) មានប្រសិទ្ធភាពជាងការបង្ខំឱ្យបំបែកក្រុមភ្លាមៗ? 2. ហេតុអ្វីបានជាការកំណត់តួនាទីច្បាស់លាស់អាចជួយកាត់បន្ថយជម្លោះបាន?
- ផ្សារភ្ជាប់របកគំហើញ ទៅនឹងទ្រឹស្តីនៃការរៀនតាមបែបសហការ និងគោលការណ៍ថ្នាក់រៀនអហិង្សា។

ផ្អែកលើទិន្នន័យ និងរបកគំហើញ គេអាចបកស្រាយបានថា៖

«បញ្ហាឥរិយាបថនេះ មានឫសគល់មកពីភាពភ័យខ្លាចនៃការរើសអើង មិនមែនមកពីការមិនចង់រៀននោះទេ។ នៅពេលដែលសុវត្ថិភាព រចនាសម្ព័ន្ធការងារច្បាស់លាស់ និងការផ្តល់តម្លៃមានការកើនឡើង នោះការប្រឆាំង និងជម្លោះក៏មានការថយចុះទៅតាមនោះដែរ។»

ក្នុងនាមជាគ្រូឧទ្ទេស លោកគ្រូ អ្នកគ្រូគួរតែ៖

- មិនលើកទឹកចិត្តឱ្យមានការបន្ទោសទៅលើសិស្ស ឬមាតាបិតា ចំពោះបញ្ហាដែលបានកើតឡើងឡើយ។
- ការឆ្លុះបញ្ចាំងត្រូវតែរួមបញ្ចូលនូវចំណុចខ្វះខាត ឬកម្រិតកំណត់ (Limitations) នៃអន្តរាគមន៍ (ឧទាហរណ៍៖ អ្វីដែលមិនទាន់ជោគជ័យ ១០០%)។
- ណែនាំគរុនិស្សិតឱ្យចេះផ្សារភ្ជាប់ការអនុវត្តជាក់ស្តែង ទៅនឹងទ្រឹស្តីអប់រំ (ដើម្បីឱ្យពួកគេយល់ពី «មូលហេតុ» នៅពីក្រោយជោគជ័យ ឬបរាជ័យនោះ)។

ជំហានទី ៦៖ ការកែសម្រួល និងការចែករំលែក (Revising and Sharing)

បន្ទាប់ពីបានឆ្លងកាត់គ្រប់ជំហានរួចមក គរុនិស្សិតអាចនឹងមើលឃើញកាន់តែច្បាស់នូវអត្ថប្រយោជន៍នៃអន្តរាគមន៍របស់ពួកគេ ឬចំណុចខ្វះខាតមួយចំនួនដែលបានកើតឡើង។ ពួកគេអាចនឹងចង់ពង្រីកបទពិសោធន៍នេះទៅកាន់ថ្នាក់រៀន ឬមុខវិជ្ជាផ្សេងៗទៀត ឬរៀបចំផែនការសម្រាប់ការស្រាវជ្រាវវដ្តថ្មី (Another cycle)។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួនដែលគរុនិស្សិតអាចពិចារណា៖

- រៀបចំផែនការពង្រីកយុទ្ធសាស្ត្ររៀនតាមបែបសហការ ទៅកាន់មុខវិជ្ជាផ្សេងៗទៀត។
- កែសម្រួលតួនាទីក្នុងក្រុម ផ្អែកលើមតិត្រឡប់ (Feedback) របស់សិស្ស។

ក្រៅពីការពិនិត្យមើលអន្តរាគមន៍ឡើងវិញ គរុនិស្សិតក៏ត្រូវរៀបចំផែនការចែករំលែកលទ្ធផលរបស់ពួកគេផងដែរ ឧទាហរណ៍៖

- បទបង្ហាញអំពីរបកគំហើញ នៅក្នុងសិក្ខាសាលាស្រាវជ្រាវ។
- ចែករំលែកយុទ្ធសាស្ត្រអនុវត្តជាក់ស្តែង ជាមួយគ្រូណែនាំ។
- ដាក់ជូននូវរបាយការណ៍ស្រាវជ្រាវប្រតិបត្តិ ដែលជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវសម្រាប់ការបញ្ចប់ការសិក្សា។

ក្នុងនាមជាគ្រូឧទ្ទេស លោកគ្រូ អ្នកគ្រូគួរតែ៖

- ធានានូវការរក្សាការសម្ងាត់ (មិនត្រូវប្រើឈ្មោះពិតរបស់សិស្សនៅក្នុងរបាយការណ៍ ឬការចែករំលែកឡើយ)។
- ការចែករំលែកគួរផ្តោតលើការរៀនសូត្រពីបទពិសោធន៍ ជាជាងការបង្ហាញតែពី «រឿងរ៉ាវជោគជ័យតែម្យ៉ាង» (ត្រូវហ៊ាននិយាយពីបញ្ហាប្រឈមដែលបានជួបប្រទះ)។
- លើកទឹកចិត្តឱ្យមានការសន្ទនាបែបវិជ្ជាជីវៈ និងការរៀនសូត្រពីមិត្តភក្តិរួមវិជ្ជាជីវៈ (Peer learning)។

កំណត់សម្គាល់សម្រាប់គ្រូឧទ្ទេស

ករណីសិក្សានេះបានបង្ហាញថា អហិង្សាក្នុងថ្នាក់រៀនមិនមែនត្រឹមតែជាការបញ្ឈប់ការដាក់ទណ្ឌកម្មលើរាងកាយប៉ុណ្ណោះទេ ប៉ុន្តែវាក៏រួមបញ្ចូលទាំងការដោះស្រាយបញ្ហា ការរើសអើង ការដកខ្លួនចេញពីសកម្មភាព ជម្លោះរវាងមិត្តភក្តិ និងការប៉ះពាល់ដល់អារម្មណ៍ផងដែរ។ តាមរយៈការធ្វើការស្រាវជ្រាវប្រតិបត្តិដែលមានរចនាសម្ព័ន្ធច្បាស់លាស់ និងការឆ្លុះបញ្ចាំងឱ្យបានស៊ីជម្រៅ គរុនិស្សិតអាចរៀនសូត្រពីរបៀបឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះបានយ៉ាងត្រឹមត្រូវតាមក្រមសីលធម៌ ប្រកបដោយការគោរព និងមានប្រសិទ្ធភាពខ្ពស់។

៧.៣. ករណីសិក្សាទី៣ (Showcase 3)

ករណីសិក្សា៖ សិស្សថ្នាក់ទី ៨ ដែលមានសម្លេងអាន (សំនៀង) ខុសគ្នា

ករណីនេះកើតឡើងនៅក្នុងថ្នាក់រៀនថ្នាក់ទី ៨ នៃសាលាមធ្យមសិក្សាសាធារណៈមួយក្នុងខេត្តបាត់ដំបង។ ក្នុងថ្នាក់រៀននេះ មានសិស្សមកពីមជ្ឈដ្ឋានចម្រុះ រួមទាំងសិស្សមួយចំនួនដែលទើបតែផ្លាស់ទីលំនៅមកពីតំបន់ដាច់ស្រយាល។ សិស្សទាំងនោះនិយាយភាសាខ្មែរបានយ៉ាងស្ទាត់ជំនាញ ប៉ុន្តែមានសំនៀងក្នុងតំបន់ខុសប្លែកពីគេយ៉ាងខ្លាំង។ នៅក្នុងម៉ោងសិក្សាភាសាខ្មែរ ជាពិសេសនៅពេលដែលគ្រូតម្រូវឱ្យសិស្សអានអត្ថបទឱ្យឮៗ ឬឆ្លើយសំណួរដោយផ្ទាល់មាត់ មិត្តរួមថ្នាក់មួយចំនួនបាននាំគ្នាបង្អាប់ ចំអកតាម ឬសើចចំអកដាក់សំនៀងតំបន់ដាច់ស្រយាលរបស់សិស្សទាំងនោះ។ ទោះបីជាការបង្អាប់ទាំងនោះជារឿយៗត្រូវបានចាត់ទុកថាជា "ការលេងសើច" ក៏ដោយ ប៉ុន្តែវាកើតឡើងដដែលៗ និងធ្វើឱ្យសិស្សទាំងនោះមានភាពអាម៉ាស់យ៉ាងខ្លាំង។

នៅពេលសង្កេត និងកំណត់រកបញ្ហានៅក្នុងករណីនេះ អ្នកអាចពិចារណាសម្រេចឱ្យបាននូវគោលបំណងមួយចំនួនដូចខាងក្រោម (បញ្ជាក់៖ អ្នកអាចជ្រើសរើសយកគោលបំណងមួយ ឬពីរក្នុងចំណោមនេះ)៖

1. កំណត់ទម្រង់ និងមូលហេតុនៃការសើចចំអកលើការបញ្ចេញសំឡេង ក្នុងម៉ោងសិក្សាភាសាខ្មែរ។
2. កាត់បន្ថយអំពើហិង្សាទៅលើផ្លូវចិត្តនិងតាមពាក្យសម្តីដែលទាក់ទងនឹងភាពខុសគ្នានៃការបញ្ចេញសម្លេង។
3. លើកកម្ពស់ការប្រើប្រាស់ភាសាប្រកបដោយការគោរព និងបទដ្ឋានក្នុងថ្នាក់រៀនដែលប្រកបដោយបរិយាបន្ន (រួមបញ្ចូលគ្នា)។
4. បង្កើនការចូលរួមបញ្ចេញមតិ និងទំនុកចិត្តរបស់សិស្សដែលមានប្រភពមកពីជនបទ។
5. ពង្រឹងវប្បធម៌ក្នុងថ្នាក់រៀនឱ្យមានភាពវិជ្ជមាន និងគ្មានអំពើហិង្សា។

ជំហានទី ១៖ ការកំណត់ និងការវិភាគបញ្ហា

គរុនិស្សិតអាចពិចារណាលើ៖

- ការសង្កេតក្នុងអំឡុងពេលសកម្មភាពអានឮខ្លាំងៗ និងការសួរ-ឆ្លើយ។
- ការកត់ត្រាខ្លីៗអំពី៖
    - ពេលណាដែលមានការសើចចំអក,
    - អ្នកណាខ្លះពាក់ព័ន្ធ,
    - កើតឡើងញឹកញាប់ប៉ុណ្ណា និង
    - ប្រតិកម្មរបស់សិស្សដែលរងគ្រោះ។
- ជួបពិភាក្សាជាមួយ៖
    - គ្រូណែនាំ (អំពីវប្បធម៌ក្នុងថ្នាក់),
    - សិស្សដែលរងគ្រោះ (ដោយលក្ខណៈឯកជន និងម៉ត់ចត់), និង
    - សិស្សមួយក្រុមតូច (អំពីបទដ្ឋានក្នុងថ្នាក់)។
- ប្រើប្រាស់ការស្នង់មតិខ្លីៗទៅកាន់សិស្សមិនស្គាល់អត្តសញ្ញាណដោយសួរអំពី៖
    - អារម្មណ៍សុវត្ថិភាពពេលនិយាយ
    - និងបទពិសោធន៍នៃការត្រូវគេបង្អាប់ ឬសើចដាក់។

លទ្ធផលដែលរកឃើញក្នុងករណីនេះ អាចត្រូវបានធ្វើរោគវិនិច្ឆ័យ (កំណត់បញ្ហា) ដូចខាងក្រោម

- សើចចំអកកើតឡើងខ្លាំងក្នុងអំឡុងពេលសកម្មភាពនិយាយ
- សិស្សយល់ថាការបញ្ចេញសំឡេងខុសគ្នាជារឿងកំប្លែង ឬជារឿងអន់ថយ
- មិនទាន់មានគោលការណ៍ថ្នាក់រៀនច្បាស់លាស់ស្តីពីការស្តាប់ដោយការគោរព
- សិស្សដែលរងគ្រោះមានអារម្មណ៍ខ្មាសអៀន និងខ្លាចការបាក់មុខ។

ការណែនាំសម្រាប់គ្រូឧទ្ទេស៖

- កុំបិទស្លាកសិស្សថាជា "អ្នកបង្ករបួសស្នាម" (Bullies)។ត្រូវផ្តោតលើសកម្មភាព មិនមែនបុគ្គល។
- ធានាថាការសន្ទនាជាមួយសិស្សគឺជាការសម្ងាត់ និងមិនមានការគំរាមកំហែង។

- ណែនាំគរុនិស្សិត ឱ្យកំណត់បញ្ហានេះថាជា "អំពើហិង្សាតាមពាក្យសម្តី និងការរើសអើង" មិនមែនគ្រាន់តែជា "បញ្ហាវិន័យ" នោះទេ។

ជំហានទី ២ៈ ការរៀបចំផែនការសកម្មភាព

គរុនិស្សិតអាចគិតពីការអន្តរាគមន៍ទាំងនេះ ៖

- ការបង្រៀនដោយផ្ទាល់អំពីការប្រើប្រាស់ភាសាប្រកបដោយការគោរព។
- បញ្ចូលមេរៀនតូចមួយស្តីពី "ការអប់រំសន្តិភាព" (Peace Education) លើប្រធានបទចម្រុះភាព និងសេចក្តីថ្លៃថ្នូរ។
- ការបង្កើតគោលការណ៍ថ្នាក់រៀនអំពីការស្តាប់ដោយការគោរពនិងស្ងៀមស្ងាត់ ក្នុងអំឡុងពេលសកម្មភាពនិយាយ(សិស្ស) ។
- ការរៀបចំឱ្យមានទម្លាប់បញ្ចេញមតិ (ដូចជាៈ ការពិភាក្សាជាដៃគូ ការហាត់និយាយក្នុងក្រុមតូច)។
- គ្រូធ្វើជាគំរូក្នុងការឆ្លើយតបដោយការគោរពចំពោះភាពខុសគ្នានៃការបញ្ចេញសំឡេង។

ក្រោយពីបានរៀបចំផែនការអន្តរាគមន៍រួចមក គរុនិសិស្សសម្រេចចិត្តអនុវត្តផែនការនេះក្នុងរយៈពេលពី ៤ ទៅ ៦ សប្តាហ៍ ដោយ៖

- បញ្ចូលទៅក្នុងមេរៀនភាសាខ្មែរជាប្រចាំ៖ ការដាក់បញ្ចូលសកម្មភាពទាំងនេះទៅក្នុងម៉ោងសិក្សាធម្មតា ដើម្បីកុំឱ្យមានការរំខានដល់កម្មវិធីសិក្សា។
- ប្រើប្រាស់យុទ្ធសាស្ត្រដែលមិនបង្កហានិភ័យ៖ ប្រើប្រាស់វិធីសាស្ត្រដែលមិនបង្ហាញអត្តសញ្ញាណ ឬមិនធ្វើឱ្យសិស្សណាម្នាក់ក្លាយជាផ្នាំងស៊ីបនៃការចាប់អារម្មណ៍ពីសាធារណៈជនឡើយ។

ក្នុងនាមជាគ្រូឧទ្ទេស គួរតែ៖

- ចៀសវាងផែនការទាំងឡាយណាដែលបង្ហាញអត្តសញ្ញាណ ឬ "ធ្វើឱ្យសិស្សរងគ្រោះក្លាយជាផ្នាំងស៊ីប" នៃការចាប់អារម្មណ៍ខ្លាំងពេក។
- លើកទឹកចិត្តឱ្យប្រើប្រាស់យុទ្ធសាស្ត្របង្ការ និងការអប់រំ ជាជាងការដាក់ទណ្ឌកម្ម។
- ធានាឱ្យមានការអនុលោមតាមគោលការណ៍សាលារៀនមេត្រីភាព និងគោលការណ៍អប់រំដោយគ្មានហិង្សា។

ជំហានទី ៣ៈ ការអនុវត្តសកម្មភាព

បន្ទាប់ពីការរៀបចំផែនការសម្រាប់អន្តរាគមន៍ គរុនិស្សិតចាប់ផ្តើម៖

- ណែនាំមេរៀនស្តីពី "ការបញ្ចេញសំឡេងខុសគ្នា តែភាសាតែមួយ"។
- បង្កើតច្បាប់ក្នុងថ្នាក់រួមគ្នាដូចជា៖
    - "យើងស្តាប់ដោយមិនសើចចំអក",
    - "យើងគោរពរាល់ការនិយាយរបស់មិត្តគ្រប់រូប"។
- ឱ្យសិស្សអនុវត្តការអានជាដៃគូ ឬក្រុមតូច មុននឹងអាននៅចំពោះមុខថ្នាក់ទាំងមូល។
- សរសើរលើការខិតខំប្រឹងប្រែង និងភាពក្លាហាន មិនមែនសរសើរលើការបញ្ចេញសម្លេង ឬភាព "ត្រឹមត្រូវ" នោះទេ។
- អន្តរាគមន៍ដោយស្ងប់ស្ងាត់ពេលមានការសើចចំអក៖ *"នៅក្នុងថ្នាក់យើង យើងគោរពគ្រប់សម្លេងទាំងអស់"*

ក្នុងនាមជាគ្រូឧទ្ទេស អ្នកគួរតែ៖

- គរុនិស្សិតអាចនឹងមានអារម្មណ៍ភិតភ័យក្នុងការកែតម្រូវការសើចចំអក—ដូច្នេះត្រូវផ្តល់ការតម្រង់ទិស និងការប្រឹក្សាដល់ពួកគេ ប៉ុន្តែ
- លើកទឹកចិត្តឱ្យពួកគេប្រើប្រាស់ការឆ្លើយតបដែលស្ងប់ស្ងាត់ និងម៉ឺងម៉ាត់ ជាជាងការប្រើប្រាស់អារម្មណ៍តបតវិញ។
- រំលឹកគរុនិស្សិតថា ការធ្វើជាគំរូដោយផ្ទាល់គឺមានសារៈសំខាន់ជាងការផ្តល់មេរៀនតែមួយមុខ។

ជំហានទី ៤៖ ការសង្កេត និងការប្រមូលទិន្នន័យ

គរុនិស្សិតអាចប្រើប្រាស់ប្រភពព័ត៌មានខាងក្រោម ដើម្បីប្រមូលទិន្នន័យ៖

- កំណត់ហេតុសង្កេត (ចំនួនដងនៃការសើចចំអក)។
- ការស្វង់មតិសិស្សមុន និងក្រោយការអនុវត្ត អំពីសុវត្ថិភាពអារម្មណ៍ ក្នុងការនិយាយ។
- កំណត់ត្រាការចូលរួម (ចំនួនសិស្សដែលស្ម័គ្រចិត្តអាន)។
- កំណត់ត្រាខ្លីៗឆ្លុះបញ្ចាំងពីការយល់ឃើញរបស់សិស្សគោលដៅ (មិនបង្ខំ និងមិនបញ្ចេញឈ្មោះ)

ក្នុងនាមជាអ្នកបណ្តុះបណ្តាលគ្រូ អ្នកគួរតែ៖

- កុំពឹងផ្អែកលើប្រភពទិន្នន័យតែមួយមុខ។

- ចៀសវាងការប្រមូលទិន្នន័យដែលងាយរងគ្រោះជាសាធារណៈ។
- ណែនាំគ្រូកម្មសិក្សាឱ្យចេះសង្កេតរកមើលចំណុចរួម ឬទម្លាប់ដែលកើតឡើងដដែលៗ ជាជាងការផ្តោតលើព្រឹត្តិការណ៍ដាច់ដោយឡែកតែមួយ។

ជំហានទី ៥៖ ការឆ្លុះបញ្ចាំង និងការបកស្រាយលទ្ធផល

បន្ទាប់ពីការប្រមូលទិន្នន័យ គរុនិស្សិតអាចពិចារណាអំពីគន្លឹះនៃការឆ្លុះបញ្ចាំងទាំងនេះ៖

- ករណីសើចចំអកថយចុះគួរឱ្យកត់សម្គាល់បន្ទាប់ពីមានកិច្ចព្រមព្រៀងក្នុងថ្នាក់។
- សិស្សស្ម័គ្រចិត្តអានកាន់តែច្រើនក្នុងក្រុមតូច។
- សិស្សមួយចំនួននៅតែលួចសើចតិចតួច ដែលបញ្ជាក់ថាត្រូវការការយកចិត្តទុកដាក់បន្តទៀត។

នេះគឺជាការបកស្រាយសំខាន់ៗមួយចំនួនដែលអាចយកមកពិចារណា ឧទាហរណ៍៖

- បទដ្ឋានច្បាស់លាស់ + ការរៀបចំឱ្យមានការចូលរួមតាមលំដាប់លំដោយ បានជួយកាត់បន្ថយអំពើហិង្សាតាមពាក្យសម្តី។
- ការបង្កើតវប្បធម៌គោរពគ្នាក្នុងថ្នាក់រៀន ទាមទារពេលវេលា និងការលើកទឹកចិត្តបន្ថែម។
- វិធីសាស្ត្រមិនប្រើអំពើហិង្សា មានប្រសិទ្ធភាពជាងការដាក់ពិន័យ។

ក្នុងនាមគ្រូឧទ្ទេស អ្នកគួរតែ៖

- មិនលើកទឹកចិត្តឱ្យមានការបន្ទោសសិស្ស ឬសហគមន៍។ ប៉ុន្តែ
- ជំរុញឱ្យមានការឆ្លុះបញ្ចាំងដោយស្មោះត្រង់៖ តើអ្វីខ្លះដែលទទួលបានជោគជ័យ អ្វីខ្លះដែលមិនជោគជ័យ និងមូលហេតុអ្វី។
- ភ្ជាប់លទ្ធផលដែលរកឃើញ ទៅនឹងឯកសារយោងស្តីពីអហិង្សា និងការអប់រំបរិយាបន្ន។

ជំហានទី ៦៖ ការកែលម្អ និងការចែករំលែក

បន្ទាប់ពីឆ្លងកាត់ជំហាននីមួយៗ គរុនិស្សិតអាចបង្កើតជាវដ្តនៃអន្តរាគមន៍ផ្សេងទៀត។ ទាំងនេះ ជាឧទាហរណ៍ ដែលគរុនិស្សិតអាចពិចារណាបាន៖

- បន្ថែមការរំលឹកជាប្រចាំអំពីការស្តាប់ដោយគោរព។
- បញ្ចូលការប្រើប្រាស់ភាសាគោរពទៅក្នុងតារាងវាយតម្លៃ (Rubrics)។

- ចែករំលែកលទ្ធផលក្នុងសិក្ខាសាលាស្រាវជ្រាវនៅសាលាគរុកោសល្យ ឬជាមួយគ្រូណែនាំ។

លើសពីការពិនិត្យឡើងវិញលើអន្តរាគមន៍ដែលបានអនុវត្ត គ្រូណែនាំមានគម្រោងចែករំលែកលទ្ធផលរបស់ពួកគេ ឧទាហរណ៍៖

- បង្ហាញលទ្ធផលស្រាវជ្រាវនៅក្នុងសិក្ខាសាលាស្រាវជ្រាវ នៅសាលាគរុកោសល្យ។
- ចែករំលែកសេចក្តីសង្ខេបជាមួយគ្រូណែនាំ និងគណៈគ្រប់គ្រងសាលារៀន។
- ឆ្លុះបញ្ចាំងពីឥទ្ធិពល ឬមេរៀនដែលទទួលបាន សម្រាប់ការអនុវត្តបង្រៀនទៅថ្ងៃអនាគត។

ក្នុងនាមជាគ្រូឧទ្ទេស អ្នកគួរតែ៖

- ធានាថា រាល់របាយការណ៍ទាំងអស់ត្រូវរក្សាការសម្ងាត់ (មិនបញ្ចេញឈ្មោះ) របស់សិស្ស និងសាលារៀន។
- ចៀសវាងការបង្ហាញរូបភាពអវិជ្ជមានអំពីសាលារៀន។
- សង្កត់ធ្ងន់លើការរៀនសូត្រ ការរីកចម្រើន និងការអនុវត្តប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

កំណត់សម្គាល់សម្រាប់គ្រូឧទ្ទេស៖

ករណីសិក្សានេះបង្ហាញថា ទង្វើតាមពាក្យសម្តីប្រចាំថ្ងៃដែលជារឿយៗត្រូវបានចាត់ទុកថាជា "ការលេងសើច" អាចក្លាយជាអំពើហិង្សាដែលធ្វើឱ្យសិស្សបាត់បង់ភាពក្លាហាន។ តាមរយៈការស្រាវជ្រាវប្រតិបត្តិ គរុនិស្សិតមិនត្រឹមតែរៀនពីរបៀបកែលម្អបរិយាកាសក្នុងថ្នាក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកសាងអត្តសញ្ញាណវិជ្ជា ជីវៈដែលផ្អែកលើការយកចិត្តទុកដាក់ និងការទទួលខុសត្រូវផ្នែកសីលធម៌ផងដែរ។

៧.៤. ករណីសិក្សាទី ៤ (Showcase 4)

ករណីសិក្សា៖ ការមកយឺតដដែលៗ

ករណីសិក្សានេះ បានកើតឡើងនៅក្នុងថ្នាក់ទី៦ នៃសាលាបឋមសិក្សារដ្ឋមួយក្នុងខេត្តបាត់ដំបង។ ក្នុងម៉ោងសិក្សាមុខវិជ្ជាសិក្សាសង្គម មានសិស្សបីនាក់តែងតែមកសាលារៀនយឺតជាញឹកញាប់។ ដោយមានអារម្មណ៍មួរម៉ៅ គ្រូបង្រៀនថ្នាក់នោះតែងតែរំលឹកពួកគេឱ្យមកឱ្យទាន់ពេលវេលា។ ជាជាងការរៀបរាប់ពន្យល់អំពីស្ថានភាពលំបាកនៅផ្ទះ (ឧទាហរណ៍៖ ការងារផ្ទះ ការមើលថែប្អូនៗ ឬការដើរផ្លូវឆ្ងាយមកសាលា) សិស្សទាំងនោះជាធម្មតាគ្រាន់តែឆ្លើយតបដោយការសុំទោស និងសន្យាថានឹងមកឱ្យទាន់ពេលតែប៉ុណ្ណោះ។ ថ្ងៃមួយ សិស្សទាំងបីនាក់នោះបានមកយឺត ហើយឈរនៅមាត់ទ្វារថ្នាក់រៀនដើម្បីសុំការអនុញ្ញាតចូលរៀន។ គ្រូបង្រៀនបានធ្វើព្រងើយដាក់ពួកគេ

ហើយបន្តបង្រៀនទៅមុខទៀត។ លុះត្រាតែពន្យល់មេរៀនចប់ ទើបគាត់ងាកមកនិយាយជាមួយពួកគេ ដោយបានស្តីបន្ទោសពួកគេយ៉ាងខ្លាំងនៅចំពោះមុខសិស្សទាំងថ្នាក់ រួចទើបអនុញ្ញាតឱ្យពួកគេចូលក្នុងថ្នាក់។ សិស្សទាំងនោះមានទឹកមុខស្រពោន ភ័យខ្លាច និងខ្មាសអៀន ហើយពួកគេបានអង្គុយស្ងៀមរហូតដល់ចប់ម៉ោងសិក្សា។

ទោះបីជាមិនមានការដាក់ទណ្ឌកម្មលើរាងកាយក៏ដោយ ប៉ុន្តែស្ថានភាពនេះឆ្លុះបញ្ចាំងពីការប៉ះទង្គិចផ្លូវចិត្ត ការធ្វើឱ្យខ្មាសអៀនជាសាធារណៈ និងវិន័យដែលផ្អែកលើការភ័យខ្លាច ដែលផ្ទុយនឹងគោលការណ៍អប់រំគ្មានហិង្សា និងសាលាកុមារមេត្រី។

ចំណងជើងស្រាវជ្រាវប្រតិបត្តិដែលបានស្នើ៖

ចំណងជើង៖ ការកាត់បន្ថយផលប៉ះពាល់ផ្លូវចិត្ត និងការកែលម្អទំនាក់ទំនងរវាងសិស្សនិងគ្រូ ពាក់ព័ន្ធនឹងការមកយឺតរបស់សិស្ស

នៅពេលសង្កេត និងកំណត់ករណីនេះ អ្នកអាចពិចារណាសម្រេចឱ្យបាននូវគោលបំណងមួយចំនួនដូចខាងក្រោម៖ (ចំណាំ អ្នកអាចជ្រើសយកមួយ ឬពីរនៃវត្ថុបំណងទាំងនេះ)

1. ដើម្បីស្វែងរកមូលហេតុឫសគល់នៃការមកយឺតដដែលៗរបស់សិស្សថ្នាក់ទី ៦ ចំនួន ៣ នាក់។
2. ដើម្បីពិនិត្យមើលថាតើការឆ្លើយតបបច្ចុប្បន្នរបស់គ្រូចំពោះការមកយឺត ប៉ះពាល់ដល់សុវត្ថិភាពផ្លូវចិត្ត និងការចូលរួមរបស់សិស្សយ៉ាងដូចម្តេច។
3. ដើម្បីអនុវត្តយុទ្ធសាស្ត្រប្រកបដោយការគោរព និងគ្មានហិង្សា ក្នុងការដោះស្រាយបញ្ហាមកយឺត។
4. ដើម្បីកែលម្អទំនាក់ទំនងរវាងសិស្សនិងគ្រូ ទំនុកចិត្ត និងបរិយាកាសក្នុងថ្នាក់រៀន។

ជំហានទី ១៖ ការកំណត់ និងការធ្វើរោគវិនិច្ឆ័យបញ្ហា

ក្នុងជំហាននេះ គរុនិស្សិតអាចពិចារណាលើ៖

- ការធ្វើការសង្កេតក្រៅផ្លូវការលើការមកដល់យឺត (ភាពញឹកញាប់ ពេលវេលា និងការឆ្លើយតបរបស់គ្រូ)។
- ការទាក់ទងក្រៅផ្លូវការជាមួយគ្រូណែនាំ ដើម្បីយល់ពីទស្សនៈ និងសម្ពាធរបស់គាត់។
- ការសន្ទនាជាឯកជន និងប្រកបដោយការគោរពជាមួយសិស្សទាំង ៣ នាក់ (មិនមែនជាការសួរចម្លើយ)។
- ការកត់ត្រាការឆ្លុះបញ្ចាំងពីប្រតិកម្មផ្លូវចិត្តរបស់សិស្ស (ការភ័យខ្លាច ការនៅស្ងៀម ការដកខ្លួនចេញ)។
- ការពិនិត្យមើលវិន័យសាលាដែលទាក់ទងនឹងការគោរពពេលវេលា។

ពួកគេអាចយកចំណុចទាំងនេះមកពិចារណា។ បញ្ហាដែលពួកគេអាចកំណត់បាន រួមមាន៖

- បញ្ហាដែលបានរកឃើញ៖ បញ្ហាមិនមែនត្រឹមតែការមកយឺតនោះទេ ប៉ុន្តែគឺកង្វះការយល់ដឹងអំពីស្ថានភាពគ្រួសាររបស់សិស្ស ការប្រើប្រាស់ការស្តីបន្ទោសជាសាធារណៈ និងការដាក់វិន័យដោយភាពស្ងប់ស្ងាត់ ដែលបង្កឱ្យមានការឈឺចាប់ផ្លូវចិត្ត ការភ័យខ្លាច និងការបាត់បង់ការចង់រៀន ដែលនេះជាអំពើហិង្សាអរូបិយ (ការប៉ះទង្គិចផ្លូវចិត្ត)។

ក្នុងនាមជាអ្នកបណ្តុះបណ្តាលគ្រូ អ្នកគួររំលឹកគរុនិស្សិតឱ្យ៖

- មើលឱ្យលើសពី "អាកប្បកិរិយាមិនល្អ" ដើម្បីស្វែងរកមូលហេតុឫសគល់។
- ចៀសវាងការប្រើភាសាបន្ទោសនៅពេលពិពណ៌នាអំពីសកម្មភាពរបស់គ្រូ។
- ផ្តោតលើប្រព័ន្ធ និងអន្តរកម្ម ជាជាងបុគ្គលម្នាក់ៗ។
- មិនត្រូវអនុញ្ញាតឱ្យគរុនិស្សិត "ធ្វើរោគវិនិច្ឆ័យ" ដោយគ្មានសំឡេងរបស់សិស្សឡើយ។
- ធានាឱ្យមានការយល់ព្រម និងរក្សាភាពឯកជននៅពេលនិយាយជាមួយកុមារ។

ជំហានទី ២៖ ការរៀបចំផែនការសកម្មភាព

គរុនិស្សិតគួរយល់ថា អន្តរាគមន៍ត្រូវតែ low cost (ចំណាយថវិកាតិច តែមានប្រសិទ្ធភាព) ប្រកបដោយការគោរព និងប្រាកដនិយម ដោយផ្តោតលើការជួសជុលទំនាក់ទំនង មិនមែនការដាក់ទណ្ឌកម្មឡើយ។ អន្តរាគមន៍គ្មានហិង្សា៖

- ប្រព័ន្ធឆែកមើលឯកជន៖ គ្រូសាកសួរសុខទុក្ខសិស្សដែលមកយឺតដោយខ្លីៗ ក្រោយបញ្ចប់ម៉ោងរៀន ឬអំឡុងពេលសម្រាក។
- ទម្លាប់នៃការចូលថ្នាក់ដែលបានព្រមព្រៀង៖ សិស្សអាចចូលរៀនដោយស្ងប់ស្ងាត់ដោយមិនចាំបាច់មានការចាប់អារម្មណ៍ពីសាធារណៈ ប្រសិនបើមកយឺត។
- ការឆ្លុះបញ្ចាំងរបស់គ្រូលើភាសា និងទឹកដមសំឡេង៖ គ្រូចៀសវាងការស្តីបន្ទោសជាសាធារណៈ ឬការធ្វើមិនដឹងមិនឮចំពោះសិស្ស។
- យុទ្ធសាស្ត្រគាំទ្រពេលព្រឹក៖ ការរៀបចំកន្លែងអង្គុយឱ្យមានភាពបត់បែន ឬកិច្ចការខ្លីៗដើម្បីឱ្យអ្នកមកយឺតអាចតាមទាន់មេរៀន។

ក្នុងនាមជាអ្នកបណ្តុះបណ្តាលគ្រូ អ្នកគួរតែណែនាំគ្រូកម្មសិក្សាឱ្យ៖

- រៀបចំផែនការផ្លាស់ប្តូរតូចៗ ដែលអាចអនុវត្តបាន

- តម្រឹមសកម្មភាពនានាឱ្យស្របទៅតាមគោលការណ៍សាលារៀនមេត្រីកុមារ
- ពិភាក្សាលើផែនការជាមួយគ្រូណែនាំដោយការគោរព ប៉ុន្តែត្រូវរំលឹកពួកគេថា៖
- កុំដាក់បង្ខំផែនការណាមួយដោយគ្មានការយល់ព្រមពីគ្រូបង្រៀនឡើយ និង
- ចៀសវាងរាល់អន្តរាគមន៍ទាំងឡាយណាដែលធ្វើឱ្យសិស្សមានភាពខ្មាសអៀន ឧទាហរណ៍៖ ការបិទតារាងឈ្មោះសិស្សមកយឺតនៅលើជញ្ជាំង។

ជំហានទី ៣៖ ការអនុវត្តសកម្មភាព

ក្រោយរៀបចំផែនការ គរុចាប់ផ្តើមអនុវត្តអន្តរាគមន៍៖

- គ្រូយល់ព្រមបញ្ឈប់ការស្តីបន្ទោសជាសាធារណៈ
- សិស្សមកយឺតចូលក្នុងថ្នាក់ដោយស្ងប់ស្ងាត់ និងអង្គុយចុះ
- គ្រូជួបសិស្សជាឯកជនម្តងក្នុងមួយសប្តាហ៍
- គរុនិស្សិតសង្កេត និងកត់ត្រាការផ្លាស់ប្តូរ៖ សិស្សហាក់ដូចជាមានការភ័យខ្លាចតិចជាងមុននៅពេលចូលថ្នាក់ ចាប់ផ្តើមចូលរួមក្នុងមេរៀនកាន់តែច្រើន ហើយគ្រូក៏កាត់បន្ថយភាពមួរម៉ៅ។

ក្នុងនាមជាគ្រូឧទ្ទេស អ្នកគួរតែណែនាំគរុនិស្សិតឱ្យ៖

- រក្សាទំនាក់ទំនងជាប្រចាំ រវាងគ្រូណែនាំ និងនិស្សិតគរុកោសល្យ។
- រក្សាភាពបត់បែន ប្រសិនបើយុទ្ធសាស្ត្រមួយចំនួនមិនទទួលបានលទ្ធផលភ្លាមៗ ប៉ុន្តែត្រូវរំលឹកពួកគេថា៖
    - មិនត្រូវកែតម្រូវ កំហុសរបស់គ្រូណែនាំ ឬគ្រូបង្រៀនក្នុងថ្នាក់ នៅចំពោះមុខសិស្សជាសាធារណៈឡើយ។
    - ជៀសវាងការជ្រៀតជ្រែកជ្រុលហួសហេតុ ដែលនាំឱ្យរំខានដល់ដំណើរការបង្រៀនធម្មតា។

ជំហានទី ៤៖ ការសង្កេត និងការប្រមូលទិន្នន័យ

គរុនិស្សិតអាចប្រមូលទិន្នន័យតាមរយៈ៖

- កំណត់ហេតុនៃការសង្កេត (ការឆ្លើយតបរបស់គ្រូ អាកប្បកិរិយាសិស្ស)
- កំណត់ត្រាខ្លីៗពីការឆ្លុះបញ្ចាំងរបស់សិស្ស (ជាសម្តីផ្ទាល់មាត់)
- ទិនានុប្បវត្តិឆ្លុះបញ្ចាំងរបស់គ្រូ និងកំណត់ត្រាវត្តមាន។

ក្នុងអំឡុងពេលប្រមូលទិន្នន័យ ពួកគេអាចសង្កេតឃើញនូវ៖

- ការថយចុះនៃភាពកម្សត់ខ្លាច និងភាពអៀនខ្មាស ដែលអាចមើលឃើញច្បាស់
- ការធ្វើអន្តរកម្មកាន់តែប្រសើរឡើង រវាងគ្រូ និងសិស្ស
- ការប្រសើរឡើងបន្តិចបន្តួចនៃភាពទៀងទាត់ពេលវេលា។

ក្នុងនាមជាគ្រូឧទ្ទេស អ្នកគួរតែរំលឹកគរុនិស្សិតឱ្យ៖

- ផ្តោតលើលំនាំជារួម ជាជាងការផ្តោតលើព្រឹត្តិការណ៍ដែលកើតឡើងតែមួយលើកៗ
- ប្រើប្រាស់ឧបករណ៍ដែលសាមញ្ញ និងត្រឹមត្រូវតាមក្រមសីលធម៌ ប៉ុន្តែត្រូវរំលឹកពួកគេថា៖
    - មិនត្រូវថតចម្លង ឬកត់ត្រា រឿងរ៉ាវផ្ទាល់ខ្លួនដែលងាយរងគ្រោះណាមួយឡើយ និង
    - ត្រូវការពារការសម្ងាត់របស់សិស្ស ឱ្យបានគ្រប់ពេលវេលា។

ជំហានទី ៥៖ ការឆ្លុះបញ្ចាំង និងការបកស្រាយលទ្ធផល

បន្ទាប់ពីការប្រមូលទិន្នន័យ គរុនិស្សិត អាចពិចារណាលើលទ្ធផលសំខាន់ៗ (របកគំហើញ) ដូចខាងក្រោម៖

- ការស្តីបន្ទោសជាសាធារណៈបង្កើនការកម្សត់ខ្លាច ប៉ុន្តែមិនបានកាត់បន្ថយការមកយឺតឡើយ
- ទំនាក់ទំនងប្រកបដោយការគោរព បានកែលម្អទំនុកចិត្ត និងការចូលរួម
- ការមកយឺតខ្លះជាប់ពាក់ព័ន្ធនឹងកត្តាដែលសិស្សមិនអាចគ្រប់គ្រងបាន។

ការបកស្រាយសំខាន់ៗមួយចំនួននៃ ការឆ្លើយតបបែបអហិង្សា ដែលអាចយកមកពិចារណា រួមមានជាអាទិ៍៖

- គាំទ្រដល់សុវត្ថិភាពផ្លូវចិត្ត
- ពង្រឹងទំនាក់ទំនងរវាងសិស្ស និងគ្រូ
- លើកទឹកចិត្តឱ្យមានការប្រាស្រ័យទាក់ទងដោយស្មោះត្រង់។

ក្នុងនាមជាអ្នកបណ្តុះបណ្តាលគ្រូ អ្នកគួរតែរំលឹកគរុនិស្សិតឱ្យ៖

- រក្សាការឆ្លុះបញ្ចាំងដោយស្មោះត្រង់ ដោយមិនមានការបន្ទោសបង្អាប់
- ផ្សារភ្ជាប់លទ្ធផលដែលរកឃើញទៅនឹងអហិង្សា និងសិទ្ធិកុមារ ប៉ុន្តែ
- ជៀសវាងការកំណត់លទ្ធផលថាជា "បរាជ័យរបស់គ្រូ"

- សង្កត់ធ្ងន់លើការរៀនសូត្រ និងការរីកចម្រើន។

ជំហានទី ៦៖ ការកែសម្រួល និងការចែករំលែក

បន្ទាប់ពីឆ្លងកាត់ជំហាននីមួយៗរួចមក គរុនិស្សិតអាចនឹងមានបំណងរៀបចំផែនការសម្រាប់វដ្តនៃអន្តរាគមន៍បន្ទាប់ទៀត។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួនដែលគរុនិស្សិតអាចពិចារណាបាន៖

- បន្តការជួបសាកសួរព័ត៌មានបែបឯកជន (Private check-ins)
- កែសម្រួលសកម្មភាពពេលព្រឹក (Morning routines)
- ចែករំលែកបទពិសោធន៍ ឬចំណេះដឹងដែលទទួលបាន ជាមួយគ្រូបង្រៀនផ្សេងទៀតក្នុងកម្រិតថ្នាក់ជាមួយគ្នា។

គរុនិស្សិតអាចរៀបចំផែនការសម្រាប់វដ្តបន្ទាប់ ឬចែករំលែកលទ្ធផល៖

- បទបង្ហាញនៅក្នុងកិច្ចប្រជុំសាលា
- ការចែករំលែកការឆ្លុះបញ្ចាំងជាមួយវិទ្យាស្ថានបណ្តុះបណ្តាលគ្រូ។

ក្នុងនាមជាអ្នកបណ្តុះបណ្តាលគ្រូ អ្នកគួរតែរំលឹកនិស្សិតគរុកោសល្យឱ្យ៖

- ប្រកាន់ខ្ជាប់នូវក្រមសីលធម៌ (ឧទាហរណ៍៖ មិនប្រើប្រាស់ឈ្មោះពិត មិនបន្ទោសបង្អាប់)
- ផ្តោតលើការកែលម្អការអនុវត្តបង្រៀន ប៉ុន្តែ
- មិនត្រូវចែករំលែករឿងរ៉ាវផ្ទាល់ខ្លួនដែលងាយរងគ្រោះជាសាធារណៈឡើយ
- ធានាថាមានការយល់ព្រមពីគ្រូណែនាំ មុនពេលផ្សព្វផ្សាយព័ត៌មានណាមួយ។

ចំណាំសម្រាប់អ្នកបណ្តុះបណ្តាលគ្រូ

អ្វីដែលអ្នកគួររំលឹកគរុនិស្សិតជានិច្ចគឺ៖

- អហិង្សារួមបញ្ចូលទាំងសុវត្ថិភាពផ្លូវចិត្ត និងសេចក្តីថ្លៃថ្នូរ
- ការផ្លាស់ប្តូរតួចតាចក្នុងអាកប្បកិរិយារបស់គ្រូ អាចមានឥទ្ធិពលយ៉ាងធំធេង
- ការស្រាវជ្រាវប្រតិបត្តិផ្តល់អំណាចឱ្យគ្រូឆ្លើយតបដោយក្តីមេត្តា មិនមែនដោយការដាក់ទណ្ឌកម្មឡើយ។

ឯកសារយោង

BERA (British Educational Research Association). (2018). *Ethical guidelines for educational research* (4th ed.). BERA.

Burns, A. (2010). *Doing action research in English language teaching: A guide for practitioners.* Routledge.

Carr, W., & Kemmis, S. (1986). *Becoming critical: Education, knowledge and action research.* Falmer Press.

Cochran-Smith, M., & Lytle, S. L. (2009). *Inquiry as stance: Practitioner research for the next generation.* Teachers College Press.

Fals-Borda, O., & Rahman, M. A. (1991). *Action and Knowledge: Breaking the Monopoly with Participatory Action Research*. Apex Press.

Freire, P. (1970). *Pedagogy of the Oppressed*. Continuum.

Gershoff, E. (2017). *School corporal punishment and its associations with student adjustment*. Psychology, Health & Medicine.

Johnson, D. W., & Johnson, R. T. (2005). *Teaching students to be peacemakers.* Interaction Book Company.

Kemmis, S., & McTaggart, R. (1988). *The action research planner.* Deakin University Press.

Kemmis, S., McTaggart, R., & Nixon, R. (2014). *The action research planner: Doing critical participatory action research.* Springer.

Lankshear, C., & Knobel, M. (2004). *A handbook for teacher research: From design to implementation.* Open University Press.

Lewin, K. (1946). Action research and minority problems. *Journal of Social Issues, 2*(4), 34–46.

McNiff, J., & Whitehead, J. (2011). *All you need to know about action research* (2nd ed.). SAGE.

Mertler, C. A. (2019). *Action research: Improving schools and empowering educators* (6th ed.). SAGE.

Mills, G. E. (2020). *Action research: A guide for the teacher researcher* (7th ed.). Pearson.

Salomon, G., & Cairns, E. (2010). *Handbook on peace education.* Psychology Press.

Schön, D. A. (1983). *The reflective practitioner: How professionals think in action.* Basic Books.

Stringer, E. T. (1999). *Action research.* SAGE.

Stringer, E. T. (2014). *Action research* (4th ed.). SAGE.

UNESCO. (2017). *School violence and bullying: Global status report.* UNESCO.

Zeichner, K. (2003). Teacher research as professional development for P–12 educators in the USA. *Educational Action Research, 11*(2), 301–326.

UNICEF Cambodia. (2019). *Violence Against Children in Cambodia Study*.

WHO. (2020). *School violence and bullying: Global status report*.

ស្រាវជ្រាវប្រតិបត្តិដើម្បីបង្កើតបរិយាយកាសអហិង្សាក្នុងថ្នាក់រៀន គឺជាសៀវភៅណែនាំមួយដែលមានភាពសមស្របតាមពេលវេលា និងមានលក្ខណៈអនុវត្តជាក់ស្តែង សម្រាប់គ្រូឧទ្ទេស និងគរុនិស្សិតនៅក្នុងវិទ្យាស្ថានគរុកោសល្យនៅកម្ពុជា។ សៀវភៅនេះបានបង្កើតឡើងដើម្បីបំពេញបន្ថែមទៅលើគោលការណ៍ណែនាំអំពីស្រាវជ្រាវប្រតិបត្តិរបស់ក្រសួងអប់រំ យុវជន និងកីឬា ដោយផ្តោតសំខាន់ជាពិសេសលើការដោះស្រាយបញ្ហាអំពើហិង្សាក្នុងថ្នាក់រៀន ទាំងអំពើហិង្សាផ្លូវកាយ ពាក្យសម្តី និងទំនាក់ទំនងសង្គម តាមរយៈការអនុវត្តវិជ្ជាជីវៈដែលមានការឆ្លុះបញ្ចាំងនិងផ្អែកលើកស្តុតាង។

ដោយយកបរិបទពិតប្រាកដនៃថ្នាក់រៀននៅកម្ពុជាជាមូលដ្ឋាន សៀវភៅណែនាំនេះបានបង្ហាញយ៉ាងច្បាស់នូវដំណើរការស្រាវជ្រាវប្រតិបត្តិចំនួនប្រាំមួយជំហាន រួមជាមួយឧបករណ៍អនុវត្ត គំរូទម្រង់ ករណីសិក្សា និងការណែនាំផ្នែកក្រមសីលធម៌ស្រាវជ្រាវ ដែលមានប្រយោជន៍យ៉ាងខ្លាំងសម្រាប់ការអនុវត្តជាក់ស្តែង។ សៀវភៅណែនាំនេះជួយបង្កើនសមត្ថភាពគ្រូឧទ្ទេសក្នុងការណែនាំ និងគាំទ្រគរុនិស្សិតជាប្រព័ន្ធ ខណៈដែលលើកទឹកចិត្តឱ្យគរុនិស្សិតក្លាយជាអ្នកអនុវត្តវិជ្ជាជីវៈដែលមានការឆ្លុះបញ្ចាំង អាចកែលម្អទំនាក់ទំនងក្នុងថ្នាក់រៀន និងអាកប្បកិរិយាសិស្ស។

ដោយទទួលបានការឧបត្ថម្ភហិរញ្ញវត្ថុពី forumZFD សៀវភៅណែនាំនេះមិនត្រឹមតែជាឯកសារសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាឧបករណ៍ណែនាំសម្រាប់ការត្រួតពិនិត្យ និងណែនាំគរុនិស្សិតផងដែរ។ សៀវភៅនេះមានគោលបំណងចូលរួមចំណែកក្នុងការបង្កើតថ្នាក់រៀនឲ្យមានសុវត្ថិភាព ឧបត្ថម្ភទំនាក់ទំនងវិជ្ជាជីវៈរវាងគ្រូនិងសិស្សឲ្យកាន់តែរឹងមាំ និងជំរុញការបង្រៀននិងរៀនឲ្យមានគុណភាពល្អប្រសើរឡើងនៅក្នុងសាលារៀនទូទាំងព្រះរាជាណាចក្រកម្ពុជា។